[1] ឱ. អ‌ាហ‌ិ‌ណ្ឌ‌ន្ត‌ោ ។

សិល្បសាស្ត្រនេះ តើនឹងបានប្រាកដក្នុងវេលាណា ។ ឯអាចារ្យនោះក៏ប្រាប់ថា នែនាយជីវក: បើដូច្នោះ អ្នកឯងត្រូវកាន់យកចបជីកដើរទៅ ចំនួន ១ យោជន៍ជុំវិញក្រុងតក្កសិលា ហើយគន់មើលវត្ថុឯណានីមួយ ដែលមិនមែនជាថ្នាំ ចូរអ្នកនាំវត្ថុនោះមក ។ ឯជីវកកោមារភត្យទទួលស្តាប់ពាក្យពេទ្យនោះដោយពាក្យថា បាទលោកអាចារ្យ ហើយក៏កាន់ចបជីកដើរទៅចំនួន ១ យោជន៍ជុំវិញក្រុងតក្កសិលា ក៏មិនឃើញមានវត្ថុអ្វីមួយដែលមិនមែនជាថ្នាំឡើយ ។ គ្រានោះ ជីវកកោមារភត្យ ក៏បានចូលទៅរកពេទ្យនោះវិញ លុះចូលទៅដល់ហើយ ក៏បាននិយាយ ពាក្យនេះនឹងពេទ្យនោះថា បពិត្រលោកអាចារ្យ ខ្ញុំបានដើរទៅ ចំនួន ១ យោជន៍ជុំវិញក្រុងតក្កសិលា ក៏មិនឃើញមានវត្ថុអ្វីមួយដែលមិនមែនជាថ្នាំសោះ ។ ឯអាចារ្យនោះក៏និយាយថា នែនាយជីវក: អ្នកឯងយើងបានបង្រៀនរួចហើយ សិល្បសាស្ត្រប៉ុណ្ណោះ ល្មមចិញ្ចឹមជីវិតរបស់អ្នកឯង បានហើយ ។ ក៏ប្រគល់ស្បៀងបន្ទិចបន្ទួចឲ្យជីវកកោ- មារភត្យ ។ លំដាប់នោះ ជីវកកោមារភត្ត ក៏បាននាំយកស្បៀងបន្ទិចបន្ទួចនោះ ចេញដើរសំដៅទៅក្រុងរាជគ្រឹះវិញ ។ វេលានោះ ស្បៀងបន្ទិចបន្ទួចរបស់ជីវកកោមារភត្យនោះ ក៏អស់រលីងទៅទៀបក្រុងសាកេត នៅពាក់កណ្តាលផ្លូវ ។ គ្រានោះ ជីវកកោមារភត្យក៏មាន

ឯតទហោសិ ឥមេ ខោ មក្តា ភន្តា អប្ប្ឯ១ភា អប្ប្ឯ១ភ្ជា ន សុភ១ អចាថេយ្យ១ ភន្តុ យន្ទ្ធ១ាមំ ចាថេយ្យ០ បរិយ១ាសេយ្យ១ន្តិ ។

[៣៦] ត១ន ខោ ២ន សមយ១ន សាភ១ាត១ សេដ្ឋិភរិយាយ សត្ត១ស្ស្ជ្ជ១ោ ២ីសាពា១ោ ហោតិ ។ ពហ្ម មហ្ត្ត មហ្ត្ត ២ិសាចាមោ ១ាា ១ជ្ជ អ១ត្ត ១ិ១ិ១ច្ច១ត្ត ១ាសក្ខ្ជ ២ាសុ អ១ោ១ំ ១ាតុ ពហ្ម ២ារ១ាា អ-១ាយ អ១ម៌ សុ ។ អ២ខោ ២ីវ១ោ ១ោមារ១ច្ចោ សាភ១ាត១ំ ២ារ១ិ១ា ២ន្ទ្ធ១ស្ស ២ុ១ាា ១ោ ១ណ១ ១ិ១ា-១ោ ១ំ ១ិ១ិ១ាមីតិ ។ ២ារ១ិ១ាា អ១ារ១ យ ១ិ១ារ១ាយ-យ ១ិ១ារ១ាា ២ីសាពា១ោ ១ច្ច អ១ារ១ យ ១ិ១ារ-ភ១ាយ ១ិ១ិ១ាមីតិ ។ អ២ខោ ២ីវ១ោ ១ោមារ១ច្ចោ យ១ន ១ិ១ារ១ាា ១ហ១ារ១ិ១ាា ២ារ១ិ១ាយ ១ុ១ារ១ិ១ាមិ ២ុ១-១ិ១ាមិ១ា ១ោ១ារ១ិ១ាយ អ១ណ១ារ១ិ១ យ ១ច្ច ១ណ១ ១ោ១ារ១ិ១ ១ិ១ារ១ាយ ១ារ១ ១ជ្ជ អ១ាា ១ាតោ ១ោ ១ាយ ១ជ្ជ១ារ១ាមីតិ ។ ២ារ១ាារ១ាតិ ខោ ១ោ ១ោ១ារ១ិ១ារ១ ២ីវ១ាសាា ១ោមារ១ចាសាា ២ជ១ិ១ាា១ណ១ាា ១ន ១ិ១ារ-

សេចក្ដីរិះគិតដូច្នេះថា ផ្លូវអស់ទាំងនេះជាផ្លូវដាច់ស្រយាល មានទឹកតិច មានចំណីអាហារតិច នរណាដែលមិនមានស្បៀងអាហារហើយ មិនងាយនឹងទៅបានឡើយ បើដូច្នោះ គួរអាត្មាអញដើរស្វែងរកស្បៀងសិន (រួចសឹមទៅ) ។

[៣៦] សម័យនោះឯង ក្នុងក្រុងសាកេត មានភរិយាសេដ្ឋីម្នាក់ កើតជំងឺឈឺក្បាល ៧ ឆ្នាំហើយ ។ ពួកពេទ្យដែលជាទិសាបាមោក្ខយ៉ាងធំ ។ ច្រើននាក់នាំគ្នាមកព្យាបាល ក៏មិនអាចធ្វើឲ្យជាពោគបាន ហើយនាំយកតែប្រាក់ទៅជាច្រើន ។ គ្រានោះ ជីវកកោមារភត្យបានចូលទៅក្រុងសាកេតហើយសួរមនុស្សទាំងឡាយថា នែនាយ នរណាមានជំងឺ (ខ្ញុំ) នរណាឲ្យខ្ញុំព្យាបាល (ខ្ញុំ) ។ មនុស្សទាំងនោះប្រាប់ថា បពិត្រលោកអាចារ្យ មានតែភរិយាសេដ្ឋីនេះមានជំងឺឈឺក្នុងក្បាល ៧ ឆ្នាំហើយ បពិត្រលោកអាចារ្យ អ្នកអញ្ជើញទៅព្យាបាលភរិយាសេដ្ឋីចុះ ។ វេលានោះ ជីវកកោមារភត្យ ក៏បានចូលទៅកាន់លំនៅរបស់សេដ្ឋីគហបតី លុះចូលទៅដល់ហើយក៏បង្គាប់នាយទ្វារថា នែនាយទ្វារ ចូរអ្នកឯងទៅជំរាបភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ ឥឡូវ មានគ្រូពេទ្យអញ្ជើញមក គាត់ចង់ឃើញអ្នកម្ចាស់ ។ នាយទ្វារនោះបានទទួលស្ដាប់ពាក្យជីវកកោមារ-ភត្យ ដោយពាក្យថា បាទលោកអាចារ្យ ហើយក៏ចូលទៅរកភរិយាសេដ្ឋី

ភរិយា តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា សេដ្ឋិភរិយំ ឯតទ-
វោច ជេដ្ឋោ អយ្យ អាគតោ សោ តំ ឧដ្ឋាបេតិ ។
តីណិ សោ ភណេ ពោធិសត្តោ ជេដ្ឋោតិ ។ ឧបារតោ
អយ្យោតិ ។ អលំ ភណេ ពោធិសត្តោ តីណ មេ ឧបារតោ
ជេដ្ឋោ ការិស្សតិ ពហូ មហន្តា មហន្តា ឧិសាចាមោក្ខា
ជេដ្ឋ អាគន្ត្វា តិកិច្ឆន្តា ជាសក្ខីសុ អរោគំ ការ៉ាតុំ ពហុ
ហិរញ្ញ អាជាយ អគមំសូតិ ។ អថខោ សោ ពោធិសត្តោ
យេន ជីវកោ ការ៉ាមរ៉ាកច្ចោ តេនុបសង្ក្រមិ ឧបសង្ក្រ-
មិត្វា ជីវកំ ការ៉ាមរ៉ាកច្ចំ ឯតទវោច សេដ្ឋិភរិយា អា-
ចរិយ ឯវមាហ អលំ ភណេ ពោធិសត្តោ តីណ មេ ឧបា-
រតោ ជេដ្ឋោ ការិស្សតិ ពហូ មហន្តា មហន្តា ឧិសាចា-
មោក្ខា ជេដ្ឋ អាគន្ត្វា តិកិច្ឆន្តា ជាសក្ខីសុ អរោគំ
ការ៉ាតុំ ពហុ ហិរញ្ញ អាជាយ អគមំសូតិ ។ តច្ច ភណេ
ពោធិសត្តោ សេដ្ឋិភរិយាយ ចាវេ ជេដ្ឋោ អយ្យ ឯវមាហ
មា ការ អយ្យ បុរេ ការ៉ាកិញ្ចិ អជាសិ យជា អរោគ
អហោសិ តជា យំ ឥច្ឆយ្យាសិ តំ ឧជ្ជយ្យាសីតិ ។
ឯវំ អាចរិយាតិ ខោ សោ ពោធិសត្តោ ជីវកស្ស

លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងកវិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ ឥឡូវមានគ្រូពេទ្យអញ្ជើញមក គាត់ចង់ឃើញអ្នកម្ចាស់ ។ ឯកវិយាសេដ្ឋីក៏សួរថា នែនាយទ្វារ គ្រូពេទ្យនោះ តើបែបយ៉ាងណា ។ នាយទ្វារជំរាបថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យនោះនៅក្មេងទេ ។ ឯកវិយាសេដ្ឋីក៏តបថា កុំឡើយនាយទ្វារ គ្រូពេទ្យនៅក្មេងម្ល៉ះ នឹងធ្វើរោគអញឲ្យជាម្តេចបាន គ្រូពេទ្យដែលជាទិសាបាមោក្ខយ៉ាងធំ ។ ច្រើននាក់ ក៏បានមកព្យា-បាលហើយ ក៏គង់មិនអាចនឹងធ្វើរោគឲ្យសះជាបាន នាំយកប្រាក់ជាច្រើនទៅហើយ ។ ខណៈនោះ នាយទ្វារក៏បានចូលទៅរកជីវកកោមារភត្យវិញ លុះចូលទៅដល់ហើយក៏បាននិយាយពាក្យនេះនឹងជីវកកោមារភត្យថា បពិត្រលោកអាចារ្យ កវិយាសេដ្ឋីបាននិយាយយ៉ាងនេះថា កុំឡើយនាយទ្វារ គ្រូពេទ្យនៅក្មេងម្ល៉ះ នឹងព្យាបាលរោគអញឲ្យសះជាម្តេចបាន គ្រូពេទ្យដែលជាទិសាបាមោក្ខជំ ។ ច្រើននាក់ បានមកព្យាបាលក៏គង់មិនអាចនឹងធ្វើរោគឲ្យសះជាបាន នាំយកប្រាក់ជាច្រើនទៅហើយ ។ ឯជីវកកោមារភត្យ ក៏និយាយវិញថា នែនាយទ្វារ ចូរអ្នកឯងទៅជំរាបកវិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យបាននិយាយពាក្យយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់កុំអាលឲ្យវត្ថុអ្វី ។ មុនឡើយ ចាំអ្នកម្ចាស់ជារោគពេលណា អ្នកម្ចាស់ចង់ឲ្យវត្ថុណាក៏គប្បីឲ្យវត្ថុនោះ ក្នុងពេលនោះចុះ ។ នាយទ្វារនោះទទួលស្តាប់

ចីវរក្ខន្ធកេ ជីវកកោមារភច្ចវត្ថុ សេដ្ឋិភរិយាវត្ថុ

កោមារភច្ចស្ស បដិស្សុណិត្វា យេន សេដ្ឋិភរិយា តេនុ-
បសង្កមិ ឧបសង្កមិត្វា សេដ្ឋិភរិយំ ឯតទវោច វេជ្ជោ
អយ្យ ឯវមាហ មា ការ អយ្យ បុរេ ការិ ញ្ចិ អជានិ
យជ អវោកា អហោសិ តជ យំ ឥច្ឆយ្យាសិ តំ
ជនេ្ជយ្យាសីតិ ។ តេនហិ ភណ្ណ ជោវារិក វេជ្ជោ អា-
ភច្ចតូតិ ។ ឯវំ អយ្យេតិ ខោ សោ ជោវារិកោ សេដ្ឋि-
ភរិយាយ បដិស្សុណិត្វា យេន ជីវកោ កោមារភច្ចោ
តេនុបសង្កមិ ឧបសង្កមិត្វា ជីវកំ កោមារភច្ចំ ឯតទ-
វោច សេដ្ឋិភរិយា តំ អាចរិយ បញ្ញោសតីតិ ។ អថខោ
ជីវកោ កោមារភច្ចោ យេន សេដ្ឋិភរិយា តេនុបសង្កមិ
ឧបសង្កមិត្វា សេដ្ឋិភរិយាយ វិការំ សល្ហក្ខេត្វា សេដ្ឋि-
ភរិយំ ឯតទវោច បសតេន មេ អយ្យ សប្ជិនា
អត្ថោតិ ។ អថខោ សេដ្ឋិភរិយា ជីវកស្ស កោមារ-
ភច្ចស្ស បសតំ សប្ជឺ ជាបេសិ ។ អថខោ ជីវកោ
កោមារភច្ចោ តំ បសតំ សប្ជឺ ជានជាកេសជ្ជេហិ
ជិប្ជចិត្វា សេដ្ឋិភរិយំ មញ្ជកេ ឧត្ថានំ ជិបជ្ជាបេត្វា[1]

1 ជិបាតេត្វាតិបិ ។

ចីវរក្ខន្ធក: រឿងជីវកកោមារភត្ស និងរឿងភរិយាសេដ្ឋី

ពាក្យជីវកកោមារភត្ស ដោយពាក្យថា បាទលោកអាចារ្យ ហើយក៏ចូលទៅរកភរិយាសេដ្ឋីវិញ លុះចូលទៅដល់ហើយក៏បាននិយាយពាក្យនេះនឹងភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យបាននិយាយពាក្យយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់កុំអាលឲ្យវត្ថុអ្វី ។ មុនឡើយ ចាំអ្នកម្ចាស់ជាពេគវេលាណា អ្នកម្ចាស់ចង់ឲ្យវត្ថុណា ក៏គប្បីឲ្យវត្ថុនោះ ក្នុងវេលានោះចុះ ។ ឯភរិយាសេដ្ឋីក៏ប្រាប់ថា នែនាយទ្វារ បើដូច្នោះ សូមឲ្យគ្រូពេទ្យអញ្ជើញចូលមកចុះ ។ នាយទ្វារនោះ បានទទួលស្តាប់ពាក្យភរិយាសេដ្ឋីដោយពាក្យថា បាទអ្នកម្ចាស់ ហើយក៏ចូលទៅរកជីវកកោមារភត្សវិញ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះ នឹងជីវកកោមារភត្សថា បពិត្រលោកអាចារ្យ ភរិយាសេដ្ឋីឲ្យអញ្ជើញលោក ។ វេលានោះ ជីវកកោមារភត្ស ក៏បានចូលទៅរកភរិយាសេដ្ឋី លុះចូលទៅដល់ហើយ ក៏សង្កេតស្គាល់វិការរបស់ភរិយាសេដ្ឋី ហើយបាននិយាយពាក្យនេះ នឹងភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ ខ្ញុំបាទត្រូវការសប្ប៊ិ ១ ទូកដៃ ។ លំដាប់នោះ ភរិយាសេដ្ឋីក៏បានបង្គាប់ឲ្យគេឲ្យសប្ប៊ិ ១ ទូកដៃទៅជីវក-កោមារភត្ស ។ វេលានោះ ជីវកកោមារភត្សក៏បានស្ងួតសប្ប៊ិនោះជាមួយនឹងថ្នាំទាំងឡាយផ្សេង ។ រួចហើយឲ្យភរិយាសេដ្ឋីដេកផ្ងារលើគ្រែហើយ

ជត្តុតោ អជាសិ ។ អថខោ តំ សប្ប៎ ជត្តុតោ ជិន្ទ្ធ
មុខតោ ឧក្ខ្ជ ។ អថខោ សេដ្ឋិភរិយា តំ បជិក្ខហ
ជុដ្ឋហិត្ត ជាសឹ អាណាបេសិ ហន្ទ ជេ ឥមំ សប្ប៎
បិចុជ ឧណ្ហាហីតិ ។ អថខោ ជីវកស្ស កោមារភ្ចស្ស
ឯតទហោសិ អច្ឆរិយំ វត ភោ[1] យាវ លូខាយ ឃរណី
យត្រ ហិ ជាម ឥមំ ឆន្ទ្ធនីយជ្ជ សប្ប៎ បិចុជ
ការាបេស្ស្ជតិ ពហុការ ច មេ មហាត្ថ្ជ មហាត្ថ្ជ
ភេសជ្ជ ឧបនាមេ ការ៎ាមាយ ការ[2] ជ្ជ ជ្ជ
ជ្ជ ។ អថខោ សេដ្ឋិភរិយា ជីវកស្ស កោមារ-
ភ្ចស្ស រិការ សលូ ក្ខ្ជ ជីវ ការ ។ ឥជ
ការ ។ ឥជ ។ ឥជ ។ ឥជ

បញ្ជូកថ្នាំនោះ ។ ខណៈនោះ សប្ប៉ាដែលជីវកកោមារភត្យបានច្រកទៅ ហើយនោះក៏ខ្ពុរចេញពីមាត់ ។ គ្រានោះ ភរិយាសេដ្ឋីក៏ខ្ជាក់សប្ប៉ានោះទៅ ក្នុងកន្ទោរហើយបង្គាប់ទាសីថា ចូរនាងយកសំឡីមកផ្ដិតសប្ប៉ានេះចេញ ។ វេលានោះ ជីវកកោមារភត្យមានសេចក្ដីរិះគិតដូច្នេះថា អើអស្ចារ្យអ្វីម្ល៉ះ ស្រីមេផ្ទះនេះជាស្រីអន់ណាស់តើ ព្រោះនាងឲ្យទាសីយកសំឡីមកផ្ដិត សប្ប៉ានេះ ដែលជារបស់គួរតែចោល ម្យ៉ាងទៀត ថ្នាំដែលមានតម្លៃច្រើន ។ អញបានប្រើប្រាស់អស់ច្រើនទៅហើយ ស្រីជាម្ចាស់ផ្ទះនេះ នឹងឲ្យទេយ្យ-ធម៌ (រង្វាន់) តិចតួចដល់អញដូចម្ដេចបាន ។ លំដាប់នោះ ភរិយាសេដ្ឋី សង្កេតស្គាល់វិការជីវកកោមារភត្យ ហើយក៏បាននិយាយពាក្យនេះ នឹងជីវក-កោមារភត្យថា នែលោកអាចារ្យ ហេតុអ្វីបានជាអ្នកមានចិត្តប្ដែកម្ល៉ះ ។ ឯជីវកកោមារភត្យតបវិញថា ខ្ញុំបាទមានសេចក្ដីរិះគិតក្នុងទីនេះយ៉ាងនេះថា អស្ចារ្យអ្វីម្ល៉ះ ស្រីមេផ្ទះនេះជាស្រីអន់ណាស់តើ ព្រោះនាងឲ្យទាសីយកសំឡីមកផ្ដិតសប្ប៉ានេះ ដែលជារបស់គួរតែចោល ម្យ៉ាងទៀត ថ្នាំដែលមានតម្លៃច្រើន ។ អញបានប្រើប្រាស់អស់ច្រើនទៅហើយ ស្រីជាម្ចាស់ផ្ទះនេះនឹងឲ្យទេយ្យធម៌តិចតួចដល់អាត្មាអញដូចម្ដេចបាន ។ ឯភរិយាសេដ្ឋីតប វិញថា នែលោកអាចារ្យ យើងជាស្រីគ្រប់គ្រងផ្ទះគួរចេះសំចៃសប្ប៉ានេះ

ចីវរក្ខន្ធកេ ជីវកគោមារភច្ចវត្ថុ សេដ្ឋិភរិយាវត្ថុ

សញ្ញមស្ស រវមេតំ សប្ប៊ិ ជាសានំ វ កម្មការានំ
វ ចាឧព្ភញ្ជនំ វ បឋីបការណោ វ អាសិត្ថំ មា ត្វំ
អាចរិយ រ៊ិបនោ អហោសិ ន តេ ឧយ្យ១ម្ហោ ហាយិ-
ស្ស្ដ៊ីតិ ។ អថខោ ជីវកោ គោមារភច្ចោ សេដ្ឋិភរិ-
យាយ សត្ដ្ដ្ដ

សប្ជិនេះ នឹងធ្វើជាថ្នាំលាបជើងពួកទាស:ពួកកម្មករ ឬនឹងស្រោចទៅក្នុងកិច្ចដែលធ្វើប្រទីបក៏គង់តែប្រសើរ នៃលោកអាចារ្យ លោកកុំតូចចិត្តឡើយ ទេយ្យធម៌របស់លោកមុខជាមិនសាបសូន្យទេ ។ ខណ:នោះ ជីវកកោមារភត្យក៏បានផ្សះជំងឺឈឺក្បាល ៧ ឆ្នាំរបស់ភរិយាសេដ្ឋីដោយការប្រកតែម្តងប៉ុណ្ណោះ ។ វេលានោះ ភរិយាសេដ្ឋីក៏បានសះជាពោគនោះទៅ ហើយបានឲ្យ (រង្វាន់) ចំនួន ៤ ពាន់កហាបណ:ទៅជីវកកោមារភត្យ ។ ឯកូនប្រុសគិតថា មាតារបស់អាត្មាអញបានសះជាជំងឺឈឺហើយ ក៏បានឲ្យ (រង្វាន់) ចំនួន ៤ ពាន់កហាបណ:ទៀត ។ ឯស្រីជាកូនប្រសាគិតថា ម្តាយក្មេករបស់អាត្មាអញបានសះជាជំងឺហើយ ក៏បានឲ្យ (រង្វាន់) ចំនួន ៤ ពាន់កហាបណ:ទៀត ។ ឯសេដ្ឋីគហបតីគិតថា ភរិយារបស់អាត្មាអញបានសះជាជំងឺហើយ ក៏ឲ្យ (រង្វាន់) ចំនួន ៤ ពាន់កហាបណ: ហើយឲ្យទាសាទាសី និងរថទឹមសេះ (ថែមទៀត) ។ គ្រានោះ ជីវកកោមារភត្យបាននាំយក (រង្វាន់) ទាំង ១៦ ពាន់កហាបណ:នោះ និងទាសាទាសីទាំងរថទឹមសេះ ហើយចេញទៅក្រុងរាជគ្រឹះ ក៏បានចូលទៅរកអភយ-រាជកុមារឲ្យដ៏ក្រុងរាជគ្រឹះដោយលំដាប់ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងអភយរាជកុមារថា សូមទ្រង់មេត្តាប្រោស រង្វាន់

សោឍ្ឍសសហស្សានិ ជាសោ ច ជាសី ច អស្ស្ សោ ច បដិក្ខណ្ហាតុ មេ ឧេវ ចោសារនិកន្តិ ។ អលំ ភណ្ណ ជីវក តុយ្ហំ ១ ហោតុ អម្ហាកញ្ច ២ អន្ត្ បុរ ជិវ្ សនំ មាបេហីតិ ។ ឯវំ ឧ ជ ជ ជ

ទាំង ១៦ ពាន់ក្តី ទាសាក្តី ទាសីក្តី សេះនិងរថក្តី នេះជាស្នាដៃដំបូងរបស់ទូលបង្គំជាខ្ញុំ សូមព្រះសម្មតិទេព ទ្រង់ទទួលយកគ្រឿងសម្រាប់ចិញ្ចឹមរបស់ទូលបង្គំជាខ្ញុំចុះ ។ ឯអកយរាជកុមារក៏តបថា នែនាយជីវក: ណ្ហើយ (របស់ទាំងនេះ) ស្រេចនឹងអ្នកឯងចុះ ប៉ុន្តែត្រូវអ្នកឯងសាងលំនៅក្នុងបូរីរបស់យើង ។ ឯជីវកកោមារភត្យ បានទទួលស្តាប់ព្រះបន្ទូលអកយរាជកុមារដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយក៏បានសាងលំនៅក្នុងវាំងរបស់អកយរាជកុមារ ។

[៣៧] សម័យនោះឯង ព្រះបាទមាគធសេនិយពិម្ពិសារទ្រង់កើតរោគឫសដូងបាត ។ សំពត់សាដកទាំងឡាយ ក៏សឹងតែប្រឡាក់ទៅដោយឈាម ។ ពួកព្រះនាងទេវីឃើញហើយក៏ចំអកថា ឥឡូវនេះ ព្រះសម្មតិ-ទេពទ្រង់មានរដូវហើយ ផ្ការីឈាមបានកើតឡើង ដល់ព្រះសម្មតិទេពហើយ មិនយូរប៉ុន្មានទេ ព្រះសម្មតិទេពមុខជានឹងប្រសូតិ (បុត្រ) មិនខាន ។ ព្រះមហាក្សត្រក៏ទ្រង់អៀនអន់ដោយហេតុនោះ ។ វេលានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់មានព្រះរាជឱង្ការសួរទៅអកយរាជកុមារថា នែនាយអភ័យ យើងមានជំងឺប្រាកដដូច្នោះហើយ អស់ទាំងសំពត់សាកដប្រឡាក់ទៅដោយឈាម ឯពួកនាងទេវីឃើញហើយក៏ចំអកថា ឥឡូវនេះព្រះសម្មតិទេពទ្រង់មានរដូវហើយ ផ្ការីឈាមបានកើតឡើង

ជនិ្ទ្ធ ដេវ ១ ១ ១

ដល់ព្រះសម្មតិទេពហើយ មិនយូរប៉ុន្មានទេ ព្រះសម្មតិទេពមុខជានឹងប្រសូតិ (បុត្រ) មិនខាន នែនាយអភ័យ យើងសូមអង្វរអ្នក ចូរអ្នកស្វែងរកពេទ្យណា ដែលអាចព្យាបាលយើងបាន ។ អភយរាជ-កុមារតបវិញថា បពិត្រព្រះសម្មតិទេព ពេទ្យរបស់ខ្ញុំព្រះអង្គឈ្មោះជីវក: នៅក្មេងជាមនុស្សកំពុងចម្រើន ពេទ្យនោះនឹងព្យាបាលព្រះសម្មតិទេពបាន ។ ព្រះបាទពិម្ពិសារត្រាស់ថា នែនាយអភ័យ បើដូច្នោះចូរអ្នកបង្គាប់ពេទ្យជីវក:ឲ្យគេមកព្យាបាលអញចុះ ។ លំដាប់នោះ អភយរាជ-កុមារក៏បានបង្គាប់ជីវកកោមារភត្យថា នែនាយជីវក: ចូរអ្នកឯងទៅព្យា-បាលរោគថ្វាយព្រះមហាក្សត្រ ។ ជីវកកោមារភត្យបានទទួលបង្គាប់អភយរាជកុមារដោយពាក្យថា ករុណាវិសេស ហើយក៏នាំយកថ្នាំចំនួនមួយក្រចក ចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះបាទមាគធសេនិយពិម្ពិសារដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមមើលជំងឺព្រះអង្គ ។ វេលានោះ ជីវកកោ-មារភត្យ ក៏បានផ្សះរោគឫសដូងបាតរបស់ព្រះបាទមាគធសេនិយពិម្ពិសារដោយលាបថ្នាំតែម្តង ។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ

អហោ សមាធោ បញ្ចេ ឥត្តីសតានិ សញ្ចាលញ្ជារំ ឱ្យ្ហ សាបេត្វា[1] ឱ្យ្ហ ញ្ចាបេត្វា បុញ្ជ ការ្ហ ការ្ហ ជីវ្ហ ជ ្ហ ្ហ ្ហ

ទ្រង់បានសះជាពោគហើយ ទើបទ្រង់ឲ្យពួកស្រីទាំងប្រាំរយស្អិតស្អាង គ្រឿងអលង្ការទាំងពួងហើយឲ្យដោះចេញ ទ្រង់ឲ្យគរជាគំនរួចទ្រង់ត្រាស់ទៅនឹងជីវកកោមារភត្យដូច្នេះថា នែនាយជីវក: គ្រឿងអលង្ការទាំង-ពួងរបស់ស្រីទាំងប្រាំរយនេះត្រូវបានអ្នកឯងហើយ ។ ជីវកកោមារភត្យក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កុំព្រួយព្រះរាជហឫទ័យឡើយ សូមព្រះសម្មតិទេពទ្រង់គ្រាន់តែរលឹកឧបការ:របស់ខ្ញុំព្រះអង្គចុះ ។ ព្រះបាទពិម្ពិសារត្រាស់ថា នែនាយជីវក: បើដូច្នោះ ចូរអ្នកឯងបម្រើយើងផង ស្រីស្នំផង ភិក្ខុសង្ឆមានព្រះពុទ្ធជាប្រធានផង ។ ជីវកកោមារភត្យបានទទួលស្តាប់ព្រះរាជឱ្ការព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ។

[៣៨] សម័យនោះឯង សេដ្ឋីនៅក្រុងរាជគ្រឹះកើតរោគឈឺក្បាល ៧ ឆ្នាំហើយ ។ ពួកពេទ្យដែលជាទិសាបាមោក្ខធំ ៗ ច្រើននាក់មកព្យាបាលក៏មិនអាចនឹងកែរោគឲ្យសះជាបាន នាំយកតែប្រាក់ជាច្រើនទៅ ។ ម្យ៉ាងទៀត សេដ្ឋីនោះពួកពេទ្យ ក៏បោះបង់ចោលហើយ ។ មានពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតីមុខជានឹងធ្វើមរណកាលក្នុងថ្ងៃទី ៥ ។ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតីមុខជានឹងធ្វើមរណកាលក្នុងថ្ងៃទី ៧ ។

ចីវរក្ខន្ធកេ រាជគហកសេដ្ឋិវត្ថុសីសាពាធកថា

អថខោ រាជគហកស្ស ឧតកមស្ស ឯតទហោសិ អយំ ខោ សេដ្ឋី គហបតិ ពហូបការោ រញ្ញោ ចេវ ឧតកមស្ស ច អបិច វេជ្ជេហិ បច្ចក្ខាតោ ឯកចេ្ច ជ្ឌា ឯវមាហំ-សុ បញ្ចមំ ឌិវសំ សេដ្ឋី គហបតិ ការាលំ ការិស្សតីតិ ឯកចេ្ច ជ្ឌា ឯវមាហំសុ សត្តមំ ឌិវសំ សេដ្ឋី គហ-បតិ ការាលំ ការិស្សតីតិ អយំ ច រញ្ញោ ជីវការោ ជ្ឌា តរុណោ ភទ្រការោ យន្ធ្ន មយំ រាជានំ ជីវការ ជ្ឌ យាចេយ្យាម សេដ្ឋី គហបតឺ តិការិច្ចិ តុន្ត ។ អថខោ រាជគហការោ ឧតមោ យេន រាជា មាតធো សេនិយោ ពិម្ពិសារោ ឧតុបសង្ក្ត ឧបសង្ក្ត ។ រាជានំ មាតធំ សេនិយំ ពិម្ពិសារ ឯតទហោ ច អយ ឧេ សេដ្ឋី គហបតិ ពហូបការោ ឧេ ចេ ឧតកមស្ស ច អបិច ជ្ឌេ ជ្ឌ ជ្ឌ ជ្ឌ

ចីវ:ក្ខន្ធក: និយាយពីរឿងសេដ្ឋីក្រុងរាជគ្រឹ:កើតរោគឈឺក្បាល

លំដាប់នោ: ពួកកុដុម្ពិក:នៅក្នុងក្រុងរាជគ្រឹ: មានសេចក្ដីរិ:គិតដូច្នេ:ថា សេដ្ឋីគហបតីនេ:ឯង មានឧបការ:ច្រើនដល់ស្ដេចផង ដល់ពួកកុដុម្ពិក:ផង ម្យ៉ាងទៀត សេដ្ឋីនោ:ពួកពេទ្យបោ:បង់ហើយ ពួកពេទ្យខ្ញុ:និយាយយ៉ាងនេ:ថា សេដ្ឋីគហបតីមុ:ជានឹងធ្វើមរណកាលក្នុងថ្ងៃទី ៥ ពួកពេទ្យខ្ញុ:និយាយយ៉ាងនេ:ថា សេដ្ឋីគហបតីមុ:ជានឹងធ្វើមរណកាលក្នុងថ្ងៃទី ៧ ម្យ៉ាងទៀត ពេទ្យជីវក:របស់ព្រះមហាក្សត្រនេ:នៅក្នុងជាមនុស្សកំពុងចម្រើន បើដូច្នោ: គួរតែយើងទូលសូមពេទ្យជីវក: អំពីព្រះមហាក្សត្រ ដើម្បីព្យាបាលរោគសេដ្ឋីគហបតី ។ គ្រានោ: ពួកកុដុម្ពិក:នៅក្នុងក្រុងរាជគ្រឹ: បានចូលទៅគាល់ព្រះបាទមាគធសេនិយ ពិម្ពិសារ លុ:ចូលទៅដល់ហើយ ក៏បានក្រាបទូលព្រះបាទមាគធសេនិយ ពិម្ពិសារថា សូមទ្រង់ព្រះមេត្ដាប្រោស សេដ្ឋីគហបតីនេ:មានឧបការ:ច្រើនដល់ព្រះសម្មតិទេពផង ដល់ពួកកុដុម្ពិក:ផង ម្យ៉ាងទៀត ពួកពេទ្យក៏បោ:បង់ហើយ ពួកពេទ្យខ្ញុ:និយាយយ៉ាងនេ:ថា សេដ្ឋីគហបតីមុ:ជានឹងធ្វើមរណកាលក្នុងថ្ងៃទី ៥ ពួកពេទ្យខ្ញុ:និយាយយ៉ាងនេ:ថា សេដ្ឋីគហបតីមុ:ជានឹងធ្វើមរណកាលក្នុងថ្ងៃទី ៧ យើងខ្ញុំសូមអង្វរសូមព្រះសម្មតិទេពទ្រង់បង្គាប់ពេទ្យជីវក ឲ្យព្យាបាលរោគសេដ្ឋីគហបតី ។

អថខោ ភជ្ជ មាតលោ សេនិយោ ពិម្ពិសារេ ជីវកំ
កោមារភច្ចំ អាណាបេសិ តច្ច ភណ្ណ ជីវក សេដ្ឋី
គហបតី តិកិច្ឆាហីតិ ។ ឯវំ ទេវាតិ ខោ ជីវកោ
កោមារភច្ចោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសា-
រស្ស បដិស្សុណិត្វា យេន សេដ្ឋី គហបតិ តេនុប-
សង្កមិ ឧបសង្កមិត្វា សេដ្ឋិស្ស គហបតិស្ស វិការំ
សល្ហក្ខេត្វា សេដ្ឋី គហបតី ឯតទវោច សចាហន្តំ
គហបតិ អរោគំ ភវេយ្យុ(១) ភ្លឹ មេ អស្ស ទេយ្យធម្មោ-
តិ ។ សព្ពំ សាបតេយ្យញ្ច តេ អាចរិយ ហោតុ អហញ្ច
តេ ជាសោតិ ។ សក្ខ្ជិ(២) បន ត្វំ គហបតិ ឯកេន
បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សណ្ហាមហំ អាចរិយ
ឯកេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សក្ខ្ជិ បន
ត្វំ គហបតិ ឧតិយេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។
សណ្ហាមហំ អាចរិយ ឧតិយេន បស្សេន សត្ត មាសេ
និបជ្ជិតុន្តិ ។ សក្ខ្ជិ បន ត្វំ គហបតិ ឧត្តានោ សត្ត
មាសេ និបជ្ជិតុន្តិ ។ សណ្ហាមហំ អាចរិយ ឧត្តានោ

---

១ ឱ. អរោគាបេយ្យុ ។ ២ ឱ. សក្ខ្ជិស្ស្ជសិ ។

ខណៈនោះ ព្រះបាទមាគធសេនិយពិម្ពិសារ ក៏ទ្រង់បានបង្គាប់ជីវកកោ-
មារភត្យថា នែនាយជីវក: អ្នកឯងចូរទៅព្យាបាលសេដ្ឋីគហបតីចុះ ។ ជីវក-
កោមារភត្យទទួលស្តាប់ព្រះរាជឱ្ការ ព្រះបាទមាគធសេនិយពិម្ពិសារ
ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស រួចចូល
ទៅរកសេដ្ឋីគហបតី លុះចូលទៅដល់ហើយ ក៏សង្កេតដឹងវិការៈរបស់
សេដ្ឋីគហបតី រួចហើយនិយាយនឹងសេដ្ឋីគហបតីដូច្នេះថា នែគហបតី
ប្រសិនបើខ្ញុំកែរោគលោកសះជាហើយ តើខ្ញុំនឹងត្រូវបានរង្វាន់ដូចម្តេច ។
សេដ្ឋីគហបតីតបថា លោកអាចារ្យ សម្បត្តិរបស់ខ្ញុំទាំងអស់ក្តី ក៏ត្រូវ
បានលោក ខ្លួនខ្ញុំក្តី ក៏ធ្វើជាខ្ញុំរបស់លោក ។ ជីវកកោមារភត្យសួរថា
នែគហបតី លោកអាចនឹងសម្រាន្តផ្ទៀងតែម្ខាងអស់ ៧ ខែបានឬទេ ។
សេដ្ឋីគហបតីតបថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ទៀងតែម្ខាងអស់
៧ ខែបាន ។ ជីវកកោមារភត្យសួរថា នែគហបតី លោកអាចនឹង
សម្រាន្តផ្ទៀងមកម្ខាងទៀតអស់ ៧ ខែបានឬទេ ។ សេដ្ឋីគហបតីតប
ថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ទៀងមកម្ខាងទៀតអស់ ៧ ខែបាន ។
ជីវកកោមារភត្យសួរថា នែគហបតី លោកអាចនឹងសម្រាន្តផ្ងារអស់ ៧ ខែ
បានឬទេ ។ សេដ្ឋីគហបតីប្រាប់ថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ងារ

ចីវរក្ខន្ធកេ រាជគហកសេដ្ឋិវត្ថុសីសាពាធកថា

សត្ត មាសេ ឯបជ្ជិតុន្តិ ។ អថខោ ជីវកោ កោមារ-
ភច្ចោ សេដ្ឋី គហបតី មញ្ចកេ ឯបជ្ជាបេត្វា[១] មញ្ច-
កេ សម្ពន្ធិត្វា សីសច្ឆវឺ ឧប្ផាដេត្វា[២] សិព្ពិនឺ រាជាមេ-
ត្វា ទ្វេ ចាណកេ ឆីហរិត្វា ជនស្ស ទស្សេសិ បស្ស-
ថ[៣] ឥមេ ទ្វេ ចាណកេ ឯកំ ខុទ្ទកំ ឯកំ មហាល្ល-
កំ យេ តេ អាចរិយា ឯវមាហំសុ បញ្ចមំ ជីវសំ សេ-
ដ្ឋី គហបតិ កាលំ ការិស្សតីតិ តេហាយំ មហាល្លកោ
ចាណកោ ជិណ្ណោ បញ្ចមំ ជីវសំ សេដ្ឋិស្ស គហបតិស្ស
មត្តលុង្ខំ បរិយាទយិស្សតិ មត្តលុង្ខស្ស បរិយាទានា
សេដ្ឋី គហបតិ កាលំ ការិស្សតិ សុជិណ្ណោ តេហិ
អាចរិយេហិ យេបិ តេ អាចរិយា ឯវមាហំសុ សត្តមំ
ជីវសំ សេដ្ឋី គហបតិ កាលំ ការិស្សតីតិ តេហាយំ
ខុទ្ទកោ ចាណកោ ជិណ្ណោ សត្តមំ ជីវសំ សេដ្ឋិស្ស
គហបតិស្ស មត្តលុង្ខំ បរិយាទយិស្សតិ មត្តលុង្ខស្ស
បរិយាទានា សេដ្ឋី គហបតិ កាលំ ការិស្សតិ
សុជិណ្ណោ តេហិបិ អាចរិយេហីតិ សិព្ពិនឺ សម្ឆដ្ដិច្ឆាទេត្វា

---

១ និបាតេត្វាតិបិ បាឬ ។ ២ ឩ. ឧប្ផាលេត្វា ។ ៣ ឩ. បស្សថយ្យោ ។

អស់ ៧ ខែបាន ។ ខណៈនោះ ជីវកកោមារភត្យក៏ឲ្យសេដ្ឋីគហបតីដេកលើគ្រែរួចចងសេដ្ឋីភ្ជាប់លើគ្រែហើយរុះស្បែកក្បាលវែកថ្នេរ (លលាដ៍ក្បាល) ចេញក៏នាំយកបាណកជាតិ[1] បានពីរហើយបង្ហាញដល់ជនថា ចូរអ្នកទាំងឡាយមើលបាណកជាតិទាំងពីរនេះចុះ បាណកជាតិ ១ តូច បាណកជាតិ ១ ធំ ពួកអាចារ្យណានិយាយយ៉ាងនេះថា សេដ្ឋីគហបតីនឹងធ្វើមរណកាលក្នុងថ្ងៃទី ៥ (ព្រោះ) ពួកអាចារ្យទាំងនោះបានឃើញបាណកជាតិធំនេះ ដល់ថ្ងៃទី ៥ វានឹងជញ្ជក់យកខួរក្នុងលលាដ៍ក្បាលរបស់សេដ្ឋីគហបតី ។ នឹងធ្វើមរណ-កាលព្រោះវាជញ្ជក់យកខួរក្នុងលលាដ៍ក្បាល អាចារ្យទាំងនោះគេឃើញត្រូវ (របស់គេមិនខុសទេ) ចំណែកខាងពួកអាចារ្យណានិយាយយ៉ាងនេះថា សេដ្ឋីគហបតីនឹងធ្វើមរណកាលក្នុងថ្ងៃទី ៧ (ព្រោះ) អាចារ្យទាំងនោះបានឃើញបាណកជាតិតូចនេះ ដល់ថ្ងៃទី ៧ វានឹងជញ្ជក់ខួរក្នុងលលាដ៍ក្បាលសេដ្ឋីគហបតី ។ នឹងធ្វើមរណកាលព្រោះវាជញ្ជក់ខួរក្នុងលលាដ៍ក្បាល អាចារ្យទាំងនោះគេឃើញត្រូវ (របស់គេមិនខុសទេ) រួចហើយទើបបិទថ្នេរ

---

១ ជាតិសត្វតូច ។ (មេរោគ) ។

សីសច្ចរឺ សិញ្ចេត្វា អាលេបំ អជាសិ ។ អថខោ សេដ្ឋី
គហបតិ សត្តាហស្ស អច្ចយេន ជីវកំ គោមារភច្ចំ
ឯតទវោច ជានាហំ អាចរិយ សង្ឃាមិ ឯកេន បស្សេន
សត្ត មាសេ និបជ្ជិតុន្តិ ។ ឧតុ មេ ត្វំ គហបតិ ប-
ដិស្សុណិ សង្ឃាមហំ អាចរិយ ឯកេន បស្សេន
សត្ត មាសេ និបជ្ជិតុន្តិ ។ សច្ចាហំ អាចរិយ បដិស្សុ-
ណឺ អថាហំ មរិស្សាមិ ជានាហំ សង្ឃាមិ ឯកេន
បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ តេនហិ ត្វំ គហ-
បតិ ឧតិយេន បស្សេន សត្ត មាសេ និបជ្ជាហីតិ ។
អថខោ សេដ្ឋី គហបតិ សត្តាហស្ស អច្ចយេន ជីវកំ
គោមារភច្ចំ ឯតទវោច ជានាហំ អាចរិយ សង្ឃាមិ ឧតិ-
យេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ ឧតុ មេ ត្វំ
គហបតិ បដិស្សុណិ សង្ឃាមហំ អាចរិយ ឧតិយេន
បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ សច្ចាហំ អាចរិ-
យ បដិស្សុណឺ អថាហំ មរិស្សាមិ ជានាហំ សង្ឃាមិ
ឧតិយេន បស្សេន សត្ត មាសេ និបជ្ជិតុន្តិ ។ តេនហិ
ត្វំ គហបតិ ឧត្តានោ សត្ត មាសេ និបជ្ជាហីតិ ។

(លលាដ៍ក្បាល) ហើយដេរស្បែកក្បាលរួចលាបថ្នាំឲ្យ ។ វេលានោះ លុះកន្ទង ៧ ថ្ងៃទៅ សេដ្ឋីគហបតីក៏និយាយទៅនឹងជីវកកោមារភត្យយ៉ាងនេះថា នែលោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្ទៀងខាងម្ខាងអស់ ៧ ខែបានទេ ។ ជីវកកោមារភត្យតបថា នែគហបតី ក្រែងលោកបានទទួលប្តេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ទៀងតែម្ខាងឲ្យអស់ ៧ ខែបាន មិនដូច្នោះឬ ។ សេដ្ឋីតបថា លោកអាចារ្យ ខ្ញុំបានទទួលប្តេជ្ញាពិតមែនហើយ ប៉ុន្តែថា ខ្ញុំមុខជានឹងស្ងាប់ (មិនខានព្រោះ) ខ្ញុំមិនអាចនឹងដេកផ្ទៀងតែម្ខាងឲ្យអស់ ៧ ខែបាន ។ ជីវកកោមារភត្យនិយាយថា នែគហបតី បើដូច្នោះ ចូរលោកដេកផ្ទៀងទៅម្ខាងទៀតអស់ ៧ ខែចុះ ។ វេលានោះ លុះកន្ទង ៧ ថ្ងៃទៅ សេដ្ឋីគហបតីបាននិយាយនឹងជីវកកោមារភត្យយ៉ាងនេះថា លោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្ទៀងម្ខាងទៀតអស់ ៧ ខែបានឡើយ ។ ជីវកកោមារភត្យតបថា នែគហបតី ក្រែងលោកបានទទួលប្តេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ទៀងទៅម្ខាងទៀងអស់ ៧ ខែបាន មិនដូច្នោះឬ ។ សេដ្ឋីនិយាយថា លោកអាចារ្យ ខ្ញុំបានទទួលប្តេជ្ញាពិតមែនហើយ ប៉ុន្តែថា ខ្ញុំមុខជានឹងស្ងាប់ (មិនខានព្រោះ) ខ្ញុំមិនអាចនឹងដេកផ្ទៀងទៅម្ខាងទៀតអស់ ៧ ខែបានទេ ។ ជីវកកោមារភត្យតបថា នែគហបតី បើដូច្នោះចូរលោកដេកផ្ងារឲ្យអស់ ៧ ខែវិញចុះ ។

ចីវរក្ខន្ធកេ រាជគហកសេដ្ឋិវត្ថុសីសាពាធកថា

អថខោ សេដ្ឋី គហបតិ សត្តាហស្ស អច្ចយេន ជីវកំ
គោមារកញ្ចុ ឯតទវោច ជាហំ អាចរិយ សណ្ហាមិ
ឧត្តានោ សត្ត មាសេ ជិបជ្ជិតុន្តិ ។ ជនុ មេ ត្វំ គហ-
បតិ បដិស្សុណិ សណ្ហាមហំ អាចរិយ ឧត្តានោ សត្ត
មាសេ ជិបជ្ជិតុន្តិ ។ សច្ចាហំ អាចរិយ បដិស្សុណិ អ-
ចាហំ មរិស្ស្ហាមិ ជាហំ សណ្ហាមិ ឧត្តានោ សត្ត មា-
សេ ជិបជ្ជិតុន្តិ ។ អហាញ្ច តំ គហបតិ ន វនេយ្យ
ឯត្តកំបិ ត្វំ ន ជិបជ្ជេយ្យាសិ អបិច បដិកច្ចេវ[1]
មយា ញ្ញាតោ តីហិ សត្តាហេហិ សេដ្ឋី គហបតិ អរោ-
គោ ភវិស្ស្ហតីតិ ឧជ្ជេហិ គហបតិ អរោគោសិ ជាជាហិ
ភ្លឹ មេ ទេយ្យធម្មោតិ ។ សត្ថុ សាបតេយ្យញ្ច តេ អា-
ចរិយ ហោតុ អហាញ្ច តេ ជានោតិ ។ អលំ គហបតិ
មា មេ ត្វំ សត្ថុ សាបតេយ្យ អជានិ មា ច មេ ជានោ
រញ្ញោ សតសហស្ស ទេហិ មយ្ហ សតសហស្ស្ហន្តិ ។

---

១ ឱ. បដិកច្ចេវ ។

លំដាប់នោះ លុះកន្ធង ៧ ថ្ងៃទៅ សេដ្ឋីគហបតីបាននិយាយទៅនឹងជីវក-កោមារភត្យយ៉ាងនេះថា លោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្ទារអស់ ៧ ខែបានទេ ។ ជីវកកោមារភត្យតបថា នែគហបតី ក្រែងលោកបានទទួលប្តេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ទារអស់ ៧ ខែបាន មិនដូច្នោះឬ ។ សេដ្ឋីនិយាយថា លោកអាចារ្យ ខ្ញុំបានទទួលប្តេជ្ញាពិតមែនហើយ ប៉ុន្តែថា ខ្ញុំមុខជានឹងស្លាប់ (មិនខានព្រោះ) ខ្ញុំមិនអាចនឹងដេកផ្ទារអស់ ៧ ខែបានទេ ។ ជីវកកោមារភត្យតបវិញថា នែគហបតី បើខ្ញុំមិនបាននិយាយនឹងលោក (យ៉ាងនេះទេ) អ្នកមុខជាមិនដេកអស់កាលមានប្រ-មាណប៉ុណ្ណោះឡើយ ម្យ៉ាងទៀត យើងបានដឹងពីមុនហើយថា ដល់គ្រប់ ៧ ថ្ងៃ ៣ ដង សេដ្ឋីគហបតីមុខជានឹងសះស្បើយរោគជាប្រាកដ (មិនខាន) នែគហបតី ចូរអ្នកក្រោកឡើង ឥឡូវ លោកបានសះជារោគហើយ ចូរលោកដឹងលោកត្រូវឲ្យរង្វាន់ខ្ញុំដូចម្តេចខ្លះ ។ សេដ្ឋីគហបតីនិយាយថា លោកអាចារ្យសម្បត្តិខ្ញុំទាំងអស់ក្តី ក៏ត្រូវបានលោក ខ្លួនខ្ញុំក្តី ក៏សូមធ្វើជាខ្ញុំលោក ។ ជីវកកោមារភត្យតបថា នែគហបតី ណ្ហើយចុះ លោកកុំឲ្យសម្បត្តិទាំងអស់មកខ្ញុំឡើយ ម្យ៉ាងទៀត លោកកុំធ្វើជាបាវរបស់ខ្ញុំ លោកចូរថ្វាយទ្រព្យ ១ សែនកហាបណៈទៅស្តេច ឲ្យទ្រព្យ ១ សែនកហាបណៈមកខ្ញុំចុះ ។

អថខោ សេដ្ឋី គហបតិ អហោសោ សមាធោ រញ្ញោ សតសហស្សំ អជ្ជាសិ ជីវកស្ស គោមារភច្ចស្ស សតសហស្សំ ។

[៣៩] តេន ខោ បន សមយេន ពារាណសេយ្យ-កស្ស សេដ្ឋិបុត្តស្ស មោក្ខចិកាយ ឧប្ផន្នស្ស អន្ត-ណ្ឌាពាធោ ហោតិ ។ តេន យាគុបិ ឬតា ន សម្ម-ប្ប រិណាមំ គច្ឆតិ ភត្តំបិ ភុត្តំ ន សម្ម ប្ប រិណាមំ គច្ឆតិ ឧច្ចារេបិ ឬ ប្ប ស្ សាវេបិ ន ឬ ប ត ុ ណោ ។ សោ តេន ភ-ិ-សោ ហោតិ ល ូ ខោ ឧ ព ្ ូ ណ ្ ណ ោ ឧ ប ្ ប ណ ្ ណ ុ ក ជ ា ត ោ ឆ ម ដ ិ ស ន ្ ត ត ត ្ ត ោ ។ អ ថ ខ ោ ព ា រ ា ណ ា ស េ យ ្ យ ក ស ្ ស ។ ។ ។

គ្រានោះ សេដ្ឋីគហបតីបានសះជាពោគហើយ ក៏បានថ្វាយទ្រព្យ ១ សែនកហាបណៈទៅស្តេច ជូនទ្រព្យ ១ សែនកហាបណៈទៅជីវកកោមារភ្ស ។

[៣៩] សម័យនោះឯង មានសេដ្ឋីបុត្តនៅក្នុងក្រុងពារាណសី លេងល្បែងដាំដូង ក៏កើតពោគដុំក្នុងពោះវៀនធំ ។ បបរដែលសេដ្ឋីបុត្ត បានហុតក្តី ក៏មិនបានរលួយស្រួល បាយដែលសេដ្ឋីបុត្តបានបរិភោគក្តី ក៏មិនបានរលួយស្រួលឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនបានស្រួលសោះ ។ ព្រោះពោគនោះ សេដ្ឋីបុត្តនោះ ក៏ទៅជាស្គមសៅហ្មង មានសម្បុរអាក្រក់កើតពោគលឿងស្វេកស្វាំង មានខ្លួនរាមដោយសរសៃ ។ វេលានោះ សេដ្ឋីនៅក្នុងក្រុងពារាណសី មានសេចក្តីរិះគិតដូច្នេះថា ជំងឺកូនអញប្រាកដដូច្នោះ ទឹកបបរ (ដែលកូនអញ) ហុតទៅក្តី ក៏មិនបានរលួយស្រួល បាយដែលបរិ-ភោគក្តី ក៏មិនបានរលួយស្រួល ឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនបានស្រួលសោះ ព្រោះពោគនោះ បានជាកូនអញទៅជាស្គមសៅហ្មង មានសម្បុរអាក្រក់ កើតពោគលឿងស្វេកស្វាំង មានខ្លួនរាមដោយសរសៃ បើដូច្នោះ គួរអាត្មាអញទៅកាន់ក្រុងរាជគ្រឹះ ហើយសូមយកពេទ្យជីវកៈពីស្តេចមក ដើម្បីឲ្យមកព្យាបាលកូនអញ ។ លំដាប់នោះ សេដ្ឋីនៅក្នុងក្រុងពារាណសី

ចីវរក្ខន្ធកេ សេដ្ឋីបុត្តវត្ថុអន្តគណ្ហាពាធកថា

ភជតហំ តត្ថ យេន ភជា មាតលោ សេនិយោ ពិម្ពិ-
សារោ តេនុបសង្កមិ ឧបសង្កមិត្វា ភជានំ មាតលំ សេ-
និយំ ពិម្ពិសារំ ឯតទវោច មយ្ហំ ខោ ឥមេ បុត្តស្ស តាទិ-
សោ អាពាធោ យាតុមិ បីតា ន សម្ម្ហាបរិណាមំ តច្ឆតិ
ភត្តំបិ ភុត្តំ ន សម្ម្ហាបរិណាមំ តច្ឆតិ ឧច្ចារេបិ បស្សា-
វេបិ ន បតុណោ សោ ឥន ឋិតោ លូខោ ទុព្ពណ្ណោ
ឧប្ផណ្ឌុប្ផណ្ឌុកជាតោ ធមនិសន្ថតតត្តោ សាធុ ឥមេ
ជីវកំ ឧជ្ជេ អាណាបេតុ បុត្តំ មេ តិកិច្ឆិតុន្តិ ។ អថ ខោ
ភជា មាតលោ សេនិយោ ពិម្ពិសារោ ជីវកំ កោមារ-
ភច្ចំ អាណាបេសិ តច្ច ភណ ជីវក ពាភណ្ឌសឺ តត្ថ
ពាភណ្ឌសេយ្យកំ សេដ្ឋិបុត្តំ តិកិច្ឆាហីតិ ។ ឯវំ ឥមាតិ
ខោ ជីវកោ កោមារភច្ចោ រញ្ញោ មាតលស្ស សេនិយស្ស
ពិម្ពិសារស្ស បដិស្សុណិត្វា ពាភណ្ឌសឺ តត្ថ យេន
ពាភណ្ឌសេយ្យកោ សេដ្ឋិបុត្តោ តេនុបសង្កមិ ឧប-
សង្កមិត្វា ពាភណ្ឌសេយ្យកស្ស សេដ្ឋិបុត្តស្ស វិការំ
សល្ទក្ខេត្វា ជនំ ឧស្សាវេត្វា តិលោការណឺ បរិក្ខិបិត្វា

បានទៅឯក្រុងរាជគ្រឹះ ហើយចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះបាទមាគធសេនិយពិម្ពិសារដូច្នេះ ថា សូមទ្រង់ព្រះមេត្តាប្រោស ជំងឺកូនខ្ញុំព្រះអង្គប្រាកដដូច្នោះ ទឹកបបរ ដែលកូនខ្ញុំព្រះអង្គហុតទៅក្តី ក៏មិនបានរលួយស្រួល បាយដែលបរិភោគ ទៅហើយក្តី ក៏មិនបានរលួយស្រួល ឧច្ចារ:ក្តី បស្សាវ:ក្តី ក៏មិនដែលបាន ស្រួលសោះ ព្រោះរោគនោះ កូនខ្ញុំព្រះអង្គទៅជាស្គមសៅហ្មង មានសម្បុរ អាក្រក់កើតរោគលឿងស្វេកស្វាំង មានខ្ជូនរវាមដោយសរសៃ ខ្ញុំព្រះអង្គ សូមអង្វរ សូមព្រះសម្មតិទេពទ្រង់បង្គាប់ពេទ្យជីវក: ឲ្យព្យាបាលរោគកូនខ្ញុំ ព្រះអង្គ ។ ខណ:នោះ ព្រះបាទមាគធសេនិយពិម្ពិសារទ្រង់បង្គាប់ជីវកកោ-មារភត្យថា នែនាយជីវក: ចូរអ្នកឯងទៅក្រុងពារាណសីហើយព្យាបាល រោគកូនសេដ្ឋីនៅក្នុងក្រុងពារាណសីផង ។ ជីវកកោមារភត្យទទួលព្រះរាជ-ឱង្ការព្រះបាទមាគធសេនិយពិម្ពិសារដោយពាក្យថា បពិត្រព្រះសម្មតិ-ទេពករុណាវិសេស ហើយទៅកាន់ក្រុងពារាណសី ចូលទៅរកកូនសេដ្ឋីនៅ ក្រុងពារាណសី លុះចូលទៅដល់ហើយ ក៏សង្កេតដឹងវិការកូនសេដ្ឋីនៅក្រុង ពារាណសី រួចបណ្តេញជនឲ្យដើរចេញ ហើយបិទបាំងរាំងនៅពីខាងក្រៅ

ថម្ភេ ឧបនិពន្ធិត្វា[1] ភរិយំ បុរតោ ឋបេត្វា ឧជុវច្ឆរឿ ឧប្ផាដេត្វា[2] អន្ធកណ្ហឿ ជីហរិត្វា ភរិយាយ ឧសេ្សសិ បស្ស តេ សាមិកស្ស អាពាធំ ឥមិនា យាគុបិ បីតា ន សម្ម្ហាបរិណាមំ គច្ឆតិ ភត្តំបិ ភុត្តំ ន សម្ម្ហាបរិណាមំ គច្ឆតិ ឧច្ចារេបិ បស្សាវេបិ ន បតុណោ ឥមិនាយំ ភិក្ខោ លូខោ ទុព្ពណ្ណោ ឧប្ផណ្ឌុប្ផណ្ឌុកជាតោ ឧ-មនិសន្ត្ថតកត្ថោតិ អន្ធកណ្ហឿ រិនិវេបេត្វា អត្ថានិ បដិប្ប-វេសេត្វា ឧជុវច្ឆរឿ សិពេ្ធត្វា អាលេបំ អទាសិ ។ អថខោ ពាវាណសេយ្យកោ សេដ្ឋិបុត្តោ ឧចិរស្ស្ស អាវេគោ អហោសិ ។ អថខោ ពាវាណសេយ្យកោ សេដ្ឋី បុត្តោ មេ អាវេគោ ឋិតោតិ ជីវកស្ស គោមារភ្ចស្ស សោឡ-ស សហស្សានិ ទាបេសិ ។ អថខោ ជីវកោ គោមា-រភ្ចោ តានិ សោឡ្ឍស សហស្សានិ អាទាយ បុនទេវ ភ្ជតហំ បច្ចាគច្ឆិ ។

---

១ ឩ. ឧពូន្ធិត្វា ។ ២ ឩ. ឧប្ផាលេត្វា ។

ហើយចង់កូនសេដ្ឋីភ្ជាប់នឹងសសរ រួចឲ្យភរិយា (នៃសេដ្ឋីបុត្ត) ឈរ
នៅពីខាងមុខរួចវះស្បែកពោះនាំយកដុំក្នុងពោះរៀនធំ បង្ហាញដល់ភរិយា
(សេដ្ឋីបុត្តនោះ) ថា នាងចូរមើលរោគរបស់ស្វាមីនាង បបរដែល
ហុតទៅហើយក្តី ក៏មិនបានរលួយស្រួល បាយដែលបរិភោគទៅហើយ
ក្តី ក៏មិនបានរលួយស្រួល ខ្ចារ:ក្តី បស្សាវ:ក្តី ក៏មិនដែលបានស្រួល
ព្រោះតែរោគនេះហើយ បានជាស្វាមីរបស់នាងនេះ ទៅជាស្គមសៅហ្មង
មានសម្បុរអាក្រក់ កើតរោគលឿងស្វេកស្វាំង មានខ្ជួនរវាមដោយសរ-
សៃ (ថាហើយក៏) ស្រាវយកដុំពីក្នុងពោះរៀនធំ ហើយបញ្ចូលពោះរៀន
ទៅវិញរួចដេរស្បែកពោះហើយលាបថ្នាំឲ្យ ។ វេលានោះ មិនយូរប៉ុន្មានកូន
សេដ្ឋីនៅក្នុងក្រុងពារាណសី ក៏បានសះជារោគនោះទៅ ។ គ្រានោះ សេដ្ឋី
នៅក្នុងក្រុងពារាណសីគិតថា កូនរបស់អាត្មាអញបានសះជារោគហើយ
ក៏បានប្រគល់ឲ្យនូវទ្រព្យ ១៦ ពាន់កហាបណ:ដល់ជីវកកោមារភត្យ ។
គ្រានោះ ជីវកកោមារភត្យបានទទួលទ្រព្យទាំង ១៦ ពាន់កហាបណ:នោះ
ហើយក៏ត្រឡប់មកក្រុងរាជគ្រឹះវិញ ។

ចីវរក្ខន្ធកេ ចណ្ឌប្បជ្ជោតវត្ថុបណ្ហាវោគាពាធកថា

[៤០] តេន ខោ បន សមយេន ឧជ្ជេនិយំ[1] រញ្ញោ បជ្ជោតស្ស បណ្ហាវោគាពាធោ ហោតិ ។ ពហូ មហន្តា មហន្តា ឧិសាចាមោក្ខា ជ្ជា អាគន្ត្វា តិកិច្ឆន្តា ជាស-ក្ខឹសុ អវោកំ ការាតុំ ពហុំ ហិរញ្ញ អាជាយ អតមំសុ ។ អថខោ ភជ្ជ បជ្ជោតោ រញ្ញោ មាតជ្ជស្ស សេនិយស្ស ពិម្ពិសារស្ស សន្តិកេ ទូតំ ចាហេសិ មយ្ហ ខោ ឌេវ[2] តាឧិសោ អាពាធោ សាធុ ឌេវោ ជីវកំ ជ្ជ អាណាបេតុ សោ មំ តិកិច្ឆិស្ស្ជតីតិ ។ អថខោ ភជ្ជ មាតជ្ជ សេនិយោ ពិម្ពិសារោ ជីវកំ ការាមារកំ អាណាបេសិ ឧ្ជ ភណ ជីវក ឧជ្ជ ឌ ឧ្ជ ភជ្ជ ជ្ជ ជ្ជ

ចីវរក្ខន្ធក: និយាយពីរឿងព្រះបាទចណ្ឌាបជ្ជោត កើតរោគស្គមលឿង

[៤០] សម័យនោះឯង ព្រះបាទបជ្ជោតក្នុងក្រុងឧជ្ជេនី ទ្រង់អា-ពាធដោយរោគលឿង ។ ពួកពេទ្យដែលជាទិសាបាមោក្ខធំ ៗ ច្រើននាក់មកព្យាបាលក៏មិនអាចនឹងកែរោគនោះ ឲ្យសះជាបាន នាំយកតែប្រាក់ទៅជាច្រើន ។ គ្រានោះ ព្រះបាទបជ្ជោត ក៏បានបញ្ជូនព្រះរាជបម្រើឲ្យទៅកាន់សំណាក់ស្តេចមាគធសេនិយពិម្ពិសារដោយព្រះបណ្តាំថា សូមទ្រង់ព្រះមេត្តាប្រោស ជំងឺខ្ញុំប្រាកដដូច្នោះ ខ្ញុំសូមអង្វរ សូមព្រះសម្មតិ-ទេពទ្រង់ត្រាស់បង្គាប់ទៅជីវកពេទ្យ ឲ្យគាត់ទៅព្យាបាលរោគខ្ញុំ ។ ខណ:នោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់បង្គាប់ទៅជីវកកោមារភត្យថានៃនាយជីវក: ចូរអ្នកទៅក្រុងឧជ្ជេនី ហើយព្យាបាលព្រះបាទបជ្ជោតផង ។ ជីវកកោមារភត្យ ទទួលស្តាប់ព្រះរាជឱ្យ៉ាងព្រះបាទមាគធសេនិយពិម្ពិសារដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយទៅកាន់ក្រុងឧជ្ជេនី ក៏ចូលទៅគាល់ព្រះបាទបជ្ជោត លុះចូលទៅគាល់ហើយក៏សង្កេតស្គាល់វិការ:របស់ព្រះបាទបជ្ជោត ហើយក៏ក្រាបបង្គំទូលព្រះបាទបជ្ជោតយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងស្វ្ងសប្បិ្ជ្ជាយ

តំ ឧភោ ឧបវិស្សតីតិ ។ អលំ ភណ្ឌ ជីវក យត្ថ សក្ការ
ឬ សម្ភាវនា អភោតំ ការ តំ ភគ្គ ជ ជ ជ ។ ។ ។

ព្រះសម្មតិទេពនឹងសោយសប្ប៉ិនោះបានដែរឬ ។ ព្រះមហាកស្សត្រ ត្រាស់ថា នែនាយជីវក: មិនបានទេ អ្នកឯងអាចនឹងរក្សាពោគឲ្យបានសះជាដោយថ្នាំណាមួយវិញ រៀរលែងតែសប្ប៉ិចេញ ចូរអ្នកផ្សំថ្នាំនោះចុះ ដ្ឋិតសប្ប៉ិជាទីខ្ពើមរអើមរបស់ខ្ញុំ ។ លំដាប់នោះ ជីវកកោ-មារភត្យមានសេចក្តីរិះគិតដូច្នេះថា អាពាធរបស់ស្តេចនេះប្រាកដដូច្នោះ តែរៀរលែងសប្ប៉ិចេញហើយ អាត្មាអញមិនអាចនឹងធ្វើឲ្យសះជាបានឡើយ ។ បើដូច្នោះ គួរអាត្មាអញនឹងស្ងសប្ប៉ិ (នោះ) ឲ្យមានពណ៌ដូចទឹកចត់ ឲ្យមានក្ងិនដូចក្ងិនទឹកចត់ ឲ្យមានរសដូចរសទឹកចត់វិញ ។ លំដាប់នោះ ជីវកកោមារភត្យស្ងសប្ប៉ិឲ្យមានពណ៌ដូចជាពណ៌ទឹកចត់ មានក្ងិនដូចជាក្ងិនទឹកចត់ មានរសដូចជារសទឹកចត់ ជាមួយនឹងថ្នាំទាំងឡាយផ្សេង ៗ ។ លំដាប់នោះ ជីវកកោមារភត្យមានសេចក្តីរិះគិតដូច្នេះថា សប្ប៉ិដែលស្តេចនេះសោយហើយ ដល់ជ្រួតជ្រាបទៅមុខជានឹងចង្ហ៊ារចេញ ហើយស្តេចកំណាចនេះនឹងបង្ក្រាប់មនុស្សឲ្យសំលាប់អាត្មាអញមិនខានឡើយ បើដូច្នោះ គួរអាត្មាអញសូមលាជាមុនឲ្យហើយ ។ វេលានោះ ជីវកកោមារភត្យបានចូលទៅគាល់ព្រះបាទបជ្ជោត លុះចូលទៅជិតហើយ ក៏បានក្រាបបង្គំទូលសេចក្តីនេះនឹងព្រះបាទបជ្ជោតថា បពិត្រព្រះសម្មតិទេព ធម្មតាពួកខ្ញុំជាពេទ្យតែងគាស់យកឫសឈើមកផ្សំថ្នាំ ដោយការរហ័សយ៉ាងនោះ

ចីវរក្ខន្ធកេ ចណ្ឌាឃ្យជ្ជោតវត្ថុសឃ្ជិទានំ

សំហរាម សាធុ ខេវ ភាហ្មណានាវេសុ ច ទ្វារេសុ ច អាណាបេតុ យេន ភាហ្មណេន ជីវកោ ឥច្ឆតិ តេន ភាហ្មណេន កច្ឆតុ យេន ទ្វារេន ឥច្ឆតិ តេន ទ្វារេន កច្ឆតុ យំ កាលំ ឥច្ឆតិ តំ កាលំ កច្ឆតុ យំ កាលំ ឥច្ឆតិ តំ កាលំ បវិសតូតិ ។ អថខោ រាជា បជ្ជោតោ ភាហ-ណានាវេសុ ច ទ្វារេសុ ច អាណាបេសិ យេន ភាហ្មណេន ជីវកោ ឥច្ឆតិ តេន ភាហ្មណេន កច្ឆតុ យេន ទ្វារេន ឥច្ឆតិ តេន ទ្វារេន កច្ឆតុ យំ កាលំ ឥច្ឆតិ តំ កាលំ កច្ឆតុ យំ កាលំ ឥច្ឆតិ តំ កាលំ បវិសតូតិ ។ តេន ខោ បន សមយេន រញ្ញោ បជ្ជោតស្ស ឧជ្ជេនិយា ជាម ហត្ថ-ិនិយា បញ្ញាសយោជនិយា ហោតិ ។ អថខោ ជីវកោ ខោមារភច្ចោ រញ្ញោ បជ្ជោតស្ស តំ សប្ប៊ី ឧបនាមេសិ ឆសារំ ខេវ ឬ ។ អថខោ ជីវកោ ខោមា-រភច្ចោ រាជានំ បជ្ជោតំ សប្ប៊ី ចាយេត្វា ហត្ថិសាលំ ឧត្ថ្ម ឧជ្ជេនិយា ហត្ថិនិយា ឧករម្ហា និ ។

ចីវរក្ខន្ធក: រឿងព្រះបាទចណ្ឌាបជ្ជោត និយាយពីការថ្វាយសប្ប៊ិ

សូមអង្វរ សូមព្រះសម្មតិទេពទ្រង់ត្រាស់បង្គាប់ពួកអ្នកដែលនៅចាំរោងសម្រាប់ដាក់រ៉ាហន:ហើយនិងពួកអ្នករក្សាទ្វារថា (បើ) ជីវក:ប្រាថ្នាទៅដោយរ៉ាហន:ណា ចូរឲ្យទៅដោយរ៉ាហន:នោះ ជីវក:ប្រាថ្នាទៅតាមទ្វារណា ចូរឲ្យទៅតាមទ្វារនោះ ជីវក:ប្រាថ្នាចង់ទៅក្នុងកាលណា ត្រូវឲ្យទៅក្នុងកាលនោះ ជីវក:ប្រាថ្នាចង់ចូលមកក្នុងក្រុងកាលណា ត្រូវឲ្យចូលមកក្នុងកាលនោះចុះ ។ ខណ:នោះ ព្រះបាទបជ្ជោតក៏បានត្រាស់បង្គាប់ទៅពួកអ្នកនៅចាំរោងសម្រាប់ដាក់រ៉ាហន: និងពួកអ្នករក្សាទ្វារថា (បើ) ជីវក:ប្រាថ្នាទៅដោយរ៉ាហន:ណា ចូរឲ្យទៅដោយរ៉ាហន:នោះ ជីវក:ប្រាថ្នាទៅតាមទ្វារណា ចូរឲ្យទៅតាមទ្វារនោះ ជីវក:ប្រាថ្នាទៅក្នុងកាលណា ចូរឲ្យទៅក្នុងកាលនោះ ជីវក:ប្រាថ្នាចូលមកក្នុងក្រុងកាលណា ចូរឲ្យចូលមកក្នុងកាលនោះចុះ ។ សម័យនោះ ព្រះបាទបជ្ជោតមានមេដំរី ១ ឈ្មោះកន្ធវតិកា អាចដើរទៅបាន ៥០ យោជន៍ (ក្នុង ១ ថ្ងៃ) ។ វេលានោះ ជីវកកោមារភត្យក៏បានបង្ហោនថ្វាយសប្ប៊ិនោះ ទៅព្រះបាទបជ្ជោតថា សូមព្រះសម្មតិទេពទ្រង់សោយទឹកចត់ (នេះ) ។ លំដាប់នោះ ជីវកកោមារភត្យបានឲ្យព្រះបាទបជ្ជោត សោយសប្ប៊ិរួចហើយ ក៏ទៅកាន់រោងដំរី (ឡើងជិះ) លើមេដំរីឈ្មោះកន្ធវតិកា ហើយក៏បរចេញពីក្រុងទៅ ។

អថខោ រញ្ញោ បជ្ជោតស្ស តំ សប្ពិ បីតំ បរិណាមេន្តំ ឧទ្ធេកំ អជាសិ ។ អថខោ ឦជ បជ្ជោតោ មនុស្ស ឯតទវោច ពុជ្ជេន ភណ្ណ ជីវកេន សប្ពឺ ចាយិតោម្ហិ តេនហិ ភណ្ណ ជីវកំ វជ្ជំ វិចិនាថាតិ ។ ភទ្ទវតិកាយ ទេវ ហត្ថិនិកាយ ឧតរម្ហា និប្ផ្ជតោតិ ។ តេន ខោ បន សមយេន រញ្ញោ បជ្ជោតស្ស ការការ ជាម ជាសោ សដ្ឋិយោជនិកោ ហោតិ អមនុស្ស្ជ បដិចូ ជាតោ ។ អថខោ ឦជ បជ្ជោតោ ការកំ ជាសំ អាណាបេសិ ភទ្ទ ភណ្ណ ការក ជីវកំ វជ្ជំ និវត្ថេហិ ឦជ តំ អាចរិយ និវត្ថាបេតីតិ ឯតេ ខោ ភណ្ណ ការក វជ្ជ ជាម ពហុមាយា មា ចស្ស ការ ជ្ជ ១ បដិក្ខហេសីតិ ។ អថខោ ការការ ជាសោ ជីវកំ ការមារភ្ជ អន្ត្ជមក្ខ ការសម្ជ្ជ សម្ភារេសិ ចាតរាសំ ការ ១ ។ អថខោ ការការ ជាសោ ជីវកំ ការមារភ្ជ ឯតទវោច ឦជ តំ អាចរិយ និវត្ថាបេតីតិ ។ អាតមេហិ ភណ្ណ ការ

ខណៈនោះ សប្បិដែលព្រះបាទបង្ហើតបានសោយហើយ ជ្រួតជ្រាបទៅក៏ចង្ហោរចេញមក ។ លោនោះ ព្រះបាទបង្ហើតទ្រង់មានបន្ទូលទៅនឹងមនុស្សទាំងឡាយដូច្នេះថា នែនាយ (ឥឡូវនេះ) ជីវកៈកំណាចបានឲ្យអញផឹកសប្បិទៅហើយ នែនាយ បើដូច្នោះ ចូរអ្នកទាំងឡាយទៅគន់រកមើលពេទ្យជីវកៈ ។ មនុស្សទាំងនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស (ឯពេទ្យជីវកៈនោះ) គាត់ជិះដំរីឈ្មោះកន្ធវតិកា បរចេញអំពីក្រុងបាត់ទៅហើយ ។ សម័យនោះឯង មានខ្ញុំម្ចាក់របស់ព្រះបាទបង្ហើតឈ្មោះកាកៈ អាចដើរទៅបានចំនួន ៦០ យោជន៍ (ក្នុង ១ ថ្ងៃ) ព្រោះអាស្រ័យដោយអមនុស្ស ។ គ្រានោះ ព្រះបាទបង្ហើតទ្រង់បង្គាប់ទៅខ្ញុំឈ្មោះកាកៈថា នែនាយកាកៈ ចូរឯងទៅឲ្យពេទ្យជីវកៈត្រឡប់មកវិញថា លោកអាចារ្យ ព្រះមហាក្សត្រឲ្យលោកត្រឡប់ទៅវិញ (កុំឲ្យខាន) នែនាយកាកៈ ធម្មតាពួកពេទ្យនេះតែងមានមាយាច្រើន ម្យ៉ាងទៀត ឯងកុំទទួលយករបស់បន្ទិចបន្ទួចរបស់ពេទ្យនោះឡើយ ។ លំដាប់នោះ ខ្ញុំឈ្មោះកាកៈក៏បានតាមទៅទាន់ជីវកកោមារភត្យកំពុងបរិភោគបាយព្រឹក ក្នុងរវាងពាក់កណ្តាលផ្លូវ ជិតក្រុងកោសម្ពី ។ លោនោះ ខ្ញុំឈ្មោះកាកៈបាននិយាយទៅនឹងជីវកកោមារភត្យដូច្នេះថា លោកអាចារ្យ ព្រះមហាក្សត្រឲ្យលោកត្រឡប់ទៅវិញ ។ ឯជីវកកោមារភត្យតបថា នែនាយកាកៈ

យាវ ភុញ្ជាមិ[1] ហន្ទ ភណ្ណ តាត ភុញ្ជស្ស្ជ្ជ ។ អលំ អាចរិយ ឯញ្ជាម្ហ្ម អាណាត្ត ឯតេ ខោ ភណ្ណ តាត ជ្ជ ជ្ជ ជ្ជ ជ្ជ ជ្ជ ជ្ជ ជ្ជ ជ្ជ ។ ។ ។

ចីវរក្ខន្ធក: រឿងព្រះបាទចណ្ឌាបជ្ជោត និយាយពីការឲ្យផ្ទែកន្ទួតព្រៃដល់ខ្ញុំឈ្មោះកាក:

ចូរអ្នកឯងបង្ហូរចាំយើងបរិភោគរួចសិន នែនាយកាក: បើដូច្នោះ ចូរអ្នកបរិភោគបាយសិន ។ កាក:តបថា លោកអាចារ្យ កុំព្រួយ ដ្បិតខ្ញុំព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ថា នែនាយកាក: ធម្មតាពួកពេទ្យទាំងនេះតែងតែមានមាយាច្រើន ម្យ៉ាងទៀត អ្នកឯងកុំទទួលរបស់បន្ទិចបន្ទួចរបស់ពេទ្យនោះឡើយ ។ សម័យនោះឯង ជីវកកោមារភត្យបានបង់ថ្នាំដោយក្រចកហើយទំពាស៊ីផ្ទែកន្ទួតព្រៃផង ផឹកទឹកផង ។ វេលានោះជីវកកោមារភត្យក៏និយាយទៅនឹងខ្ញុំឈ្មោះកាក:ដូច្នេះថា នែនាយកាក: បើដូច្នេះ អ្នកចូរទំពាស៊ីផ្ទែកន្ទួតព្រៃផង ផឹកទឹកផងចុះ ។ លំដាប់នោះ ខ្ញុំឈ្មោះកាក:គិតថា ពេទ្យនេះឯងហ៊ានទំពាស៊ីផ្ទែកន្ទួតព្រៃផង ផឹកទឹកផង ពេទ្យនេះមិនគួរនឹងមានអំពើអាក្រក់តិចតួចឡើយ ហើយក៏ទំពាស៊ីផ្ទែកន្ទួតព្រៃមួយចំហៀងផង ផឹកទឹកផង ។ ផ្ទែកន្ទួតព្រៃមួយចំហៀងដែលខ្ញុំឈ្មោះកាក:ទំពាស៊ីហើយនោះ ក៏ចុះរាកក្នុងទីនោះឯង ។ ខណៈនោះខ្ញុំឈ្មោះកាក:បាននិយាយទៅនឹងជីវកកោមារភត្យដូច្នេះថា លោកអាចារ្យ ខ្ញុំនៅមានជីវិត (តទៅទៀតឬទេ) ។ ជីវកកោមារភត្យប្រាប់ថា នែនាយកាក: អ្នកឯងកុំភ័យឡើយ ខ្ជូនអ្នកឯងក្តី ស្តេចកំណាចក្តី នឹងបានសះជាពោគហើយ ស្តេចនោះនឹងឲ្យគេសម្ងាប់ខ្ញុំមិនខាន ព្រោះហេតុនោះបានជាខ្ញុំមិនត្រឡប់ទៅវិញ ថាដូច្នោះហើយ ក៏ប្រគល់មេដំរីឈ្មោះកន្ធវតិកា

ហត្ថិនិកំ ការកស្ស និយ្យាតេត្វា យេន ភ១តហំ តេន
បណ្ណាមិ អនុបុព្ពេន យេន ភ១តហំ យេន ភ១ា មា-
ត១ោ សេនិយោ ពិម្ពិសារោ តេនុបសង្ក១មិ ឧបសង្ក១មិត្វា
រញ្ញោ មាត១ស្ស សេនិយស្ស ពិម្ពិសារស្ស ឯតមត្ថំ អា-
រោចេសិ ។ សុដ្ឋុ ភណ ជីវ១ អការិ យំ ន និវត្តោ
ចណ្ឌោ សោ ភ១ា ឃាតាបេយ្យាបិ ត១ិ ។ អ១ោ
ភ១ា បជ្ជោតោ អ១ោ សមាត១ោ ជីវ១ស្ស ការ-
ភ១ូ ត១ិ ទ្ធ ចាហេសិ អាត១ត្ថ ជីវ១ោ
រ ១ស្ស ១ីតិ ។ អលំ ១េ(១) អ១ិការ ១េ ១ោ ១ត្ថ-
តិ ។ តេ ១ោ ១ត ១ស ១ាយ ១ញ្ញ ១ជ្ជ ១ត ១ស
ិ ១ាយ ១ុ ១ស ១ាយ ១ុ ១ ១ ១

ទៅខ្ញុំឈ្មោះកាក:វិញ ហើយចៀសចេញទៅកាន់ក្រុងរាជគ្រឹះ ចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារឯក្រុងរាជគ្រឹះដោយលំដាប់ លុះចូលទៅដល់ហើយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះបាទមាគធសេនិយ-ពិម្ពិសារ ។ ស្ដេចទ្រង់ត្រាស់តបថា នែនាយជីវក:អ្នកឯងមិនបានវិលត្រឡប់ទៅវិញ ដោយហេតុណា ឈ្មោះថា បានធ្វើនូវហេតុនោះដោយល្អហើយ ស្ដេចកំណាចនោះមុខជានឹងឲ្យគេសម្ងាប់អ្នកឯងមិនខាន ។ គ្រានោះ ព្រះបាទបជ្ជោតបានសះជាពោគហើយ ក៏បញ្ជូនរាជបម្រើទៅក្នុងសំណាក់ជីវកកោមារភត្យថា សូមឲ្យជីវក:មក (កុំខាន) យើងនឹងឲ្យពរ ។ ឯជីវកកោមារភត្យតបថា សូមទ្រង់ព្រះមេត្តាប្រោស កុំព្ងួយព្រះទ័យ សូមព្រះសម្មតិទេពគ្រាន់តែទ្រង់រលឹក នូវឧបការ:របស់ខ្ញុំព្រះអង្គចុះ ។ សម័យនោះ សំពត់សិវេយ្យក: ១ គู ក៏កើតឡើងដល់ព្រះបាទបជ្ជោត ជាសំពត់ដ៏លើសលុបប្រសើរ ជាប្រធានខ្ពង់ខ្ពស់ ក្រៃលែងជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន ។ វេលានោះ ព្រះបាទបជ្ជោតបានបញ្ជូនសំពត់សិវេយ្យក: ១ គូនោះ

ជីវកស្ស គោមារភច្ចស្ស ចាហេសិ ។ អថខោ ជីវ-
កស្ស គោមារភច្ចស្ស ឯតទហោសិ ឥទំ ខោ មេ
សិវេយ្យកំ ឧុស្សយុតំ រញ្ញា បជ្ជោតេន បហិតំ ពហុន្នំ
ឧុស្សានំ ពហុន្នំ ឧុស្សយុតានំ ពហុន្នំ ឧុស្សយុតសតានំ
ពហុន្នំ ឧុស្សយុតសហស្សានំ ពហុន្នំ ឧុស្សយុតសត-
សហស្សានំ អត្តញ្ច សេដ្ឋញ្ច ចាមោក្ខញ្ច ឧត្តមញ្ច
បវរញ្ច ឧយិមំ អញ្ញោ គោចិ បច្ចារហតិ បរិភុញ្ជិតុំ
អញ្ញត្រ តេន ភគវតា អរហតា សម្មាសម្ពុទ្ធេន រញ្ញា
ឯ មាគធេន សេនិយេន ពិម្ពិសារេនាតិ ។

[៤១] តេន ខោ បន សមយេន ភគវតោ ការោ
ឧោសាភិសង្ខោ ហោតិ ។ អថខោ ភគវា អាយស្មន្តំ
អានន្ទំ អាមន្តេសិ ឧោសាភិសង្ខោ ខោ អានន្ទ តថា-
គតស្ស ការោ ឥច្ឆតិ តថាគតោ វិវេចនំ ចាតុន្តិ ។
អថខោ អាយស្មា អានន្ទោ យេន ជីវកោ គោមារ-
ភច្ចោ តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា ជីវកំ គោមារភច្ចំ
ឯតទវោច ឧោសាភិសង្ខោ ខោ អាវុសោ ជីវក តថា-
គតស្ស ការោ ឥច្ឆតិ តថាគតោ វិវេចនំ ចាតុន្តិ ។

ទៅជីវកកោមារភត្យ ។ លំដាប់នោះ ជីវកកោមារភត្យមានសេចក្តីរិះគិតដូច្នេះថា សំពត់សិវេយ្យក: ១ គូ ដែលព្រះបាទបជ្ជោតបានបញ្ជូនមកឲ្យអាត្មាអញនេះ ជាសំពត់ដ៏លើសលុបប្រសើរ ជាប្រធានខ្ពង់ខ្ពស់ក្រៃលែង ជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន អ្នកដទៃណាមួយ មិនគួរនឹងប្រើប្រាស់សំពត់សិវេយ្យក:នេះឡើយ រៀរលែងតែព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះចេញ ឬរៀរលែងតែព្រះបាទមាគធ-សេនិយពិម្ពិសារចេញ ។

[៦១] សម័យនោះឯង ព្រះកាយរបស់ព្រះមានព្រះភាគ ក្រាស់ដោយទោស (រោគទល់) ។ វេលានោះ ព្រះមានព្រះភាគត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា នែអានន្ទ កាយរបស់តថាគតក្រាស់ដោយទោសហើយ តថាគតប្រាថ្នានឹងធាន់ថ្នាំបញ្ចុះ ។ ខណ:នោះ ព្រះអានន្ទដ៏មានអាយុ ក៏ចូលទៅរកជីវកកោមារភត្យ លុះចូលទៅដល់ហើយ ក៏និយាយនឹងជីវកកោមារភត្យដូច្នេះថា នែជីវក:ដ៏មានអាយុ កាយរបស់ព្រះតថាគតក្រាស់ដោយទោសហើយ ព្រះតថាគតត្រូវការធាន់ថ្នាំបញ្ចុះ ។

តេនហិ ភន្តេ អានន្ទ ភគវតោ កាយំ ភតិចាមំ សិនេហេថាតិ ។ អថខោ អាយស្មា អានន្ទោ ភគ-
វតោ កាយំ ភតិចាមំ សិនេហេត្វា យេន ជីវកោ
កោមារភច្ចោ តេនុបសង្កមិ ។ ឧបសង្កមិត្វា ជីវកំ កោ-
មារភច្ចំ ឯតទវោច ។ សិនិន្ទោ ខោ អាវុសោ ជីវក
តថាគតស្ស ការយោ ។ យស្ស ជានិ ការលំ មញ្ញសីតិ ។
អថខោ ជីវកស្ស ។ កោមារភច្ចស្ស ។ ឯតទហោសិ ។ ន
ខោ មេ តំ ។ បដិរូបំ ។ យោហំ ។ ភគវតោ ។ ឧប្ប្ការិកំ
។ ។ ។

ជីវកកោមារភត្យតបថា បពិត្រព្រះអានន្ទដ៏ចម្រើន បើដូច្នោះ សូមឲ្យ លោកសម្រួលព្រះកាយរបស់ព្រះដ៏មានព្រះភាគបាន ២ ៣ ថ្ងៃសិន ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុបានសម្រួលព្រះកាយរបស់ព្រះដ៏មាន ព្រះភាគ ២ ៣ ថ្ងៃ រួចហើយក៏ចូលទៅរកជីវកកោមារភត្យ លុះចូល ទៅដល់ហើយ ក៏និយាយនឹងជីវកកោមារភត្យដូច្នេះថា នែអាវុសោជីវក: ព្រះកាយរបស់ព្រះតថាគត បានស្រួលបួលហើយ អ្នកសំគាល់នូវកាល គួរក្នុងគ្រានេះចុះ ។ គ្រានោះ ជីវកកោមារភត្យមានសេចក្តីរិះគិតដូច្នេះ ថា អាត្មាអញថ្វាយថ្នាំបញ្ចុះដ៏គ្រោតគ្រាត ដល់ព្រះដ៏មានព្រះភាគ អំពើ នេះមិនសមគួរដល់អាត្មាអញឡើយ ណ្ហើយចុះ គួរអាត្មាអញនឹងអប់ផ្ការ ឧប្បលទាំងឡាយបាន ៣ ក្តាប់ ជាមួយនឹងថ្នាំទាំងឡាយផ្សេង ៗ ហើយ សឹមបង្ហោនថ្វាយដល់ព្រះតថាគត ។ គ្រានោះ ជីវកកោមារភត្យបានអប់ ផ្ការឧប្បល ៣ ក្តាប់ ជាមួយនឹងថ្នាំទាំងឡាយផ្សេង ៗ រួចហើយចូលទៅ គាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏បង្ហោនថ្វាយផ្ការឧប្បល ១ ក្តាប់ដល់ព្រះដ៏មានព្រះភាគដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគទ្រង់ហិតផ្ការឧប្បល ១ ក្តាប់ដំបូងនេះ ផ្ការឧប្បលនេះ នឹងបញ្ចុះព្រះដ៏មានព្រះភាគបាន ១០ ដង រួចបង្ហោនថ្វាយផ្ការឧប្បលក្តាប់ ទី ២ ដល់ព្រះដ៏មានព្រះភាគដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស

ចីវរក្ខន្ធកេ ភគវតោ វិវេចនកថា

ភគវា ឧតិយំ ឧប្ឍលហត្ថំ ឧបសិជ្ឍតុ ឥទំ ភគវន្តំ ឧសក្ខត្ថុំ វិវេចេស្ឍតីតិ តតិយំ ឧប្ឍលហត្ថំ ភគវតោ ឧបនាមេសិ ឥមំ ភន្តេ ភគវា តតិយំ ឧប្ឍលហត្ថំ ឧប-សិជ្ឍតុ ឥទំ ភគវន្តំ ឧសក្ខត្ថុំ វិវេចេស្ឍតិ ឯវំ ភគវតោ សមត្ថ្ថីសាយ វិវេចនំ ភវិស្ឍតីតិ ។ អថខោ ជីវកោ កោមារភច្ចោ ភគវតោ សមត្ថ្ថីសាយ វិវេចនំ ឧត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ជីវកស្ស កោមារភច្ចស្ស ពហិទ្ធារកោដ្ឋកា និក្ខន្តស្ស ឯតទហោសិ មយា ខោ ភគវតោ សម-ត្ថ្ថីសាយ វិវេចនំ ទិន្នំ ឧោសាកិសន្ធោ តថាគតស្ស ការយោ ន ភគវន្តំ សមត្ថ្ថីសក្ខត្ថុំ វិវេចេស្ឍតិ ឯកូ-ឧត្ថ្ថីសក្ខត្ថុំ ភគវន្តំ វិវេចេស្ឍតិ អបិច ភគវា ឋិតោ ឧហាយិស្ឍតិ ឧហាតំ ភគវន្តំ សកឹ វិវេចេស្ឍតិ ឯវំ ភគវតោ សមត្ថ្ថីសាយ វិវេចនំ ភវិស្ឍតីតិ ។ យថា[១] ខោ ភគវា ជីវកស្ស កោមារភច្ចស្ស ចេតសា ចេ-តោបរិតក្កមញ្ញាយ អាយស្មន្តំ អានន្ទំ អាមន្តេសិ

១ អថខោតិ ទិស្សតិ ។

សូមព្រះដ៏មានព្រះភាគទ្រង់ហិតផ្ការឧប្បលក្តាប់ទី ២ នេះ ផ្ការឧប្បលនេះនឹងបញ្ចុះព្រះដ៏មានព្រះភាគបាន ១០ ដង រួចបង្ហោនថ្វាយផ្ការឧប្បលក្តាប់ទី ៣ ដល់ព្រះដ៏មានព្រះភាគដោយពាក្យថា សូមទ្រង់មេត្តាប្រោស សូមព្រះដ៏មានព្រះភាគទ្រង់ហិតផ្ការឧប្បលក្តាប់ទី ៣ នេះ ផ្ការឧប្បលនេះនឹងបញ្ចុះព្រះដ៏មានព្រះភាគបាន ១០ ដង រួមកិច្ចដែលបញ្ចុះថ្នាំព្រះដ៏មានព្រះភាគត្រូវជា ៣០ ដងគត់ដោយអាការយ៉ាងនេះ ។ លំដាប់នោះ ជីវកកោមារភត្យ បានថ្វាយថ្នាំបញ្ចុះ ៣០ ដងគត់ចំពោះព្រះដ៏មានព្រះភាគ រួចថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណហើយថយចេញទៅ ។ លំដាប់នោះ ជីវកកោ-មារភត្យ កាលចេញទៅដល់ក្រៅខ្វាងទ្វារហើយ ក៏មានសេចក្តីរិះគិតដូច្នេះថា ថ្នាំបញ្ចុះទាំង ៣០ ដងគត់អាត្មាអញបានថ្វាយដល់ព្រះដ៏មានព្រះភាគ ហើយព្រះកាយរបស់ព្រះតថាគត ដែលក្រាស់ដោយទោស ថ្នាំនោះនឹងបញ្ចុះព្រះដ៏មានព្រះភាគគ្រប់ ៣០ ដងគត់ក៏ទេ មុខជានឹងបញ្ចុះព្រះដ៏មានព្រះភាគត្រឹមតែ ២៩ ដង ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគបានបញ្ចុះថ្នាំហើយ មុខជានឹងស្រង់ទឹក ថ្នាំនោះនឹងបញ្ចុះព្រះដ៏មានព្រះភាគ ដែលបានស្រង់ទឹកហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ ដងគត់ដោយអាការយ៉ាងនេះ ។ ព្រះដ៏មានព្រះភាគបានជ្រាបសេចក្តីរិះគិតនៃចិត្តរបស់ជីវកកោមារភត្យ ដោយព្រះទ័យហើយទើបទ្រង់ត្រាស់ហៅព្រះអានន្ទ

ឥជានន្ត ជីវកស្ស គោមារភចស្ស ពហិទ្វារគោដ្ឋ-
ការ ជិក្ខន្តស្ស ឯតទហោសិ មយា ខោ ភគវតោ
សមត្តីសាយ វិវេចនំ ជិន្នំ ឧោសាកិសញ្ញោ ឥថាគតស្ស
ការយោ ន ភគវន្តំ សមត្តីសក្ខត្តុំ វិវេចេស្សតិ ឯកូន-
ត្តីសក្ខត្តុំ ភគវន្តំ វិវេចេស្សតិ អបិច ភគវា រ្ហិត្តោ
ឧហាយិស្សតិ ឧហាតំ ភគវន្តំ សកឹ វិវេចេស្សតិ ឯវំ
ភគវតោ សមត្តីសាយ វិវេចនំ ភវិស្សតីតិ ឥតិ ឧហានន្ត
ឧណ្ហោទកំ បដិយាទេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា
អានន្ទោ ភគវតោ បដិស្សុណិត្វា ឧណ្ហោទកំ បដិ-
យាទេសិ ។ អថ ខោ ជីវកោ គោមារភច្ចោ យេន
ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា
ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជីវកោ
គោមារភច្ចោ ភគវន្តំ ឯតទវោច រ្ហិត្តោ ភន្តេ ភគវាតិ ។

ដ៏មានអាយុមកក្នុងពេលនោះថា នែអានន្ទ កាលជីវកកោមារភត្យចេញ ទៅដល់ក្រៅខ្ទាងទ្វារហើយ ក៏មានសេចក្តីរិះគិតដូច្នេះថា ថ្នាំបញ្ចុះ ៣០ ដងគត់ អាត្មាអញបានថ្វាយដល់ព្រះដ៏មានព្រះភាគរួចហើយ កាយរបស់ព្រះតថាគត ក្រាស់ដោយទោស ថ្នាំនោះនឹងបញ្ចុះព្រះមានព្រះភាគគ្រប់ ៣០ ដងគត់ក៏ទេ មុខជានឹងបញ្ចុះព្រះដ៏មានព្រះភាគបានត្រឹមតែ ២៩ ដង ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគបានបញ្ចុះហើយមុខជានឹងស្រង់ទឹក ថ្នាំនោះនឹងបញ្ចុះព្រះដ៏មានព្រះភាគ ដែលបានស្រង់ទឹកហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ ដងគត់ ដោយអាការយ៉ាងនេះ នែអានន្ទ បើដូច្នោះ អ្នកចូរចាត់ចែងទឹកក្តៅឡើង ។ ព្រះអានន្ទដ៏មានអាយុ បានទទួលស្តាប់ព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគ ដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះករុណាម្ចាស់ ហើយក៏បានចាត់ចែងទឹកក្តៅ ។ លោនោះ ជីវកកោមារភត្យបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ជីវកកោមារភត្យអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះដ៏មានព្រះភាគទ្រង់បានបញ្ចុះថ្នាំហើយឬនៅ ។

ភិក្ខូ ជីវកាតិ ។ ឥធ មយ្ហំ ភន្តេ ពហិទ្ធារកោដ្ឋកា ជិក្ខុន្តស្ស ឯតទហោសិ មយា ខោ ភគវតោ សមត្តីសាយ វិវេចនំ ជិន្នំ ខោសាកិសន្ធោ តថាគតស្ស កាយោ ន ភគវន្តំ សមត្តីសក្ខត្តុំ វិវេចេស្សតិ ឯកូនត្តីសក្ខត្តុំ ភគវន្តំ វិវេចេស្សតិ អបិច ភគវា ភិក្ខូ ជហាយិស្សតិ ជហាតំ ភគវន្តំ សកឹ វិវេចេស្សតិ ឯវំ ភគវតោ សមត្តីសាយ វិវេចនំ ភវិស្សតីតិ ជហាយតុ ភន្តេ ភគវា ជហាយតុ សុគតោតិ ។ អថខោ ភគវា ឧណ្ហោទកំ ជហាយិ ជហាតំ ភគវន្តំ សកឹ វិវេចេសិ ឯវំ ភគវតោ សមត្តីសាយ វិវេចនំ អហោសិ ។ អថខោ ជីវកោ គោមារភច្ចោ ភគវន្តំ ឯតទវោច យាវ ភន្តេ ភគវតោ កាយោ បក-តត្តោ ហោតិ អលំ[1] យូសបិណ្ឌោកេជាតិ ។ អថខោ

---

១ អលំ តាវាតិ ទិស្សតិ ។

ចីវរក្ខន្ធក: និយាយអំពីព្រះមានព្រះភាគ (ទ្រង់ហាត) ថ្នាំបញ្ចុះ

ព្រះមានព្រះភាគទ្រង់តបថា នែជីវក: តថាគតបានបញ្ចុះថ្នាំហើយ ។ ជីវកកោមារភត្យ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលខ្ញុំ ព្រះអង្គចេញទៅដល់ក្រៅក្លោងទ្វារហើយ ក៏មានសេចក្តីរិះគិតដូច្នេះថា ថ្នាំបញ្ចុះចំនួន ៣០ ដងគត់ អាត្មាអញបានថ្វាយដល់ព្រះមានព្រះភាគ រួចហើយ កាយរបស់ព្រះតថាគត ក្រាស់ដោយទោស ថ្នាំនោះ នឹងបញ្ចុះព្រះមានព្រះភាគ ៣០ ដងគត់ក៏ទេ មុខជានឹងបញ្ចុះព្រះមាន ព្រះភាគបានត្រឹមតែ ២៩ ដង ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគទ្រង់បញ្ចុះ ថ្នាំរួចហើយ មុខជានឹងស្រង់ទឹក ថ្នាំនោះនឹងបញ្ចុះព្រះដ៏មានព្រះភាគដែល ស្រង់ទឹករួចហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ ដងគត់ដោយអាការយ៉ាងនេះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះ ដ៏មានព្រះភាគទ្រង់ស្រង់ទឹកចុះ សូមព្រះសុគតទ្រង់ស្រង់ទឹកចុះ ។ លំ-ដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្រង់ទឹកក្តៅហើយ ថ្នាំនោះក៏បានបញ្ចុះ ព្រះដ៏មានព្រះភាគដែលបានស្រង់ទឹកហើយម្តងទៀត រួមជាការបញ្ចុះថ្នាំ របស់ព្រះមានព្រះភាគ ៣០ ដងគត់យ៉ាងនេះ ។ លោនោះ ជីវកកោមា-រភត្យបានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា សូមទ្រង់ព្រះ មេត្តាប្រោស កាយរបស់ព្រះមានព្រះភាគ តាំងនៅជាប្រក្រតីដរាប ណាហើយ នឹងបានចម្រើនដោយដុំព្រះមំស:ដរាបនោះ ។ លោនោះ

ភគវតោ ការយោ ជ១ិរស្សេ បកតត្តោ អហោសិ ។

អថ១ោ ជីវកោ ១ោមារ១ច្ចោ តំ សិ១ាយ្យ១ំ ១ុ្ស្ស១ុ១ំ

អ១ាយ យេ១ ភគ១ា ត១ុ១ុ១ុ១ុ ១ុ១ុ១ុ១ុ ១ុ១ុ១ុ១ុ

ភគ១ន្តំ អ១ិ១ាត១ា ១ត១ុ១ន្តំ ១ិ១ីទិ ។ ១ត១ុ១ន្តំ

១ិ១ិ១ន្ទោ ១ោ ជីវកោ ១ោមារ១ច្ចោ ភគ១ន្តំ ១ត១ត១ោ១

១ត១ាហ១ំ ១ន្ត ភគ១ន្តំ ១ រ១ំ យ១ាចាមីតិ ។ អ១ិ១ន្ត១ន្ត១ា

១ោ ជីវ១ ត១ាត១ាតិ ។ យ១ា ១ន្ត ១ប្ប១ិ យ១ា

អ១ាវ១ន្ធ១ិ ។ ១ត១ហិ ជីវ១ាតិ ។ ភគ១ា ១ន្ត ២ំ១ុ១ុ-

ល១ោ ១ិ១ុ១ុ១ុ ១ ១ ១ ២ ១ ១ ១

មិនយូរប៉ុន្មាន កាយរបស់ព្រះមានព្រះភាគក៏បានជាប្រក្រតីវិញ ។ ខណៈ នោះ ជីវកកោមារភត្យបាននាំយកសំពត់សិវេយ្យកៈ[(១)] ១ គូនោះ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគហើយ អង្គុយនៅក្នុងទីសមគួរ ។ ជីវកកោមារភត្យ អង្គុយនៅ ក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគ ដោយ ពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមពរ ១ ចំពោះព្រះ មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា នែជីវកៈ ព្រះតថាគតទាំង ឡាយមានពរកន្ទ្ធហើយ ។ ជីវកកោមារភត្យទូលថា សូមទ្រង់ព្រះ មេត្តាប្រោស អំពើណាគួរផង មិនមានទោសផង (ខ្ញុំព្រះអង្គសូម ចំពោះអំពើនោះ) ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែជីវកៈ អ្នក ចូរនិយាយមកចុះ ។ ជីវកកោមារភត្យទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះមានព្រះភាគក្តី ភិក្ខុសង្ឆក្តី តែងតែទ្រទ្រង់សំពត់បង្សុកូល សូមទ្រង់ព្រះមេត្តាប្រោស សំពត់សិវេយ្យកៈ ១ គូនេះហើយដែលព្រះបាទ បជ្ជោត បញ្ជូនមកឲ្យខ្ញុំព្រះអង្គ ជាសំពត់លើសលុបប្រសើរ ជាប្រធាន

---

១ អដ្ឋកថាថា បានដល់សំពត់ដែលគេចោលនៅព្រៃខ្មោច ក្នុងឧត្តរកុរុទ្វីប ។ បានឮមកថា ពួកមនុស្សក្នុងឧត្តរកុរុទ្វីបតែងរុំសាកសពដោយសំពត់នោះឯងហើយយកទៅចោល ។ មានសត្ត បក្សីមានប្រមោយដូចដំរីវាសំគាល់នូវសំពត់នោះថា ជាដុំសាច់ ហើយឆាបនាំយកទៅ តម្កល់ទុក លើកំពូលភ្នំហិមពាន្តបកសំពត់នោះចោលចេញវាស៊ីសាច់សពនោះ ។ វេលានោះ ពួកអ្នកដើរ ព្រៃបានឃើញសំពត់នោះហើយក៏នាំយកមកថ្វាយស្តេច ។ សំពត់នេះហើយដែលព្រះបាទបជ្ជោត បានមកដោយហេតុយ៉ាងនេះឯង ។

ចីវរក្ខន្ធកេ គហបតិចីវរានុជាននំ

ពហុន្ធំ ឧុស្ឍយុតានំ ពហុន្ធំ ឧុស្ឍយុតសតានំ ពហុន្ធំ ឧុស្ឍយុតសហស្សានំ ពហុន្ធំ ឧុស្ឍយុតសតសហស្ស-ំ អត្តញ្ច សេដ្ឋញ្ច ចាមោកញ្ច ឧត្តមញ្ច ឋវរញ្ច បដិក្ខណ្ហាតុ មេ ភន្តេ ភគវា សិវេយ្យកំ ឧុស្ឍយុកំ ភិក្ខុសង្ឆ្យ ច គហបតិចីវរំ អនុជានាតូតិ ។ បដិក្ខ-ហេសិ ភគវា សិវេយ្យកំ ឧុស្ឍយុកំ ។ អថខោ ភគវា ជីវកំ គោមារភចុ ធម្មិយា កថាយ សន្ទស្ឍេសិ សមា-ឧបេសិ សមុត្តេជេសិ សម្ឍហំសេសិ ។ អថខោ ជីវកោ គោមារភចោ ភគវតា ធម្មិយា កថាយ សន្ទស្ឍិតោ សមាឧបិតោ សមុត្តេជិតោ សម្ឍហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្ក្លាមិ ។ អថខោ ភគវា ឍតស្ម៏ ជិនាធេ ឍតស្ម៏ បការណេ ធម្ម៏ ភេ០ ភ០ ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គហបតិចីវរំ យោ ឥច្ឆតិ បំសុកូលិកោ ហោតុ យោ ឥច្ឆតិ គហបតិចីវរំ សាធិយតុ ឥតរិតរេន ចាហំ ភិក្ខវេ សន្ទុដ្ឋ៏ វណ្ណ្ណោមីតិ ។

ចីវរក្ខន្ធក: ការទ្រង់អនុញ្ញាតគហបតីចីវរ

ខ្ពង់ខ្ពស់ក្រៃលែងជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគទ្រង់ទទួលយកសំពត់សិវេយ្យក: ១ គូរបស់ខ្ញុំព្រះអង្គ សូមទ្រង់អនុញ្ញាតគហបតិ-ចីវរ ដល់ភិក្ខុសង្ឆផង ។ ព្រះមានព្រះភាគ ព្រមទទួលយកសំពត់សិវេយ្យក: ១ គូ ។ លុះនោះ ព្រះមានព្រះភាគទ្រង់ពន្យល់ជីវក-កោមារភត្យ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លុះដាប់នោះ ជីវកោមារភត្យ កាលដែលព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសន: ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណាហើយចេញទៅ ។ ព្រោះនិទានេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគហបតីចីវរ ភិក្ខុណាប្រាថ្នា (បង្សុកូល) ភិក្ខុនោះ ចូរទ្រទ្រង់សំពត់បង្សុកូលចុះ ភិក្ខុណាប្រាថ្នា (គហបតីចីវរ) ភិក្ខុនោះ ចូរត្រេកអរនឹងគហបតីចីវរចុះ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគតពោលសរសើរសេចក្តីសន្តោសដោយបច្ច័យណាមួយ (តាមមានតាមបាន) ។

[៤២] អស្សោសុំ ខោ ភាគ្គវហេ មនុស្សា ភគ្គវតា ការ ភិក្ខូនំ គហបតិចីវរំ អនុញ្ញាតន្តិ ។ តេ ច មនុស្សា ហដ្ឋា អហេសុំ ឧឧក្តា ឥជានិ ខោ មយំ ជានានិ ឧស្សាម បុញ្ញានិ ការិស្សាម យតោ ភគ្គវតា ភិក្ខូនំ គហបតិចីវរំ អនុញ្ញាតន្តិ ។ ឯកាហេនេវ ភាគ្គវហេ ពហូនិ ចីវរសហស្សានិ ឧប្ផ្ជិំសុ ។ អស្សោសុំ ខោ ជានបទា មនុស្សា ភគ្គវតា ការ ភិក្ខូនំ គហបតិចីវរំ អនុញ្ញាតន្តិ ។ តេ ច មនុស្សា ហដ្ឋា អហេសុំ ឧឧក្តា ឥជានិ ខោ មយំ ជានានិ ឧស្សាម បុញ្ញានិ ការិស្សាម យតោ ភគ្គវតា ភិក្ខូនំ គហបតិចីវរំ អនុញ្ញាតន្តិ ។ ឯកាហេនេវ ជនបទេបិ ពហូនិ ចីវរសហស្សានិ ឧប្ផ្ជិំសុ ។

[៤៣] តេន ខោ បន សមយេន សជ្ជ្យ្ស ចារ្ យ ឧប្ផ្ជ្ នោ ហោតិ ។ ភគ្ គ ឯតមត្ថំ អ ចេ ។

[៤២] ពួកមនុស្ស ក្នុងក្រុងរាជគ្រឹះ បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតគហបតីចីវរដល់ភិក្ខុទាំងឡាយហើយ ។ មនុស្សទាំងនោះ ក៏មានចិត្តរីករាយស្រស់ស្រាយឡើងថា យើងមុខជានឹងបានឲ្យទាន មុខជានឹងបានធ្វើបុណ្យក្នុងកាលនេះឯង ចាប់ដើមតាំងពីព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតគហបតីចីវរដល់ភិក្ខុទាំងឡាយ ។ ក្នុងក្រុងរាជ-គ្រឹះមានចីវរច្រើនពាន់កើតឡើងតែក្នុង ១ ថ្ងៃប៉ុណ្ណោះ ។ ពួកមនុស្សដែលនៅក្នុងជនបទបានឮដំណឹងថា គហបតីចីវរ ព្រះមានព្រះភាគទ្រង់បានអនុញ្ញាតដល់ភិក្ខុទាំងឡាយហើយ ។ មនុស្សទាំងនោះ ក៏មានចិត្តរីករាយស្រស់ស្រាយឡើងថា យើងមុខជានឹងបានឲ្យទាន មុខជានឹងបានធ្វើបុណ្យក្នុងកាលនេះឯង ចាប់ដើមតាំងពីព្រះដ៏មានព្រះភាគ ទ្រង់បានអ-នុញ្ញាតគហបតីចីវរដល់ភិក្ខុទាំងឡាយ ។ សូម្បីតែក្នុងជនបទ ក៏មានចីវរច្រើនពាន់កើតឡើងតែក្នុង ១ ថ្ងៃប៉ុណ្ណោះ ។

[៤៣] សម័យនោះឯង សំពត់បាវារ[១] កើតឡើងដល់សង្ឆ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។

---

១ សំពត់ដែលមានលាយដោយរោមសត្វជ៉ាន ។

អនុជានামិ ភិក្ខវេ ចាវារន្តិ ។ គោសេយ្យចាវាវេ ឧប្ឋន្ធោ ហោតិ ។ អនុជានামិ ភិក្ខវេ គោសេយ្យចា-
វារន្តិ ។ គោជវំ ឧប្ឋន្ធំ ហោតិ ។ អនុជានামិ ភិក្ខវេ គោជវន្តិ ។

[៤៤] តេន ខោ បន សមយេន គាសីវជា ជីវ-
កស្ស គោមារកចូស្ស អឌ្ឍកាសិយំ[1] កម្ពលំ ចា-
ហេសិ ឧបឌ្ឍគាសីនំ ឧបមានំ[2] ។ អថខោ ជីវកោ
គោមារកច្ចោ តំ អឌ្ឍកាសិយំ កម្ពលំ អាទាយ
យេន ភគវា តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា ភគវន្តំ អភិ-
វាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ
ជីវកោ គោមារកច្ចោ ភគវន្តំ ឯតទវោច អយំ មេ ភន្តេ
អឌ្ឍកាសិយោ កម្ពលោ គាសិវញ្ញោ បហិតោ ឧបឌ្ឍ-
គាសីនំ ឧបមាទោ បដិក្ខណ្ហាតុ មេ ភន្តេ ភគវា

---

១ ឱ. អឌ្ឍកាសិកំ ។ ២ ខមមានំ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់បាវារ ។ សំពត់បាវារធ្វើពីសូត្របានកើតឡើង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់បាវារដែលគេធ្វើពីសូត្រ ។ សំពត់កោជវ:[1] បានកើតឡើង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់កោជវ: ។

ចប់ ភាណវារ: ជាដំបូង ។

[៤៤] សម័យនោះឯង ស្តេចក្នុងដែនកាសី បានបញ្ជូនសំពត់កម្ពលមានតម្លៃកន្ទ:ពាន់ (៥០០ កហាបណ:) គឺប្រហែលនឹងវត្ថុទាំងឡាយដែលមានតម្លៃកន្ទ:ពាន់ដែរ ទៅឲ្យជីវកកោមារភត្យ ។ លោនោះ ជីវកកោមារភត្យក៏បាននាំយកសំពត់កម្ពល មានតម្លៃកន្ទ:ពាន់នោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ជីវកកោមារភត្យ លុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា សូមទ្រង់មេត្តាប្រោស សំពត់កម្ពលមានតម្លៃកន្ទ:ពាន់របស់ខ្ញុំព្រះអង្គនេះ ប្រហែលនឹងវត្ថុទាំងឡាយ ដែលមានតម្លៃកន្ទ:ពាន់ដែរ ស្តេចកាសីបានបញ្ជូនមកប្រទាន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ

---

1 (អដ្ឋកថាថា) សំពត់នេះប្រហែលគ្នានឹងសំពត់បាវារ:សំពត់នេះគេធ្វើពីពោមសត្ត ។

កម្ពលំ យំ មម អស្ស ជីយរត្តំ ហិតាយ សុខាយាតិ ។ បដិក្ខិបិ ភគវា កម្ពលំ ។ អថ ខោ ភគវា ជីវកំ កោមារភច្ចំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថ ខោ ជីវកោ កោ-មារភច្ចោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ ស-មាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថ-ខោ ភគវា ឯតស្មឹ ជិណ្ណេ ឯតស្មឹ បការណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ កម្ពលន្តិ ។

[៤៥] តេន ខោ បន សមយេន សជ្ជ្យស្ស ឧច្ចា-រចានិ ចីវរានិ ឧប្ផជ្ជន្តិ ។ អថ ខោ ភិក្ខូនំ ឯតទហោ-សិ កឹ នុ ខោ ភគវតា ចីវរំ អនុញ្ញាតំ កឹ អនុញ្ញា-តន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ

ទ្រង់ទទួលយកសំពត់កម្ពលរបស់ខ្ញុំព្រះអង្គ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ខ្ញុំព្រះអង្គអស់កាលជាអង្វែង (តទៅ) ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលយកសំពត់កម្ពល ។ វេលានោះ ព្រះមានព្រះភាគទ្រង់ពន្យល់ជីវកកោមារភត្យ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ។ លំដាប់នោះ ជីវកកោមារភត្យ កាលដែលព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចយចេញទៅ ។ ព្រោះនិទានេះ ដំណើរនេះ ព្រះមានព្រះភាគ ក៏ទ្រង់ធ្វើធម្មីកថាក្នុងពេលនោះហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវសំពត់កម្ពល ។

[៤៥] សម័យនោះឯង មានចីវរល្អនិងមិនល្អ កើតឡើងដល់សង្ឆ ។ ភិក្ខុទាំងឡាយ មានសេចក្ដីរិះគិតដូច្នេះថា ចីវរដូចម្ដេចដែលព្រះមានព្រះភាគទ្រង់អនុញ្ញាត ចីវរដូចម្ដេច ដែលព្រះមានព្រះភាគ មិនអនុញ្ញាត ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

ភិក្ខវេ ឆ ចីវរានិ ខោមំ កប្ប៉ាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គន្តិ ។ តេន ខោ បន សមយេន យេ តេ ភិក្ខូ គហាបតិចីវរំ សាទិយន្តិ តេ ពុក្ក្ជ្ជ្ជ

ចីវរក្ខន្ធក: និយាយពី (ការទ្រង់អនុញ្ញាត) ចីវរ ៦ យ៉ាងនិងគហបតីចីវរ

ចីវរ ៦ យ៉ាង គឺ ចីវរដែលធ្វើដោយសម្បកឈើ ១ ចីវរដែលធ្វើដោយកប្បាស ១ ចីវរដែលធ្វើដោយសូត្រ ១ ចីវរដែលធ្វើដោយរោមសត្ត (រៀវលែងតែសក់ ឬរោមមនុស្សចេញ) ១ សំពត់ដែលធ្វើដោយសម្បកឆ្មែ ១ សំពត់ដែលធ្វើលាយដោយវត្ថុ ៥ យ៉ាងខាងដើម ១ ។ សម័យនោះឯង ពួកភិក្ខុណាត្រេកអរនឹងគហបតីចីវរ ភិក្ខុទាំងនោះ ក៏រង្គៀសមិនត្រេកអរនឹងសំពត់បង្សុកូលឡើយ ព្រោះគិតថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតតែចីវរ ១ មិនបានអនុញ្ញាតចីវរពីរទេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលត្រេកអរនឹងគហបតីចីវរហើយ ត្រេកអរនឹងសំពត់បង្សុកូលផងក៏បាន ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគតសរសើរសេចក្ដីសន្តោសដោយចីវរទាំងពីរយ៉ាងនោះ ។

[៤៦] សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោ-សលជនបទ ។ ភិក្ខុពួកខ្លះ ដើរទៅកាន់ព្រៃស្មសាន ដើម្បីនឹងបង្សុកូល ភិក្ខុពួកខ្លះ មិនបានរង់ចាំឡើយ ។ ពួកភិក្ខុណា ដើរទៅកាន់ព្រៃស្មសានដើម្បីនឹងបង្សុកូល ភិក្ខុទាំងនោះ ក៏បានសំពត់បង្សុកូលទាំងឡាយ ។ ពួកភិក្ខុណាដែលមិនបានរង់ចាំ ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ

ភាកំ ឧេថាតិ ។ តេ ឍវមាហំសុ ន មយំ អាវុសោ
តុម្ហាកំ ភាកំ ឧស្ឆាម កិស្ស តុម្ហេ ជាតមិត្ថាតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
ជាតមេត្ថានំ ជាកាមា ភាកំ ជាតុន្តិ ។ តេន ខោ បន
សមយេន សម្ពហុលា ភិក្ខូ កោសលេសុ ជនបទេសុ
អទ្ធានមគ្គប្បដិបន្ន ហោន្តិ ។ ឯកច្ចេ ភិក្ខូ សុសានំ
ឧក្ខិត្តមីសុ បំសុកូលាយ ឯកច្ចេ ភិក្ខូ អាតមេសុំ ។
យេ តេ ភិក្ខូ សុសានំ ឧក្ខិត្តមីសុ បំសុកូលាយ តេ
បំសុកូលានិ លភីសុ ។ យេ តេ ភិក្ខូ អាតមេសុំ
តេ ឍវមាហំសុ អម្ហាកំបិ អាវុសោ ភាកំ ឧេថាតិ ។ តេ
ឍវមាហំសុ ន មយំ អាវុសោ តុម្ហាកំ ភាកំ ឧស្ឆាម
កិស្ស តុម្ហេ ន ឧក្ខិត្ថាតិ ។ ភគវតោ ឯតមត្ថំ អា-
រោចេសុំ ។ អនុជានាមិ ភិក្ខវេ អាតមេត្ថានំ អកាមា
ភាកំ ជាតុន្តិ ។ តេន ខោ បន សមយេន សម្ពហុលា

ចូរលោកទាំងឡាយឲ្យចំណែកមកយើងខ្ញុំ ។ ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ (បើលោកទាំងឡាយចង់បានសំពត់បង្សុកូល) ហេតុដូចម្តេច បានជាលោកទាំងឡាយមិនរង់ចាំយើង ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមិនប្រាថ្នានឹងឲ្យ ក៏កុំឲ្យនូវចំណែកដល់ភិក្ខុទាំងឡាយដែលមិនរង់ចាំបាន ។ សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវធ្វើដំណើរក្នុងកោសលជនបទ ។ ភិក្ខុពួកខ្ញុំ ដើរទៅកាន់ព្រៃស្មសានដើម្បីនឹងបង្សុកូល ភិក្ខុពួកខ្ញុំបានរង់ចាំ ។ ពួកភិក្ខុណាចូលទៅកាន់ព្រៃស្មសានដើម្បីនឹងបង្សុកូល ភិក្ខុទាំងនោះ ក៏បានសំពត់បង្សុកូល ។ ពួកភិក្ខុណាដែលរង់ចាំ ភិក្ខុទាំងនោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ ចូរលោកទាំងឡាយឲ្យចំណែកមកយើងខ្ញុំ ។ ភិក្ខុទាំងនោះពោលតបវិញយ៉ាងនេះថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុម្តេច បានជាលោកទាំងឡាយមិនចូលទៅ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ដែលទុកជាមិនចង់ឲ្យក៏ត្រូវឲ្យចំ-ណែកដល់ភិក្ខុទាំងឡាយដែលរង់ចាំ ។ សម័យនោះឯង មានពួកភិក្ខុច្រើនរូប

ចីវរក្ខន្ធកេ សុសានោក្កមនកថា

ភិក្ខូ គោសលេសុ ជនបទេសុ អជ្ឌានមក្ខប្ជដិបជ្ជ-
ហោន្តិ ។ ឯកចេ ភិក្ខូ បឋមំ សុសានំ ឱ្ក្ខមីសុ
បំសុកូលាយ ឯកចេ ភិក្ខូ បច្ឆា ឱ្ក្ខមីសុ ។ យេ
តេ ភិក្ខូ បឋមំ សុសានំ ឱ្ក្ខមីសុ បំសុកូលាយ តេ
បំសុកូលានិ លភីសុ ។ យេ តេ ភិក្ខូ បច្ឆា ឱ្ក្ខ-
មីសុ តេ ន លភីសុ ។ តេ ឯវមាហំសុ អម្ហាកំបិ
អាវុសោ ភាគំ ទេថាតិ ។ តេ ឯវមាហំសុ មយំ អាវុសោ
តុម្ហាកំ ភាគំ ទស្ជាម កិស្ជ តុម្ហេ បច្ឆា ឱ្ក្ខមិត្ជា-
តិ ។ ភគ្ជវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ
ភិក្ខវេ បច្ឆា ឱ្ក្ខមន្ជានំ ជាតាមា ភាគំ ជាតុន្តិ ។
តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ គោ-
សលេសុ ជនបទេសុ អជ្ឌានមក្ខប្ជដិបជ្ជ ហោន្តិ ។
តេ សនិសា សុសានំ ឱ្ក្ខមីសុ បំសុកូលាយ ។ ឯ-
កចេ ភិក្ខូ បំសុកូលានិ លភីសុ ឯកចេ ភិក្ខូ ន
លភីសុ ។ យេ តេ ភិក្ខូ ន លភីសុ តេ ឯវមាហំសុ
អម្ហាកំបិ អាវុសោ ភាគំ ទេថាតិ ។ តេ ឯវមាហំសុ
ន មយំ អាវុសោ តុម្ហាកំ ភាគំ ទស្ជាម កិស្ជ

ចីវរក្ខន្ធក: និយាយពីភិក្ខុចូលទៅកាន់ព្រៃស្មសាន

ដើរទៅកាន់ផ្លូវធ្វើយ ក្នុងកោសលជនបទ ។ ភិក្ខុពួកខ្លះ ដើរចូលទៅ
កាន់ព្រៃស្មសានជាមុន ដើម្បីបង្សុកូល ភិក្ខុពួកខ្លះដើរចូលទៅជាខាង
ក្រោយ ។ ពួកភិក្ខុណាដែលដើរចូលទៅព្រៃស្មសានមុន ដើម្បីបង្សុកូល
ភិក្ខុទាំងនោះ ក៏បានសំពត់បង្សុកូល ។ ពួកភិក្ខុណាចូលទៅក្រោយ ភិក្ខុ
ទាំងនោះ ក៏ឥតបានឡើយ ។ ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអា-
វុសោ លោកទាំងឡាយចូរឲ្យចំណែកដល់យើងខ្លះ ។ ភិក្ខុទាំងនោះនិ-
យាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនបានឲ្យចំណែកដល់លោកទេ
ហេតុអ្វី បានជាលោកទាំងឡាយដើរចូលទៅក្រោយគេ ។ ភិក្ខុទាំងនោះ
ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាត
ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមិនចង់ឲ្យ ក៏កុំបាច់
ឲ្យនូវចំណែក ដល់ភិក្ខុទាំងឡាយ ដែលដើរចូលទៅក្រោយគេ ។ សម័យ
នោះឯង មានពួកភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវធ្វើយ ក្នុងកោសលជនបទ ។
ភិក្ខុទាំងនោះបានដើរចូលទៅកាន់ព្រៃស្មសាន ដើម្បីបង្សុកូលព្រមគ្នា ។
ភិក្ខុពួកខ្លះ បានសំពត់បង្សុកូល ភិក្ខុពួកខ្លះ មិនបាន ។ ពួកភិក្ខុណា
ដែលមិនបាន ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ លោកទាំង-
ឡាយ ចូរឲ្យចំណែកមកយើងខ្លះ ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះវិញថា
នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វីបានជា

តុម្ហេ ន លភិត្ថាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សនិសានំ ឧក្ក្ដមណ្ដានំ អកាមា ភាកំ ជាតុន្ដិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភោសលេសុ ជនបទេសុ អជ្ជាន-មត្ដប្ប្ដជ្ជិបន្ដា ហោន្ដិ ។ តេ ភតិកំ ភត្ថា សុសានំ ឧក្ក្ដមីសុ បំសុកូលាយ ។ ឯកចេ ភិក្ខូ បំសុកូលានិ លភីសុ ឯកចេ ភិក្ខូ ន លភីសុ ។ យេ តេ ភិក្ខូ ន លភីសុ តេ ឯវមាហំសុ អម្ហាកំបិ អាវុសោ ភាកំ ទេថាតិ ។ តេ ឯវមាហំសុ ន មយំ អាវុសោ តុម្ហាកំ ភាកំ ទស្ស្ដាម ភិស្ស តុម្ហេ ន លភិត្ថាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភតិកំ ភត្ថា ឧក្ក្ដមណ្ដានំ អកាមា ភាកំ ជាតុន្ដិ ។

[៤៧] តេន ខោ បន សមយេន មនុស្ស្ដា ចីវរំ អាជាយ អាវមំ អាគច្ដន្ដិ ។ តេ បដិត្ដាហកំ អលភមានា បដិហរន្ដិ ។ ចីវរំ បរិត្ដំ ឧប្ប្ដជ្ដតិ ។ ភគវតោ

លោកមិនបាននឹងគេ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះ ព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ដែលទុកជាមិនចង់ឲ្យ ក៏ត្រូវឲ្យចំណែកដល់ភិក្ខុទាំងឡាយ ដែលចូលទៅកាន់ព្រៃស្មសានព្រមគ្នា ។ សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវធ្វើដំណើរក្នុងកោសលជនបទ ។ ភិក្ខុទាំងនោះ បានធ្វើកតិកា (ប្ដេជ្ញា) នឹងគ្នារួចហើយ ក៏ចូលទៅកាន់ព្រៃស្មសានដើម្បីបង្សុកូល ។ ភិក្ខុពួកខ្លះ បានសំពត់បង្សុកូល ភិក្ខុពួកខ្លះ មិនបាន ។ ពួកភិក្ខុណាដែលមិនបាន ភិក្ខុទាំងនោះក៏និយាយយ៉ាងនេះថា នែអាវុសោ លោកទាំងឡាយចូរឲ្យចំណែកមកយើងខ្លះ ។ ភិក្ខុទាំងនោះនិយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វីបានជាលោកមិនបាននឹងគេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះ ព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ដែលទុកជាមិនចង់ឱ្យ ក៏ត្រូវឲ្យចំណែក ដល់ភិក្ខុទាំងឡាយ ដែលធ្វើកតិកា (ប្ដេជ្ញា) គ្នាហើយចូលទៅកាន់ព្រៃស្មសាន ។

[៤៧] សម័យនោះឯង ពួកមនុស្សបាននាំយកចីវរមកកាន់អារាម ។ មនុស្សទាំងនោះ កាលមិនបានភិក្ខុណាមួយទទួលចីវរ ក៏ត្រឡប់នាំយកចីវរទៅវិញ ។ ឯចីវរក៏កើតតិច ๆ ទៅ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ

ឯតមត្ថំ អាហេចេសុំ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គ-
ហិ សមន្នាគតំ ភិក្ខុំ ចីវរប្បដិក្ខាហកំ សម្មន្ទិតុំ យោ
ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោ-
ហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ គហិតាគហិ-
តញ្ច ជានេយ្យ ។ ឯវញ្ច បន ភិក្ខវេ សម្មន្ទិតព្ពោ ។
បឋមំ ភិក្ខុ យាចិតព្ពោ យាចិត្វា ញ្ញត្តេន ភិក្ខុនា
បដិពលេន សង្ឆោ ញ្ញាបេតព្ពោ សុណាតុ មេ ភន្តេ
សង្ឆោ យទិ សង្ឆស្ស បត្តកល្ល សង្ឆោ ឥត្ថន្នាមំ
ភិក្ខុំ ចីវរប្បដិក្ខាហកំ សម្មន្ទេយ្យ ។ ឯសា ញត្តិ ។
សុណាតុ មេ ភន្តេ សង្ឆោ សង្ឆោ ឥត្ថន្នាមំ ភិក្ខុំ
ចីវរប្បដិក្ខាហកំ សម្មន្ទតិ ។ យស្សាយស្មតោ ខមតិ
ឥត្ថន្នាមស្ស ភិក្ខុនោ ចីវរប្បដិក្ខាហកស្ស សម្មតិ សោ
តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ
សង្ឆេន ឥត្ថន្នាមោ ភិក្ខុ ចីវរប្បដិក្ខាហកោ ។ ខមតិ
សង្ឆស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

ចីវរក្ខន្ធក: ការសន្ទតភិក្ខុឲ្យជាអ្នកទទួលចីវរ

ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្ទតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកទទួលចីវរ គឺ ភិក្ខុមិនបានលុះឆន្ទាគតិ ១ មិនបានលុះទោសាគតិ ១ មិនបានលុះមោហាគតិ ១ មិនបានលុះភយាគតិ ១ ដឹងនូវចីវរដែលខ្លួនបានទទួលនិងមិនបានទទួល ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវសង្ឆសន្ទតយ៉ាងនេះ ។ សង្ឆត្រូវអង្វរករភិក្ខុជាមុន លុះអង្វរករួចហើយ ភិក្ខុដែលធ្វាសប្រតិពលត្រូវញ៉ាំងសង្ឆឲ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឆហើយ សង្ឆគប្បីសន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរចុះ ។ នេះជាពាក្យផ្តៀងសង្ឆឲ្យដឹង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ សង្ឆសន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរ ។ ការសន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរ គួរដល់លោកដ៏មានអាយុអង្គណាហើយ លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឆបានសន្ទតឲ្យ ជាអ្នកទទួលចីវរហើយ ។ ការសន្ទតនេះ សមគួរដល់សង្ឆ ព្រោះហេតុនោះ បានជាសង្ឆស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៤៨] តេន ខោ បន សមយេន ចីវរប្ឆដ្ដិកាហ-
ភិក្ខូ ចីវរំ បដិក្ខិបិត្វា តត្ថេវ ឧជ្ឈិត្វា បក្កមន្តិ ។ ចី-
វរំ ន ឆ្ឍតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-
ជាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ចីវរនិជ-
ហកំ សម្មន្ទិតុំ យោ ន ឆន្ទាគតិ គច្ឆេយ្យ ន ទោ-
សាគតិ គច្ឆេយ្យ ន មោហាគតិ គច្ឆេយ្យ ន ភយាគតិ
គច្ឆេយ្យ និឧហិតានិឧហិតញ្ច[1] ជានេយ្យ ។ ឯវញ្ច
បន ភិក្ខវេ សម្មន្ទិតព្ពោ ។ បឋមំ ភិក្ខុ យាចិតព្ពោ
យាចិត្វា ញ្ឍត្តេន ភិក្ខុនា បដិពលេន សង្ឆោ ញា-
បេតព្ពោ សុណាតុ មេ ភន្តេ សង្ឆោ យទិ សង្ឆស្ស
បត្តកល្ឋំ សង្ឆោ ឥត្ថន្នាមំ ភិក្ខុំ ចីវរនិជាហកំ
សម្មន្ទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ
សង្ឆោ សង្ឆោ ឥត្ថន្នាមំ ភិក្ខុំ ចីវរនិជាហកំ សម្មន្ទតិ ។
យស្ឆាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ចីវរនិ-
ជាហកស្ស សម្មតិ សោ តុណ្ហស្ស យស្ស ន ក្ខមតិ

១ ឩ. និហិតានិហិតញ្ច ។

[៤៨] សម័យនោះឯង ពួកភិក្ខុអ្នកទទួលចីវរ បានទទួលចីវរទុកចោលក្នុងទីនោះឯង ហើយចៀសចេញទៅ ។ ចីវរក៏វិនាសទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆស្ន្ទតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកទុកដាក់ចីវរ គឺភិក្ខុដែលមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ដឹងនូវចីវរដែលខ្លួនបានទុកដាក់ហើយនិងមិនទាន់បានទុកដាក់ហើយ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវសង្ឆស្ន្ទតយ៉ាងនេះ ត្រូវសង្ឆអង្វរករភិក្ខុជាមុន លុះអង្វរករួចហើយ ភិក្ខុអ្នកធ្វាសប្រតិពលត្រូវញ្ជាំងសង្ឆឲ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឆហើយ គួរសង្ឆស្ន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកដាក់ចីវរ ។ នេះជាពាក្យផ្ទៀងសង្ឆឲ្យដឹង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ សង្ឆស្ន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកដាក់ចីវរ ។ ការស្ន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកដាក់ចីវរសមគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនសមគួរដល់លោកដ៏មានអាយុអង្គណាទេ

សោ ភាសេយ្យ ។ សម្ផតោ សង្ឆេ ឥត្ថន្ថាមោ ភិក្ខុ ចីវរនិធាមកោ ។ ១មតិ សង្ឆស្ស តស្ម តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៤៩] តេន ខោ បន សមយេន ចីវរនិធាមកា ភិក្ខូ មណ្ដបេបិ រុក្ខមូលេបិ និម្ពកោសេបិ អជ្ឌោកា-សេបិ ចីវរំ និធមន្តិ ។ ឧន្ទុរេហិបិ ឧបចិកាហិបិ ១ជ្ជន្តិ ។ ភគ្ដវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានামិ ភិក្ខវេ ភណ្ឌាគារំ សម្ផន្ដិតុំ យំ សង្ឆោ អាកង្ខតិ វិហារំ ១ អ ឌ្ឍយោគំ ១ ១ ១

លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះសង្ឆបាន សន្ទតឲ្យ ជាអ្នកទុកដាក់ចីវរហើយ ។ ការសន្ទតនេះសមគួរដល់សង្ឆ ព្រោះហេតុនោះ បានជាសង្ឆស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយ អាការស្ងៀមនៅយ៉ាងនេះ ។

[៤៩] សម័យនោះឯង ពួកភិក្ខុអ្នកទុកដាក់ចីវរ ទុកចីវរក្នុង មណ្ឌប (បាវ៉ាំ) ខ្លះ ក្រោមម្ទប់ឈើខ្លះ ទៀបយុវស្ស្ងខ្លះ ក្នុងទីកណ្ដាល រាលខ្លះ ។ ពួកសត្វកណ្ដុរខ្លះ ពួកសត្វកណ្ដៀរខ្លះ ក៏កាត់ចីវរទាំងនោះ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ (បើ) សង្ឆប្រាថ្នានូវទីណា គឺ វិហារក្ដី ប្រាសាទមានសណ្ឋានដូចស្ទាបគ្រុឌក្ដី ប្រាសាទវែងក្ដី ប្រាសាទមានដំបូលត្រងិលក្ដី គុហាក្ដី ក៏តថាគតអនុញ្ញាតឲ្យសង្ឆសន្ទត នូវទីនោះឲ្យជាឃ្លាំងបាន ។ ម្នាលភិក្ខុទាំងឡាយ គួរសង្ឆសន្ទតយ៉ាង នេះ ។ ត្រូវភិក្ខុអ្នកធ្វាសប្រតិពលញ្ជាំងសង្ឆឲ្យដឹងថា បពិត្រព្រះសង្ឆ ដ៏ចម្រើន សូមព្រះសង្ឆស្ដាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឆហើយ សង្ឆគួរសន្ទតវិហារឈ្មោះនេះ ឲ្យជាឃ្លាំងបាន ។ នេះជាពាក្យផ្ដៀង សង្ឆឲ្យដឹង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្ដាប់ខ្ញុំ សង្ឆ សន្ទតវិហារឈ្មោះនេះ ឲ្យជាឃ្លាំងហើយ ។ ការសន្ទតវិហារឈ្មោះនេះ

ភណ្ឌាការស្ស សម្ម្ងតិ សោ តុណ្ហាស្ស យស្ស ឌក្ខ-
មតិ សោ ភាសេយ្យ ។ សម្ម្ងតោ សង្ឆេ ឥត្ថ្ងាមោ
វិហារេ ភណ្ឌាការ ។ ខមតិ សង្ឆស្ស ឥស្ម តុណ្ហី ។
ឯវមេតំ ធារយាមីតិ ។

[៤០] ត្ថេ ខោ បេ សមយេ សង្ឆស្ស ភណ្ឌា-
ការេ ចីវរ អតុត្ថ ហោតិ ។ ភតវតោ ឯតមត្ថ អារោចេ-
សុ ។ អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្ថ្ងតេ
ភិក្ខុ ភណ្ឌាការិកេ សម្ម្ងន្ថ្ងិតុ យោ ន ឆន្ថ្ងតតី ត្ថេ ន
ន ទោសាតតី ត្ថេ ន មោហាតតី ត្ថេ ន ភ-
យាតតី ត្ថេ ត្ថ ត្ថ ត្ថ ជានេយ្យ ។ ឯវញ្ច ត្ថ
ភិក្ខវេ សម្ម្ងន្ថ្ងិតេ ។ ឯ ភិក្ខុ យាចិតេ ។ ត្ថ
ព្យ ត្ថ ភិក្ខុ ។ ត ត ។ ។ ។

ឲ្យជាឃ្លាំង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ វិហារឈ្មោះនេះ សង្ឆបានសន្ទតឲ្យជាឃ្លាំងហើយ ។ ការសន្ទតគួរដល់សង្ឆហើយ ព្រោះហេតុនោះ បានជាសង្ឆស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៥០] សម័យនោះឯង ចីវរក្នុងឃ្លាំងរបស់សង្ឆ ឥតមានលោកណាគ្រប់គ្រងរក្សាឡើយ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្ទតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នករក្សាឃ្លាំង គឺ ភិក្ខុដែលមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ដឹងនូវរបស់ដែលខ្លួនបានគ្រប់គ្រងរក្សាហើយ និងមិនទាន់បានគ្រប់គ្រងរក្សា ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវសន្ទតយ៉ាងនេះ ។ សង្ឆត្រូវអង្វរករភិក្ខុជាមុន លុះអង្វរករហើយ ភិក្ខុអ្នកធ្ងាសប្រតិពលត្រូវញ្ជាំងសង្ឆឲ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឆហើយ សង្ឆគួរសន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង ។

ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឆោ សង្ឆោ ឥត្ថន្នាមំ ភិក្ខុំ ភណ្ឌាគារិកំ សម្មន្ទតិ ។ យស្សាយស្ម-តោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ភណ្ឌាគារិកស្ស សម្មតិ សោ តុណ្ហស្ស យស្ស ឧក្ខមតិ សោ ភា-សេយ្យ ។ សម្មតោ សង្ឆេន ឥត្ថន្នាមោ ភិក្ខុ ភណ្ឌា-គារិកោ ។ ខមតិ សង្ឆស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៤១] តេន ខោ បន សមយេន ឆព្ភក្ខិយា ភិក្ខូ ភណ្ឌាគារិកំ រុន្ធាបេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេ-សុំ ។ ន ភិក្ខវេ ភណ្ឌាគារិកោ រុន្ធាបេតព្ពោ យោ រុន្ធាបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

នេះជាពាក្យផ្ទៀងសង្ឆឲ្យដឹង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ សង្ឆសន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង ។ ការសន្ទតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឆបានសន្ទតឲ្យជាអ្នករក្សាឃ្លាំងហើយ ។ ការសន្ទតនេះគួរដល់សង្ឆហើយ ព្រោះហេតុនោះ បានជាសង្ឆស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៥១] *សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបណ្តេញភិក្ខុអ្នករក្សាឃ្លាំងឲ្យចៀសចេញ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្តេញ[1] ភិក្ខុអ្នករក្សាឃ្លាំងចេញទេ ភិក្ខុណាបណ្តេញ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។*

---

១ បុគ្គលដែលមិនត្រូវបណ្តេញចេញចាកទីកន្លែងមាន ៤ ពួក គឺភិក្ខុចាស់ជាង ១ ភិក្ខុជាអ្នករក្សាឃ្លាំង ១ ភិក្ខុមានជំងឺ ១ ភិក្ខុដែលបានសេនាសន:អំពីសង្ឆ ១ ។ ភិក្ខុក្មេងមិនត្រូវបណ្តេញភិក្ខុចាស់ចេញ ព្រោះលោកចាស់ជាងខ្លួន ។ ភិក្ខុជាអ្នករក្សាឃ្លាំង ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះសង្ឆបានសន្ទតឲ្យជាអ្នករក្សាឃ្លាំង ។ ភិក្ខុមានជំងឺ ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះលោកឈឺ ។ ភិក្ខុដែលបានសេនាសន:អំពីសង្ឆ ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះសង្ឆបានឲ្យទីកន្លែងជាទីសប្បាយដល់លោកដែលជាពហូសូត្រ មានឧបការ:ដល់សង្ឆដោយកិច្ច មានបង្រៀនបាឡីនិងអដ្ឋកថាជាដើម (អដ្ឋកថា) ។

[៤២] តេន ខោ បន សមយេន សជ្ជ្សុ ភណ្ឌា-
ការេ ចីវរំ ឧស្សន្នំ ហោតិ ។ ភគ្ការតោ ឯតមត្ថំ អារោចេ-
សុំ ។ អនុជានាមិ ភិក្ខវេ សម្ម៉ុ ទ្ធ ីភ្ជ ូ ត ្ត ន សជ្ជ ្ ន ភា-
ជេតុន្តិ ។ តេន ខោ បន សមយេន សញ្ជ្ញ សជ្ជ ្ ា
ចីវរំ ភាជេន្ត ្ ា ្ ្ ្

[៥២] *សម័យនោះឯង ចីវរក្នុងឃ្លាំងរបស់សង្ឆក៏សម្ផូណ៌ឡើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆដែលនៅជួបជុំគ្នា[1] ចែកចីវរបាន ។ គ្រានោះឯង សង្ឆទាំងពួងកាលចែកចីវរក៏បានធ្វើនូវសេចក្តីកោលាហលឡើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆសន្ទតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកចែកចីវរបាន គឺ ភិក្ខុដែលមិនលុះឆន្ទាគតិ ១ មិនលុះទោសាគតិ ១ មិនលុះមោហាគតិ ១ មិនលុះភយាគតិ ១ ដឹងនូវរបស់ដែលខ្លួនបានចែកហើយ និងមិនទាន់បានចែក ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវសន្ទតយ៉ាងនេះ ។ សង្ឆត្រូវអង្វរករភិក្ខុជាមុន លុះអង្វរករួចហើយ ភិក្ខុអ្នកធ្វាសប្រតិពលត្រូវញ្ជាំងសង្ឆឲ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឆហើយ សង្ឆគួរសន្ទតភិក្ខុឈ្មោះនេះឲ្យជាអ្នកចែកចីវរ ។ នេះជាពាក្យផ្តៀងសង្ឆឲ្យដឹង ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ*

---

1 បានដល់សង្ឆដែលនៅខាងក្នុងឧបចារសីមាជាមួយគ្នា (អដ្ឋកថា) ។

ចីវរក្ខន្ធកេ ចីវរភាជកសម្មតិ

សង្ឆោ សង្ឆោ ឥត្ថន្នាមំ ភិក្ខុំ ចីវរភាជកំ សម្មន្ថតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ចីវរភាជ-កស្ស សម្មតិ សោ តុណ្ហាស្ស យស្ស ឧក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឆេន ឥត្ថន្នាមោ ភិក្ខុ ចីវ-ភាជកោ ។ ខមតិ សង្ឆស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថខោ ចីវរភាជកានំ ភិក្ខូនំ ឯតទ-ហោសិ កថំ នុ ខោ ចីវរំ ភាជេតព្ពន្តិ ។ ភគវតោ ឯត-មត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បឋមំ ឧច្ចិនិត្វា តុលយិត្វា វណ្ណាវណ្ណេ ភាគ្យា ភិក្ខូ ភណេត្វា រត្តំ ពន្ធិត្វា ចីវរឃ្ដជិវិសំ ឋបេតុន្តិ ។ អថខោ ចីវរភាជកានំ ភិក្ខូនំ ឯតទហោសិ កថំ នុ ខោ សាមណេរានំ ចីវរឃ្ដជិវិសោ ជានេយ្យាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុ-ជានាមិ ភិក្ខវេ សាមណេរានំ ឧបឌ្ឍឃ្ដជិវិសំ ជានុន្តិ ។

ចីវរក្ខន្ធក: ការសន្មតភិក្ខុឲ្យជាអ្នកចែកចីវរ

សង្ឆសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចែកចីវរ ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចែកចីវរគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គ នោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មាន អាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះសង្ឆបានសន្មតឲ្យជា អ្នកចែកចីវរហើយ ។ ការសន្មតនេះគួរដល់សង្ឆហើយ ព្រោះហេតុ នោះបានជាសង្ឆស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអា-ការស្ងៀមនៅយ៉ាងនេះ ។ វេលានោះ ពួកភិក្ខុអ្នកចែកចីវរ មានសេចក្តី រិះគិតដូច្នេះថា យើងគួរចែកចីវរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំ ទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជ្រើសរើស (ចីវរ) ជាមុន ហើយស្ទង់មើល (តម្លៃ) ហើយលៃលកចីវរដែលមានសណ្ឋានតូចធំថ្ងៃ ច្រើនតិច (ឲ្យមានចំណែកស្មើគ្នា) ហើយរាប់ភិក្ខុ ហើយចងចីវរឲ្យជា ពួក ។ រួច សឹមតម្កល់ទុកនូវចំណែកនៃចីវរ ។ វេលានោះ ពួកភិក្ខុអ្នក ចែកចីវរមានសេចក្តីរិះគិតដូច្នេះថា យើងត្រូវឲ្យចំណែកចីវរដល់ពួកសាម-ណេរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏ មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុទាំងឡាយ ឲ្យចំណែកពាក់កណ្តាលដល់ពួកសាមណេរ ។

តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សកេន ភាគេន ឧត្តរិតុត្តាមោ ហោតិ ។ ភគវតោ ឯតមត្តំ អា- រោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧត្តរន្ត្ស្ស សកំ ភាគំ ជានុន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អតិរេកភាគេន ឧត្តរិតុត្តាមោ ហោតិ ។ ភគវតោ ឯត-មត្តំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អនុក្ខេបេ ជិន្ន អតិរេកភាគំ ជានុន្តិ ។ អថខោ ចីវរភាជកានំ ភិក្ខូនំ ឯតទហោសិ ភគ្គ ១ ខោ ចីវរប្ប្ជិវិសោ ជានេ្ជ អាតតប្ប្ជិចាជិយ ១ ខោ ឧជាហ យថារុ្ជ្ជន្តិ ។ ភគវតោ ឯតមត្តំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ រិកលកេ តោសេត្ថ ភុ្ជ្ជ ១ ១ ១

សម័យនោះឯង ភិក្ខុ ១ រូបមានសេចក្តីប្រាថ្នានឹងធ្វើដំណើរ ឬធ្វើផ្លូវឆ្ងាយហើយ ចង់បានចំណែករបស់ខ្លួន (ជាប់ទៅផង) ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចំណែករបស់ខ្លួន (គឺរបស់ភិក្ខុអ្នកធ្វើដំណើរ) ដល់ភិក្ខុអ្នកធ្វើ (ដំណើរ ឬផ្លូវឆ្ងាយ) ចុះ ។ សម័យនោះឯង ភិក្ខុ ១ រូបមានសេចក្តីប្រាថ្នានឹងធ្វើដំណើរ ឬ ធ្វើផ្លូវឆ្ងាយ ចង់បានចំណែកថ្ងៃច្រើនជាងគេ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើកប្បិយកណ្ឌគេបានឲ្យហើយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចំណែកដ៏ច្រើនចុះ ។ គ្រានោះពួកភិក្ខុអ្នកចែកចីវរ មានសេចក្តីរិះគិតដូច្នេះថា យើងត្រូវឲ្យចំណែកចីវរដូចម្តេចហ្ន៎ យើងត្រូវឲ្យចំណែកចីវរដោយលំដាប់ភិក្ខុដែលមកឬ ។ នឹងត្រូវឲ្យចំណែកចីវរតាមលំដាប់ភិក្ខុចាស់ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើចីវរខ្វះហើយ តថាគតអនុញ្ញាតឲ្យ អ្នកទាំងឡាយញ៉ាំងភិក្ខុឲ្យត្រេកអរសិន ហើយសឹមធ្វើការបោះស្លាក ។

[៥៣] សម័យនោះឯង ភិក្ខុទាំងឡាយជ្រលក់ចីវរ ដោយអាចម៍គោខ្លះ ដោយដីស្ពិតមានពណ៌លឿងខ្លះ ។ ចីវរនោះក៏មានពណ៌មិនល្អ ។

ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឆ រជនានិ មូលរជនំ ខន្ធរជនំ តចរជនំ បត្តរជនំ បុប្ផរជនំ ផលរជនន្តិ ។ តេន ខោ បន សមយេន ភិក្ខូ សីតូទកាយ[1] ចីវរំ រជន្តិ ។ ចីវរំ ទុក្ខន្ធំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ រជនំ បចិតុំ ចូឡរជនកុម្ភិន្តិ ។ រជនំ ឧត្តរិ-យតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧត្តរាឡ្ឍ[2] ពន្ធិតុន្តិ ។ តេន ខោ បន សមយេន ភិក្ខូ ន ជានន្តិ រជនំ បក្ក ្ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧទកេ

---

១ ឱ. សីតុន្ទកាយ ។ ២ ឱ. ឧត្តរាទ្ឍ្ឍ ។

ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកជ្រលក់ ៦ យ៉ាង គឺ ទឹកជ្រលក់កើតពីមើម ១ ទឹកជ្រលក់កើតពីដើម ១ ទឹកជ្រលក់កើតពីសម្បក ១ ទឹកជ្រលក់កើតពីស្លឹក ១ ទឹកជ្រលក់កើតពីផ្កា ១ ទឹកជ្រលក់កើតពីផ្លែ ១ ។ សម័យនោះឯង ភិក្ខុទាំងឡាយជ្រលក់ចីវរដោយទឹកត្រជាក់ ។ ចីវរនោះក៏មានក្លិនមិនល្អ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវធ្នាំងជ្រលក់តូច ដើម្បីដាំទឹកជ្រលក់ ។ ទឹកជ្រលក់ក៏ផុលឡើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចង់ប្រទាស[១] ។ សម័យនោះឯង ភិក្ខុទាំងឡាយមិនដឹងទឹកជ្រលក់ឆ្អិនហើយ ឬនៅមិនទាន់ឆ្អិន ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបន្ត្ក់[២] តំណក់ទឹក

---

១ គឺដាក់ឈើតារាងនៅមាត់ឆ្នាំង ដើម្បីកុំឲ្យគ្រឿងជ្រលក់មានចំណាំងឈើជាដើមផុលឡើងបាន ។ ២ បើទឹកដែលដាំពុះហើយយកទៅបន្ត្ក់លើភាជន:ទឹក (ដទៃ) ក៏មិនសាយចេញរហ័ស ឬ បន្ត្ក់លើខ្នងក្រចកក៏ដូច្នោះដែរ (អដ្ឋកថា) ។

ឯ ឧទ្ធបិដ្ឋិកាយ ឯ ថេវកំ ជានុន្តិ ។ តេន ខោ
បន សមយេន ភិក្ខូ រជនំ ឱរោបេត្វា ការ្ម អាវជ្ជន្តិ
ការ្ម ភិជ្ជតិ ។ ភគ្គវតោ ឯតមត្ថំ អារោចេសុំ ។ អនុ-
ជានামិ ភិក្ខវេ រជនុជ្ជ្ញ ឧណ្ហាកថាលិកន្តិ ។ តេន
ខោ បន សមយេន ភិក្ខូ រជនកាជំ ន សំវិជ្ជតិ ។
ភគ្គវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានামি ភិក្ខវេ
រជនគោលម្ពំ រជនយជន្តិ ។ តេន ខោ បន សមយេ-
ន ភិក្ខូ ចាតិយាបិ បត្តេបិ ចីវរំ មទ្ទន្តិ[1] ។ ចីវរំ បរិភិជ្ជ-
តិ ។ ភគ្គវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានামি
ភិក្ខវេ រជនគោណិកន្តិ ។ តេន ខោ បន សមយេន
ភិក្ខូ ឆមាយំ ចីវរំ បត្តវន្តិ ចីវរំ បំសុកិតំ ហោតិ ។
ភគ្គវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានামি ភិក្ខវេ តិ-
ណាសន្ថារកន្តិ ។ តិណាសន្ថារកោ ឧបចិកាហិ ខជ្ជតិ ។
ភគ្គវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានামি ភិក្ខវេ

---

១ ឱ. សម្ម ទ្ទ ន្តិ ។

លើទឹកក៏បាន លើខ្នងក្រចកក៏បាន ។ សម័យនោះឯង ភិក្ខុទាំងឡាយកាលដាក់ទឹកជ្រលក់ក៏ទង្គិចនឹងឆ្នាំង ។ ក៏បែកទៅ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវបោយសម្រាប់ដងទឹកជ្រលក់ ដែលមានដង ។ សម័យនោះឯង ភាជន៍សម្រាប់ដាក់ទឹកជ្រលក់របស់ភិក្ខុទាំងឡាយមិនទាន់មាន ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឆ្នាំងសម្រាប់ដាក់ទឹកជ្រលក់ និងកួមសម្រាប់ដាក់ទឹកជ្រលក់ ។ សម័យនោះឯង ភិក្ខុទាំងឡាយគក់ចីវរក្នុងថាសខ្ទះ ក្នុងបាត្រខ្ទះ ។ ចីវរក៏ដាច់ដាចអស់ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវស្នូកសម្រាប់ជ្រលក់ ។ សម័យនោះឯង ភិក្ខុទាំងឡាយ ត្រដាងហាលចីវរលើផែនដី ចីវរក៏ប្រឡាក់ដោយអាចម៍ដី ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកម្រាលស្មៅ ។ កម្រាលស្មៅពួកសត្វកណ្តៀរកោរអស់ទៅ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ចីវរក្ខន្ធកេ កណ្ណសុត្តកាទិអនុជានានំ

ចីវរំ ចីវរជ្ជន្តិ ។ មជ្ឌេន លក្ខេន្តិ រជនំ ឧភតោ
តលតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-
ជាមិ ភិក្ខវេ ការណ្ឌ ពន្ធិតុន្តិ ។ ការណ្ឌ ជីរតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
ការណ្ឌសុត្តកន្តិ ។ រជនំ ឯកតោ តលតិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សម្ឆរិតត្តកំ
សម្ឆរិតត្តកំ រជេតុំ ន ច អច្ឆិន្នេ ថេវ បក្ខិបិតុន្តិ ។
តេន ខោ បន សមយេន ចីវរំ បត្តិន្នំ ហោតិ ។ ភគ-
វតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧនកេ
ឱសាបេតុន្តិ ។ តេន ខោ បន សមយេន ចីវរំ ជរុសំ
ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-
ជាមិ ភិក្ខវេ ចាណិជា អាកោដេតុន្តិ ។

តថាគតអនុញ្ញាតនូវឈើស្ទូ សម្រាប់ហាលចីវរនិងខ្សែស្បៃង ។ ភិក្ខុទាំង-ឡាយ ពាក់ចីវរចំទីពាក់កណ្តាល ទឹកជ្រលក់ក៏ហៀរចុះទៅតាមជាយទាំងពីរ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចងត្រង់ជាយចីវរ ។ ជាយចីវរក៏ទក់ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតនូវខ្សែសម្រាប់ចងជាយចីវរ ។ ទឹកជ្រលក់ក៏ហៀរទៅតាមជាយម្ខាង ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យជ្រលក់ចីវរប្រៃត្រឡប់ឲ្យសព្វគ្រប់ ម្យ៉ាងទៀត កាលបើតំណក់ទឹកមិនទាន់ដាច់អស់ទេ ភិក្ខុកុំអាលដើរចេញឡើយ ។ សម័យនោះឯង ចីវរដិតខ្ជាំងពេក ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យត្រាំចីវរទៅក្នុងទឹក (ទទេ) ។ សម័យនោះឯង ចីវរក៏មានសាច់រឹង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគក់ចីវរដោយដៃ ។

[៤៤] តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ អច្ឆិន្នកានិ ចីវរានិ ធារេន្តិ ញត្ត្ត*សាវានិ ធារេន្តិ ។ មនុស្សា ញជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ[១] ។ ភិក្ខូ[២] ភគវ-តោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អច្ឆិន្នកានិ ចីវរានិ ធារេតព្ពានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៤៥] អថ ខោ ភគវា រាជគហេ យថាភិរន្តំ វិហរិត្វា យេន ញក្ខិណាគិរិ តេន ចារិកំ បក្កាមិ ។ អទ្ធ-ាសា ខោ ភគវា មាគធកេ*ត្តំ[៣] អចិ*ពន្ធំ ចាលិ*ពន្ធំ មរិ-យាញ*ពន្ធំ សិង្ឆាដ*ពន្ធំ[៤] ញិ*ស្ទាន អាយ*ស្ម*ន្តំ អានន្ទ*ំ អាមន្ត*េសិ បស្ស*សិ ណោ ត្វំ អានន្ទ មាគធ*េ*ត្តំ អចិ*ពន្ធំ ចាលិ*ពន្ធំ មរិយាញ*ពន្ធំ សិង្ឆាដ*ពន្ធ*ន្តិ ។

---

១ ឥតោ បរំ ឱ*ារោ*ិ*យ*ោ*ត*ត*េ* ។ ២ ត*ត*ាយ*ំ ។ ៣ ឱ. ។ ៤ ។

[៥៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់ចីវរមិនបានកាត់ ទ្រទ្រង់ចីវរជ្រលក់ដោយទឹកចត់មានពណ៌ដូចក្ពុក ។ មនុស្សទាំង-ឡាយ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មិនត្រូវប្រើប្រាស់ចីវរដែលមិនបានកាត់ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៥៥] គ្រានោះ ព្រះមានព្រះភាគគង់នៅក្នុងក្រុងរាជគ្រឹះ ដោយសមគួរដល់ពុទ្ធអធ្យាស្ស័យ ហើយក៏ទ្រង់យាងចេញទៅ កាន់ចារិកក្នុងទក្ខិណាគិរីជនបទ ។ ព្រះដ៏មានព្រះភាគទ្រង់ឃើញស្រែអ្នកដែនមគធ: មានសណ្ឋានជាស្រែមានជ្រុងបួន មានសណ្ឋាន ជាស្រែមានភ្ជឿងដោយបណ្ដោយផង ទទឹងផង មានសណ្ឋានជាស្រែមានភ្ជឿខ្ចីក្នុងចន្ទោះ ។ មានសណ្ឋានជាបួនជ្រុង ដោយមានភ្ជឿខ្ចីបាញ់រត់គ្នា លុះទ្រង់ទតឃើញហើយ ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា នែអានន្ទ អ្នកឃើញស្រែអ្នកដែនមគធ: មានសណ្ឋាន ជាស្រែមានជ្រុងបួន មានសណ្ឋានជាស្រែមានភ្ជឿង ដោយបណ្ដោយផងទទឹងផង មានសណ្ឋានជាស្រែមានភ្ជឿខ្ចីក្នុងចន្ទោះ ។ មានសណ្ឋានជាបួនជ្រុង ដោយមានភ្ជឿខ្ចីបាញ់រត់គ្នា ឬទេ ។

ចីវរក្ខន្ធកេ អានន្ទត្ថេរវត្ថុ

ឯវំ ភន្តេតិ ។ ឧស្សហាសិ ត្វំ អានន្ទ ភិក្ខូនំ ឯវរូចានិ ចីវរានិ សំវិនហិតុន្តិ ។ ឧស្សហាមិ ភគវាតិ ។ អថខោ ភគវា ឧក្កិណ្ណាកិរិស្មឺ យថាភិរន្តំ វិហរិត្វា បុនទេវ ភាគ្គវហំ បច្ចាគច្ឆិ ។ អថខោ អាយស្មា អានន្ទោ សម្ពហុលានំ ភិក្ខូនំ ចីវរានិ សំវិនហិត្វា យេន ភគវា តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា ភគវន្តំ ឯតទវោច បស្សតុ[1] មេ ភន្តេ ភគវា ចីវរានិ សំវិន-ហិត្វានីតិ ។ អថខោ ភគវា ឯតស្មឺ ជិណ្ណេ ឯតស្មឺ បការណេ ឆម្មឺ ឆេ ឆ ឆ ភិក្ខូ អាមន្តេសិ បណ្ឌិ-តោ ភិក្ខវេ អានន្ទោ មហាបញ្ញោ ភិក្ខវេ អានន្ទោ យត្រ ហិ នាម មយា សង្ខ្ងិត្តេន ភាសិតស្ស វិត្ថារេ អត្ថំ អាជានិស្សតិ ឆុសិម្ឍ ជាម ឆារិស្សតិ អ្ឍ្ឍ-ឆុ-សិម្ឍ ជាម ឆារិស្សតិ ម្ណ្ឌ្ឍ្ឍ ជាម ឆារិស្សតិ អ្ឍ្ឍ-ម្ណ្ឌ្ឍ ជាម ឆារិស្សតិ ១ ជ ជាម ឆារិស្សតិ

---

1 បស្សថ ឆុ-ម្ពេ-ត ទ-ស្ស-ត ។

ព្រះអានន្ទក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះ
ភាគទ្រង់ត្រាស់សួរថា នែអានន្ទ អ្នកអាចចាត់ចែងចីវរបែបនេះ ដល់ភិក្ខុ
ទាំងឡាយបានឬទេ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះដ៏មាន
ព្រះភាគ ខ្ញុំព្រះអង្គអាចធ្វើបាន ។ លោនោះ ព្រះដ៏មានព្រះភាគទ្រង់
គង់ក្នុងទក្ខិណាគិរីជនបទ គួរដល់ពុទ្ធអធ្យាស្ស័យហើយ ក៏ទ្រង់យាងត្រ-
ឡប់មកក្រុងរាជគ្រឹះវិញ ។ ខណៈនោះ ព្រះអានន្ទដ៏មានអាយុ ក៏បាន
ចាត់ចែងចីវរដល់ភិក្ខុទាំងឡាយជាច្រើនរូប រួចហើយចូលទៅគាល់ព្រះ
មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ
យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ទត
ចីវរដែលខ្ញុំព្រះអង្គបានចាត់ចែងហើយចុះ ។ ព្រោះនិទាននេះ ដំណើរ
នេះ ព្រះដ៏មានព្រះភាគក៏ធ្វើនូវធម្មីកថាក្នុងលោនោះ រួចទ្រង់ត្រាស់ហៅ
ភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ម្នាលភិក្ខុ
ទាំងឡាយ អានន្ទមានប្រាជ្ញាច្រើន ព្រោះថា ពាក្យដែលតថាគតពោល
ហើយដោយសង្ខេប អានន្ទអាចដឹងសេចក្តីដោយពិស្តារបាន ហើយចេះ
ធ្វើសំពត់ឈ្មោះកុសិផង ធ្វើសំពត់ឈ្មោះអឌ្ឍកុសិផង ធ្វើសំពត់ឈ្មោះ
មណ្ឌលៈផង ធ្វើសំពត់ឈ្មោះអឌ្ឍមណ្ឌលៈផង ធ្វើសំពត់ឈ្មោះវិវដ្តៈផង

អនុវិវដ្ដម្បិ ជាម ការិស្សតិ ឥរិយ្យាបថម្បិ ជាម ការិស្សតិ ជង្ឃេ្យ្យ្យ្យ្យ ជាម ការិស្សតិ ពាហាម្បិ ជាម ការិស្ស-
តិ ធិន្ធ្ការ ការិស្សតិ សត្ថ្ការ សមណ្ណ្ការ ការ ការ
ការ ធិន្ធ្ការ ការ ការ ការ ការ ការ ។

[៤៦] អថ ខោ ភ្ការ ការ ការ ការ ការ ការ

ធ្វើសំពត់ឈ្មោះអនុវិវដ្ដ:ផង ធ្វើសំពត់ឈ្មោះគីវេយ្យក:ផង ធ្វើសំពត់ឈ្មោះជង្ឆេយ្យក:ផង ធ្វើសំពត់ឈ្មោះពាហន្ត:ផង ហើយសំពត់នោះ អានន្ទក៏បានកាត់ដាច់ ឲ្យសៅហ្មងដោយមុខកាំបិត ឲ្យសមគួរដល់សមណ: ឲ្យជារបស់មិនគួរប្រាថ្នា ដល់ពួកចោរជាសត្រូវ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសង្ឆាដិកាត់ ឧត្ដរាសង្គ:កាត់ អន្ដរវាសក:កាត់ ។

[៥៦] គ្រានោះ ព្រះមានព្រះភាគគង់ក្នុងក្រុងរាជគ្រឹះ គួរដល់ពុទ្ធអធ្យាស្ស័យ ហើយក៏ទ្រង់ចៀសទៅកាន់ចារិកក្រុងវេសាលី ។ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ផ្លូវធ្វាយ ជាចន្ទោះក្រុងរាជគ្រឹះ និងចន្ទោះក្រុងវេសាលី ក៏បានទតឃើញភិក្ខុទាំងឡាយច្រើនរូប មានចីវរវេចជាសំពាយ បានដាក់ផ្ដត់ចីវរលើក្បាលខ្លះ ដាក់ផ្ដត់ចីវរលើ-ក១ខ្លះ ដាក់ផ្ដត់ចីវរលើចង្កេះខ្លះ ដើរមក លុះទតឃើញហើយ ព្រះដ៏មានព្រះភាគទ្រង់រិះគិតយ៉ាងនេះថា ពួកមោឃបុរសទាំងនេះ រ៉ាមមករកសេចក្ដីលោកក្នុងចីវរធាប់រហ័សណាស់ បើដូច្នោះ គួរតថាគតចងសីមាតាំងទុកនូវខេត្ដដែនក្នុងចីវរដល់ភិក្ខុទាំងឡាយ ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ទើបបានដល់ទៅក្រុងវេសាលី ។

ចីវរក្ខន្ធកេ អន្តរដ្ឋករត្តិកថា

តត្រ សុទំ ភគវា វេសាលិយំ វិហរតិ គោតមកេ ចេតិ-
យេ ។ តេន ខោ បន សមយេន ភគវា សីតាសុ ហេ-
មន្តិកាសុ រត្តីសុ អន្តរដ្ឋកាសុ ហិមចាតសមយេ រត្តឹ
អជ្ឌោកាសេ ឯកចីវរោ និសីទិ ន ភគវន្តំ សីតំ
អហោសិ[1] និក្ខន្តេ បឋមេ យាមេ សីតំ ភគវន្តំ អហោសិ
ទុតិយំ ភគវា ចីវរំ ចារុបិ ន ភគវន្តំ សីតំ អហោសិ
និក្ខន្តេ មជ្ឌិមេ យាមេ សីតំ ភគវន្តំ អហោសិ តតិយំ
ភគវា ចីវរំ ចារុបិ ន ភគវន្តំ សីតំ អហោសិ និក្ខន្តេ
បច្ឆិមេ យាមេ ឧទ្ធតេ អរុណេ ឧដ្ឌិមុទិយា រត្តិយា សីតំ
ភគវន្តំ អហោសិ ចតុត្ថំ ភគវា ចីវរំ ចារុបិ ន ភគវន្តំ
សីតំ អហោសិ ។ អថខោ ភគវតោ ឯតទហោសិ យេបិ
ខោ តេ កុលបុត្តា ឥមស្មឹ ធម្មវិនយេ សីតាលុកា
សីតភីរុកា តេបិ សក្ខ្លោន្តិ តិចីវរេន យាបេតុំ យន្ទ្ធ-
ហំ ភិក្ខូនំ ចីវរេ សីមំ ពន្ធេយ្យំ មរិយាទំ បញ្ញបេយ្យំ
តិចីវរំ អនុជានេយ្យន្តិ ។ អថខោ ភគវា ឯតស្មឹ និទានេ

1 ន ភគវន្តំ សីតំ អហោសីតិ ភគវតោ សីតំ នាហោសីតិ (អដ្ឌកថា) ។

បានឮថា ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងគោតមចេតិយ ទៀបក្រុងវេសាលីនោះ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់ចីវរតែមួយ គង់នៅក្នុងទីកណ្ដាលវាលក្នុងវេលាយប់ ក្នុងសម័យមានទឹកសន្សើមធ្លាក់ចុះ ក្នុងរាត្រីទាំងឡាយ ដែលត្រជាក់នៅក្នុងហេមន្តរដូវ បិតនៅជាចន្លោះនៃខែមាឃនិងខែផល្គុន[1] ព្រះអង្គក៏មិនរងាឡើយ លុះបឋមយាមកន្ធងទៅហើយទើបព្រះអង្គរងា ហើយព្រះអង្គទ្រង់ចីវរជាគម្រប់ពីរ ព្រះអង្គក៏បាត់រងាទៅ លុះមជ្ឈិមយាមកន្ធងទៅហើយទើបព្រះអង្គរងា ហើយព្រះអង្គទ្រង់ដណ្ដប់ចីវរជាគម្រប់បី ព្រះអង្គក៏បាត់រងារទៀត លុះបច្ឆិមយាមកន្លងទៅហើយ កាលអរុណរះឡើង រាត្រីក៏ភ្ជឿព្រាង ។ ទើបព្រះអង្គរងា ព្រះអង្គទ្រង់ដណ្ដប់ចីវរជាគម្រប់បួន ព្រះអង្គក៏បាត់រងាទៅ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់រិះគិតដូច្នេះថា ក្នុងធម៌វិន័យនេះ កុលបុត្តទាំងឡាយណា ដែលជាអ្នករងាជាប្រក្រតី ជាអ្នកខ្លាចរងា កុលបុត្តទាំងនោះក៏អាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរ ៣ បាន បើដូច្នេះ គួរតថាគតចងសីមាហើយតាំងទុកនូវខេត្តដែនក្នុងចីវរ ហើយអនុញ្ញាតចីវរ ៣ ដល់ភិក្ខុទាំងឡាយ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា

---

១ វិមតិវិនោទនីដីកាថា រាត្រី ៨ គឺខាងចុងខែមាឃ ៤ រាត្រីខាងដើមខែផល្គុន ៤ រាត្រី ហៅថា រាត្រីនៅជាចន្លោះនៃខែមាឃនិងខែផល្គុន ។

ឯតស្មឺ បការណោ ជម្ម៏ កបំ កត្វា ភិក្ខូ អាមន្តេសិ ឥជាហំ ភិក្ខវេ អន្តរា ច រាជគហំ អន្តរា ច វេសាលឺ អទ្ធានមគ្គប្បដិបន្ណោ អទ្ធសំ សម្ពហុលេ ភិក្ខូ ចីវរេហិ ឧព្ភណ្ណ៏ាកតេ សីសេបិ ចីវរភិសឺ ការិត្វា ខន្ធេបិ ចីវរភិ-សឺ ការិត្វា ការិយាបិ ចីវរភិសឺ ការិត្វា អាតបេ ជ-ណ្ណ ១ ឯតជហោសិ អតិលហុំ ខោ ឥមេ ១ យុ-ណ្ណ ១ ចីវរេ ពហុណ្ណ ១ អាវជ្ជ ១ ១ ១

ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនេះតថាគតបានដើរទៅកាន់ផ្លូវធ្វើយ ជាចន្លោះក្រុងរាជគ្រឹះ និងចន្លោះក្រុងវេសាលី ហើយឃើញភិក្ខុច្រើនរូប មានចីវរវេចជាសំពាយដាក់ផ្នត់ចីវរលើក្បាលខ្លះ ដាក់ផ្នត់ចីវរលើ-កខ្លះ ដាក់ផ្នត់ចីវរលើចង្កេះខ្លះដើរមក លុះឃើញហើយ តថាគតក៏មានសេចក្តីត្រិះរិះដូច្នេះថា ពួកមោឃបុរសទាំងនេះ រ៉ាលមករកសេចក្តីលោភក្នុងចីវរធាប់ពេកណាស់ បើដូច្នេះ គួរតថាគតចងសីមាតាំងទុកនូវខេត្តដែនក្នុងចីវរ ដល់ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនេះតថាគតទ្រង់ចីវរតែមួយអង្គុយនៅក្នុងទីកណ្តាលវាលក្នុងវេលាយប់ ក្នុងសម័យមានទឹកសន្សើមធ្លាក់ចុះ ក្នុងរាត្រីទាំងឡាយដែលត្រជាក់ នៅក្នុងហេមន្តរដូវ ឋិតនៅចន្លោះនៃខែមាឃនិងខែផល្គុន តថាគតក៏មិនរងាឡើយ លុះបឋមយាមកន្ធងទៅហើយ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគម្រប់ពីរ តថាគតក៏បាត់រងាទៅ លុះមជ្ឈិមយាមកន្ធងទៅហើយ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគម្រប់បី ទើបតថាគតបាត់រងាទៅ លុះបច្ឆិមយាមកន្ធងទៅហើយ អរុណរះឡើងរាត្រីក៏ភ្ជឿព្រាង ។ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគម្រប់បួន តថាគតក៏បាត់រងាទៅ ម្នាលភិក្ខុទាំងឡាយ តថា-គតក៏មានសេចក្តីរិះគិតដូច្នេះថា ក្នុងធម្មវិន័យនេះ កុលបុត្តទាំងឡាយណា

ឥមស្មឹ ធម្មវិនយេ សីតាលុកា សីតកីរុកា តេបិ សណ្ហោន្តិ តិចីវរេន យាបេតុំ យន្ត្វាជាហ ភិក្ខវេ ចីវរេ សីមំ ពន្ធេយ្យ មរិយាទំ ឋបេយ្យ តិចីវរំ អនុជានេយ្យន្តិ អនុជានামិ ភិក្ខវេ តិចីវរំ ទ្វិកុណ្ឌ(១) សង្ឆ្យាដឺ ឯកចិ្ចយំ ឧត្តរាសង្គំ ឯកចិ្ចយំ អន្តរវាសកន្តិ ។

[៤៧] តេន ខោ បន សមយេន ធព្ពក្ដិយា ភិក្ខូ ភគវតា តិចីវរំ អនុញ្ញាតន្តិ អញ្ញេនេវ តិចីវរេន តាមំ បវិសន្តិ អញ្ញេនេវ តិចីវរេន អារាមេ អច្ឆន្តិ អញ្ញេនេវ តិចីវរេន ជហាន ឋិតន្តិ ។ យេ តេ ភិក្ខូ អប្ឆិច្ឆា ។ បេ ។ តេ ឧជ្ឌាយន្តិ ខីយន្តិ វិចារេន្តិ កថំ ហិ នាម ធព្ពក្ដិយា ភិក្ខូ អតិរេកចីវរំ ធារេស្សន្តីតិ ។ អថ ខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថ ខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បការណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ អតិរេកចីវរំ ធារេតព្ពំ យោ ធារេយ្យ យថាធម្មោ ការេតព្ពោតិ ។ តេន ខោ បន

---

១ ឱ. ទ្វិគុណ្ឌ ។

ដែលជាអ្នករងាជាប្រក្រតី ជាអ្នកខ្ជាចរងា កុលបុត្តទាំងនោះអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរ ៣ បើដូច្នោះ គួរតថាគតចងសីមាតាំងទុកនូវខេត្តដែនក្នុងចីវរ គួរអនុញ្ញាតចីវរ ៣ ដល់ភិក្ខុទាំងឡាយ ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតចីវរ ៣ គឺ សង្ឃាដិពីរជាន់ ឧត្តរាសង្គ: (ចីពរ) ១ ជាន់ ស្បង់ ១ ជាន់ ។

[៥៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា ចីវរ ៣ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតរួចហើយ ។ ក៏នាំគ្នាចូលទៅកាន់ស្រុកដោយចីវរ ៣ ដងទៃទៀត នៅក្នុងវត្តដោយចីវរ ៣ ដងទៃទៀត ចុះទៅកាន់កំពង់ជាទីស្រង់ទឹកដោយចីវរ ៣ ដងទៃទៀត ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ពួកឆព្វ-គ្គិយភិក្ខុមិនសមបើនឹងទ្រទ្រង់អតិរេកចីវរសោះ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងពេលនោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់អតិរេក-ចីវរទេ ភិក្ខុណាទ្រទ្រង់ ភិក្ខុនោះត្រូវវិនយធរឲ្យធ្វើតាមធម៌ ។ សម័យនោះ

សមយេន អាយស្មតោ អានន្ទស្ស អតិរេកចីវរំ ឧប្ផន្នំ ហោតិ ។ អាយស្មា ច អានន្ទោ តំ ចីវរំ អាយស្មតោ សារីបុត្តស្ស ជាតុកាមោ ហោតិ ។ អាយស្មា ច សារីបុត្តោ សាកេតេ វិហរតិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ ភគវតា បញ្ញត្តំ ន អតិរេ-កចីវរំ ជានិតព្វន្តិ ឥទញ្ច មេ អតិរេកចីវរំ ឧប្ផន្នំ អហញ្ចិមំ ចីវរំ អាយស្មតោ សារីបុត្តស្ស ជាតុកាមោ អាយស្មា ច សារីបុត្តោ សាកេតេ វិហរតិ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ ការណំ បជានន្ទ សារីបុត្តោ អាគច្ឆិស្សតីតិ ។ ឌវមំ ភ ភគវា ជិវសំ ឧសមំ ភតិ ។ អថខោ ភគវា ឯតស្មឿ ជិជានេ ឯតស្មឿ បការណេ ឧម្ម៏ កថំ ភគ្ងា ភិក្ខូ អាមន្តេសិ អនុជា-ជាមិ ភិក្ខវេ ឧសាហរមំ អតិរេកចីវរំ ជានិតុន្តិ ។ តេន ខោ បន សមយេន ភិក្ខូនំ អតិរេកចីវរំ ឧប្ផន្នំ ហោតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កថំ

អតិរេកចីវរបានកើតឡើង ដល់ព្រះអានន្ទដ៏មានអាយុ ។ ឯព្រះអានន្ទ ដ៏មានអាយុប្រាថ្នាប្រគេនចីវរនោះ ទៅព្រះសារីបុត្តដ៏មានអាយុ ។ ព្រះ សារីបុត្តដ៏មានអាយុក៏គង់នៅឯក្រុងសាកេត ។ លុះនោះ ព្រះអានន្ទ ដ៏មានអាយុមានសេចក្តីរិះគិតដូច្នេះថា ព្រះមានព្រះភាគ បានបញ្ញត្តថា ភិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរទេ ក៏ឯអតិរេកចីវរនេះ កើតឡើងដល់អាត្ម អញហើយ តែថាអាត្មអញចង់ប្រគេនចីវរនេះ ទៅព្រះសារីបុត្តដ៏មាន អាយុ ឥឡូវព្រះសារីបុត្តដ៏មានអាយុគង់នៅឯក្រុងសាកេត តើអាត្ម អញត្រូវប្រតិបត្តិដូចម្តេច ។ ខណៈនោះ ព្រះអានន្ទដ៏មានអាយុក្រាប បង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរ ថា នែអានន្ទ ចុះសារីបុត្តនៅយូរប៉ុន្មានថ្ងៃទៀត ទើបបានមក ។ ព្រះ អានន្ទក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ព្រះសារីបុត្តមុខជានឹង មកក្នុងថ្ងៃទី ៨ ឬក្នុងថ្ងៃទី ១០ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះ ភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទ្រទ្រង់អតិ-រេកចីវរកំណត់ត្រឹម ១០ ថ្ងៃ ។ សម័យនោះ អតិរេកចីវរកើតឡើងដល់ ភិក្ខុទាំងឡាយ ។ លុះនោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា

ន្ត ខោ អម្ហេហិ[1] អតិរេកចីវរេ បដិបជ្ជិតព្ពន្តិ ។ ភគ-
វតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ
អតិរេកចីវរំ រាកាយ្យ ត្ថុន្តិ ។

[៤៨] អថខោ ភគវា វេសាលិយំ យថាភិរន្តំ វិហ-
រិត្វា យេន ពារាណសី តេន ចារិកំ បក្កាមិ អនុបុព្វេន
ចារិកំ ចរមានោ យេន ពារាណសី តទវសរិ ។ ត្រ
ត្រ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគ-
យ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុ-
ណោ អន្តរវាសកោ ធិណ្ណោ ហោតិ ។ អថខោ តស្ស
ភិក្ខុណោ ឯតទហោសិ ភគវតា តិចីវរំ អនុញ្ញាតំ ទ្វិ-
ត្ថុណា សង្ឆាដិ ឯកចិ្ចយោ ឧត្តរាសង្គោ ឯកចិ្ចយោ
អន្តរវាសកោ អយញ្ច មេ អន្តរវាសកោ ធិណ្ណោ យន្ន-
ណាហំ អត្ត ១ អច្ចុបេយ្យំ សមន្ត្ថតោ ឧបដ្ឋំ ភវិស្ស្ត
មជ្ឌ ឯកចិ្ចយន្តិ ។ អថខោ សោ ភិក្ខុ អត្ត ១
អច្ចុបេសិ ។ អទ្ធសា ខោ ភគវា សេណាសនចារិកំ
អាហិណ្ឌ្ណោ តំ ភិក្ខុ អត្ត ១ អច្ចុបេន្ត ១ ឥ ១ ១ ១

1 ឱរោបិយបោត្ថកេ អយំ ១ ១ ១

ចីវរក្ខន្ធក: រឿងភិក្ខុ ១ រូប

យើងគួរប្រតិបត្តិក្នុងអតិរេកចីវរដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យវិកប្បអតិរេកចីវរទុកបាន ។

[៥៨] គ្រានោះ ព្រះដ៏មានព្រះភាគគង់ក្នុងក្រុងវេសាលី គួរដល់ពុទ្ធអធ្យាស្ស័យ ហើយក៏ទ្រង់យាងទៅកាន់ចារិកក្រុងពារាណសី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសី ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងឥសិបតនមិគទាយវន ទៀបក្រុងពារាណសីនោះ ។ សម័យនោះ ភិក្ខុ ១ រូប មានស្បង់ធ្ងុ: ។ វេលានោះ ភិក្ខុនោះមានសេចក្តីត្រិះរិះដូច្នេះថា ចីវរ ៣ គឺ សង្ឆាដិ ២ ជាន់ ឧត្តរ-សង្គ: ១ ជាន់ ស្បង់ ១ ជាន់ ព្រះដ៏មានព្រះភាគបានអនុញ្ញាតរួចហើយ ឯស្បង់របស់អាត្មាអញធ្ងុ: បើដូច្នោះ គួរអាត្មាអញប៉ះនូវបំណះ កាលបើដូច្នោះស្បង់នោះនឹងទៅជា ២ ជាន់ដោយជុំវិញ កណ្តាល ១ ជាន់ ។ វេលានោះ ភិក្ខុនោះក៏បានប៉ះនូវបំណះ ។ ព្រះដ៏មានព្រះភាគបានយាងទៅកាន់សេនាសនចារិកក៏បានទតឃើញភិក្ខុនោះកំពុងប៉ះនូវបំណះ លុះទតឃើញ

យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ
ឯតទវោច កឹ ត្វំ ភិក្ខុ ការោសីតិ ។ អត្តជ្ឈំ ភគវា
អច្ឆុបេមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ
អត្តជ្ឈំ អច្ឆុបេសីតិ ។ អថខោ ភគវា ឯតស្មឹ និទានេ
ឯតស្មឹ បការណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ
អនុជានামិ ភិក្ខវេ អហានំ ទុស្សានំ អហតកប្បានំ
ទ្វិកុណ្ណំ សង្ឆាដឿ ឯកចិ្ចយំ ឧត្តរាសង្គំ ឯកចិ្ចយំ អន្ត-
រវាសកំ ឧតុទ្ធតានំ ទុស្សានំ ចតុក្កុណ្ណំ សង្ឆាដឿ ទ្វិកុ-
ណ្ណំ ឧត្តរាសង្គំ ទ្វិកុណ្ណំ អន្តរវាសកំ បំសុកូលេ យា-
វទត្ថំ ចាបណិកេ ឧស្សាហោ ការណីយោ អនុជានামិ
ភិក្ខវេ អត្តជ្ឈំ តុន្ទំ ឱវដ្ដិកំ កណ្ឌាសកំ ឧជ្ឈ្ជិកម្ម្ជ ។

ហើយក៏ទ្រង់យាងចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងភិក្ខុនោះដូច្នេះថា នែភិក្ខុ អ្នកធ្វើអ្វី ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គប៉ះនូវបំណះ ។ ព្រះដ៏មានព្រះភាគទ្រង់តបថា ប្រពៃហើយ ។ ភិក្ខុ ប្រពៃហើយភិក្ខុ អ្នកបានប៉ះនូវបំណះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគក៏ទ្រង់ធ្វើនូវធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នៅថ្នាង ឬសំពត់ដែលគេបោកលាងម្តងហើយ តថាគតអនុញ្ញាត (ឲ្យអ្នកទាំងឡាយធ្វើ) សង្ឆាដី ២ ជាន់ ឧត្តរាសង្គ: ១ ជាន់ ស្បង់ ១ ជាន់ (បើ) សំពត់ដែលគេរើឡើងពីរដូវ (គឺសំពត់ចាស់) តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយធ្វើសង្ឆាដី ២ ជាន់ ឧត្តរាសង្គ: ២ ជាន់ ស្បង់ ២ ជាន់ អ្នកទាំងឡាយគួរធ្វើនូវសេចក្តីប្រឹងប្រែងស្វែងរកសំពត់បង្សុកូលសំពត់ធ្លាក់ចុះក្នុងវានផ្សារតាមត្រូវការ ម្នាលភិក្ខុទាំងឡាយ តថាគតអ-នុញ្ញាតនូវបំណះ[១] នូវការជុល នូវក្រវិលកណ្ដុំ នូវកណ្ដុំ នូវការធ្វើឲ្យមាំ[២]

---

១ បានដល់សំពត់ដែលភិក្ខុប៉ះត្រង់កន្លែងធ្លុះ ឬត្រង់កន្លែងដែលខ្លួនកាត់ចេញ ។ ២ បានដល់សំពត់ដែលភិក្ខុប៉ះត្រង់កន្លែងដែលមិនបានកាត់ចេញ ។

ចីវរក្ខន្ធកេ វិសាខាមិគារមាតាវត្ថុ

[៤៩] អថខោ ភគវា ពាវណាសិយំ យថាភិរន្តំ
វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន
ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ
ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស
អារាមេ ។ អថខោ វិសាខា មិគារមាតា យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ
ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ
សមុត្តេជេសិ សម្បហំសេសិ ។ អថខោ វិសាខា
មិគារមាតា ភគវតា ធម្មិយា កថាយ សន្ទស្សិតា
សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ ឯត-
ទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ
សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភា-
វេន ។ អថខោ វិសាខា មិគារមាតា ភគវតោ អធិវាសនំ

ចីវរក្ខន្ធក: រឿងនាងវិសាខាមិគារមាតា

[៥៩] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្រុងពារាណសី គួរដល់ពុទ្ធអធ្យាស្ស័យហើយ ក៏ទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថីនោះ ។ លុះនោះ នាងវិសាខាមិគារមាតាបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ កាលនាងវិសាខាមិគារមាតាអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងវិសាខាមិគារមាតា ដែលអង្គុយនៅក្នុងទីដ៏សមគួរហើយ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ នាងវិសាខាមិគារមាតា លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលកត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឆ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ នាងវិសាខាមិគារមាតាបានដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ

រិនិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ
កត្វា បក្កាមិ ។ តេន ខោ បន សមយេន ឥស្ស
រត្តិយា អច្ចយេន ចាតុទ្ទីបិកោ មហាមេឃោ ចាវស្សិ ។
អថខោ ភគវា ភិក្ខូ អាមន្តេសិ យថា ភិក្ខវេ ផេតវនេ
វស្សតិ ឯវំ ចតូសុ ឌីបេសុ វស្សតិ ឱវស្សាបេថ ភិក្ខ-
វេ ការយំ អយំ បច្ឆិមកោ ចាតុទ្ទីបិកោ មហាមេ-
ឃោតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុណិត្វា
ជិក្ខិត្តចីវរា ការយំ ឱវស្សាបេន្តិ ។ អថខោ វិសាខា
មិការមាតា បណីតំ ខាទនីយំ ភោជនីយំ បដិយាទា-
បេត្វា ទាសឹ អាណាបេសិ ១ អាវាមំ ១ ១ ១
ការលំ អារោចេហិ ការលោ ១ ១ ១ ១ ។ ១
អយ្យេតិ ១ ១ ១ ១ ១ ១ ១ ១ ១ ១
១ ១ ១ ១ ១ ១ ១ ១ ១ ១

ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។ សម័យនោះឯង លុះរាត្រីនោះកន្ធង់ទៅហើយមានភ្លៀងធំធ្លាក់ចុះសព្វទ្វីបទាំង ៤ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ភ្លៀងធ្លាក់ចុះក្នុងវត្តជេតពនយ៉ាងណា ភ្លៀងធ្លាក់ចុះក្នុងទ្វីបទាំង ៤ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយចូរងូតជម្រះកាយគ្រប់ ៗ គ្នាទៅចុះ (ព្រោះ) ភ្លៀងធំដែលធ្លាក់សព្វទ្វីបទាំង ៤ នេះ ជាបំផុតត្រឹមនេះហើយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះករុណាព្រះអង្គ ហើយក៏នាំគ្នាដាក់ចីវរចេញងូតទឹកភ្លៀងជម្រះកាយ[1] ។ គ្រានោះ នាងវិសាខាមិគារមាតាបានឲ្យជនតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តមហើយបង្គាប់ទាសីថា នែហង ហង ចូរទៅកាន់អារាម ហើយក្រាបបង្គំទូលកត្តកាល[2] ថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ ទាសីនោះទទួលស្តាប់ពាក្យរបស់នាងវិសាខាមិគារមាតាដោយពាក្យថា ចាំ អ្នកជាម្ចាស់ ហើយទៅកាន់អារាម ក៏បានឃើញពួកភិក្ខុដែលដាក់ចីវរចេញ

---

១ ភិក្ខុទាំងនោះងូតទឹកភ្លៀងគ្មានសំពត់ងូត (អាក្រាត) ។ ២ ពេលគួរឆាន់ចង្ហាន់ ។

ចីវរក្ខន្ធកេ វិសាខាមិគារមាតាវត្ថុ

ការយំ ឱវស្សាបេន្តេ ជិស្វាន ជត្តិ អាវមេ ភិក្ខូ អាជី-
វការ ការយំ ឱវស្សាបេន្តីតិ យេន វិសាខា មិគារមាតា
តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា វិសាខំ មិគារមាតរំ ឯតទ-
វោច ជត្តយ្យ អាវមេ ភិក្ខូ អាជីវការ ការយំ
ឱវស្សាបេន្តីតិ ។ អថខោ វិសាខាយ មិគារមាតុយា
បណ្ហិតាយ វិយត្តាយ មេធាវិនិយា ឯតទហោសិ ជិស្សុ-
សយំ ខោ អយ្យា ជិក្ខិត្តចីវរា ការយំ ឱវស្សាបេន្តិ
សាយំ ពាលា មញ្ញិត្ត ជត្តិ អាវមេ ភិក្ខូ អាជីវការ
ការយំ ឱវស្សាបេន្តីតិ ។ ជាសឹ អាណាបេសិ ឥច្ច ដេ
អាវមំ ឥត្ថ្ងា ការលំ អាវេចេហិ ការលោ ភន្តេ ជិដ្ឋិតំ
ភត្តន្តិ ។ អថខោ តេ ភិក្ខូ ឥត្ថ្ងានិ សីតីការិត្វា ការ-
ការយ ចីវរានិ ឥហេត្ថ្ងា យថាវិហារំ បវិសឹសុ ។ អថខោ
សា ជាសី អាវមំ ឥត្ថ្ងា ភិក្ខូ អបស្សន្តី ជត្តិ អាវមេ
ភិក្ខូ សុញ្ញោ អាវមោតិ យេន វិសាខា មិគារមាតា
តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា វិសាខំ មិគារមាតរំ ឯតទ-

ចីវរក្ខន្ធក: រឿងនាងវិសាខាមិគារមាតា

កំពុងផ្ងូតទឹកភ្ជៀងជម្រះកាយ លុះឃើញហើយក៏គិតថា ក្នុងអារាមនេះគ្មានពួកភិក្ខុទេ មានតែពួកអាជីវកកំពុងផ្ងូតទឹកភ្ជៀងជម្រះកាយ រួចហើយក៏ត្រឡប់ចូលទៅកាន់សំណាក់នាងវិសាខាមិគារមាតាវិញ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងនាងវិសាខាមិគារមាតាថា បពិត្រអ្នកម្ចាស់ ក្នុងអារាមនេះគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវកកំពុងផ្ងូតទឹកភ្ជៀងជម្រះកាយ ។ លំដាប់នោះ នាងវិសាខាមិគារមាតាជាបណ្ឌិតជាស្រីធ្ងាស ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ជាលោកម្ចាស់ទាំងឡាយ ដាក់ចីវរចេញហើយនាំគ្នាផ្ងូតទឹកភ្ជៀងជម្រះកាយ តែទាសីនេះជាស្រីលួងសំគាល់ថា ក្នុងអារាមគ្មានភិក្ខុទេ មានសុទ្ធតែពួកអាជីវកកំពុងនាំគ្នាផ្ងូតទឹកភ្ជៀងជម្រះកាយ ។ នាងវិសាខាមិគារមាតាបង្គាប់ទាសីថា នែហង ហងចូរទៅកាន់អារាមហើយ ក្រាបបង្គំទូលកត្តកាលថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ កត្តក៏សម្រេចហើយ ។ កាលនោះ ភិក្ខុទាំងនោះផ្ងូតទឹកឲ្យត្រជាក់ខ្លួន មានកាយដ៏ស្រួល ហើយក៏នាំគ្នាយកចីវរទាំងឡាយ ចូលទៅកាន់លំនៅដូចដែលវិញ ។ ឯទាសីនោះទៅកាន់អារាមមិនឃើញពួកភិក្ខុក៏គិតថា ក្នុងអារាមគ្មានភិក្ខុសោះ មានតែអារាមទេ ហើយក៏ត្រឡប់ចូលទៅកាន់សំណាក់នាងវិសាខាមិគារមាតាវិញ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងនាងវិសាខាមិគារមាតាថា

ហេច ជនេ្ជយ្យ អាវាមេ ភិក្ខូ សុញ្ញោ អាវាមោតិ ។ អថខោ វិសាខាយ មិគារមាតុយា បណ្ហិតាយ ទ្វិយត្តាយ មេជាវិនិយា ឯតទហោសិ ជិស្ស៎ុ សយំ ខោ អយ្យា កត្តានិ សីតីការិត្វា ភាណ្ដកាយ ចីវរានិ ភហេត្វា យថាវិហារំ បវិដ្ឋា សាយំ ពាលា មញ្ជិត្ត ជត្ថ្ម អាវាមេ ភិក្ខូ សុញ្ញោ អាវាមោតិ ។ បុន ជាសឹ អាណាបេសិ ភច្ច ដ អាវាមំ ភន្ត្ថ ការាលំ អាវេចេហិ ការាលោ ភន្ត្ថ ជិដ្ឋិតំ ភត្ត្ថ ។ អថខោ ភគវា ភិក្ខូ អាមន្ត្ថេសិ សន្ធ្ហាជ ភិក្ខូវ បត្ត្ថចីវរំ ការាលោ ភត្ត្ថ្ម ។ ឯវំ ភន្ត្ថ ខោ ត្ថ ភិក្ខូ ភគ្ត្ថ បច្ចុស្ស្ធ្ម ។ អថខោ ភគវា បុព្ជ-ណ្ហ-សមយំ ជិវាសេ្ត្ថ្ម បត្ត្ថចីវ្ត្ថ្ម ជាយ ស្ត្ថ្ម ជាមពលវ ។ ១ ។ ១ ។ ១

បពិត្រអ្នកម្ចាស់ ក្នុងអារាមគ្មានកិក្ខុសោះ មានតែអារាមទទេ ។ លំដាប់នោះ នាងវិសាខាមិគារមាតាជាបណ្ឌិត ជាស្រីធ្ងាស ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ចាស់ជាលោកម្ចាស់ទាំងឡាយងូតទឹកឲ្យត្រជាក់ខ្លួន មានកាយដ៏ស្រួល ហើយនាំយកចីវរទាំងឡាយ ចូលទៅកាន់លំនៅដូចដែល ទាសីនេះជាស្រីលួងសំគាល់ថា ក្នុងអារាមគ្មានពួកកិក្ខុសោះ មានតែអារាមទទេ ។ នាងវិសាខាក៏បង្គាប់ទាសីទៀតថា នែហង ហងចូរទៅកាន់អារាមហើយ ក្រាបបង្គំទូលកត្តកាលថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកពាល់គ្នារៀបចំបាត្រនិងចីវរចុះ (ព្រោះ) ដល់ពេលចង្ហាន់ហើយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះបន្ទូលរបស់ព្រះដ៏មានព្រះភាគដោយពាក្យថា ព្រះករុណា ព្រះអង្គ ។ លុះវេលាព្រឹកឡើង ព្រះដ៏មានព្រះភាគទ្រង់ស្បៃកស្បង់ប្រដាប់ដោយបាត្រ និងចីវរហើយទ្រង់បំបាត់ព្រះអង្គអំពីវត្តជេតពន ទៅប្រាកដទៀបក្បាងទ្វាររបស់នាងវិសាខាមិគារមាតា (ដោយធាប់រហ័ស) ប្រៀបដូចបុរសមានកម្ទាំងលាដៃដែលខ្ជួនបត់ចូល ឬបត់ដៃដែលខ្ជួនលាចេញ ។ ព្រះដ៏មានព្រះភាគទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយជាមួយនឹងព្រះភិក្ខុសង្ឆ ។ គ្រានោះ

ចីវរក្ខន្ធកេ វិសាខាមិគារមាតាវត្ថុអដ្ឋវរកថា

វិសាខា មិគារមាតា អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ តថាគតស្ស មហិទ្ធិកតា មហានុភាវតា យត្រ ហិ នាម ជន្ទុកមត្តេសុបិ ឱយេសុ វត្តមានេសុ[1] ឆាយមត្តេសុបិ ឱយេសុ វត្តមានេសុ ន ហិ នាម ឯកភិក្ខុស្សាបិ ចាតា ឯ ចីវានិ ឯ អលាជានិ ឯ ការិស្សន្តីតិ ហាជ្ជ ឧនក្ខ ពុទ្ធ-ប្បមុខំ ភិក្ខុសង្ឆំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្ប្ជ្ជ សម្ប្ជ្ជ ភតវន្តំ ភុត្តាវឿ ឱនី-តបត្តចាណឿ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្ន ខោ វិសាខា មិគារមាតា ភតវន្តំ ឯតទវោច អជ្ជាហំ ភន្តេ ភតវន្តំ ១ រាជ និ យាចាមីតិ ។ អតិក្ខ្ជ្ជ ១ ១ ១

ចីវរក្ខន្ធក: រឿងនាងវិសាខាមិគារមាតា និយាយអំពីពរ ៨ ប្រការ

នាងវិសាខាមិគារមាតាគិតថា អើហ្ន៎ (ហេតុនេះ) អស្ចារ្យពេកណាស់ អើហ្ន៎ (ហេតុនេះ) ចម្លែកពេកណាស់ ព្រះតថាគត មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថា ជំនន់ប្រមាណត្រឹមជង្គង់ខ្ទះ ត្រឹមចង្កេះខ្ទះ កំពុងហូរទៅ ។ សូម្បីតែជើង ឬចីវររបស់ភិក្ខុ ១ អង្គក៏គ្មានទទឹកឡើយ ហើយក៏មានចិត្តរីករាយខ្ពស់ឡើង រួចអង្គាសព្រះភិក្ខុសង្ឆ មានព្រះពុទ្ធជាប្រធានដោយខាទនីយ: និងភោជនីយាហារដ៏ឧត្តមដោយដៃរបស់ខ្លួន ត្រាតែព្រះភិក្ខុសង្ឆ ហាមឃាត់ លុះកំណត់ដឹងថា ព្រះមានព្រះភាគឆាន់ហើយ ដាក់ព្រះហស្តចុះចាកបាត្រហើយ នាងក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ នាងវិសាខាមិគារមាតាអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមពរ ៨ ប្រការអំពីព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ធម្មតា ព្រះតថាគតទាំងឡាយគ្មានពរទេ ។ នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមតែពរណាដែលគួរ និងពរណាដែលឥតទោស ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ចូរនាងនិយាយមកចុះ ។ នាងវិសាខាក៏ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់ប្រគេនវស្សិកសាដក (សំពត់សម្រាប់ងូតទឹកភ្ជៀង) ចង់ប្រគេនអាគន្ធុកកត្ត (កត្តដែលប្រគេនដល់ភិក្ខុទើបមកដល់ថ្មី)

តមិកភត្តំ ជាតុំ កិលានភត្តំ ជាតុំ កិលានុបដ្ឋាកភត្តំ
ជាតុំ កិលានភេសជ្ជំ ជាតុំ ឆុវយាកុំ ជាតុំ ភិក្ខុនីសង្ឆ្យសង្ឆ
ឧទកសាដិកំ ជាតុន្តិ ។ កឹ បន ត្វំ វិសាខេ អត្ថវសំ
សម្ឆ្យសង្ឆមាជ ឥថាតតំ អដ្ឋ ១ាជិ យាចសីតិ ។ ឥជាហំ
ភន្តេ ជាសឺ អាណាបេសឺ ឥច្ច ១ជ អ១ាមំ ឥត្ថ ១ាលំ
អ១ាចេ១ហិ ១ាលោ ភន្តេ ជិដ្ឋិតំ ភត្តន្តិ អ១ខោ សា
ភន្តេ ជាសឺ អ១ាមំ ឥត្ថ អ១ួស ភិក្ខូ ជិក្ខិត្តចីវរេ ១ា-
យំ ឋិវសង្ឆាបេន្តេ ជិស្ងាជ ជត្ថិ អ១ាមេ ភិក្ខូ អ១ី-
១ា ១ាយំ ឋិវសង្ឆាបេន្តីតិ យេជាហំ ១ជុបសង្ក្ជមិ
ឧបសង្ក្ជមិត្ងា មំ ឍ១ជ១ាេ១ ជត្ថយ្យ អ១ាមេ ភិក្ខូ

ចង់ប្រគេនគមិកភត្ត (ភត្តដែលប្រគេនដល់ភិក្ខុអ្នកមានដំណើរទៅ) ចង់ប្រគេនគិលានភត្ត (ភត្តដែលប្រគេនដល់ភិក្ខុមានជំងឺ) ចង់ប្រគេនគិលានុបដ្ឋាកភត្ត (ភត្តដែលប្រគេនដល់ភិក្ខុអ្នកបម្រើជំងឺ) ចង់ប្រគេនគិលានភេសជ្ជៈ (ថ្នាំដែលប្រគេនដល់ភិក្ខុមានជំងឺ) ចង់ប្រគេនធុវយាគូ (បបរដែលត្រូវប្រគេនជានិច្ច) ដល់ព្រះសង្ឆ និងចង់ប្រគេនឧទកសាដិក (សំពត់សម្រាប់ងូតទឹក) ដល់ភិក្ខុនីសង្ឆ ដរាបដល់អស់ជីវិត ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនាងវិសាខា នាងឃើញអំណាចប្រយោជន៍ដូចម្តេច បានជាសូមពរ ៨ ប្រការអំពីតថាគត ។ នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវេលាព្រឹកមិញនេះ ខ្ញុំព្រះអង្គបង្គាប់ទាសីថា នែហង ហងចូរទៅកាន់អារាម ហើយក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ បពិត្រព្រះអង្គដ៏ចម្រើន ទាសីនោះក៏ទៅកាន់អារាម ហើយបានឃើញពួកភិក្ខុ ដាក់ចីវរចេញហើយ កំពុងនាំគ្នាងូតទឹកភ្ជៀងជម្រះកាយ លុះឃើញហើយក៏សំគាល់ថា ក្នុងអារាមគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវក កំពុងងូតទឹកភ្ជៀងជម្រះកាយ រួចក៏ត្រឡប់ចូលមកកាន់សំណាក់ខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ បាននិយាយពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រអ្នកម្ចាស់ ក្នុងអារាមគ្មានពួកភិក្ខុទេ

ចីវរក្ខន្ធកេ វិសាខាមិគារមាតាវត្ថុអដ្ឋវរកថា

តែងងាយគេបម្រើ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជំងឺប្រកប ដោយអង្គ ៥ មិនគួរនឹងបម្រើជំងឺទេ គឺបុគ្គលមិនប្រសប់ចាត់ចែងថ្នាំ ១ មិនស្គាល់ហេតុសប្បាយនិងមិនសប្បាយ ១ នាំរបស់ដែលមិនសប្បាយ ចូលទៅ នាំរបស់ដែលសប្បាយចេញមក ១ បម្រើអ្នកជំងឺចង់បានតែ អាមិស: ឥតមានចិត្តមេត្តា មានតែខ្ពើមរអើម និងការនាំចេញនូវឧច្ចារ:ក្តី បស្សាវ:ក្តី ទឹកមាត់ក្តី កំអួតក្តី ១ មិនអាចនឹងពន្យល់អ្នកមានជំងឺឲ្យឃើញ ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាសព្វ ។ កាល ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជំងឺប្រកបដោយអង្គ ៥ នេះ ឯង មិនគួរបម្រើជំងឺទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជំងឺ បើ ប្រកបដោយអង្គ ៥ ទើបគួរបម្រើជំងឺបាន គឺបុគ្គលប្រសប់ចាត់ចែងថ្នាំ ១ ស្គាល់ហេតុសប្បាយនិងមិនសប្បាយ ១ នាំរបស់ដែលមិនសប្បាយ ចេញទៅ នាំរបស់ដែលសប្បាយចូលមក ១ មានចិត្តមេត្តា មិនប្រាថ្នា អាមិស:ហើយបម្រើជំងឺមិនខ្ពើមរអើមក្នុងការនាំចេញនូវឧច្ចារ:ក្តី បស្សាវ:ក្តី

ខេឡ្ម វ វន្តំ វ ជីហាតុំ បដិពលោ ហោតិ គិលានំ
ការលេន ការលំ ជម្ម្ហិយ ការ្ថាយ សន្ធ្ហេ្ហតុំ សមា-
ធេតុំ សមុត្តេជេតុំ សម្ប្ហាំសេតុំ ឥមេហិ ខោ ភិក្ខ្ហវ
បញ្ចហ្ហ ្ហ ្ហ

ទឹកមាត់ក្តី កំអួតក្តី ១ អាចនឹងពន្យល់អ្នកមានជំងឺឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាសព្វ ៗ កាល ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជំងឺ លុះតែប្រកបព្រមដោយអង្គទាំង ៥ នេះ ឯង ទើបគួរបម្រើជំងឺបាន ។

[៧៣] សម័យនោះឯង មានភិក្ខុពីររូបដើរទៅតាមផ្លូវធ្ងាយ ក្នុងកោសលជនបទ ។ ភិក្ខុទាំងពីររូបនោះ ចូលទៅកាន់អាវាស ១ ។ ក្នុងអាវាសនោះមានភិក្ខុមួយរូបឈឺ ។ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់សរសើរការបម្រើជំងឺពេកណាស់ អាវុសោ បើដូច្នោះ មានតែយើងទាំងឡាយនឹងបម្រើភិក្ខុនេះ ។ ភិក្ខុទាំងនោះ ក៏នាំគ្នាបម្រើភិក្ខុឈឺនោះ ។ កាលដែលភិក្ខុទាំងនោះកំពុងបម្រើ ភិក្ខុឈឺក៏ធ្វើមរណកាលទៅ ។ គ្រានោះ ភិក្ខុទាំងនោះក៏នាំយកបាត្រនិងចីវររបស់ភិក្ខុឈឺនោះទៅឯក្រុងសាវត្ថី ហើយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុ (ណាមួយ) ធ្វើមរណភាពទៅហើយ ត្រូវសង្ឆ ជាម្ចាស់លើបាត្រ

អបិច តិលាឧបជ្ឌាការ ពហូបការ ។ អនុជានាមិ
ភិក្ខវេ សង្ឆេន តិចីវរញ្ច បត្តញ្ច តិលាឧបជ្ឌាការំ
ជានុំ ។ ឯវញ្ច បន ភិក្ខវេ ជានិតព្ពំ ។ តេន តិលាឧ-
បជ្ឌាកេន ភិក្ខុនា សង្ឆំ ឧបសង្កមិត្វា ឯវមស្ស វចនី-
យោ ឥត្ថន្ថាមោ ភន្តេ ភិក្ខុ ការាលកតោ ឥទំ តស្ស
តិចីវរញ្ច បត្តោ ចាតិ ។ ព្យត្តេន ភិក្ខុនា បដិពលេ-
ន សង្ឆោ ញាបេតព្ពោ សុណាតុ មេ ភន្តេ សង្ឆោ
ឥត្ថន្ថាមោ ភិក្ខុ ការាលកតោ ឥទំ តស្ស តិចីវរញ្ច បត្តោ
ច ។ យទិ សង្ឆស្ស បត្តកល្ល សង្ឆោ ឥមំ តិចីវរញ្ច
បត្តញ្ច តិលាឧបជ្ឌាការំ ឧទេយ្យ ។ ឯសា ញត្តិ ។
សុណាតុ មេ ភន្តេ សង្ឆោ ឥត្ថន្ថាមោ ភិក្ខុ ការាល-
កតោ ឥទំ តស្ស តិចីវរញ្ច បត្តោ ច ។ សង្ឆោ ឥមំ
តិចីវរញ្ច បត្តញ្ច តិលាឧបជ្ឌាការំ ទេតិ ។ យស្សា-
យស្មតោ ខមតិ ឥមស្ស តិចីវរស្ស ច បត្តស្ស ច
តិលាឧបជ្ឌាការំ ជានំ សោ តុណ្ហស្ស យស្ស ឧក្ខ-
មតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឆេន តិចីវរញ្ច

និងចីវរ (របស់ភិក្ខុនោះ) តែថាពួកភិក្ខុអ្នកបម្រើជំងឺ មានឧបការៈច្រើនជាងគេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆឲ្យត្រៃចីវរនិងបាត្រដល់ភិក្ខុអ្នកបម្រើជំងឺចុះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវឲ្យយ៉ាងនេះ ។ ភិក្ខុអ្នកបម្រើជំងឺនោះ ត្រូវចូលទៅរកសង្ឆហើយនិយាយយ៉ាងនេះនឹងសង្ឆថា បពិត្រព្រះសង្ឆដ៏ចម្រើន ភិក្ខុឈ្មោះនេះធ្វើមរណភាពទៅហើយ ត្រៃចីវរនិងបាត្រនេះជារបស់ភិក្ខុនោះ ។ ភិក្ខុដែលធ្វាសប្រតិពលត្រូវផ្ទៀងសង្ឆឲ្យដឹងថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ ដ្ឋិតភិក្ខុឈ្មោះនេះធ្វើមរណភាពទៅហើយ ត្រៃចីវរនិងបាត្រនេះ ជារបស់ភិក្ខុនោះ ។ បើការឲ្យត្រៃចីវរនិងបាត្រ មានកាលសមគួរដល់សង្ឆហើយ សង្ឆត្រូវឲ្យត្រៃចីវរនឹងបាត្រនេះដល់ពួកភិក្ខុអ្នកបម្រើជំងឺចុះ ។ នេះជាពាក្យផ្ទៀងសង្ឆ ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ ដ្ឋិតភិក្ខុឈ្មោះនេះធ្វើមរណភាពទៅហើយ ត្រៃចីវរនេះនិងបាត្រនេះ ជារបស់ភិក្ខុនោះ ។ ឥឡូវ សង្ឆបានឲ្យត្រៃចីវរនឹងបាត្រនេះ ដល់ពួកភិក្ខុអ្នកបម្រើជំងឺហើយ ។ ការឲ្យត្រៃចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជំងឺនេះ (បើ) គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ ត្រូវលោកដ៏មានអាយុអង្គនោះនិយាយឡើង ។ សង្ឆបានឲ្យត្រៃចីវរនិងបាត្រនេះ ដល់ពួកភិក្ខុ

ចីវរក្ខន្ធកេ គិលានុបដ្ឋានកានំ កាលកតបត្តចីវរទានកថា

បត្តោ ច គិលានុបដ្ឋាកានំ ។ ខមតិ សង្ឆស្ស តស្មា
តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តេន ខោ បន សម-
យេន អញ្ញតរោ សាមណេរោ កាលកតោ ហោតិ ។
ភគវតោ ឯតមត្ថំ អារោចេសុំ ។ សាមណេរស្ស ភិក្ខវេ
កាលកតេ សង្ឆោ សាមី បត្តចីវរេ អបិច គិលានុ-
បដ្ឋាកា ពហូបការា ។ អនុជានាមិ ភិក្ខវេ សង្ឆេន
ចីវរញ្ច បត្តញ្ច គិលានុបដ្ឋាកានំ ទាតុំ ។ ឯវញ្ច បន
ភិក្ខវេ ទាតព្ពំ ។ តេន គិលានុបដ្ឋាកេន ភិក្ខុនា
សង្ឆំ ឧបសង្កមិត្វា ឯវមស្ស វចនីយោ ឥត្ថន្នាមោ
ភន្តេ សាមណេរោ កាលកតោ ឥទំ តស្ស ចីវរញ្ច
បត្តោ ចាតិ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឆោ
ញាបេតព្ពោ សុណាតុ មេ ភន្តេ សង្ឆោ ឥត្ថន្នាមោ
សាមណេរោ កាលកតោ ឥទំ តស្ស ចីវរញ្ច បត្តោ
ច ។ យទិ សង្ឆស្ស បត្តកល្លំ សង្ឆោ ឥមំ ចីវរញ្ច
បត្តញ្ច គិលានុបដ្ឋាកានំ ឧទេយ្យ ។ ឯសា ញត្តិ ។

អ្នកបម្រើជំងឺហើយ ។ ការឲ្យត្រៃចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជំងឺប្រ-ហែលជាគាប់ចិត្តដល់សង្ឆហើយ ព្រោះហេតុនោះ បានជាសង្ឆស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។ សម័យនោះ ឯង មានសាមណេរមួយរូបធ្វើមរណភាព ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើសាមណេរ (ណាមួយ) ធ្វើមរណភាពទៅហើយ ត្រូវសង្ឆជាម្ចាស់លើបាត្រនិងចីវរ (របស់សាមណេរនោះ) តែថាភិក្ខុអ្នកបម្រើជំងឺមានឧបការ:ច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆឲ្យចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជំងឺ ។ ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវឲ្យយ៉ាងនេះ ។ ភិក្ខុអ្នកបម្រើជំងឺនោះត្រូវចូលទៅរកសង្ឆហើយនិយាយយ៉ាងនេះនឹងសង្ឆថា បពិត្រព្រះសង្ឆដ៏ចំ-រើន សាមណេរឈ្មោះនេះ ធ្វើមរណភាពទៅហើយ ចីវរនិងបាត្រនេះជារបស់សាមណេរនោះ ។ ភិក្ខុដែលធ្វាសប្រតិពលត្រូវផ្ទៀងសង្ឆថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ ដ្ឋិតសាមណេរឈ្មោះនេះ ធ្វើមរណភាពទៅហើយ ចីវរនិងបាត្រនេះជារបស់សាមណេរនោះ ។ បើការឲ្យចីវរនិងបាត្រមានកាលសមគួរដល់សង្ឆហើយ សង្ឆត្រូវឲ្យចីវរនិងបាត្រនេះដល់ពួកភិក្ខុអ្នកបម្រើជំងឺចុះ ។ នេះជាពាក្យផ្ទៀងសង្ឆ ។

សុណាតុ មេ ភន្តេ សង្ឆោ ឥត្ថន្ថាមោ សាមណេរោ
ការណការោ ឥមំ ឥស្ស ចីវរញ្ច បត្តោ ច ។ សង្ឆោ
ឥមំ ចីវរញ្ច បត្តញ្ច តិណ្ណនុបជ្ឌាការំ ទេតិ ។
យស្សាយស្មតោ ខមតិ ឥមស្ស ចីវរស្ស ច បត្តស្ស
ច តិណ្ណនុបជ្ឌាការំ ឌានំ សោ តុណ្ហោស្ស យស្ស
ឧក្ខមតិ សោ ភាសេយ្យ ។ ឌិន្នំ ឥមំ សង្ឆេន
ចីវរញ្ច បត្តោ ច តិណ្ណនុបជ្ឌាការំ ។ ខមតិ
សង្ឆស្ស ឥត្ថ តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។
ត្ថេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ច សា-
មណេរោ ច តិណ្ណំ ឧបជ្ឌហ៊ីសុ ។ សោ ត្ថេហិ ឧ-
បជ្ឌហិយមានោ ការណមការិ ។ អថ ខោ ឥស្ស
តិណ្ណនុបជ្ឌាការស្ស ភិក្ខូនោ ឯតទហោសិ ការំ នុ ខោ
តិណ្ណនុបជ្ឌាការស្ស សាមណេរស្ស ចីវរប្ឌជិវិសោ ឌា-
ត្ឆោតិ ។ ភគវតោ ឯតទមត្ថំ អារោចេសុំ ។ អនុ-
ជានាមិ ភិក្ខវេ តិណ្ណនុបជ្ឌាការស្ស សាមណេរស្ស
សមការំ បដិវិសំ ឌាតុន្ត្ថិ ។ ត្ថេន ខោ បន ស-
មយេន អញ្ញតរោ ភិក្ខុ ពហុការណ្ណោ ពហុបរិក្ខារោ

បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ខ្ញុំ ដ្ឋិតសាមណេរឈ្មោះ នេះធ្វើមរណភាពទៅហើយ ចីវរនិងបាត្រនេះជារបស់សាមណេរនោះ ។ ឥឡូវសង្ឆឲ្យចីវរនិងបាត្រនេះដល់ពួកភិក្ខុអ្នកបម្រើជំងឺហើយ ។ ការឲ្យចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជំងឺនេះ (បើ) គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ ត្រូវលោកដ៏មានអាយុអង្គនោះនិយាយឡើង ។ ចីវរនិងបាត្រនេះ សង្ឆបានឲ្យដល់ពួកភិក្ខុអ្នកបម្រើជំងឺហើយ ។ ការឲ្យចីវរនិងបាត្រ ដល់ពួកភិក្ខុអ្នកបម្រើជំងឺ ប្រហែលជាគាប់ចិត្តដល់សង្ឆហើយ ព្រោះហេតុនោះ បានជាសង្ឆស្ងៀម ។ ខ្ញុំសូមចាំទុករឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។ សម័យនោះឯង មានភិក្ខុ ១ រូបនិងសាមណេរ ១ រូបបម្រើភិក្ខុឈឺ ។ កាលបើភិក្ខុនិងសាមណេរទាំងនោះ កំពុងបម្រើ ភិក្ខុឈឺនោះក៏ធ្វើមរណភាពទៅ ។ ឯភិក្ខុអ្នកបម្រើជំងឺនោះក៏ មានសេចក្តីត្រិះរិះថា អាត្មាអញត្រូវឲ្យចំណែកចីវរទៅសាមណេរ ដែលជាអ្នកបម្រើជំងឺដែរឬ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះ ព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចំណែកស្មើគ្នា ទៅសាមណេរ ដែលជាអ្នកបម្រើជំងឺចុះ ។ សម័យនោះឯង មានភិក្ខុ ១ រូបមានទ្រព្យច្រើន មានបរិក្ខារច្រើន

ការលកតោ ហោតិ ។ ភតវតោ ឯតមត្ថំ អារោ-
ចេសុំ ។ ភិក្ខុស្ស ភិក្ខវេ ការលកតេ សង្ឆោ
សាមី បត្តចីវរេ អបិច កិលាសុបដ្ឋាការ ពហូបការ ។
អនុជានាមិ ភិក្ខវេ សង្ឆេន តិចីវរញ្ច បត្តញ្ច កិលា-
សុបដ្ឋាការ ជានុំ យំ តត្ត លហុកណ្ហំ លហុបរិក្ខារ
តំ សម្មុខីភូតេន សង្ឆេន ការេតុំ យំ តត្ត ករុកណ្ហំ
ករុបរិក្ខារ តំ អាកតាជានតស្ស ចាតុទ្ទិសស្ស សង្ឆស្ស
អវិស្ស ជ្ជិកំ អវេភ ជ្ជិកន្តិ ។

[៧៤] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ
ជក្ខោ ហុត្វា យេន ភគវា តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា
ភគវន្តំ ឯតទវោច ភគវា ភន្តេ អនេកបរិយាយេន
អប្ប ិច្ឆស្ស សន្តុដ្ឋស្ស សល្លេ ខស្ស ធូតស្ស ចាសាធិ-
ការ ស្ស អបចយស្ស វ ិរិយារម្ភស្ស វណ្ណ ាវ ធី ឥ ធ ភន្តេ

ធ្វើមរណភាពទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុ (ណាមួយ) ធ្វើមរណភាពទៅហើយ ត្រូវសង្ឆាជាម្ចាស់លើបាត្រនិងចីវរ (របស់ភិក្ខុនោះ) តែថា ពួកភិក្ខុអ្នកបម្រើជំងឺមានឧបការ:ច្រើនជាងគេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឆ ឲ្យត្រៃចីវរនិងបាត្រដល់ពួកភិក្ខុអ្នកបម្រើជំងឺចុះ បើមានវត្ថុណាមួយជាគ្រឿងលហុកណ្ហ[1] ឬជាគ្រឿងលហុបរិក្ខារ[2] នៅក្នុងទីនោះ តថាគតអនុញ្ញាតឲ្យសង្ឆ ដែលមានក្នុងទីចំពោះមុខ (ព្រមព្រៀងគ្នា) ចែកគ្រឿងលហុកណ្ហនិងគ្រឿងលហុប-រិក្ខារនោះបាន បើមានគ្រឿងគរុកណ្ហ ឬគ្រឿងគរុបរិក្ខារណានៅក្នុងទីនោះ គ្រឿងគរុកណ្ហនិងគ្រឿងគរុបរិក្ខារនោះ ត្រូវទុកសម្រាប់សង្ឆ ដែលមកឬមិនទាន់បានមកពីទិសទាំង ៤ ភិក្ខុមិនត្រូវលះ មិនត្រូវចែកគ្នាទេ ។

[៧៤] សម័យនោះឯង មានភិក្ខុ ១ រូប មានកាយអាក្រាតហើយ ចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងទ្រង់សរសើរគុណរបស់បុគ្គលអ្នកប្រាថ្នាតិច មានចិត្តសន្ដោស មានចិត្តផ្ទរផង់ កម្ចាត់បង់កិលេស នាំឲ្យកើតសេចក្ដីជ្រះថ្លា មិនសន្សំកិលេស-វដ្ដ: ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចម្រើន

១-២ គឺរបស់រាយរង ក្រៅអំពីគរុកណ្ហទាំង ២៥ ។

ឧក្ខិយំ អនេកបរិយាយេន អប្ឋិច្ឆតាយ សន្តុដ្ឋតាយ
សល្លេខាយ ធូតត្តាយ ចាសាធិកតាយ អបចយាយ
វីរិយារម្ភាយ សំវត្តតិ សាធុ ភន្តេ ភគវា ភិក្ខូនំ ឧក្ខិ-
យំ អនុជានាតូតិ ។ វិតរហិ ពុទ្ធោ ភគវា អនុច្ឆវិកំ
មោឃបុរិស ។ បេ ។ កថំ ហិ នាម ត្វំ មោឃបុរិស
ឧក្ខិយំ តិត្តិយសមាចារំ សមាធិយិស្ឃសិ នេតំ មោ-
ឃបុរិស អប្ឋសន្ថារំ វ បសាទាយ ។ បេ ។ វិតរ-
ហិត្វា ធម្មឺ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ
ឧក្ខិយំ តិត្តិយសមាចារំ សមាធិយិតព្ពំ យោ សមា-
ធិយេយ្យ អាបត្តិ ថុល្លច្ចយស្ឃាតិ ។ តេន ខោ បន
សមយេន អញ្ញតរោ ភិក្ខុ ឈុសចីរំ ធិវាសេត្វា ។ បេ ។
ឆកចីរំ ធិវាសេត្វា ។ បេ ។ ផលកចីរំ ធិវាសេត្វា
។ បេ ។ កេសកម្ពលំ ធិវាសេត្វា ។ បេ ។ វាលកម្ពលំ
ធិវាសេត្វា ។ បេ ។ ឧលូកបក្ខំ ធិវាសេត្វា ។ បេ ។

ការអាក្រាតនេះនាំឲ្យមានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស សេចក្តីផ្ទរ ផង់ កម្ចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្ត: និង នាំឲ្យមានសេចក្តីប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះ អង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់អនុញ្ញាតការអាក្រាត ដល់ពួកភិក្ខុ ជាការស្រួលពេកណាស់ ។ ព្រះពុទ្ធមានព្រះភាគបន្ទោសថា នែមោយ-បុរស អំពើនេះ មិនទំនងទេ ។ បេ ។ ម្នាលមោយបុរស អ្នកមិនសមបើនឹង សមាទាននូវការអាក្រាតជាតិត្ថិយសមាទាន[១] (ដូច្នេះ) សោះ ម្នាល មោយបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ទេ ។ បេ ។ ទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយ មកថា ម្នាលភិក្ខុទាំងឡាយ ការអាក្រាតជាតិត្ថិយសមាទាន ភិក្ខុមិនត្រូវ សមាទានទេ ភិក្ខុណាសមាទាន ត្រូវអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុ ១ រូបស្លៀកសំពត់ដែលគេធ្វើពីស្ជូវក្ងាំង ។ បេ ។ ស្លៀកសំពត់ ដែលគេធ្វើពីសម្បកឈើ ។ បេ ។ ស្លៀកសំពត់ដែលគេធ្វើពីផែនក្តារ ។ បេ ។ ស្លៀកសំពត់កម្ពលដែលគេធ្វើពីសក់ ។ បេ ។ ស្លៀកសំពត់កម្ពលដែលគេ ធ្វើពីរោមកន្ទុយសត្ត ។ បេ ។ ស្លៀកសំពត់ដែលគេធ្វើពីស្ទាបមៀម ។ បេ ។

---

១ ទ្រង់ឃាត់មិនឲ្យភិក្ខុប្រព្រឹត្តវត្តបែបពួកតិរ្ថិយ ព្រោះតិរ្ថិយខ្លះអាក្រាតតមមិនស្លៀកសំពត់ មិនដណ្តប់សំពត់ ។

ចីវរក្ខន្ធកេ នគ្គិយាទិតិត្ថិយសមាទានកថា

អជិនក្ខិបំ ជិវាសេត្វា យេន ភគវា តេនុបសង្កមិ ឧ-
បសង្កមិត្វា ភគវន្តំ ឯតទវោច ភគវា ភន្តេ អនេកប-
រិយាយេន អប្ប៎ិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស
ចាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណ៎ាវាទី ឥតិ
ភន្តេ អជិនក្ខិបំ អនេកបរិយាយេន អប្ប៎ិច្ឆតាយ សន្តុ-
ដ្ឋតាយ សល្លេខាយ ធុតត្តាយ ចាសាទិកតាយ អប-
ចយាយ វីរិយារម្ភាយ សំវត្តតិ សាធុ ភន្តេ ភគវា ភិក្ខូនំ
អជិនក្ខិបំ អនុជានាតូតិ ។ វិតរហិ ពុទ្ធោ ភគវា អន-
ុច្ឆវិកំ មោឃបុរិស ។ បេ ។ ឥមំ ហិ ជាម តុ្វំ
មោឃបុរិស អជិនក្ខិបំ តិត្ថិយធ្ជំ ជាវេស្ស៎សិ នេតំ
មោឃបុរិស អប្ប៎សន្ថានំ ឥ បសាទាយ ។ បេ ។
វិតរហិត្វា ឆម្ម៎ឿ ឥមំ ឥមត្វា ភិក្ខូ អាមន្តេសិ ន
ភិក្ខវេ អជិនក្ខិបំ តិត្ថិយធ្ជំ ជាវេតពុ្វំ យោ ជាវេយ្យ
អាបត្តិ ថុល្លច្ចយ៎ស្ស តិ ។ តេន ខោ បន សម-
យេន អញ្ញតរោ ភិក្ខុ អក្ខ្ជាលំ ជិវាសេត្វា ។ បេ ។

ស្បៃកសំពត់ ដែលគេធ្វើពីស្បែកខ្វា ហើយចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងទ្រង់សរសើរគុណរបស់បុគ្គលអ្នកប្រាថ្នាតិច មានចិត្តសន្ដោស មានចិត្តផ្ទរផង់ កម្ចាត់បង់កិលេសនាំឲ្យកើតសេចក្ដីជ្រះថ្លា មិនសន្សំកិលេសវដ្ដ: ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចម្រើន ស្បែកខ្វានេះនាំឲ្យមានសេចក្ដីប្រាថ្នាតិច សេចក្ដីសន្ដោស សេចក្ដីផ្ទរផង់ កម្ចាត់បង់កិលេស នាំឲ្យកើតសេចក្ដីជ្រះថ្លា មិនសន្សំកិលេសវដ្ដ: និងនាំឲ្យមានសេចក្ដីប្រារព្ធព្យាយាមដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់អនុញ្ញាតឲ្យពួកភិក្ខុស្បៃកដណ្ដាប់សំពត់ស្បែកខ្វា ជាការស្រួលពេកណាស់ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អំពើនេះមិនទំនងទេ ។ បេ ។ នែមោឃបុរស អ្នកមិនសមបើនឹងទ្រទ្រង់សំពត់ស្បែកខ្វាជាទង់ជ័យនៃតិរ្ថិយសោះ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ទ្រង់បន្ទោសរួចទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់ស្បែកខ្វាជាទង់ជ័យរបស់តិរ្ថិយទេ ភិក្ខុណាទ្រទ្រង់ ត្រូវអាបត្តិថុល្លច្ច័យ ។ សម័យបនោះឯង មានភិក្ខុ ១ រូបស្បៃកសំពត់ដែលគេធ្វើពីដើមរាក់ ។ បេ ។

ចោត្តកំ ជិវ្ហាសេត្វា យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ ឯតទវោច ភគវា ភន្តេ អនេ-
កបរិយាយេន អប្ឆិច្ឆស្ស សន្ទុដ្ឋស្ស សល្ខេ១ស្ស ជូ-
តស្ស ចាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណោ
អយំ ភន្តេ ចោត្តោ អនេកបរិយាយេន អប្ឆិច្ឆតាយ
សន្ទុដ្ឋតាយ សល្ខេ១ាយ ជូតត្តាយ ចាសាទិកតាយ
អបចយាយ វីរិយារម្ភាយ សំវត្តតិ សាធុ ភន្តេ ភគវា
ភិក្ខូនំ ចោត្តកំ អនុជានាតូតិ ។ វិតរហិ ពុទ្ធោ
ភគវា អនុច្ឆវិកំ មោឃបុរិស ។ បេ ។ ឆកំ ហិ
ជាម ត្វំ មោឃបុរិស ចោត្តកំ ជិវ្ហាសេស្ស្ស្ស្ស្ស្ស្ស្ស
មោឃបុរិស អប្ឆ្ស
ជ្ឈ្ឈ្ឈ

ស្ងៀកសំពត់ដែលគេធ្វើពីសម្បកក្រចៅ ហើយចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងទ្រង់សរសើរគុណរបស់បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច មានចិត្តសន្ទោស មានចិត្តផ្ទរផង់ កម្ចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្ត: ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចម្រើន សំពត់សម្បកក្រចៅនេះ នាំឲ្យមានសេចក្តីប្រាថ្នាតិច សេចក្តីសន្ទោស សេចក្តីផ្ទរផង់ កម្ចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្ត: និងនាំឲ្យមានសេចក្តីប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់អនុញ្ញាតឲ្យពួកភិក្ខុ (ទ្រទ្រង់) សំពត់សម្បកក្រចៅ ជាការស្រួលពេកណាស់ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អំពើនេះមិនទំនងទេ ។ បេ ។ ម្នាលមោឃបុរស អ្នកមិនសមបើនឹងស្ងៀកសំពត់សម្បកក្រចៅសោះ ម្នាលមោឃបុរស អំពើនេះមិនមែននាំពួកជន ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើងទេ ។ បេ ។ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថារួចត្រាស់ហៅភិក្ខុទាំង-ឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្ងៀកសំពត់សម្បកក្រចៅទេ ភិក្ខុណាស្ងៀក ត្រូវអាបត្តិទុក្កដ ។

ចីវរក្ខន្ធកេ ឆព្វគ្គិយភិក្ខុវត្ថុសព្វនីលកាទិចីវរធារណកថា

[៧៤] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សព្វនីលកានិ ចីវរានិ ធារេន្តិ សព្វបីតកានិ ចីវរានិ ធារេន្តិ សព្វលោហិតកានិ ចីវរានិ ធារេន្តិ សព្វមញ្ជ-ដ្ឋកានិ ចីវរានិ ធារេន្តិ សព្វកណ្ហានិ ចីវរានិ ធារេន្តិ សព្វមហារង្គរត្តានិ ចីវរានិ ធារេន្តិ សព្វមហាធាមរត្តានិ ចីវរានិ ធារេន្តិ អច្ឆិន្ទនសានិ ចីវរានិ ធារេន្តិ ឌីឃនសានិ ចីវរានិ ធារេន្តិ បុប្ផនសានិ ចីវរានិ ធារេន្តិ ផលន-សានិ[1] ចីវរានិ ធារេន្តិ កញ្ចុកំ ធារេន្តិ តិរីដកំ ធារេន្តិ វេឋនំ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិចារេន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សព្វនីលកានិ ចីវរានិ ធារ-តព្វានិ ន សព្វបីតកានិ ចីវរានិ ធារេតព្វានិ ន សព្វ-លោហិតកានិ ចីវរានិ ធារេតព្វានិ ន សព្វមញ្ជដ្ឋកានិ ចីវរានិ ធារេតព្វានិ ន សព្វកណ្ហានិ ចីវរានិ ធារ-តព្វានិ ន សព្វមហារង្គរត្តានិ ចីវរានិ ធារេតព្វានិ

---

1 ផលាទសានីតិ ឱ. ឧបាត្តកេ ទិស្សតិ ។

ចីវរក្ខន្ធក: រឿងឆព្វគ្គិយភិក្ខុនិយាយអំពីការប្រើចីវរមានពណ៌ខៀវសុទ្ធជាដើម

[៧៥] *សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទ្រទ្រង់*[1] *ចីវរខៀវសុទ្ធ ទ្រទ្រង់ចីវរលឿងសុទ្ធ ទ្រទ្រង់ចីវរក្រហមសុទ្ធ ទ្រទ្រង់ចីវរពណ៌ហង្ស-បាទសុទ្ធ ទ្រទ្រង់ចីវរខ្មៅសុទ្ធ ទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ (ពណ៌ខ្នងក្អែប) ទ្រទ្រង់ចីវរលឿងទុំសុទ្ធ (ពណ៌ដូចផ្កាឈូក) ទ្រទ្រង់ចីវរមានជាយមិនបានកាត់ចេញ ទ្រទ្រង់ចីវរមានជាយវែង ទ្រទ្រង់ចីវរមានជាយជាផ្ការ៉ៃ ទ្រទ្រង់ចីវរមានជាយជាផ្ទៃ ទ្រទ្រង់អាវ ទ្រទ្រង់មួក ទ្រទ្រង់សំពត់ឈ្នួត ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្ទុះបង្ហាប់ថា ដូចជាពួកគ្រហស្ថអ្នកបរិភោគកាម ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់ចីវរខៀវសុទ្ធ មិនត្រូវទ្រទ្រង់ចីវរលឿងសុទ្ធ មិនត្រូវទ្រទ្រង់ចីវរក្រហមសុទ្ធ មិនត្រូវទ្រទ្រង់ចីវរពណ៌ហង្សបាទសុទ្ធ មិនត្រូវទ្រទ្រង់ចីវរខ្មៅសុទ្ធ មិនត្រូវទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ*

---

១ នេះជាពាក្យសាធារណ: នឹងហៅថាស្លៀកឬហៅថាដណ្ដប់ឬហៅថា ពាក់និងជួតជាដើមក៏បាន ហៅតាមសមគួរដល់របស់ដែលប្រើប្រាស់ ។

ន សព្វមហាជាមវត្ថានិ ចីវរានិ ជានេតព្វានិ ន អច្ឆិន្ន-ឧសានិ ចីវរានិ ជានេតព្វានិ ន ឌីឃឧសានិ ចីវរានិ ជានេតព្វានិ ន បុប្ផឧសានិ ចីវរានិ ជានេតព្វានិ ន ផល-ឧសានិ ចីវរានិ ជានេតព្វានិ ន ឧកញ្ចុកំ ជានេតព្វំ ន តិរីដកំ ជានេតព្វំ ន វេឋនំ ជានេតព្វំ យោ ជានេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[៧៦] តេន ខោ បន សមយេន វស្សំ វុត្ថា ភិក្ខូ អនុប្ផន្នេ ចីវរេ បក្ខ្លាមន្តិបិ ១ ១ ១

មិនត្រូវទ្រទ្រង់ចីវរលឿងទុំសុទ្ធ មិនត្រូវទ្រទ្រង់ចីវរមានជាយមិនបានកាត់ចេញ មិនត្រូវទ្រទ្រង់ចីវរមានជាយដែង មិនត្រូវទ្រទ្រង់ចីវរមានជាយជាផ្ការឈើ មិនត្រូវទ្រទ្រង់ចីវរមានជាយជាផ្លែឈើ មិនត្រូវទ្រទ្រង់អាវ មិនត្រូវទ្រទ្រង់មួក មិនត្រូវទ្រទ្រង់សំពត់ឈ្នួត ភិក្ខុណាទ្រទ្រង់ត្រូវអាបត្តិទុក្កដ ។

[៧៦] *សម័យនោះឯង ភិក្ខុទាំងឡាយនៅចាំវស្សារួចហើយ តែចីវរមិនទាន់កើតឡើង*[1] *ក៏នាំគ្នាចៀសចេញទៅខ្លះ សឹកចេញទៅខ្លះ ស្លាប់ទៅខ្លះ ប្តេជ្ញាខ្លួនជាសាមណេរខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលពោលលាសិក្ខាខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលត្រូវអន្តិមវត្ថុខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលឆ្កួតខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលមានចិត្តអណ្តែតអណ្តូងខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលគឺវេទនាគ្របសង្កត់ខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលគឺសង្ឆាលើកវត្ត ព្រោះមិនឃើញអាបត្តិខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលគឺសង្ឆាលើកវត្ត ព្រោះមិនបានសំដែងអាបត្តិខ្លះ ប្តេជ្ញាខ្លួនជាបុគ្គលគឺសង្ឆាលើកវត្ត ព្រោះមិនបានលះបង់ទិដ្ឋិអាក្រក់ខ្លះ ប្តេជ្ញាខ្លួនជាខ្ទើយខ្លះ ប្តេជ្ញាខ្លួនជាអ្នកលួចសំវាសខ្លះ ប្តេជ្ញាខ្លួនជាអ្នកចូលពួកតិរ្ថិយខ្លះ ប្តេជ្ញាខ្លួនជាសត្វតិរិច្ឆានខ្លះ ប្តេជ្ញាខ្លួនជាអ្នកសម្លាប់មាតាខ្លះ ប្តេជ្ញាខ្លួនជាអ្នកសម្លាប់បិតាខ្លះ*

---

១ បានសេចក្ដីថា ភិក្ខុទាំងនោះនៅចាំវស្សារួចហើយ មិនទាន់បានចីវរពីណាទេនៅឡើយ ។

បដិជានន្តិ អហារន្តយាតកាបិ បដិជានន្តិ ភិក្ខុនីឥូស-
កាបិ បដិជានន្តិ សជ្ជ្យកេ ឧកាបិ បដិជានន្តិ លោហិ-
តុប្ប្ឍ ឧកាបិ បដិជានន្តិ ឧកតោ ១ ញ្ជ ឧកាបិ បដិ-
ជានន្តិ ។ ភ្ជ ១ ១ ១

ប្តេជ្ញាខ្ជួនជាអ្នកសម្ងាប់ព្រះអរហន្តខ្លះ ប្តេជ្ញាខ្ជួនជាអ្នកទ្រុស្តភិក្ខុនីខ្លះ ប្តេជ្ញាខ្ជួនជាអ្នកបំបែកសង្ឆខ្លះ ប្តេជ្ញាខ្ជួនជាអ្នកធ្វើលោហិត (ព្រះបរមគ្រូ) ឲ្យពុះពងឡើងខ្លះ ប្តេជ្ញាខ្ជួនជាឧភតោព្យញ្ជនក (មនុស្សមានភេទពីរ) ខ្លះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង ក៏ចៀសចេញទៅ ។ កាលបើមានភិក្ខុអ្នកទទួលយកចីវរដ៏សមគួរ សង្ឆត្រូវឲ្យចីវរ (នោះទៅ) ចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង ក៏សឹកទៅក្តី ស្លាប់ទៅក្តី ប្តេជ្ញាខ្ជួនជាសាមណេរក្តី ប្តេជ្ញាខ្ជួនជាអ្នកពោលលាសិក្ខាក្តី ប្តេជ្ញាខ្ជួនជាអ្នកត្រូវអន្តិមវត្ថុក្តី ។ សង្ឆត្រូវជាម្ចាស់ (ចីវរនោះឯង) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង ក៏ប្តេជ្ញាខ្ជួនជាមនុស្សឆ្កួតក្តី ប្តេជ្ញាខ្ជួនជាមនុស្សមានចិត្តអណ្តែតអណ្តូងក្តី ប្តេជ្ញាខ្ជួនជាមនុស្សមានវេទនាគ្របសង្កត់ក្តី ប្តេជ្ញាខ្ជួនជាភិក្ខុគឺសង្ឆលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី ប្តេជ្ញាខ្ជួនជាភិក្ខុគឺសង្ឆលើកវត្តព្រោះមិនបានសំដែងអាបត្តិក្តី ប្តេជ្ញាខ្ជួនជាភិក្ខុគឺសង្ឆលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី ។ កាលបើមានភិក្ខុជាអ្នកទទួលយកចីវរដ៏សមគួរ

ជាតពុំ ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថោ ភិក្ខុ អនុប្ឋន្នេ ចីវរេ បណ្ណាកោ បដិជានាតិ ។ បេ ។ ឧភតោព្យញ្ជនកោ បដិជានាតិ ។ សង្ឆ្យោ សាមី ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថោ ភិក្ខុ ឧប្ឋន្នេ ចីវរេ អភាជិតេ បក្កមតិ ។ សន្តេ បជ្ជ្ជេ តាហាកេ ជាតពុំ ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថោ ភិក្ខុ ឧប្ឋន្នេ ចីវរេ អភាជិតេ វិព្ភមតិ តាលំ ឆ្ការតិ សាមណេរេ បដិជានាតិ សិក្ខំ បច្ចក្ខាតកោ បដិជានាតិ អន្តិមវត្ថុំ អជ្ឈាបន្នកោ បដិជានាតិ ។ សង្ឆ្យោ សាមី ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថោ ភិក្ខុ ឧប្ឋន្នេ ចីវរេ អភាជិតេ ឧម្មត្តកោ បដិជានាតិ ខិត្តចិត្តោ បដិជានាតិ វេទនដ្ដោ បដិជានាតិ អាបត្តិយា អទស្ឆនេ ឧក្ខិត្តកោ បដិជានាតិ អាបត្តិយា អប្ឋដិកម្មេ ឧក្ខិត្តកោ បដិជានាតិ ចាបិ-ការយ ទិដ្ឋិយា អប្ឋដិនិស្ឆ្ឆេ ឧក្ខិត្តកោ បដិជានាតិ ។

ត្រូវសង្ឆ ឲ្យចីវរ (នោះទៅ) ចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង ក៏ប្តេជ្ញាខ្លួនជាមនុស្សខ្ជើយក្តី ។ បេ ។ ប្តេជ្ញាខ្លួនជាឧកតោព្យញ្ជនកក្តី ។ សង្ឆត្រូវជាម្ចាស់ (ចីវរនោះឯង) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឆមិនទាន់បានចែកខ្លួនក៏ចៀសចេញទៅ ។ កាលបើមានភិក្ខុជាអ្នកទទួលចីវរដ៏សមគួរ ត្រូវសង្ឆ ឲ្យចីវរ (នោះទៅ) ចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឆមិនទាន់បានចែក ខ្លួនក៏សឹកទៅក្តី ស្លាប់ទៅក្តី ប្តេជ្ញាខ្លួនជាសាមណេរក្តី ប្តេជ្ញាខ្លួនជាអ្នកពោលលាសិក្ខាក្តី ប្តេជ្ញាខ្លួនជាបុគ្គលត្រូវអន្តិមវត្ថុក្តី ។ សង្ឆត្រូវជាម្ចាស់ (ចីវរនោះ) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើង តែសង្ឆមិនទាន់បានចែក ក៏ប្តេជ្ញាខ្លួនជាមនុស្សឆ្កួតក្តី ប្តេជ្ញាខ្លួនជាបុគ្គលមានចិត្តអណ្តែតអណ្តូងក្តី ប្តេជ្ញាខ្លួនជាបុគ្គលមានវេទនាគ្របសង្កត់ក្តី ប្តេជ្ញាខ្លួនជាភិក្ខុគឺសង្ឆលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី ប្តេជ្ញាខ្លួនជាភិក្ខុគឺសង្ឆលើកវត្ត ព្រោះមិនបានសំដែងអាបត្តិក្តី ប្តេជ្ញាខ្លួនជាភិក្ខុគឺសង្ឆលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី ។

ចីវរក្ខន្ធកេ វស្សំ វុត្ថានំ អនុប្បន្នចីវរកថា

សន្តេ បជ្ជូបេ តាហាកេ ជាតពុំ ។ ឥធ បន ភិក្ខវេ
វស្សំ វុត្ថោ ភិក្ខុ ឧប្ជន្ធេ ចីវរេ អភាជិតេ បណ្ណាកោ
បជិជ្ជានាតិ ។ បេ ។ ឧភតោព្យ ញ្ជនកោ បជិជ្ជានាតិ ។
សជ្ជោ សាមី ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថានំ
ភិក្ខូនំ អនុប្ជន្ធេ ចីវរេ សជ្ជោ ភិជ្ជតិ ។ តត្ត
មនុស្ស ឯកស្មឹ បក្ខេ ឧឌកំ ទេន្តិ ឯកស្មឹ បក្ខេ
ចីវរំ ទេន្តិ សជ្ជ្ជ ទេមាតិ ។ សជ្ជ្ជ ។ ឥធ
បន ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ អនុប្ជន្ធេ ចីវរេ
សជ្ជោ ភិជ្ជតិ ។ តត្ត មនុស្ស ឯកស្មឹ បក្ខេ
ឧឌកំ ទេន្តិ តស្មឹយេវ បក្ខេ ចីវរំ ទេន្តិ សជ្ជ្ជ
ទេមាតិ ។ សជ្ជ្ជ ។ ឥធ បន ភិក្ខវេ វស្សំ
វុត្ថានំ ភិក្ខូនំ អនុប្ជន្ធេ ចីវរេ សជ្ជោ ភិជ្ជតិ ។

ចីវរក្ខន្ធក: និយាយអំពីចីវរដែលមិនទាន់កើតឡើង ដល់ភិក្ខុដែលនៅចាំវស្សារួចហើយ

កាលបើមានភិក្ខុជាអ្នកទទួលចីវរដ៏សមគួរ ត្រូវសង្ឆឲ្យចីវរ (នោះទៅ) ចុះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឆមិនទាន់បានចែក ក៏ប្តេជ្ញាខ្ជួនជាមនុស្សខ្ជើយក្តី ។ បេ ។ ប្តេជ្ញាខ្ជួនជាឧកតោព្យញ្ជនកក្តី ។ សង្ឆត្រូវជាម្ចាស់ (ចីវរនោះឯង) ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឆក៏បែកគ្នាទៅ[១] ។ មនុស្សទាំងឡាយក្នុងទីនោះ ក៏នាំគ្នាប្រគេនទឹកចំពោះភិក្ខុមួយពួក ប្រគេនចីវរចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយប្រគេនចំ-ពោះសង្ឆ ។ ទឹកនឹងចីវរនេះ ក៏នៅជារបស់សង្ឆដដែល ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឆក៏បែកគ្នាទៅ ។ មនុស្សទាំងឡាយក្នុងទីនោះ ក៏នាំគ្នាប្រគេនទឹក ចំពោះភិក្ខុមួយពួក ប្រគេនចីវរ ចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះសង្ឆ ។ ទឹកនឹងចីវរនេះ ក៏នៅជារបស់សង្ឆដដែល ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឆក៏បែកគ្នាទៅ ។

---

១ សង្ឆបែកគ្នាជាពីរពួក ដូចពួកភិក្ខុនៅក្រុងកោសម្ពី (អដ្ឋកថា) ។

តត្ត មនុស្ឃា ឯកស្មឹ បក្ខេ ឧឧកំ ទេន្តិ ឯកស្មឹ បក្ខេ ចីវរំ ទេន្តិ បក្ខស្ស ទេមាតិ ។ បក្ខស្ស-
វេតំ ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ អនុប្ឃន្ធេ ចីវរេ សង្ហ្លា ភិជ្ជតិ ។ តត្ត មនុស្ឃា ឯកស្មឹ បក្ខេ ឧឧកំ ទេន្តិ តស្មឹយេវ បក្ខេ ចីវរំ ទេន្តិ បក្ខស្ស ទេមាតិ ។ បក្ខស្សវេតំ ។ ឥធ បន ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ ឧប្ឃន្ធេ ចីវរេ អភាជិតេ សង្ហ្លា ភិជ្ជតិ ។ សព្ពេសំ សមកំ ភាជេតព្ពន្តិ ។

[៧៧] តេន ខោ បន សមយេន អាយស្មា យសោ អញ្ញតរស្ស ភិក្ខុនោ ហត្ថេ អាយស្មតោ សារីបុត្តស្ស ចីវរំ ចាហេសិ ឥមំ ចីវរំ ថេរស្ស ទេហីតិ ។ អថ ខោ សោ ភិក្ខុ អត្តភាមត្តេ អាយស្មតោ យសស្ស វិស្ឃាសាតំ ចីវរំ អត្តហេសិ ។ អថ ខោ អាយស្មា យសោ អាយស្មតា សារីបុត្តេន សមាគន្ត្វា បុច្ឆិ អហំ ភន្តេ

មនុស្សទាំងឡាយក្នុងទីនោះ ក៏នាំគ្នាប្រគេនទឹកចំពោះភិក្ខុមួយពួក ប្រគេនចីវរចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយ ប្រគេនចំពោះពួក ។ ទឹកនិងចីវរនេះក៏នៅជារបស់ពួកដដែល ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឆក៏បែកគ្នាទៅ ។ មនុស្សទាំងឡាយក្នុងទីនោះ ក៏នាំគ្នាប្រគេនទឹកចំពោះភិក្ខុមួយពួក ប្រគេនចីវរ ចំពោះភិក្ខុមួយពួកនោះឯង ដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះពួក ។ ទឹកនិងចីវរនេះ ក៏នៅជារបស់ពួកដដែល ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឆមិនទាន់ចែក សង្ឆក៏បែកគ្នាទៅ ។ ចីវរនោះ សង្ឆត្រូវចែកដល់ពួកភិក្ខុទាំងអស់ឲ្យស្មើគ្នា ។

[៧៧] សម័យនោះឯង ព្រះវេត:ដ៏មានអាយុ បានផ្ញើចីវរទៅប្រគេនព្រះសារីបុត្តដ៏មានអាយុនឹងដៃភិក្ខុ ១ រូប ដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ព្រះថេរ:ផងចុះ ។ គ្រានោះឯង លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុនោះក៏យកចីវរនោះ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងព្រះវេត:ដ៏មានអាយុ ។ គ្រាក្រោយ ព្រះវេត:ដ៏មានអាយុបានមកជួបនឹងព្រះសារីបុត្តដ៏មានអាយុហើយសួរថា បពិត្រព្រះថេរ:ដ៏ចម្រើន

ចីវរក្ខន្ធកេ រវតត្ថេរវត្ថុវិស្សាសគ្គាហកថា

ថេរស្ស ចីវរំ ចាហេសឹ សម្ឆត្ដំ តំ ចីវរន្ដិ ។ ជាហន្ដំ អាវុសោ ចីវរំ បស្ឆាមីតិ ។ អថខោ អាយស្មា រវតោ តំ កិក្ខុ ឯតទវោច អហំ អាវុសោ អាយស្មតោ ហត្ថេ ថ- រស្ស ចីវរំ ចាហេសឹ ឥហន្ដំ ចីវរន្ដិ ។ អហំ ឥន្ដ អាយ-ស្មតោ វិស្ឆាសា តំ ចីវរំ អក្ខហេសិន្ដិ ។ ឥតរតោ ឯតមត្ថំ អារោចេសុំ ។ ឥជ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្ដ្ថាមស្ស ទេហីតិ ។ សោ អន្ដ្ដរាមគ្ដ្ដ យោ បហិណាតិ ឥស្ស វិស្ឆាសា ឥណ្ណាតិ សុក្ខហិតំ ។ យស្ស បហីយតិ ឥស្ស វិស្ឆាសា ឥណ្ណា-តិ ទុក្ខហិតំ ។ ឥជ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្ដ្ថាមស្ស ទេហីតិ ។

ខ្ញុំព្រះករុណាបានផ្ញើចីវរមកប្រគេនព្រះថេរ: តើចីវរនោះបានដល់មកហើយ ឬ ។ ព្រះសារីបុត្តឆ្វើយថា ម្នាលអាវុសោ ខ្ញុំមិនឃើញចីវរនោះទេ ។ ទើបព្រះរេវត:ដ៏មានអាយុបាននិយាយទៅនឹងភិក្ខុនោះថា ម្នាលអាវុសោ ខ្ញុំបានផ្ញើចីវរមកប្រគេនព្រះថេរ:នឹងដៃលោកដ៏មានអាយុ តើចីវរនោះនៅឯណា ។ ភិក្ខុនោះឆ្វើយថា បពិត្រព្រះថេរ:ដ៏ចម្រើន ខ្ញុំបានយកចីវរនោះ (មកប្រើប្រាស់ដោយខ្លួនឯងទៅហើយ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងលោកដ៏មានអាយុ ។ ភិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នាដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះផងចុះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើនោះក៏យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ បើភិក្ខុអ្នកទទួលបញ្ជើយកចីវរ (មកប្រើប្រាសដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នាដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះផងចុះ ។

សោ អន្តរាមក្តេ យស្ស បហីយតិ តស្ស វិស្សាសោ គណ្ហាតិ ទុក្តហិតំ ។ យោ បហិណាតិ តស្ស វិស្សាសោ គណ្ហាតិ សុក្តហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមក្តេ សុណាតិ យោ បហិណាតិ សោ កាលកតោតិ តស្ស មតកចីវរំ អធិដ្ឋាតិ ស្វធិដ្ឋិតំ ។ យស្ស បហីយតិ តស្ស វិស្សាសោ គណ្ហាតិ ទុក្តហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទេហីតិ ។ សោ អន្តរាមក្តេ សុណាតិ យស្ស បហីយតិ សោ កាលកតោតិ តស្ស មតកចីវរំ អធិដ្ឋាតិ ទ្វធិដ្ឋិតំ ។ យោ បហិណាតិ តស្ស

លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើនោះក៏យកចីវរ (មកប្រើ-ប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ បើភិក្ខុអ្នកទទួលបញ្ជើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះផងចុះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើនោះឮដំណឹងថា ភិក្ខុដែលផ្ញើចីវរមកនោះស្លាប់ទៅហើយ ។ ក៏អធិដ្ឋានមតកចីវរ[1] របស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ ។ បើភិក្ខុអ្នកទទួលបញ្ជើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះផងចុះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើនោះឮដំណឹងថា ភិក្ខុដែលចាំទទួលចីវរនោះស្លាប់ទៅហើយ ។ ក៏អធិដ្ឋានមតកចីវររបស់ភិក្ខុនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អ (អធិដ្ឋានមិនឡើង) ។ បើភិក្ខុអ្នកទទួលបញ្ជើ

---

១ ចីវររបស់ភិក្ខុដែលស្លាប់ ។

វិស្សាសា តណ្ហាតិ សុក្ខហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នামស្ស ទេហីតិ ។ សោ អន្តរាមគ្គេ សុណាតិ ឧភោ កាលកតាតិ យោ បហិណាតិ តស្ស មតកចីវរំ អធិដ្ឋាតិ ស្វធិដ្ឋិតំ ។ យស្ស បហីយតិ តស្ស មតកចីវរំ អធិដ្ឋាតិ ទ្វធិដ្ឋិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នামស្ស ទម្មីតិ ។ សោ អន្តរាមគ្គេ យោ បហិណាតិ តស្ស វិស្សាសា តណ្ហាតិ ទុក្ខហិតំ ។ យស្ស បហីយតិ តស្ស វិស្សាសា តណ្ហាតិ សុក្ខហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ

យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្ដីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ ម្នាលភិក្ខុទាំង-ឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះផងចុះ ។ លុះដល់ពាក់កណ្ដាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើនោះឮដំណឹងថា ភិក្ខុទាំងពីររូប[1] ស្លាប់ទៅហើយ ។ ក៏អធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ ។ បើភិក្ខុអ្នកទទួលបញ្ជើអធិដ្ឋានមតកចីវររបស់ភិក្ខុដែលចាំទទួលចីវរវិញ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំកុណាប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្ដាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើក៏យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្ដីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ បើភិក្ខុអ្នកទទួលបញ្ជើយកចីវរ (មកប្រើប្រាស់ ដោយខ្លួនឯងវិញ) ដោយអាងសេចក្ដីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលចីវរវិញ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា

---

១ សំដៅយកភិក្ខុអ្នកផ្ញើចីវរ ១ រូប ភិក្ខុអ្នកចាំទទួលយកចីវរ ១ រូប ។

ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទម្មីតិ ។ សោ
អន្តរាមគ្គេ យស្ស បហីយតិ តស្ស វិស្ជ្ជាសា តណ្ហាតិ
សុត្តហិតំ ។ យោ បហិណាតិ តស្ស វិស្ជ្ជាសា តណ្ហាតិ
ទុត្តហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ
ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្នាមស្ស ទម្មីតិ ។ សោ
អន្តរាមគ្គេ សុណាតិ យោ បហិណាតិ សោ កាលក-
តោតិ តស្ស មតកចីវរំ អធិដ្ឋាតិ ទ្វិធិដ្ឋិតំ ។ យស្ស
បហីយតិ តស្ស វិស្ជ្ជាសា តណ្ហាតិ សុត្តហិតំ ។ ឥធ
បន ភិក្ខវេ ភិក្ខុ ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ
ចីវរំ ឥត្ថន្នាមស្ស ទម្មីតិ ។ សោ អន្តរាមគ្គេ សុណាតិ
យស្ស បហីយតិ សោ កាលកតោតិ តស្ស មតកចីវរំ

ដោយពាក្យថា ខ្ញុំព្រះករុណាប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើនោះក៏យកចីវ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ បើភិក្ខុអ្នកទទួលបញ្ជើយកចីវរ (មកប្រើប្រាស់ ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំព្រះករុណាប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើក៏ឮដំណឹងថា ភិក្ខុដែលផ្ញើចីវរមកនោះស្លាប់ទៅហើយ ហើយក៏អធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អទេ ។ បើភិក្ខុអ្នកទទួលបញ្ជើយកចីវរ (មកប្រើ-ប្រាស់ ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំព្រះករុណាប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើនោះឮដំណឹងថា ភិក្ខុអ្នកចាំទទួលយកចីវរនោះស្លាប់ទៅហើយ ។ ក៏អធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកចាំទទួលយកចីវរនោះ

អធិដ្ឋាតិ ស្វធិដ្ឋិតំ ។ យោ បហិណាតិ តស្ស វិស្ជ-
សា តណ្ហាតិ ឧក្ខិត្តហិតំ ។ ឥធ បន ភិក្ខវេ ភិក្ខុ
ភិក្ខុស្ស ហត្ថេ ចីវរំ បហិណាតិ ឥមំ ចីវរំ ឥត្ថន្ជាមស្ស
ជម្មីតិ ។ សោ អន្តរាមគ្គេ សុណាតិ ឧភោ ការាលក-
តាតិ យោ បហិណាតិ តស្ស មតកចីវរំ អធិដ្ឋាតិ ទ្ធ-
ជិដ្ឋិតំ ។ យស្ស បហីយតិ តស្ស មតកចីវរំ អធិដ្ឋាតិ
ស្វធិដ្ឋិតំ ។

[៧៨] អដ្ឋិមា ភិក្ខវេ មាតិកា ចីវរស្ស ឧប្ជាជ-
យ សីមាយ ឧតិ ការតិការយ ឧតិ ភិក្ខាបញ្ញត្តិយា
ឧតិ សជ្ជ្ជស្ស ឧតិ ឧកតោសជ្ជ្ជស្ស ឧតិ វស្ស
ត្ថ្ជស្ស សជ្ជ្ជស្ស ឧតិ អាធិស្ស ឧតិ បុក្ខ្ជលស្ស ឧតិ ។
សីមាយ ឧតិ យាវតិការ ភិក្ខ្ជ អន្ជោសីមកតា ឧតេហិ
ការ ជ ឧតុ ។ ការតិការយ ឧតិ សម្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ

(យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ ។ បើភិក្ខុអ្នកទទួលបញ្ជើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្ដីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំព្រះករុណាប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ ។ លុះដល់ពាក់កណ្ដាលផ្លូវ ភិក្ខុអ្នកទទួលបញ្ជើនោះឮដំណឹងថា ភិក្ខុទាំងពីររូបស្លាប់ទៅហើយ ។ ក៏អធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកផ្ញើទៅនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អ ។ បើភិក្ខុអ្នកទទួលបញ្ជើអធិដ្ឋានមតកចីវររបស់ភិក្ខុអ្នកចាំទទួលចីវរនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ ។

[៧៨] ម្នាលភិក្ខុទាំងឡាយ មាតិកា (ហេតុ) ដែលនាំឲ្យកើតចីវរឡើងមាន ៨ យ៉ាងគឺ គេឲ្យចីវរក្នុងសីមា ១ គេឲ្យចីវរដោយសេចក្ដីប្ដេជ្ញា ១ គេឲ្យចីវរដោយសេចក្ដីបញ្ញត្តនៃកិក្ខា (ទីបរិច្ចាគទានរបស់ខ្លួន) ១ គេឲ្យចីវរចំពោះសង្ឆ ១ គេឲ្យចីវរចំពោះឧភតោសង្ឆ ១ គេឲ្យចីវរចំពោះសង្ឆដែលនៅចាំវស្សា ១ គេចំពោះវត្ថុ ឬកំណត់វត្ថុហើយទើបឲ្យចីវរ ១ គេឲ្យចីវរចំពោះបុគ្គល ១ ។ ដែលហៅថា គេឲ្យចីវរក្នុងសីមាគឺ (សំដៅយក) ភិក្ខុមានចំនួនប៉ុន្មានរូបដែលនៅខាងក្នុងសីមា ត្រូវភិក្ខុទាំងនោះចែកចីវរគ្នាចុះ ។ ដែលហៅថា គេឲ្យចីវរដោយសេចក្ដីប្ដេជ្ញាគឺ (សំដៅយក) អារ៉ាសច្រើន

សមានលាភា ហោន្តិ ឯកស្មឿ អាវាសេ ឯិន្ទ្ធ សព្ធ្ធ ឯិន្ទ្ធ ហោតិ ។ ភិក្ខាបញ្ញត្តិយា ទេតិ យត្ត សជ្ជ្ជ ជុវការ ការ្យន្តិ ត្ត ទេតិ[1] ។ សជ្ជ្ជ ទេតិ សម្ម្ទ្ធ ីភ្ជ្ជ ្ជ ្ជ

ជាអាវាសមានលាកស្មើគ្នា កាលបើគេឲ្យចីវរក្នុងអាវាសតែ ១ ទុកដូចជាបានឲ្យចីវរក្នុងអាវាសទាំងអស់ ។ ដែលហៅថា គេឲ្យចីវរដោយសេចក្តីបញ្ញត្តិនៃភិក្ខាគឺ (សំដៅយក) ការបូជាជានិច្ចដែលគេធ្វើ ចំពោះសង្ឆក្នុងទីណា គេក៏ឲ្យចីវរក្នុងទីនោះ ។ ដែលហៅថា គេឲ្យចីវរចំពោះសង្ឆគឺ (សំ-ដៅយក) សង្ឆដែលមកជួបជុំមុខគ្នាហើយត្រូវចែកចីវរចុះ ។ ដែលហៅថា គេឲ្យចីវរចំពោះឧកតោសង្ឆ (សំដៅយក) ភិក្ខុសូម្បីច្រើនរូប ភិក្ខុនីតែ ១ រូប សង្ឆក៏ត្រូវឲ្យចីវរពាក់កណ្តាល (ស្មើគ្នា) ។ ភិក្ខុនីសូម្បីច្រើនរូប ភិក្ខុតែ ១ រូប សង្ឆក៏ត្រូវឲ្យចីវរពាក់កណ្តាល (ស្មើគ្នា) ។ ដែលហៅថា គេឲ្យចីវរចំពោះសង្ឆដែលនៅចាំវស្សា (សំដៅយក) ភិក្ខុមានកំណត់ប៉ុន្មានរូបនៅចាំវស្សាក្នុងអាវាសនោះ ភិក្ខុទាំងនោះត្រូវចែកចីវរគ្នាចុះ ។ ដែលហៅថា ចំពោះវត្ថុ ឬកំណត់វត្ថុហើយទើបគេឲ្យចីវរគឺ (សំដៅយកត្រង់ហេតុ) ដែលគេឲ្យបបរហើយគេឲ្យចីវរផង ជួនកាលគេឲ្យកត្តហើយគេឲ្យចីវរផង ជួនកាលគេឲ្យខាទនីយ:ហើយគេឲ្យចីវរផង ជួនកាលគេឲ្យចីវរតែម្តង ជួនកាលគេឲ្យសេនាសន:ហើយគេឲ្យទាំងចីវរផង ពុំនោះសោត គេឲ្យកេ-សជ្ជ:ព្រមទាំងចីវរផង ។ ដែលហៅថា គេឲ្យចីវរចំពោះបុគ្គលគឺ (សំដៅយកត្រង់ហេតុ) ដែលគេឲ្យដោយពាក្យថា ខ្ញុំឲ្យចីវរនេះ ចំពោះភិក្ខុឈ្មោះនេះ ។

ចប់ ចីវរក្ខន្ធក:ទី ៨ ។

ក្នុងខន្ធក:នេះមាន ៩៦ រឿង ។

ចីវរក្ខន្ធកេ ឧទ្ទានគាថា

តស្សុទ្ទានំ

[៧៩] ភ១តហាកោ ឌេតមោ
ជិស្វា វេសាលិយំ ឥណ
បុន ភ១តហាំ ឥន្ធ
រញ្ញោ តំ បដិវេ១យិ ។
បុត្តោ សាលវតិកាយ
អ១យ្ស ហិ អ្ត្រជោ
ជីវតីតិ ១ុមារេ
ស១ ្ធ្ាតោ ជីវ១ោ ១ តិ ។
ស១ ហិ ១ ្ក ្ាសិ ្ ១ ្ធ
ឧ ្ ១ ្ ហ ្ ១ ្ ្ ្

ចីវរក្ខន្ធក: ឧទ្ទានគាថា

ឧទ្ទានរបស់ចីវរក្ខន្ធក:នោះគឺ

[៧៩] រឿងពួកកុដុម្ពិក:នៅក្នុងក្រុងរាជគ្រឹះ ឃើញពួកស្រីផ្ការមាសក្នុងក្រុងវេសាលី ហើយទៅក្រុងរាជគ្រឹះវិញ ក៏បានក្រាបទូលសេចក្ដីនុ៎ះដល់ស្ដេច ១ ។ រឿងកូនប្រុសនៃស្រីផ្ការ-មាសឈ្មោះសាលវតី ត្រឡប់បានមកជាកូនអភយរាជកុមារវិញ ព្រះរាជកុមារបានចិញ្ចឹមទុកឲ្យឈ្មោះថា ជីវក: ព្រោះហេតុតែពាក្យសួរថា កូននោះមានជីវិតរស់នៅឬស្លាប់ ១ ។ រឿងជីវកកោមារភត្យទៅក្រុងតក្កសិលា រៀនធ្វើពេទ្យបានជាមហាពេទ្យហើយមើលជំងឺ ក្នុងក្បាលភរិយារបស់សេដ្ឋីដែលឈឺ ៧ ឆ្នាំ ឲ្យសះជាដោយនត្ថុកម្ម គឺការបញ្ជ្រាកថ្នាំទៅតាមច្រមុះ ១ ។ រឿងជីវកកោមារភត្យទាញចេញ (មើលជា) អាពាធឫសដូងបាតនៃព្រះបាទពិម្ពាសារ ដោយថ្នាំលាប ។ ព្រះរាជាទ្រង់មានបន្ទូលនឹងកោមារភត្យថា អ្នកឯងចូរបម្រើអញផង ពួកស្រីក្នុងវាំងផង ព្រះពុទ្ធនិងព្រះសង្ឆផង ១ ។

ភ១ជកហាគោ ច សេដ្ឋី
អន្ត្ដកណ្ហិ តិកិច្ឆិ តំ
បជ្ជោ ត ស្ស មហាភោ តំ
ឃ ជ ចា ណេ ន ជ ាសយិ ។
អ ធិ ការ ញ្ច សិ ។ យ ្យ ។
អ ភ ិ ស ន ្ធ ំ ។ (១) ។
ត ី ហ ិ ។ ឧ ប ្ប ល ហ ា ត ្ត េ ហ ិ
ស ម ត ្ត ឹ ស ว ิ ว េ ច ន ំ
ប ក ត ត ្ត ំ ว ำ ។ យ ា ច ិ
ស ิ ว ย ្ย ญ ฺ ฺ ฺ

រឿងសេដ្ឋីនៅក្នុងក្រុងរាជគ្រឹះ ១ រឿងជីវកកោមារភត្យ មើលអាពាធពកក្នុងពោះវៀន ១ រឿងជីវកកោមារភត្យ ញ៉ាំងមហាពោគនៃព្រះបាទបជ្ជោតឲ្យសះជាទៅ ព្រោះសោយទឹកដោះរាវ ។ ជីវកកោមារភត្យក្រាបទូលថា សូមឲ្យព្រះបាទបជ្ជោតរឭកអធិការរបស់ខ្ញុំន រួចទ្រង់បានផ្ញើសំពត់សិវេយ្យក: មួយគូមកជីវកកោមារភត្យ ១ រឿងជីវកកោមារភត្យញ៉ាំងកាយព្រះមានព្រះភាគដែលមានពោគទល់ឲ្យស្រួល ហើយបានថ្វាយថ្នាំបញ្ចុះ ៣០ ដងដោយផ្ការ ឧប្បល ៣ ក្តាប់ ព្រះមានព្រះភាគក៏មានព្រះកាយជាប្រក្រតី ទើបទ្រង់ទទួលសំពត់សិវេយ្យក:ដែលជីវកកោមារភត្យសុំពរ ហើយថ្វាយព្រះអង្គ ១ រឿងព្រះតថាគតអនុញ្ញាតគហបតីចីវរ ១ ។ រឿងចីវរកើតឡើងជាច្រើនក្នុងក្រុងរាជគ្រឹះ ១ ក្នុងជនបទ ១ រឿងព្រះមានព្រះភាគអនុញ្ញាតសំពត់ឈ្នោះបាវារ: ធ្វើដោយសូត្រ ១ សំពត់កោជវ:ធ្វើដោយរោម ១ រឿងស្តេចក្នុងដែនកាសីបញ្ជូនសំពត់កម្ពលមានតម្លៃកន្ទ:ពាន់មកជីវកកោមារភត្យ ១

ចីវរក្ខន្ធកេ ឧទ្ទានគាថា

ឧច្ចាវចា ច សន្ធ្យុដ្ឋិ

ជាតមេសាតមេសុ ច

បឋមំ បច្ឆា សនិសា

ភតិកា ច បដិហារុំ

ភណ្ឌាការំ អតុត្តញ្ច

រុដ្ឋាបេន្តិ តថេវ ច

ឧស្ឆ្ឍុំ ភោលាហាលញ្ច

ភជ្ជ ភាជ ភជ្ជ ជនេ

សភាតិបេភភាគេន

ចីវរក្ខន្ធក: ឧទ្ទានគាថា

រឿងចីវរខ្ពស់និងទាបកើតឡើងដល់សង្ឆហើយ ព្រះអង្គទ្រង់សរសើរសេចក្តីសន្តោស ១ រឿងព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតកុំឲ្យភិក្ខុឲ្យចំណែកចីវរដល់ភិក្ខុដែលមិនបានឈប់ចាំគ្នា ១ រឿងព្រះដ៏មានព្រះភាគអនុញ្ញាតឲ្យភិក្ខុឲ្យចំណែកចីវរដល់ភិក្ខុដែលឈប់ចាំគ្នា ១ រឿងភិក្ខុចូលទៅកាន់ព្រៃស្មសានមុន និងចូលទៅកាន់ព្រៃស្មសានក្រោយ ១ រឿងភិក្ខុចូលទៅក្នុងព្រៃស្មសានដំណាលគ្នា ១ រឿងភិក្ខុធ្វើសេចក្តីប្តេជ្ញានឹងគ្នាហើយចូលទៅក្នុងព្រៃស្មសានដើម្បីបង្ស៊ីកូល ១ រឿងពួកមនុស្សនាំយកចីវរមកកាន់អារាម លុះរកភិក្ខុអ្នកទទួលមិនបានក៏នាំត្រឡប់ទៅវិញ ១ រឿងព្រះសាស្តាអនុញ្ញាតឲ្យភិក្ខុសន្ទតឃ្វាំងដាក់ចីវរ ១ រឿងចីវរក្នុងឃ្វាំងឥតមានអ្នកណាថែរក្សា ១ រឿងធព្ធគ្គិយភិក្ខុបណ្តេញភិក្ខុអ្នករក្សាឃ្វាំង ១ រឿងចីវរកើតឡើងក្រាស់ក្រែល ១ រឿងសង្ឆចែកចីវរធ្វើឲ្យកោលាហល ១ រឿងភិក្ខុអ្នកចែកចីវររិះគិតថា យើងត្រូវចែកចីវរដូចម្តេច ១ រឿងភិក្ខុអ្នកចែកចីវររិះគិតថា យើងត្រូវឲ្យចំណែកចីវរដល់សាមណេរដូចម្តេច ១ រឿងភិក្ខុមានសេចក្តីប្រាថ្នានឹងធ្វើបឹងឬផ្ទះលំបាកយកទាំងចំណែកចីវររបស់ខ្លួនទៅផង ១

បជិវិសោ ភេជ្ជ ជនេ

ឆកណេន សីតុណ្ហា ច

ឧត្តរិតុំ ន ជានរ

ឧ្ហេបេត្តា ភាជនញ្ច

ចាតិយា ច ឆមាយ ច

ឧបចិកា មជ្ឌ ជីវន្តិ

ឯកតោ បត្ថិនេន ច

ផរុសាធិន្ទ្ធ ចិ ពន្ធ

អន្ធសាសិ ឧកណ្ហិ ភេ

រីមំ សិត្ថ សក្យមុនិ

អនុញ្ញាសិ តិចីវរំ

រឿងភិក្ខុមានសេចក្តីប្រាថ្នា នឹងធ្វើសម្ងឹងឬផ្ទូរលំបាកយកទាំងចំ-
ណែកចីវរដែលមានតម្លៃច្រើនជាងគេ ១ រឿងភិក្ខុអ្នកចែកចីវ
រិះគិតថា យើងត្រូវឲ្យចំណែកចីវរដូចម្តេច ១ រឿងភិក្ខុជ្រលក់
ចីវរដោយអាចម៍គោ ១ រឿងភិក្ខុជ្រលក់ចីវរដោយទឹកត្រជាក់និង
ទឹកក្តៅ ១ រឿងទឹកជ្រលក់ពុះផុលកំពប់ ១ រឿងភិក្ខុមិនដឹងថា
ទឹកជ្រលក់ធ្ពិនឬមិនធ្ពិន ១ រឿងភិក្ខុសិតទឹកជ្រលក់ ធ្នាំងក៏បែក
ទៅ ១ រឿងភិក្ខុគ្មានភាជន៍សម្រាប់ដាក់ទឹកជ្រលក់ ១ រឿងភិក្ខុ
ជ្រលក់ចីវរក្នុងផើង ១ រឿងភិក្ខុហាលចីវរលើផែនដី ១ រឿងសត្វ
កណ្តៀរកាត់កម្រាលស្មៅ ១ រឿងភិក្ខុហាលចីវរបត់ចំទីពាក់
កណ្តាល ១ រឿងចីវរវេច ១ រឿងទឹកជ្រលក់ហូរទៅតែម្ខាង ១
រឿងភិក្ខុជ្រលក់ចីវរដិតពេក ១ រឿងចីវរអាក្រក់ ១ រឿងធ្ងូគ្គិយ-
ភិក្ខុទ្រទ្រង់ចីវរមិនកាត់ ១ រឿងស្រីអ្នកមគធ:មានសណ្ឋាន
ជាបួនជ្រុង ១ រឿងព្រះមានព្រះភាគបានទតឃើញភិក្ខុទាំង-
ឡាយ រេចចីវរធ្វើជាបង្ហេច ១ រឿងព្រះសក្យមុនីទ្រង់ឈ្ងង
មើលរដូវត្រជាក់ក្នុងវេលាយប់ ហើយទ្រង់អនុញ្ញាតត្រៃចីវរ ១

ចីវរក្ខន្ធកេ ឧទ្ទានគាថា

អញ្ញេន អតិរេកេន
ឧប្ផជ្ជិ ធិក្ខមេ ច
ចាតុទ្ទីចោ រវំ យាចិ
ជាតុំ រស្ជិកសាដិកំ
អាកន្ត្តុតមិកិលាដ
ឧបជ្ជាកញ្ច ភេសជ្ជំ
ជុរ ឧឧកសាដ ច
បណ្ណីតំ អតិខុទ្ធកំ
ជុលកច្ច មុ១ ១ោ
បរិបុណ្ណ អធិដ្ឋ
បច្ចិ ១ ១ ១ ១ ១
ជ ១ ១ ១ ១ ១
ជ ១ ១ ១ ១ ១
ជ ១ ១ ១ ១ ១
ជ ១ ១ ១ ១ ១
ជ ១ ១ ១ ១ ១

ចីវរក្ខន្ធក: ឧទ្ទានគាថា

រឿងធ្ងគ្គិយភិក្ខុទ្រទ្រង់អតិរេកចីវរដទៃ ៣ ១ រឿងព្រះអានន្ទ
បានអតិរេកចីវរ ១ រឿងភិក្ខុស្ស្ងប់ធ្ងុ: ១ រឿងកៀងធ្លាក់សព្ទទ្វីប
ទាំងបួន ១ រឿងនាងវិសាខាសុំពរដើម្បីប្រគេនវស្សិកសាដិក:
អាគន្ទុកភត្ត គមិកភត្ត គិលានភត្ត ឧបដ្ឋាកភត្ត ភេសជ្ជ: ធុវយាគុ
និងឧទកសាដិក: ១ រឿងភិក្ខុធាន់បណ្ដាតភោជន ១ រឿង
សំពត់និសីទនតូចពេក ១ រឿងព្រះវេលដ្ឋសីសកើតបូសធំ ១
រឿងព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសំពត់ជូតមុខ ១ រឿង
ពោជមល្ហក្សត្រធ្វើសំពត់សម្បកឈើទុកនឹងព្រះអានន្ទ ១ រឿង
ត្រៃចីវរបរិបូណ៌កើតឡើងដល់ភិក្ខុ ១ រឿងព្រះអង្គទ្រង់អនុញ្ញាត
ឲ្យភិក្ខុអធិដ្ឋានត្រៃចីវរជាដើម ១ រឿងព្រះអង្គទ្រង់អនុញ្ញាតឲ្យ
វិកប្បចីវរយ៉ាងតូចបំផុត ១ រឿងព្រះកស្សបធ្វើសេចក្ដីគោរព
ក្នុងការដេរប៉ះសំពត់បង្ស្ងកូល ១ រឿងចីវរមានជាយមិនស្មើ
គ្នា ១ រឿងចេសរសាត់ចេញ ១ រឿងស្រទាប់សង្ឆាដិដាច់
ចេញពីគ្នា ១ រឿងភិក្ខុកាត់ចីវរសំពត់មិនគ្រាន់ ព្រះអង្គទ្រង់
អនុញ្ញាតឲ្យលើកឡើងនូវអាគន្ទុកបដ: ១ រឿងចីវរច្រើនកើត

អន្ធវនេ អសតិយា

ឯកោ វស្សំ ឧតុម្ហិ ច

ទ្វេ ភាតុកា ภาชตเหา

ឧបនន្ទោ បុន ទ្វិសុ

ការ្ចិវិការេ តិលាតោ

ឧភោ ចេវ តិលាយនា

ជក្ខា ការ ภาคชีรํ

ផលកំ[1] ភេសកម្ពលំ

ภาลขลูคปกฺขญฺ

អជិនំ អក្ខជាលកំ

ចោត្តកំ នីលបីតញ្ច

---

១ ឱ. ថលកោ ។

ទ្បើងដល់ភិក្ខុ ១ រឿងភិក្ខុទុកចីវរក្នុងអន្ទរ៉ែន (ព្រៃងងឹត) ១ រឿងព្រះអានន្ទមានតែស្បង់និងឧត្តរាសង្ក: ចូលទៅបិណ្ឌបាតក្នុងស្រុកដោយភ្ជេចស្មារតី ១ រឿងភិក្ខុចាំវស្សាតែម្នាក់ឯង ១ រឿងភិក្ខុនៅតែម្នាក់ឯងអស់មួយរដូវ ១ រឿងព្រះថេរៈពីររូបជាបងប្អូននឹងគ្នានៅចាំវស្សាក្នុងក្រុងសាវត្ថី ១ រឿងភិក្ខុបីរូបនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ១ រឿងព្រះឧបនន្ទនៅចាំវស្សាក្នុងក្រុងសាវត្ថី ១ រឿងព្រះឧបនន្ទនៅចាំវស្សាតែម្នាក់ឯងក្នុងអារ៉ាសទាំងពីរ ១ រឿងភិក្ខុមានអាពាធវិការក្នុងពោះ ១ រឿងភិក្ខុមួយរូបមានជំងឺ ១ រឿងជនទាំងពីរ គឺភិក្ខុមួយរូបសាម-ណេរមួយរូបបម្រើភិក្ខុមានជំងឺ ១ រឿងភិក្ខុអាក្រាត ១ រឿងភិក្ខុស្ងៀកសំពត់ធ្វើពីស្ស្ងរភ្ជាំង ១ រឿងភិក្ខុស្ងៀកសំ-ពត់ធ្វើពីសម្ជកឈើ ១ រឿងភិក្ខុស្ងៀកសំពត់ធ្វើពីផ្ទៃនក្ការ ១ រឿងភិក្ខុស្ងៀកសំពត់កម្ពលធ្វើពីសក់ ១ រឿងភិក្ខុស្ងៀកសំពត់ធ្វើពីពោមកន្ទុយសត្ត ១ រឿងភិក្ខុស្ងៀកសំពត់ធ្វើពីស្ងាបមៀម ១ រឿងភិក្ខុស្ងៀកសំពត់ធ្វើពីស្ស្ងកខ្ចា ១ រឿងភិក្ខុស្ងៀកសំពត់ធ្វើពីដើមរាក់ ១ រឿងភិក្ខុស្ងៀកសំពត់ធ្វើពីសម្ជកក្រចៅ ១ រឿងឆព្ជគ្ជិយភិក្ខុប្រើចីវរមានពណ៌ខ្ចៀ ពណ៌លឿង

ចីវរក្ខន្ធកេ ឧទ្ទានគាថា

លោហិតំ មញ្ជេដ្ឋេ ច
កណ្ណា មហារដ្ឋជាម-
អច្ឆិន្ទនសិកា តថា
ឌីឃបុប្ផជលនសា[1]
ភញ្ជុតិរីដវេឋនំ
អនុប្ឋន្ទ បក្ខមតិ
សជ្ជោ ភិជ្ជតិ តាវនេ
បក្ខ ឧនន្ត្ថ សជ្ជ្ឍ
អាយស្ម ឋវតោ ឋហិ
ឋិស្ឍ្ឍ្ឍ្ឍ្ឍ្ឍ្ឍ
អដ្ឋ ចីវរមាតិកាតិ ។

---

១ ផលទ្ទសាតិ ឌ. ឋោត្ថកេ ទិស្ស្ឍ្ឍ ។

ចីវរក្ខន្ធក: ឧទ្ទានគាថា

ពណ៌ក្រហម ពណ៌ហង្សបាទ ពណ៌ខ្មៅ ពណ៌ក្រហមក្រមៅដូចខ្នងក្អែប ពណ៌លឿងទុំដូចផ្កាឈូក មានជាយមិនកាត់ មានជាយវែង មានជាយមានផ្កាជាផ្កាឈើ មានជាយមានផ្កាជាផ្លែឈើ អាវ មួក និងសំពត់ឈ្នួត ១ រឿងចីវរមិនទាន់កើតឡើង ភិក្ខុចៀសចេញទៅ ១ រឿងសង្ឆបែកគ្នា ១ រឿង ពួកជនប្រគេនទឹកមួយចំណែកនិងចីវរមួយចំណែកចំពោះសង្ឆ ១ រឿងព្រះវេត:ដ៏មានអាយុផ្ញើចីវរ ១ រឿងភិក្ខុកាន់យកចីវរដោយសេចក្តីស្និទ្ធស្នាល ១ រឿងភិក្ខុអធិដ្ឋានមតកចីវរ ១ រឿងមាតិកានាំឲ្យកើតចីវរមានប្រាំបីយ៉ាង ១ ។

ចម្បេយ្យក្ខន្ធកំ

[៨០] តេន សមយេន ពុទ្ធោ ភគវា ចម្ប្យាយំ
វិហរតិ គគ្គរាយ ១ បោក្ខរណិយា តីរេ ។ តេន ខោ បន
សមយេន ការីសុ ជនបទេសុ រាសភតាមោ ជាម
ហោតិ ។ តត្ត ការ្ជ្ជបតោត្តោ ជាម ភិក្ខុ អាវាសិកោ
ហោតិ ។ តត្ថ ពុទ្ធោ ឧស្ស្ដ្ឋ អាបន្ន ការ្ជ្ជ អជ្ជតតា
ច ២ សលា ភិក្ខូ អាតច្ចយ្យ អាតតា ច ២ សលា
ភិក្ខូ ជាសុ ២ យ្យ អយ្ជ អាវាសោ ២ ២ ២ ២-
២ ២ អាបជ្ជ ២ ។ ២ ២ ២ ២
២ ២ ២ ២ ២ ២ ២ ២ ២ ២-
២ ២ ២ ២ ២ ២ ២ ២ ២ ២
ភិក្ខូ ២ ២ ២ ២ ២ ២ ២ ២ ២ ២-
ជ

ចម្ប្យ្យ្ក្ខ្ន្ធ:

[៨០] សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នាផ្ទ្ះ
ប្ចាក្ខ្ណ្ណ្ណ

ចម្បេយ្យក្ខន្ធកេ កស្សបគោត្តភិក្ខុវត្ថុ

អាតន្ត្ដកានំ ភិក្ខូនំ ឯតទហោសិ ភន្ទកោ ខោ អយំ អាវុសោ អាវាសិកោ ភិក្ខុ ជហាតេ ឧស្សុក្កំ ករោតិ ឧស្សុក្កំបិ ករោតិ យាគុយា ខាទនីយេ ភត្ដស្មឿ ហន្ទ មយំ អាវុសោ ឥធេវ វាសភតាមេ ជិវាសំ ករេ្យមាតិ ។ អថខោ តេ អាតន្ត្ដកា ភិក្ខូ តត្ដេវ វាសភតាមេ ជិវាសំ ករេ្យសុំ ។ អថខោ ករេ្ដបគោត្ដស្ស ភិក្ខុ-ណោ ឯតទហោសិ យោ ខោ ឥមេសំ អាតន្ត្ដកានំ ភិក្ខូនំ អាតន្ត្ដកកិលមថោ សោ បដិប្ដស្ដ្ដោ យេ-ឬមេ គោចរេ អប្ដកតញ្ញូណោ ឥធានីមេ គោចរេ ប-ករតញ្ញូណោ ជុក្ករំ ខោ បន ឬរកុលេសុ យាវជីវំ ឧស្ដ្ដុក្ករ ការតុំ ១ញ្ញត្ដិ ច មនុស្ដ្ដានំ អមជាចា យន្ទ្ធជាហំ ជ ឧស្ដ្ដុក្ករ ករេយ្យ យាគុយា ខាទនីយេ ភត្ដស្ដ្ដិ ។ សោ ជ ឧស្ដ្ដុក្ករ អការិ យាគុយា ខាទនីយេ ភត្ដ-ស្ដ្ដ ។ អថខោ តេសំ អាតន្ត្ដកានំ ភិក្ខូនំ ឯតទហោ-សិ បុព្ដ្ដ ខ្ដ្ដាយ អាវុសោ អាវាសិកោ ភិក្ខុ ជហា-ណ ឧស្ដ្ដុក្ករ ករោតិ ឧស្ដ្ដុក្ករ១ិ ករោតិ យាគុយា ខាទនីយេ ភត្ដស្ដ្ដ សោជានាយ ជ ឧស្ដ្ដុក្ករ ករោតិ

ម្នាលអាវុសោទាំងឡាយ ភិក្ខុជាម្ចាស់អាវាសនេះល្អណាស់ ធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងការងូត ធ្វើសេចក្ដីខ្ជិលខ្ជាយ ក្នុងបបរនិងខាទនីយ:និងភត្តទៀត ម្នាលអាវុសោទាំងឡាយ បើដូច្នេះ យើងនឹងសម្រេចការនៅក្នុងវាសកគ្រាមនេះចុះ ។ គ្រានោះ ពួកអាគន្ដុកភិក្ខុនោះ ក៏សម្រេចការនៅក្នុងវាសកគ្រាមនោះឯង ។ ភិក្ខុឈ្មោះកស្សបគោត្តមានសេចក្ដីត្រិះរិះក្នុងពេលនោះដូច្នេះថា សេចក្ដីលំបាកដោយកិច្ចជាអាគន្ដុករបស់អាគន្ដុក-ភិក្ខុទាំងនេះ ក៏សូប់រម្ងាប់ទៅហើយ ឥឡូវភិក្ខុទាំងឡាយនោះ ដែលមិនស្គាល់ទីគោចរជាប្រក្រតី ក៏ត្រឡប់ស្គាល់ហើយ ឯការធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងត្រកូលនៃបុគ្គលដទៃ អស់មួយជីវិត ជាការកម្រពេកណាស់ម្យ៉ាងទៀត ការសូមមិនជាទីគាប់ចិត្ដដល់មនុស្សទាំងឡាយ បើដូច្នោះគួរតែអញកុំធ្វើសេចក្ដីខ្ជិលខ្ជាយ ក្នុងបបរនិងខាទនីយ:និងភត្តទៀត ។ ភិក្ខុឈ្មោះកស្សបគោត្ដនោះ លែងធ្វើសេចក្ដីខ្ជិលខ្ជាយ ក្នុងបបរនិងខាទ-នីយ:និងភត្ត ។ សេចក្ដីប្រឹក្សាដូច្នេះ កើតមានដល់ភិក្ខុអាគន្ដុក:នោះថា ម្នាលអាវុសោទាំងឡាយ ពីដើមភិក្ខុជាម្ចាស់អាវាសនេះ ធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងការងូត ធ្វើសេចក្ដីខ្ជិលខ្ជាយ ក្នុងបបរនិងខាទនីយ:និងភត្តទៀត ឥឡូវភិក្ខុជាម្ចាស់អាវាសនោះ លែងធ្វើសេចក្ដីខ្ជិលខ្ជាយ

យាតុយា ១ាតនីយេ ១ត្ត១ឺ ១ុ១្ជោ១ាតាយ០ អាវុសោ អាវាសិ១ោ ១ិ១្ខុ ហ១ួ ម០ យ០ អាវុសោ ឥ០ម០[1] អាវ-សិ១ំ ១ិ១ុ០ ១ុ១ិ១ាមាតិ ។ អ១ោ ១ោ អាត១ុ១ា ១ិ១ិ១ួ ស១ិ្ឋ១ិ១ិ១ា ១ស្ស១ោ១ុ០ ១ិ១ុ០ ១ត១ោ១ុ០ ១ុ១ ១ោ ១ុ០ អាវុសោ ១ហា១ ១ុ១ុ១ុ១ ១ុ១ុ១ុ-១ិ ១ុ១ុ១ យាតុយា ១ាតនីយេ ១ត្ត១ឺ ១ោ១ាតិ ១ុ០ ១ ១ុ១ុ១ ១ុ១ុ១ យាតុយា ១ាតនីយេ ១ត្ត១ឺ អ១ត្ត១ ១ុ០ អាវុសោ អ១ណ្ណ ១ស្ស១ោ១ ១ ១

ក្នុងបបរនិងខាទនីយ:និងកត្តហើយ ម្នាលអាវុសោទាំងឡាយ ឥឡូវនេះ ភិក្ខុជាម្ចាស់អាវាសនេះ ត្រឡប់ទៅជាកាចវិញហើយ ម្នាលអាវុសោទាំង-ឡាយ បើដូច្នោះ គួរយើងទាំងឡាយលើកវត្តភិក្ខុជាម្ចាស់អាវាសនេះ ។ គ្រានោះឯង ពួកភិក្ខុជាអាគន្តុកនោះ ប្រជុំគ្នាហើយបាននិយាយពាក្យនេះ នឹងភិក្ខុឈ្មោះកស្សបគោត្តថា ម្នាលអាវុសោ ពីដើមលោកធ្វើសេចក្តីខ្ជិល ខ្ជាយក្នុងការងូត ធ្វើសេចក្តីខ្ជិលខ្ជាយក្នុងបបរ និងខាទនីយ:និងកត្ត ឥឡូវ នេះលោកលែងធ្វើសេចក្តីខ្ជិលខ្ជាយ ក្នុងបបរនិងខាទនីយ:និងកត្ត ម្នាល អាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះឬទេ ។ ភិក្ខុ ជាម្ចាស់អាវាសនោះធ្វើយថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំគប្បីឃើញ នោះខ្ញុំគ្មានទេ ។ លំដាប់នោះ ពួកភិក្ខុជាអាគន្តុកនោះលើកវត្តភិក្ខុ ឈ្មោះកស្សបគោត្ត ព្រោះមិនឃើញអាបត្តិ ។ ភិក្ខុឈ្មោះកស្សបគោត្ត មានសេចក្តីត្រិះរិះក្នុងពេលនោះថា អាត្មាអញមិនដឹងនូវហេតុនេះថា នេះ ជាអាបត្តិ ឬមិនមែនជាអាបត្តិ ម្យ៉ាងទៀត អញត្រូវអាបត្តិហើយ ឬមិនទាន់ ត្រូវទេ សង្ឃ (គួរ) លើកវត្តអញ ឬមិន (គួរ) លើកវត្តទេ ដោយកម្ម ប្រកបដោយធម៌ ឬមិនប្រកបដោយធម៌ទេ ដោយកម្មដ៏ក្រៀម ឬមិនក្រៀម ទេ ដោយកម្មគួរដល់ហេតុ ឬមិនគួរដល់ហេតុទេ បើដូច្នោះ មានតែអញ

ចម្បេយ្យក្ខន្ធកេ កស្សបគោត្តភិក្ខុវត្ថុ

ចម្បំ ឥន្ធ ភគវន្តំ ឯតមត្ថំ បុច្ឆេយ្យន្តិ ។ អថខោ
កស្សបគោត្តោ ភិក្ខុ សេនាសនំ សំសាមេត្វា បត្តចីវ-
មាទាយ យេន ចម្ប តេន បក្កាមិ អនុបុព្វេន យេន
ចម្ប យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគ-
វន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អាចិណ្ណា ខោ ប-
ទេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធឹ បដិ-
សម្មោទិតុំ ។ អថខោ ភគវា កស្សបគោត្តំ ភិក្ខុំ ឯតទ-
វោច កច្ចិ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិ សិ
អប្ផកិលមថេន អទ្ធានំ អាគតោ ឥតោ ច ត្វំ ភិក្ខុ
អាគច្ឆសីតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា
អប្ផកិលមថេន ចាហំ ភន្តេ អទ្ធានំ អាគតោ អត្ថិ
ភន្តេ ការាសីសុ ជនបទេសុ វាសភគាមោ ជាម តត្ថ-
ហំ អាវាសិកោ តន្តិពន្ធោ ឧស្សុក្កេ អាបន្នោ ភិន្ទ

គប្បីទៅកាន់ក្រុងចម្បា ហើយក្រាបបង្គំទូលសួរសេចក្តីនេះ នឹងព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ភិក្ខុឈ្មោះកស្សបគោត្តរៀបចំទុកដាក់សេនាសន: ហើយកាន់យកបាត្រនិងចីវរ ចៀសចេញទៅកាន់ក្រុងចម្បា ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ ឯក្រុងចម្បាដោយលំដាប់ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ការរាក់ទាក់មួយអន្ទើដោយភិក្ខុទាំងឡាយជាអាគន្តុក:នេះ ជាប-រណីរបស់ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលនេះនឹងភិក្ខុឈ្មោះកស្សបគោត្តថា ម្នាលភិក្ខុ អ្នកឯងអាចអត់ទ្រាំសេចក្តីទុក្ខបានឬទេ អាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ អ្នកឯងមកកាន់ផ្លូវធ្ងាយមិនលំបាកទេឬ ម្នាលភិក្ខុ ម្យ៉ាងទៀត អ្នកមកពីណា ។ ភិក្ខុឈ្មោះកស្សបគោត្តក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គអាចអត់ធន់សេចក្តីទុក្ខបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកកាន់ផ្លូវធ្ងាយ ដោយមិនមានសេចក្តីលំបាកទេ បពិត្រព្រះអង្គដ៏ចម្រើន ស្រុកឈ្មោះវាសក: មានក្នុងកាសីជនបទ ខ្ញុំព្រះអង្គជាម្ចាស់អាវាសក្នុងស្រុកឈ្មោះវាសក:នោះ ជាប់ជំពាក់ ដោយការរៀបចំក្នុងអាវាសនោះ ដល់នូវសេចក្តីខ្ជល់ខ្ជាយថា ធ្វើដូចម្តេច

អជានតា ច បេសលា ភិក្ខូ អាតច្ចេយ្យុំ អាតតា ច បេ-
សលា ភិក្ខូ ជាសុំ វិហរេយ្យុំ អយញ្ច អាវាសោ រុឌ្ឍី
រ្យុឌ្ឍី រេបុលុំ អាបជ្ជេយ្យាតិ អថខោ ភគ្គេ សម្ពហុលា ភិក្ខូ
ការាសីសុ ចារិកំ ចរមានា យេន ឱ្យសភគាមោ តទវស-
រិសុ អទ្ធសំ ខោ អហំ ភគ្គេ តេ ភិក្ខូ ទ្ធរតោ ១ អា-
ភច្ចេ ជិស្ងាន អាសនំ បញ្ញាបេសឺ ចាគោទកំ ចាទបីបំ
ចាទកថលិកំ ឧបនិក្ខិបឺ បចុក្ត្ធ្ងា បត្ត្ធ ចីវរំ បជិក្ត្ធហេសិ
ចានីយេន អាបុច្ឆ ជហាគេ ឧស្ស្ធ្ងាក្ត្ធ អការ្ធ ឧស្ស្ធ្ងាក្ត្ធ
អការ្ធ យាតុយា ខាទនីយេ ភត្ត្ធ ១ អថខោ គេ
ភគ្គេ អាតត្ត្ធការ្ធ ភិក្ខូ ជហាគេ ឧស្ស្ធ្ងាក្ត្ធ
ការ្ធ ឧស្ស្ធ្ងាក្ត្ធ ការ្ធ យាតុយា ខាទនីយេ ភត្ត-
១ ១ ១

ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ដែលមិនទាន់មក គប្បីឲ្យមកផង ភិក្ខុដែលមានសីលជាទីស្រឡាញ់មកដល់ហើយ គប្បីនៅសប្បាយផង ម្យ៉ាងទៀត អាវាសនេះ គប្បីដល់នូវសេចក្តីចម្រើនលូតលាស់ទូលំ-ទូលាយ បពិត្រព្រះអង្គដ៏ចម្រើន ពេលនោះ មានពួកភិក្ខុជាច្រើនរូបត្រេចទៅកាន់ចារិកក្នុងកាសីជនបទក៏បានទៅដល់វាសកគ្រាម បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញពួកភិក្ខុនោះមកពីចម្ងាយ លុះឃើញហើយក៏ក្រាលអាសនៈតម្កល់ទឹកលាងជើង តាំងសម្រាប់ទ្រជើង និងវត្ថុសម្រាប់ជូតជើង ហើយក្រោកទទួលនូវបាត្រនិងចីវរ អើពើដោយទឹកធាន់ បានធ្វើសេចក្តីខ្ជិលខ្ជាយក្នុងការងូត បានធ្វើសេចក្តីខ្ជិលខ្ជាយក្នុងបបរនិងខាទនីយៈនិងភត្តទៀត បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីប្រឹក្សាដូច្នេះមានដល់ភិក្ខុទាំងឡាយជាអាគន្តុកៈនោះក្នុងពេលនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាម្ចាស់អាវាសនេះល្អណាស់ ធ្វើសេចក្តីខ្ជិលខ្ជាយក្នុងការងូត ធ្វើសេចក្តីខ្ជិលខ្ជាយក្នុងបបរនិងខាទនីយៈនិងភត្តទៀត ម្នាលអាវុសោទាំងឡាយ បើដូច្នោះ មានតែយើងទាំងឡាយនឹងសម្រេចការនៅក្នុងវាសកគ្រាមនេះឯង បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ពួកភិក្ខុជាអាគន្តុកៈនោះសម្រេចការនៅក្នុងវាសកគ្រាមនោះ បពិត្រព្រះអង្គដ៏ចម្រើន

ចម្បេយ្យក្ខន្ធកេ កស្សបគោត្តភិក្ខុវត្ថុ

ឯតទហោសិ យោ ខោ ឥមេសំ អាតន្ត្ពុកានំ ភិក្ខូនំ អា-
តន្ត្ពុកកិលមថោ សោ បដិប្ប ស្ស ទ្ធោ យេ ២ មេ គោ ១ ២
អ ២ ១ ១ ១

ចម្បេយ្យក្ខន្ធក: រឿងកស្សបគោត្តភិក្ខុ

សេចក្ដីត្រិះរិះនេះមានដល់ខ្ញុំព្រះអង្គថា ការលំបាក ដោយអាគន្ដុកកិច្ចរបស់អាគន្ដុកភិក្ខុទាំងនេះក៏សូប់រម្ងាប់ទៅហើយ ឥឡូវ ភិក្ខុទាំងឡាយដែលមិនស្គាល់ទីគោចរជាប្រក្រតីនោះ ក៏បានស្គាល់ហើយ ការធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងត្រកូលនៃបុគ្គលដទៃ អស់មួយជីវិតជាការកម្រពេកណាស់ ម្យ៉ាងទៀត ការសូមក៏មិនជាទីគាប់ចិត្ដដល់មនុស្សទាំងឡាយឡើយ បើដូច្នោះ គួរតែអាត្មាអញលែងធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងបបរ និងខាទនីយ:និងភត្ដទៀត បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះលែងធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងបបរនិងខាទនីយ:និងភត្ដទៀត បពិត្រព្រះអង្គដ៏ចម្រើន ក្នុងពេលនោះ ភិក្ខុជាអ-គន្ដុក:ទាំងនោះបានប្រឹក្សាគ្នាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ពីដើមភិក្ខុជាម្ចាស់អាវាសនេះធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងការងូត ធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងបបរនិងខាទនីយ:និងភត្ដទៀត ឥឡូវ ភិក្ខុនោះលែងធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងបបរនិងខាទនីយ:និងភត្ដហើយ ម្នាលអាវុសោទាំងឡាយ ឥឡូវភិក្ខុជាម្ចាស់អាវាសនេះកាចណាស់ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ មានតែយើងទាំងឡាយនឹងលើកវត្ដភិក្ខុជាម្ចាស់អាវាសនេះ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួកភិក្ខុជាអាគន្ដុក:នោះប្រជុំគ្នាហើយនិយាយពាក្យនេះនឹងខ្ញុំព្រះអង្គថា ម្នាលអាវុសោ ពីដើមអ្នកធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងការងូត ធ្វើសេចក្ដីខ្ជិលខ្ជាយក្នុងបបរនិងខាទនីយ:និងភត្ដ ឥឡូវអ្នកលែងធ្វើ

យាតុយា ១ាតនីយេ ១ត្តស្ម៏ អាបត្តឺ ១ំ អាវុសោ អាបន្នោ
បស្សេ១ តំ អាបត្តិ១ិ ១ត្តិ មេ អាវុសោ អាបត្តិ យមហំ
បស្សេ១ យ្យ១ិ អ១ោ តេ ១ន្តេ អាត១ុ១ា ១ិ១ូ ១ំ អាបត្តិ-
យា អ១ស្ស១េ ១ុ១ូ១ិ១ីសុ ១ស្ស ១ យ្ហ ១ន្តេ ១ត១ហោសិ
អហំ ១ោ ១ តំ ១ ១ាមិ អាបត្តិ ១ ១ សា
អ១ាបត្តិ ១ អាបន្នោ ១ ១ អ១ាបន្នោ ១ ១ុ១ូ១ោ
១ ១ អ១ុ១ូ១ោ ១ ១ ១ អ១ ១ ១ អ១ ១
១ុ១ ១ អ១ុ១ ១ ១ ១ អ១ ១ អ១ ១-
រ១ ១ យ១ ១ ១ ១ ១ ១ ១ ១ ១
១ ១ ១

សេចក្ដីខ្ជល់ខ្ជាយក្នុងបបរនិងខាទនីយ:និងកត្តហើយ ម្នាលអាវុសោ អ្នកត្រូវអាបត្តិហើយ អ្នកឃើញអាបត្តិឬទេ ខ្ញុំព្រះអង្គធ្វើយថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំគប្បីឃើញនោះមិនមានទេ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុជាអាគន្ដុក:នោះលើកវត្ដខ្ញុំព្រះអង្គ ព្រោះមិនឃើញអាបត្តិក្នុងកាលនោះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញមិនដឹងហេតុនេះថា នេះជាអាបត្តិ ឬមិនមែនជាអាបត្តិ ម្យ៉ាងទៀត អញត្រូវអាបត្តិហើយ ឬមិនទាន់ត្រូវទេ ម្យ៉ាងទៀត សង្ឆ (គួរ) លើកវត្ដអញ ឬមិន(គួរ)លើកវត្ដទេ ដោយកម្មប្រកបដោយធម៌ ឬមិនប្រកបដោយធម៌ទេ ដោយកម្មដ៏កម្រើក ឬមិនកម្រើកទេ ដោយកម្មគួរដល់ហេតុ ឬមិនគួរដល់ហេតុទេ បើដូច្នោះ មានតែអញគប្បីទៅកាន់ក្រុងចម្បា ហើយក្រាបបង្គំទូលសួរសេចក្ដីនោះ ចំពោះព្រះដ៏មានព្រះភាគ បពិត្រព្រះដ៏មានព្រះភាគ ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គមក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ នេះជាអនាបត្ដិ នេះមិនមែនជាអាបត្ដិទេ អ្នកជាភិក្ខុដែលមិនត្រូវអាបត្ដិ អ្នកជាភិក្ខុមិនត្រូវអាបត្ដិ (អ្វីទេ) អ្នកជាភិក្ខុដែលសង្ឆមិនគួរលើកវត្ដ ជាភិក្ខុដែលសង្ឆលើកវត្ដមិនបានទេ អ្នកសង្ឆបានលើកវត្ដហើយ ដោយកម្មមិនប្រកបដោយធម៌ ដោយកម្មដ៏កម្រើក ដោយកម្មមិនគួរតាមហេតុទេ ម្នាលភិក្ខុ អ្នកចូរ

តត្ថេវ ភាសកតាមេ ជិវាសំ ការេហីតិ ។ ឯវំ ភន្តេតិ ខោ ការេ្ជ្ជបតោត្តោ ភិក្ខូ ភគវតោ បដិស្សុណិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ ការ្ជ្ជា យេន ភាសភតាមោ តេន បក្ការ្ជ្ជាមិ ។ អថខោ តេសំ អាតន្ទុការ្ជ្ជានំ ភិក្ខូនំ អហុទេវ ការ្ជ្ជុ្ជ្ជ្ជ្ជ ចុ្ជ្ជ អហុ ១ប្ជ្ជ្ជ្ជ

ទៅសម្រេចការនៅក្នុងវាសកគ្រាមនោះវិញចុះ ។ ភិក្ខុឈ្មោះកស្សបគោត្ត ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគ ដោយពាក្យថា ព្រះករុណា ព្រះអង្គ ហើយក៏ក្រោកចាកអាសន: ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើ ប្រទក្សិណហើយ ចៀសចេញទៅកាន់វាសកគ្រាមនោះ ។ ក្នុងលំដាប់ នោះ ពួកភិក្ខុជាអាគន្តុក:នោះ កើតសេចក្តីរង្គៀសក្តៅក្រហាយថា មិន មែនជាលាភរបស់យើងហើយ យើងឈ្មោះថា ឥតលាភហើយ អត្តភាព ជាមនុស្សយើងបានដោយក្រ មិនមែនយើងបានដោយងាយទេ (ព្រោះ) យើងលើកវត្តភិក្ខុបរិសុទ្ធមិនមានអាបត្តិ ដោយឥតរឿង ឥតហេតុ ម្នាល អាវុសោទាំងឡាយ បើដូច្នោះ មានតែយើងទាំងឡាយនឹងទៅកាន់ក្រុងចម្បា ហើយសំដែងនូវទោសតាមទោស ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ពួកភិក្ខុជាអាគន្តុក:នោះ ក៏រៀបចំទុកដាក់សេនាសន:ហើយ កាន់យកបាត្រនិងចីវរចៀសចេញទៅកាន់ក្រុងចម្បា ចូលទៅគាល់ព្រះ ដ៏មានព្រះភាគឯក្រុងចម្បាដោយលំដាប់ លុះចូលទៅដល់ហើយ ក៏ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ សេចក្តី រីករាយនឹងភិក្ខុជាអាគន្តុក:នេះ ជាប្រពៃណីរបស់ព្រះពុទ្ធទាំងឡាយមាន ព្រះភាគ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលនេះ នឹងពួកភិក្ខុនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអាចអត់ទ្រាំ

យាបនីយំ ភគ្ចិ្ត អប្ជកិលមថេន អ្ជ្ជាំ អ្ជ្ជតា
ភ្ជុតោ ច ភ្ជុម្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ្ជ ។ ១ម្ជ ១ម
ភ្ជ ១ម ១ម ១ម ១ម ១ម ១ម ១ម ១ម

សេចក្ដីទុក្ខបានឬទេ អាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ អ្នកទាំងឡាយមកកាន់ផ្លូវធ្ងាយដោយការមិនលំបាកទេឬ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អ្នកទាំងឡាយមកអំពីទីណា ។ ពួកភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គអាចអត់ទ្រាំបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចម្រើន ម្យ៉ាងទៀត យើងខ្ញុំទាំងឡាយមកកាន់ផ្លូវធ្ងាយដោយការមិនលំបាកទេ បពិត្រព្រះអង្គដ៏ចម្រើន មានស្រុកមួយឈ្មោះវ៉ាសក: នៅក្នុងកាសីជនបទ បពិត្រព្រះមានព្រះភាគ យើងខ្ញុំទាំងឡាយ មកអំពីស្រុកឈ្មោះវ៉ាសក:នោះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយលើកវត្តភិក្ខុជាចៅអាវ៉ាស មែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយលើកវត្តព្រោះវត្ថុដូចម្តេច ព្រោះហេតុដូចម្តេច ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយលើកវត្តដោយគ្មានវត្ថុ គ្មានហេតុទេ ។ ព្រះពុទ្ធមានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ការនេះមិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណ: មិនគប្បី មិនត្រូវធ្វើទេ ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងលើកវត្តភិក្ខុដ៏ស្អាតគ្មានអាបត្តិ ដោយគ្មានវត្ថុ

ចម្បេយ្យក្ខន្ធកេ អាគន្តុកភិក្ខុវត្ថុ

អការណេ ឧក្ខិបិស្សថ ឌេតំ មោឃបុរិសា អប្ប-
សន្ថានំ វ បសាជាយ ។ បេ ។ វិតរហិត្វា ជម្ម៌ តថំ
ឥត្វា ភិក្ខូ អាមន្ដេសិ ជ ភិក្ខវេ សុណ្ដោ ភិក្ខុ អជា-
បត្ដិកោ អវត្ដ្ស៌ អការណេ ឧក្ខិបិតព្ពោ យោ ឧក្ខិ-
ដេយ្យ អាបត្ដិ ទុក្ខ្ជ៌ជ្ជ្ជ្ជ ។ អថ ខោ ឌេ ភិក្ខូ
ឧជ្ជ្ជ្ជ្ជ្ជ ឍ្ជ្ជ្ជ ឧត្ដ្ជ្ជ ជ្ជ ការ្ជ ភ្ជ្ជ ភ្ជ្ជ
ចាឌេសុ ស្ជ្ជ ជ្ជ ជ្ជ ភ្ជ្ជ ភ្ជ្ជ ឍ្ជ្ជ ឍ្ជ
ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ
ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ្ជ ភ្ជ ភ

គ្មានហេតុទេ ម្នាលមោឃបុរសទាំងឡាយ ការនេះនាំមិនឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ។ បេ ។ ទ្រង់តិះដៀលហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលើកវត្ថុភិក្ខុដ៏បរិសុទ្ធគ្មានអាបត្តិ ដោយគ្មានវត្ថុគ្មានហេតុទេ ភិក្ខុណាលើកវត្ថុ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ គ្រានោះ ពួកភិក្ខុនោះក្រោកចាកអាសន: ហើយធ្វើសំពត់ឧត្តរាសង្គ:លើស្មាម្ខាង ហើយក្រាបចុះទៀបព្រះបាទទាំងឡាយនៃព្រះដ៏មានព្រះភាគ ដោយសិរសា ហើយទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយត្រូវទោសព្រោះជាបុគ្គលពាលយ៉ាងណា ជាបុគ្គលវង្វេងយ៉ាងណា ជាបុគ្គលមិនឆ្ងាសយ៉ាងណា (ដោយហេតុ) យើងខ្ញុំទាំងឡាយលើកវត្ថុភិក្ខុដ៏ស្អាតមិនមានអាបត្តិ ដោយគ្មានវត្ថុគ្មានហេតុ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទទួលអត់ទោសតាមទោសនៃយើងខ្ញុំទាំងឡាយ ដើម្បីសង្រួមតទៅ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវទោសព្រោះជាបុគ្គលពាល ជាបុគ្គលវង្វេង ជាបុគ្គលមិនឆ្ងាសយ៉ាងណា (ដោយហេតុ) អ្នកទាំងឡាយបានលើកវត្ថុភិក្ខុដ៏ស្អាត មិនមានអាបត្តិដោយគ្មានវត្ថុគ្មានហេតុ ម្នាលភិក្ខុទាំងឡាយ កាលណាបើអ្នកទាំងឡាយឃើញទោសតាមទោសហើយចូរធ្វើតប (សំដែង) នូវទោសតាមធម៌ចុះ

តំ ហ មយំ បដិក្ខណ្ណាម រុឌ្ឍិ ហេសា ភិក្ខវេ
អរិយស្ស វិនយេ យោ អចូយំ អចូយតោ ជិស្ណា
យ ថាឋមុ្ម បដិកហតិ អាយតឺ សំវរ អាបជ្ជតីតិ ។

[៨១] តេន ខោ បន សមយេន ចម្ប ាយ ភិក្ខ
ឯ្ យ ូ ចានិ កម្ មានិ ករ ាន្ តិ អ ធ ម្ ម ន ្ យ ត ្ ត ្ (១) ករ ាន្ តិ
អ ធ ម្ ម ន ្ (២) ករ ាន្ តិ ធ ម្ ម ន ្ យ ត ្ ត ្ ករ ាន្ តិ
ធ ម្ ម ្ (((

តថាគតទទួលអត់ទោសនោះ របស់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិតថា ភិក្ខុណាឃើញទោសតាមទោស ហើយធ្វើតបទោសនោះ តាមធម៌ ដល់នូវសេចក្តីសង្រួមតទៅ នេះជាសេចក្តីចម្រើនរបស់ភិក្ខុនោះ ក្នុងអរិយវិន័យ ។

[៨១] សម័យនោះឯង ភិក្ខុទាំងឡាយនៅក្នុងក្រុងចម្បា ធ្វើកម្ម ទាំងឡាយមានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួកព្រមទាំងមិនប្រកបដោយ ធម៌ខ្លះ ធ្វើកម្មព្រមព្រៀងតែមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួកតែប្រកប ដោយធម៌ខ្លះ ធ្វើកម្មជាពួកព្រមទាំងប្រកបដោយធម៌ឫមខ្លះ ធ្វើកម្មព្រម ព្រៀងតែប្រកបដោយធម៌ឫមខ្លះ ភិក្ខុមួយរូបលើកវត្តភិក្ខុមួយរូបក៏មាន ភិក្ខុមួយរូបលើកវត្តភិក្ខុពីររូបក៏មាន ភិក្ខុមួយរូបលើកវត្តភិក្ខុច្រើនរូបក៏មាន ភិក្ខុមួយរូបលើកវត្តសង្ឆក៏មាន ភិក្ខុពីររូបលើកវត្តភិក្ខុមួយរូបក៏មាន ភិក្ខុពីរ រូបលើកវត្តភិក្ខុពីររូបក៏មាន ភិក្ខុពីររូបលើកវត្តភិក្ខុច្រើនរូបក៏មាន ភិក្ខុពីរ រូបលើកវត្តសង្ឆក៏មាន ភិក្ខុច្រើនរូបលើកវត្តភិក្ខុមួយរូបក៏មាន ភិក្ខុច្រើនរូប លើកវត្តភិក្ខុពីររូបក៏មាន ភិក្ខុច្រើនរូបលើកវត្តភិក្ខុច្រើនរូបក៏មាន ភិក្ខុច្រើន រូបលើកវត្តសង្ឆក៏មាន សង្ឆលើកវត្តសង្ឆក៏មាន ។ ភិក្ខុទាំងឡាយណា

អប្ជិច្ចា ។ បេ ។ តេ ឧជ្ជាយន្តិ ទីយន្តិ វិចាចេន្តិ កថំ ហិ ជាម ចម្ជាយំ ភិក្ខូ ឝ្ជ្ជ្ជ

មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះ-ដៀល បន្ទុះបង្ហាប់ថា ភិក្ខុក្នុងក្រុងចម្បាមិនគួរនឹងធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះ នឹងធ្វើកម្មជាពួកព្រមទាំងមិនប្រកបដោយធម៌ ។ បេ ។ សង្ឆលើកវត្តសង្ឆក៏មាន ។ គ្រានោះ ពួកភិក្ខុនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុក្នុងក្រុងចម្បាធ្វើកម្មទាំងឡាយ មានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួកព្រមទាំងមិនប្រកបដោយធម៌ ។ បេ ។ សង្ឆលើកវត្តសង្ឆក៏មានពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោស ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថារួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ។

[៨២] ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកទាំងមិនប្រកបដោយធម៌ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀងតែមិនប្រកបដោយធម៌ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកតែប្រកបដោយធម៌ ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ

វត្ថុកម្មំ អកម្មំ ន ច ការណីយំ ។ ឩម្ម្ជ្ជ្ជ

បើកម្មជាពួកទាំងប្រកបដោយធម៌ឫម ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀងគ្នាតែប្រកបដោយធម៌ឫម ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុមួយរូបលើកវត្ត ភិក្ខុមួយរូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ភិក្ខុមួយរូបលើកវត្តភិក្ខុពីររូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុមួយរូបលើកវត្តភិក្ខុច្រើនរូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុមួយរូបលើកវត្តសង្ឆក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុពីររូបលើកវត្តភិក្ខុមួយរូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុពីររូបលើកវត្តភិក្ខុពីររូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុពីររូបលើកវត្តភិក្ខុច្រើនរូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុពីររូបលើកវត្តសង្ឆក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុច្រើនរូបលើកវត្តចំពោះភិក្ខុមួយរូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុច្រើនរូបលើកវត្តភិក្ខុពីររូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុច្រើនរូបលើកវត្តភិក្ខុច្រើនរូបក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ ភិក្ខុច្រើនរូបលើកវត្តសង្ឆក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។ សង្ឆលើកវត្ត សង្ឆក្តី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ។

ចម្បេយ្យក្ខន្ធកំ ចតុក្កម្មកថា

[៨៣] ចត្តារីមានិ ភិក្ខវេ កម្មានិ អជម្ជេន វត្ត-
កម្មំ អជម្ជេន សមត្តកម្មំ ជម្ជេន វត្តកម្មំ ជម្ជេន
សមត្តកម្មំ ។ តត្រ ភិក្ខវេ យនិទំ[1] អជម្ជេន វត្ត-
កម្មំ ឥទំ ភិក្ខវេ កម្មំ អជម្មត្តា វត្តត្តា កុប្បំ អដ្ឋានារហំ
ន ភិក្ខវេ ឯវរូបំ កម្មំ ការេតព្វំ ន ច មយា ឯវរូបំ
កម្មំ អនុញ្ញាតំ ។ តត្រ ភិក្ខវេ យនិទំ អជម្ជេន សមត្ត-
កម្មំ ឥទំ ភិក្ខវេ កម្មំ អជម្មត្តា កុប្បំ អដ្ឋានារហំ ន
ភិក្ខវេ ឯវរូបំ កម្មំ ការេតព្វំ ន ច មយា ឯវរូបំ កម្មំ
អនុញ្ញាតំ ។ តត្រ ភិក្ខវេ យនិទំ ជម្ជេន វត្តកម្មំ ឥទំ
ភិក្ខវេ កម្មំ វត្តត្តា កុប្បំ អដ្ឋានារហំ ន ភិក្ខវេ ឯវរូ-
បំ កម្មំ ការេតព្វំ ន ច មយា ឯវរូបំ កម្មំ អនុញ្ញាតំ ។

---

១ ឩ. យមិទំ ។

ចម្បេយ្យក្ខន្ធក: និយាយអំពីកម្ម ៤ យ៉ាង

[៨៣] ម្នាលភិក្ខុទាំងឡាយ ឯកម្មនេះមាន ៤ យ៉ាង គឺកម្មជាពួកទាំងមិនប្រកបដោយធម៌ ១ កម្មព្រមព្រៀងតែមិនប្រកបដោយធម៌ ១ កម្មជាពួកតែប្រកបដោយធម៌ ១ កម្មព្រមព្រៀងទាំងប្រកបដោយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្មទាំង ៤ យ៉ាងនោះ កម្មណាជាពួកទាំងមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឯងជាកម្មកម្រើក (ខ្ជូច) មិនគួរដល់ហេតុ ព្រោះជាកម្មមិនប្រកបដោយធម៌ផង ជាពួកផង ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះតថាគតមិនបានអនុញ្ញាតទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្មទាំងឡាយនោះ កម្មណាព្រមព្រៀងតែមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះជាកម្មកម្រើក មិនគួរដល់ហេតុ ព្រោះថា កម្មនោះមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះតថាគតមិនបានអនុញ្ញាតទេ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្មទាំងឡាយនោះ កម្មណាជាពួកតែប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឯងជាកម្មកម្រើក មិនគួរដល់ហេតុ ព្រោះថា កម្មនោះជាពួក ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះ តថាគតមិនបានអនុញ្ញាតទេ ។

តត្រ ភិក្ខវេ យជិដំ ឆម្មេន សមក្ខកម្មំ ឥដំ ភិក្ខវេ
កម្មំ ឆម្មត្តា សមក្ខត្តា អកុប្ប៎ ហានារហំ ឯវ្រូបំ ភិក្ខវេ
កម្មំ ការតព្ពំ ឯវ្រូបញ្ច មយា កម្មំ អនុញ្ញាតំ ។ តស្មា-
តិហ ភិក្ខវេ ឯវ្រូបំ កម្មំ ការិស្ស្ជាម យជិដំ ឆម្មេន
សមក្ខន្តិ ឯវញ្ហិ ហេ ភិក្ខវេ សិក្ខិតព្ពន្តិ ។

[៨៤] តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ
ឯវ្រូចានិ កម្មានិ ការេន្តិ អឆម្មេន វត្តកម្មំ ការេន្តិ
អឆម្មេន សមក្ខកម្មំ ការេន្តិ ឆម្មេន វត្តកម្មំ ការេន្តិ
ឆម្មប្ប្ជិរ្ូបកេន វត្តកម្មំ ការេន្តិ ឆម្មប្ប្ជិរ្ូបកេន
សមក្ខកម្មំ ការេន្តិ ញត្តិវិបន្ទ្ធំ្ធ កម្មំ ការេន្តិ អ-
នុ្ស្ជ្ជាវនសម្ប្ជ្ជ(១) អនុ្ស្ជ្ជាវនវិបន្ទ្ធ្ធ កម្មំ ការេន្តិ
ញត្តិសម្ប្ជ្ជ ញត្តិវិបន្ទ្ធ្ធ អនុ្ស្ជ្ជាវនវិបន្ទ្ធ្ធ កម្មំ ការេន្តិ
អញ្ញ្ជ្ជ្ជ្ជ ឆម្ម្ម្ម ការេន្តិ អញ្ញ្ជ្ជ្ជ ១ យ

១ អនុ្ស្ជ្ជ្ជ្ជ ។

ម្នាលភិក្ខុទាំងឡាយ បណ្ណាកម្មទាំងឡាយនោះ កម្មណាព្រមព្រៀងទាំងប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឯង ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ព្រោះថា កម្មនោះប្រកបដោយធម៌ផង ព្រមព្រៀងផង ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុត្រូវធ្វើចុះ កម្មមានសភាពយ៉ាងនេះតថាគតក៏អនុញ្ញាត ។ ព្រោះហេតុដូច្នោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាក្នុងសាសនានេះថា យើងទាំងឡាយនឹងធ្វើកម្មមានសភាពយ៉ាងនេះ គឺកម្មព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាដោយប្រការដូច្នេះឯង ។

[៨៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើកម្មទាំងឡាយ មានសភាពយ៉ាងនេះគឺ ធ្វើកម្មជាពួកទាំងមិនប្រកបដោយធម៌ខ្វះ ធ្វើកម្មព្រម-ព្រៀងតែមិនប្រកបដោយធម៌ខ្វះ ធ្វើកម្មជាពួកតែប្រកបដោយធម៌ខ្វះ ធ្វើកម្មជាពួកទាំងប្រកបដោយធម៌ឫមខ្វះ ធ្វើកម្មព្រមព្រៀងតែប្រកបដោយធម៌ឫមខ្វះ ធ្វើកម្មវិបត្តិដោយញត្តិ តែបរិបូណ៌ដោយអនុស្សាវនាខ្វះ ធ្វើកម្មវិបត្តិដោយអនុស្សាវនា តែបរិបូណ៌ដោយញត្តិខ្វះ ធ្វើកម្មវិបត្តិដោយញត្តិនិងវិបត្តិដោយអនុស្សាវនាខ្វះ ធ្វើកម្មខុសចាកធម៌ខ្វះ ធ្វើកម្មខុសចាកវិន័យខ្វះ

កម្មំ ការេន្តិ អញ្ញត្រាបិ សត្ថុ សាសនា កម្មំ ការេន្តិ បដិកុដ្ឋកតំបិ កម្មំ ការេន្តិ អធម្មិកំ ការ្ម អដ្ឋានារហំ ។ យេ តេ ភិក្ខូ អប្ឆិន្ន ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ការ ហិ ជាម ឆព្ភក្ខិយា ភិក្ខូ ឯវ្ហ្ជានិ ការ្ម ការ្ម ការ្ម ការ្ម ។ ។ ។

ចម្បេយ្យក្ខន្ធក: រឿងឆព្វគ្គិយភិក្ខុ និយាយអំពីធម្មជាតិមិនមែនជាកម្ម

ធ្វើកម្មខុសចាកសត្ថុសាសន:ខ្ញុះ ធ្វើកម្មដែលព្រះពុទ្ធតិះដៀលហើយ ជាកម្ម មិនប្រកបដោយធម៌ ជាកម្មកម្រើក មិនគួរដល់ហេតុខ្ញុះ ។ ពួកភិក្ខុណាមាន សេចក្ដីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះពោលទោស តិះដៀល បន្ទុះ បង្ហាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះ សោះ គឺធ្វើកម្មជាពួកទាំងមិនប្រកបដោយធម៌ខ្ញុះ ។ បេ ។ ធ្វើកម្មដែល ព្រះពុទ្ធទ្រង់តិះដៀលហើយ ជាកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជា កម្មមិនគួរដល់ហេតុខ្ញុះ ។ គ្រានោះ ពួកភិក្ខុនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយភិក្ខុធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួក ទាំងមិនប្រកបដោយធម៌ខ្ញុះ ។ បេ ។ ធ្វើកម្មដែលព្រះពុទ្ធទ្រង់តិះដៀល ជាកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុខ្ញុះ ពិត មែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀល ។ បេ ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ។

[៨៥] ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកទាំងមិនប្រកបដោយធម៌ ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្ម ព្រមព្រៀងតែមិនប្រកបដោយធម៌ ក៏ឈ្មោះថា មិនមែនជាកម្ម មិន

ន ច ការណីយំ ។ ឧម្មេន ចេ ភិក្ខវេ វត្តកម្មំ អកម្មំ ន ច ការណីយំ ។ ឧម្មប្បជ្ជិរូបកេន ចេ ភិក្ខវេ វត្តកម្មំ អកម្មំ ន ច ការណីយំ ។ ឧម្មប្បជ្ជិរូបកេន ចេ ភិក្ខវេ សមត្តកម្មំ អកម្មំ ន ច ការណីយំ ។ ញត្តិវិបន្នញ្ចេ ភិក្ខវេ កម្មំ អនុស្សាវនសម្បន្នំ អកម្មំ ន ច ការណីយំ ។ អនុស្សាវនវិបន្នញ្ចេ ភិក្ខវេ កម្មំ ញត្តិសម្បន្នំ អកម្មំ ន ច ការណីយំ ។ ញត្តិវិបន្នញ្ចេ ភិក្ខវេ កម្មំ អនុស្សា-វនវិបន្នំ អកម្មំ ន ច ការណីយំ ។ អញ្ញត្រាបិ ភិក្ខ-វេ ឧម្មា កម្មំ អកម្មំ ន ច ការណីយំ ។ អញ្ញត្រាបិ ភិក្ខវេ វិនយា កម្មំ អកម្មំ ន ច ការណីយំ ។ អញ្ញ-ត្រាបិ ភិក្ខវេ សត្ថុ សាសនា កម្មំ អកម្មំ ន ច ការ-ណីយំ ។ បដិកុដ្ឋកតំ ចេ ភិក្ខវេ កម្មំ អឧម្មិកំ ឥមិ ឥ អដ្ឋានារហំ អកម្មំ ន ច ការណីយំ ។

ត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកតែប្រកបដោយធម៌ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួកទាំងប្រកបដោយធម៌ឬម ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀងតែប្រកបដោយធម៌ឬម ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិដោយញត្តិ តែបរិបូណ៌ដោយអនុស្សាវនា ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិដោយអនុស្សាវនា តែបរិបូណ៌ដោយញត្តិ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិដោយញត្តិផង វិបត្តិដោយអនុស្សាវនាផង ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកធម៌ក្តី ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកវិន័យ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកសត្ថុសាសន: ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មដែលព្រះពុទ្ធទ្រង់តិះដៀល ជាកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ ។

ចម្បេយ្យក្ខន្ធកំ ឆក្កម្មកថា

[៨៦] ឆយិមានិ ភិក្ខវេ កម្មានិ អធម្មកម្មំ វគ្គកម្មំ សមគ្គកម្មំ ធម្មប្បដិរូបកេន វគ្គកម្មំ ធម្មប្បដិរូបកេន សមគ្គកម្មំ ធម្មេន សមគ្គកម្មំ ។

[៨៧] កតមញ្ច ភិក្ខវេ អធម្មកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ ឯកាយ ញត្តិយា កម្មំ ករោតិ ន ច កម្មវាចំ អនុស្សាវេតិ អធម្មកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ ទ្វីហិ ញត្តីហិ កម្មំ ករោតិ ន ច កម្មវាចំ អនុស្សាវេតិ អធម្មកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ ឯកាយ កម្មវាចាយ កម្មំ ករោតិ ន ច ញត្តឺ ឋបេតិ អធម្មកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ ទ្វីហិ កម្មវាចាហិ កម្មំ ករោតិ ន ច ញត្តឺ ឋបេតិ អធម្មកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ ឯកាយ ញត្តិយា កម្មំ ករោតិ ន ច កម្មវាចំ អនុ-ស្សាវេតិ អធម្មកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ ទ្វីហិ ញត្តីហិ តីហិ ញត្តីហិ ចតូហិ ញត្តីហិ កម្មំ ករោតិ ន ច កម្មវាចំ អនុស្សាវេតិ អធម្មកម្មំ ។

ចម្បេយ្យក្ខន្ធក: និយាយអំពីកម្ម ៦ យ៉ាង

[៨៦] ម្នាលភិក្ខុទាំងឡាយ កម្មនេះមាន ៦ យ៉ាង គឺកម្មមិនប្រកបដោយធម៌ ១ កម្មជាពួក ១ កម្មព្រមព្រៀង ១ កម្មជាពួកទាំងប្រកបដោយធម៌ឫម ១ កម្មព្រមព្រៀងតែប្រកបដោយធម៌ឫម ១ កម្មព្រមព្រៀងទាំងប្រកបដោយធម៌ ១ ។

[៨៧] ម្នាលភិក្ខុទាំងឡាយ កម្មមិនប្រកបដោយធម៌តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ (សង្ឆ) ធ្វើកម្មដោយញត្តិម្តង តែមិនសូត្រកម្មវាចា ហៅថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ (សង្ឆ) ធ្វើកម្មដោយញត្តិពីរដង តែមិនសូត្រកម្មវាចា ហៅថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំង-ឡាយ បើកម្មមានញត្តិជាគម្រប់ពីរ (សង្ឆ) ធ្វើកម្មដោយកម្មវាចា ១ តែមិនតាំងញត្តិ ហៅថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ (សង្ឆ) ធ្វើកម្មដោយកម្មវាចាពីរ តែមិនតាំងញត្តិ ហៅថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ (សង្ឆ) ធ្វើកម្មដោយញត្តិ ១ តែមិនសូត្រកម្មវាចា ហៅថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ (សង្ឆ) ធ្វើកម្មដោយញត្តិពីរក្តី ដោយញត្តិបីក្តី ដោយញត្តិបួនក្តី តែមិនសូត្រកម្មវាចា ហៅថា កម្មមិនប្រកបដោយធម៌ ។

ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ ឯកាយ កម្មវាចាយ
កម្មំ ការោតិ ន ច ញត្តឺ ឋបេតិ អធម្មកម្មំ ។ ញត្តិច-
តុត្ថេ ចេ ភិក្ខវេ កម្មេ ទ្វីហិ កម្មវាចាហិ តីហិ កម្ម-
វាចាហិ ចតូហិ កម្មវាចាហិ កម្មំ ការោតិ ន ច ញត្តឺ
ឋបេតិ អធម្មកម្មំ ។ ឥមំ រុច្ចតិ ភិក្ខវេ អធម្មកម្មំ ។

[៨៨] ការតមញ្ច ភិក្ខវេ វត្តកម្មំ ។ ញត្តិទុតិយេ
ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អនា-
គតា ហោន្តិ ឆន្ទារហានំ ឆន្ទো អនាហាដោ ហោតិ សម្ម-
ីភូតា បដិក្កោសន្តិ វត្តកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ
កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា ហោន្តិ
ឆន្ទារហានំ ឆន្ទো អនាហាដោ ហោតិ សម្មីភូតា
បដិក្កោសន្តិ វត្តកម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ
កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាគតា
ហោន្តិ ឆន្ទារហានំ ឆន្ទো អាហាដោ ហោតិ សម្មីភូតា

ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ (សង្ឃ) ធ្វើកម្មដោយកម្មវាចា ១ តែមិនតាំងញត្តិ ហៅថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ (សង្ឃ) ធ្វើកម្មដោយកម្មវាចាពីរក្តី ដោយកម្មវាចាបីក្តី ដោយកម្មវាចាបួនក្តី តែមិនបានតាំងញត្តិ ហៅថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះតថាគតហៅថា កម្មមិនប្រកបដោយធម៌ ។

[៨៨] ម្នាលភិក្ខុទាំងឡាយ កម្មជាពួក (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ ភិក្ខុប៉ុន្មានរូបគួរដល់កម្ម ភិក្ខុទាំងឡាយនោះ មិនទាន់មកជួបជុំគ្នាក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុក៏មិនបាននាំមកក្តី ភិក្ខុទាំងឡាយដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរភិក្ខុប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងឡាយនោះមកជួបជុំគ្នាហើយ តែឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុក៏មិនបាននាំមកក្តី ភិក្ខុទាំង-ឡាយដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់ក្តី ហៅថា កម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះ ក៏មកជួបជុំគ្នាហើយក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុក៏បាននាំមកក្តី តែភិក្ខុទាំងឡាយដែលមានក្នុងទីចំពោះមុខ

បដិក្ខោសន្តិ វត្តកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ
កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អជ្ជតនា
ហោន្តិ ឆន្ទារហានំ ឆន្ទោ អជ្ជាហាជោ ហោតិ សម្ម-
ខីភូតា បដិក្ខោសន្តិ វត្តកម្មំ ។ ញត្តិចតុត្ថេ ចេ
ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាតតា
ហោន្តិ ឆន្ទារហានំ ឆន្ទោ អជ្ជាហាជោ ហោតិ សម្ម-
ខីភូតា បដិក្ខោសន្តិ វត្តកម្មំ ។ ញត្តិចតុត្ថេ ចេ
ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ អាតតា
ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហាជោ ហោតិ សម្មុខីភូតា
បដិក្ខោសន្តិ វត្តកម្មំ ។ ឥទំ រុច្ចតិ ភិក្ខវេ វត្តកម្មំ ។

[៨៩] កតមញ្ច ភិក្ខវេ សមត្តកម្មំ ។ ញត្តិទុតិ-
យេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្បត្តា តេ
អាតតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហាជោ ហោតិ

ក៏ហាមឃាត់កម្ម ហៅថា កម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្ម មានញត្តិជាគម្រប់ ៤ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះ ក៏មិន បានមកជួបជុំគ្នាក្តី ឆន្ទ:របស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទ: ភិក្ខុមិនបាន នាំមកក្តី ភិក្ខុទាំងឡាយដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះ ក៏បានមកជួបជុំគ្នាហើយ តែ ឆន្ទ:របស់ភិក្ខុដែលគួរដល់ឆន្ទ: ភិក្ខុមិនបាននាំមក ភិក្ខុទាំងឡាយដែលមាន ក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក ។ ម្នាលភិក្ខុទាំង-ឡាយ បើកម្មមានញត្តិជាគម្រប់ ៤ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុ ទាំងនោះ ក៏បានមកជួបជុំគ្នាហើយ ឆន្ទ:របស់ភិក្ខុដែលគួរដល់ឆន្ទ: ភិក្ខុក៏បាន នាំមកហើយ តែភិក្ខុដែលមានក្នុងទីចំពោះមុខហាមឃាត់កម្ម ហៅថា កម្ម ជាពួក ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះតថាគតហៅថា កម្មជាពួក ។

[៨៥] ម្នាលភិក្ខុទាំងឡាយ កម្មព្រមព្រៀង (នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ ភិក្ខុទាំងឡាយ មាន ប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងឡាយនោះ បានមកជួបជុំគ្នាហើយផង ឆន្ទ:របស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទ: ភិក្ខុបាននាំមកហើយផង ភិក្ខុ

សម្ភុ១ីភូតា ជប្ជដិ១ាណ្ណាសន្តិ សមក្ខកម្ម ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ យាវតិកា ភិក្ខូ កម្មប្ជត្តា តេ អាកតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហាដោ ហោតិ សម្ភុ១ីភូតា ជប្ជដិ១ាណ្ណាសន្តិ សមក្ខកម្ម ។ ឥទំ ១ុ១ូតិ ភិក្ខវេ សមក្ខកម្ម ។

[៩០] ១ាតមញ្ច ភិក្ខវេ ឆម្ម្ជ្ជ១ូ១ូ១ាកេ ១ាតកម្ម ។ ញត្តិ១ុតិយេ ចេ ភិក្ខវេ ១ាម្ម ១ាមមំ ១ាម្ម១ាចំ អ១ុ១ាវ-ាតិ ១ាន្ត ញ្ញត្តិ ១ាមេតិ យាវតិ១ា ភិ១ូ ១ាម្ម១ាត្ត ១ាតេ អ១ាតតា ១ាន្តិ ១ន្ទារ១ាន ១ន្ទ ១ាហាដ ១ាន្ត ១ាតេ ១ាតមញ្ច ១ាតេ ១ាតមញ្ច ១ាតេ ១ាតមញ្ច

ទាំងឡាយដែលមានក្នុងទីចំពោះមុខ មិនហាមឃាត់កម្មផង ហៅថា កម្ម
ព្រមព្រៀង ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ ភិក្ខុទាំង-
ឡាយមានប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងឡាយនោះ បានមកជួបជុំគ្នា
ហើយផង ឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមក
ហើយផង ភិក្ខុទាំងឡាយមានក្នុងទីចំពោះមុខ មិនហាមឃាត់កម្មផង
ហៅថា កម្មព្រមព្រៀង ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះ តថាគតហៅ
ថា កម្មព្រមព្រៀង ។

[៩០] ម្នាលភិក្ខុទាំងឡាយ កម្មជាពួកព្រមទាំងប្រកបដោយធម៌
ឫម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ (ភិក្ខុ)
សូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមាន
ប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះមិនបានមកជួបជុំគ្នាក្តី ឆន្ទៈរបស់ភិក្ខុ
ទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកហើយក្តី ភិក្ខុទាំងឡាយ
ដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថា កម្មជាពួកព្រមទាំង
ប្រកបដោយធម៌ឫម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ
ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយ
មានប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកជួបជុំគ្នាហើយ តែឆន្ទៈ
របស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកក្តី ភិក្ខុទាំងឡាយ

ហោតិ សម្ភុ១ីភូតា បដិ១ាណ្ណាសន្តិ ឆម្ម្ជ្ជ១ិ១ូ១ូ១ាកេ
ឆ១ាកកម្ម ។ ញ១ាតិ១ុ១ាតិ១ូ ១េ ១ិ១ាកូ១ូ ១ាកម្ម ១ូ១ូ១ាំ
១ាកម្ម១ាំ អ១ុ១ាកូ១ូ១ាតិ ១ូ១ា ១ាតិ ១ូ១ូ១ាតិ ១ូ១ូ១ាតិ១ា
១ិ១ាកូ ១ាកម្ម១ូ១ាតា ១ូ អ១ាតា ១ូ១ាតិ ១ាតូ១ូ១ូ១ាំ ១ាតូ
១ូ១ូ ១ូ១ាតិ ១ូ១ូ ១ាតិ ១ាតូ១ូ១ាតិ ១ាតូ១ូ

ដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថា កម្មជាពួកព្រមទាំងប្រកបដោយធម៌ឫម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ពីរ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយ មានប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកជួបជុំគ្នាហើយក្តី ឆន្ទ: របស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទ: ភិក្ខុបាននាំមកហើយក្តី តែភិក្ខុទាំង-ឡាយដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្ម ហៅថា កម្មជាពួកព្រមទាំងប្រកបដោយធម៌ឫម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះមិនទាន់មកជួបជុំគ្នាក្តី ឆន្ទ:របស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទ: ភិក្ខុមិនបាននាំមកក្តី ភិក្ខុទាំង-ឡាយដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថា កម្មជាពួកព្រមទាំងប្រកបដោយធម៌ឫម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយ មានប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះមកជួបជុំគ្នាហើយ តែឆន្ទ: របស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទ: ភិក្ខុមិនបាននាំមកហើយក្តី ភិក្ខុទាំង-ឡាយដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថា កម្មជាពួកព្រមទាំងប្រកបដោយធម៌ឫម ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤

កម្មេ បឋមំ កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តឺ
ឋបេតិ យាវតិកា ភិក្ខូ កម្មប្ផត្តា តេ អាគតា ហោន្តិ
ឆន្ទារហានំ ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា ប-
ដិក្ក្រោសន្តិ ធម្មប្ផដិរូបកេន វត្តកម្មំ ។ ឥទំ រុច្ចតិ
ភិក្ខវេ ធម្មប្ផដិរូបកេន វត្តកម្មំ ។

[៩១] កតមញ្ច ភិក្ខវេ ធម្មប្ផដិរូបកេន សមក្ត-
កម្មំ ។ ញត្តិទុតិយេ ចេ ភិក្ខវេ កម្មេ បឋមំ កម្មវាចំ
អនុស្សាវេតិ បច្ឆា ញត្តឺ ឋបេតិ យាវតិកា ភិក្ខូ កម្ម-
ប្ផត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ ឆន្ទោ អាហដោ
ហោតិ សម្មុខីភូតា ធប្ផដិក្ក្រោសន្តិ ធម្មប្ផដិរូបកេន
សមក្តកម្មំ ។ ញត្តិចតុត្ថេ ចេ ភិក្ខវេ កម្មេ បឋមំ
កម្មវាចំ អនុស្សាវេតិ បច្ឆា ញត្តឺ ឋបេតិ យាវតិ-
កា ភិក្ខូ កម្មប្ផត្តា តេ អាគតា ហោន្តិ ឆន្ទារហានំ
ឆន្ទោ អាហដោ ហោតិ សម្មុខីភូតា ធប្ផដិក្ក្រោសន្តិ

ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយ មានប៉ុន្មានរូបដែលគួរដល់កម្ម ភិក្ខុទាំងនោះបានមកជួបជុំគ្នាហើយក្តី ឆន្ទៈ របស់ភិក្ខុទាំងឡាយដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយក្តី តែភិក្ខុទាំង-ឡាយដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្ម ហៅថា កម្មជាពួកព្រម ទាំងប្រកបដោយធម៌ឫម ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះ តថាគតហៅ ថា កម្មជាពួកព្រមទាំងប្រកបដោយធម៌ឫម ។

[៩១] ម្នាលភិក្ខុទាំងឡាយ ឯកម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែ ប្រកបដោយធម៌ឫម (នោះ) ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្ម មានញត្តិជាគម្រប់ពីរ ភិក្ខុសូត្រកម្មវាចាជាមុន ហើយទើបតាំងសូត្រញត្តិជា ខាងក្រោយ ភិក្ខុទាំងឡាយដែលគួរដល់កម្មមានប៉ុន្មានរូប ភិក្ខុទាំងនោះ ក៏បានមកហើយ ទាំងបាននាំឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈមក ហើយ ភិក្ខុទាំងឡាយមកជួបជុំគ្នាហើយ ក៏មិនឃាត់ហាម កម្មនោះឈ្មោះ ថា កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នាដែរ តែប្រកបដោយធម៌ឫម ។ ម្នាល ភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ ភិក្ខុសូត្រកម្មវាចាជាមុន ហើយ ទើបតាំងញត្តិជាខាងក្រោយ ភិក្ខុទាំងឡាយ ដែលគួរដល់កម្មមានប៉ុន្មាន រូប ភិក្ខុទាំងនោះក៏បានមកហើយ ទាំងបាននាំឆន្ទៈ របស់ភិក្ខុដែលគួរ ដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយមកជួបជុំគ្នាហើយ ក៏មិនឃាត់ហាម

ឆម្ភប្ជិ្ជ្ជ្ជ

កម្មនោះឈ្មោះថា កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នាដែរ តែប្រកបដោយ ធម៌ឬម ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះតថាគតហៅថា កម្មរបស់ភិក្ខុព្រម-ព្រៀងគ្នា តែប្រកបដោយធម៌ឬម ។

[៩២] ម្នាលភិក្ខុទាំងឡាយ ឯកម្មរបស់ភិក្ខុព្រមព្រៀងគ្នា ទាំង ប្រកបដោយធម៌ (នោះ) ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមាន ញត្តិជាគម្រប់ពីរ ភិក្ខុតាំងញត្តិមុនហើយ ទើបធ្វើកម្ម (នោះ) ដោយកម្ម-វាចាតែម្តងជាខាងក្រោយ ភិក្ខុទាំងឡាយដែលគួរដល់កម្ម មានប៉ុន្មានរូប ភិក្ខុទាំងនោះក៏បានមកហើយ ទាំងបាននាំឆន្ទ:របស់ភិក្ខុទាំងឡាយ ដែល គួរដល់ឆន្ទ:មកហើយ ភិក្ខុទាំងឡាយមកជួបជុំគ្នា ក៏មិនឃាត់ហាម កម្ម នោះឈ្មោះថា កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគម្រប់ ៤ ភិក្ខុតាំងញត្តិមុនហើយ ទើបធ្វើកម្ម (នោះ) ដោយកម្មវាចាបីដងជាខាងក្រោយ ភិក្ខុទាំងឡាយ ដែលគួរដល់កម្មមានប៉ុន្មានរូប ភិក្ខុទាំងនោះក៏បានមកហើយ ទាំងបាន នាំឆន្ទ:របស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទ:មកហើយ ភិក្ខុទាំងឡាយមក ជួបជុំគ្នាក៏មិនឃាត់ហាម កម្មនោះឈ្មោះថា កម្មរបស់ភិក្ខុដែលព្រមព្រៀង គ្នា ទាំងប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ កម្មនេះតថាគតហៅ ថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ ។

[៩៣] បញ្ច សង្ឆា ចតុវគ្គោ ភិក្ខុសង្ឆো បញ្ចវគ្គោ ភិក្ខុសង្ឆো ឧសវគ្គោ ភិក្ខុសង្ឆো វីសតិវគ្គោ ភិក្ខុ-សង្ឆো អតិរេកវីសតិវគ្គោ ភិក្ខុសង្ឆোតិ[១] ។ តត្រ ភិក្ខវេ យ្វាយំ ចតុវគ្គោ ភិក្ខុសង្ឆো បវេត្វា តីហិ កម្មានិ ឧបសម្ផទំ បវារណំ អព្ភានំ ឆន្ទេន សមគ្គោ សព្ពកម្មេសុ កម្មប្ផត្តো ។ តត្រ ភិក្ខវេ យ្វាយំ បញ្ច-វគ្គោ ភិក្ខុសង្ឆো បវេត្វា ទ្វេ កម្មានិ មជ្ឈិមេសុ ជ-នបទេសុ ឧបសម្ផទំ អព្ភានំ ឆន្ទេន សមគ្គោ សព្ព-កម្មេសុ កម្មប្ផត្តো ។ តត្រ ភិក្ខវេ យ្វាយំ ឧសវគ្គោ ភិក្ខុសង្ឆো បវេត្វា ឯកំ កម្មំ អព្ភានំ ឆន្ទេន សមគ្គោ សព្ពកម្មេសុ កម្មប្ផត្តো ។ តត្រ ភិក្ខវេ យ្វាយំ វីស-តិវគ្គោ ភិក្ខុសង្ឆো ឆន្ទេន សមគ្គោ សព្ពកម្មេសុ កម្មប្ផត្តো ។ តត្រ ភិក្ខវេ យ្វាយំ អតិរេកវីសតិវគ្គោ ភិក្ខុសង្ឆো ឆន្ទេន សមគ្គោ សព្ពកម្មេសុ កម្មប្ផត្តោ ។

---

១ ឱ. ឥតិ សទ្ទោ ន ទិស្សតិ ។

[៨៣] ជុំនុំសង្ឆមាន ៥ ពួក គឺ ភិក្ខុសង្ឆចតុវគ្គ (សង្ឆមានភិក្ខុ ៤ រូប) ១ ភិក្ខុសង្ឆបញ្ចវគ្គ (សង្ឆមានភិក្ខុ ៥ រូប) ១ ភិក្ខុសង្ឆទសវគ្គ (សង្ឆមានភិក្ខុ ១០ រូប) ១ ភិក្ខុសង្ឆវីសតិវគ្គ (សង្ឆមានភិក្ខុ ២០ រូប) ១ ភិក្ខុសង្ឆអតិរេកវីសតិវគ្គ (សង្ឆមានភិក្ខុលើសពី ២០ រូប) ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាលភិក្ខុសង្ឆទាំង ៥ ពួកនោះ ឯភិក្ខុសង្ឆចតុវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្មក្នុងកម្មទាំងពួង រៀរលែងតែកម្ម ៣ យ៉ាង គឺ ឧបសម្បទាកម្ម ១ បវារណាកម្ម ១ អព្ភានកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឆទាំង ៥ ពួកនោះ ឯភិក្ខុសង្ឆបញ្ចវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្មក្នុងកម្មទាំងពួង រៀរលែងតែកម្ម ២ យ៉ាងគឺ ឧបសម្បទាកម្មក្នុងមជ្ឈិមជនបទ ១ អព្ភានកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឆទាំង ៥ ពួកនោះ ឯភិក្ខុសង្ឆទសវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្មក្នុងកម្មទាំងពួងរៀរលែងតែកម្ម ១ គឺ អព្ភានកម្ម ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឆទាំង ៥ ពួកនោះ ឯភិក្ខុសង្ឆវីសតិវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្មក្នុងកម្មទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសង្ឆទាំង ៥ ពួកនោះ ឯភិក្ខុសង្ឆអតិរេកវីសតិវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្មក្នុងកម្មទាំងពួង ។

ចម្បេយ្យក្ខន្ធកេ បញ្ចសង្ឆកថាចតុវគ្គករណកម្មំ

[៩៤] ចតុវត្តការណានេ្ត ភិក្ខវេ កម្មំ ភិក្ខុនីចតុត្តោ
កម្មំ ការេយ្យ អកម្មំ ន ច ការណីយំ ។ ចតុវត្តក-
រណានេ្ត ភិក្ខវេ កម្មំ សិក្ខមានចតុត្តោ ។ បេ ។
សាមណេរចតុត្តោ សាមណេរីចតុត្តោ សិក្ខំ បចូក្ខាត-
កចតុត្តោ អន្តិមវត្ថុំ អជ្ឈាបន្នកចតុត្តោ អាបត្តិយា
អទស្សនេ ឧក្ខិត្តកចតុត្តោ អាបត្តិយា អប្បដិការេ
ឧក្ខិត្តកចតុត្តោ ទ្ធាបិការយ ទិដ្ឋិយា អប្បដិនិស្សគ្គេ
ឧក្ខិត្តកចតុត្តោ បណ្ឌកចតុត្តោ ថេយ្យសំវាសកច-
តុត្តោ តិត្ថិយប្ឆ្ការ្ជ្ជកចតុត្តោ តិរច្ឆានគតចតុត្តោ មា-
តុឃាតកចតុត្តោ បិតុឃាតកចតុត្តោ អរហន្តឃាតក-
ចតុត្តោ ភិក្ខុនីទូសកចតុត្តោ សង្ឆ្ជ្ជេទកចតុត្តោ
លោហិតុប្ប្ជាទកចតុត្តោ ឧភតោព្យ្ជ្ជនកចតុត្តោ
ជាជាសំវាសកចតុត្តោ ជាជាសីមាយ ឋិតចតុត្តោ

ចម្បេយ្យក្ខន្ធក: និយាយអំពីជំនុំសង្ឆមាន ៥ ពួក និងកម្មសម្រាប់ធ្វើដោយសង្ឆចតុវគ្គ

[៨៤] ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឆចតុវគ្គ សង្ឆមានភិក្ខុនីជាគម្រប់ ៤ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថា កម្ម ផង សង្ឆក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឆចតុវគ្គ សង្ឆមានសិក្ខមានាជាគម្រប់ ៤ ។ បេ ។ មានសាមណេរជាគម្រប់ ៤ មានសាមណេរីជាគម្រប់ ៤ មានភិក្ខុដែលពោលលាសិក្ខាជាគម្រប់ ៤ មានភិក្ខុដែលត្រូវអន្តិមវត្ថុជាគម្រប់ ៤ មានភិក្ខុដែលសង្ឆលើកវត្តព្រោះមិនឃើញអាបត្តិជាគម្រប់ ៤ មានភិក្ខុដែលសង្ឆលើកវត្តព្រោះមិនសំដែងអាបត្តិជាគម្រប់ ៤ មានភិក្ខុដែលសង្ឆលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់ជាគម្រប់ ៤ មានមនុស្សខ្វើយជាគម្រប់ ៤ មានបុគ្គលដែលលួចសំវាសជាគម្រប់ ៤ មានភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយជាគម្រប់ ៤ មានសត្វតិរិច្ឆានជាគម្រប់ ៤ មានបុគ្គលដែលសម្ងាប់មាតាជាគម្រប់ ៤ មានបុគ្គលដែលសម្ងាប់បិតាជាគម្រប់ ៤ មានបុគ្គលដែលសម្ងាប់ព្រះអរហន្តជាគម្រប់ ៤ មានបុគ្គលដែលទ្រុស្តភិក្ខុនីជាគម្រប់ ៤ មានភិក្ខុដែលបំបែកសង្ឆជាគម្រប់ ៤ មានបុគ្គលដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពង់ឡើងជាគម្រប់ ៤ មានឧកតោព្យញ្ជនកជាគម្រប់ ៤ មានភិក្ខុដែលមានសំវាសផ្សេង ។ គ្នាជាគម្រប់ ៤ មានភិក្ខុដែលបិតនៅក្នុងសីមាផ្សេង ។ គ្នាជាគម្រប់ ៤

ឥទ្ធិយា វេហាសេ ឋិតចតុត្ថោ យស្ស សជ្ជោ កម្មំ
ភវតិ តំចតុត្ថោ ភិក្ខុ ការយ្យ អកម្មំ ន ច
ការណីយំ ។

ចតុវគ្គការណំ ។

[៩៤] បញ្ចវត្ថុការណានេ ភិក្ខវេ ភិក្ខុនីបញ្ចមោ
ភិក្ខុ ការយ្យ អកម្មំ ន ច ការណីយំ ។ បញ្ចវត្ថុ-
ការណានេ ភិក្ខវេ ភិក្ខុ សិក្ខមានាបញ្ចមោ ។ បេ ។ សាម-
ណេរបញ្ចមោ សាមណេរីបញ្ចមោ សិក្ខំ បច្ចក្ខាតក-
បញ្ចមោ អន្តិមវត្ថុំ អជ្ឈាបន្នកបញ្ចមោ អាបត្តិយា
អទស្សនេ ឧក្ខិត្តកបញ្ចមោ អាបត្តិយា អប្បដិកម្មេ
ឧក្ខិត្តកបញ្ចមោ ទ្ធាបិ ការ ទ ដ្ឋិយ អ ប ដ ដ ន ិ ស ្ច ត ្ត
ឧក្ខិត្តកបញ្ចមោ បណ្ឌកបញ្ចមោ ថេយ្យសំវាសក-
បញ្ចមោ តិត្ថិយប្ចក្កន្តកបញ្ចមោ តិរច្ឆានគតបញ្ចមោ
មាតុឃាតកបញ្ចមោ បិតុឃាតកបញ្ចមោ អរហន្ត-

មានភិក្ខុដែលឋិតនៅលើអាកាសដោយឫទ្ធិជាគម្រប់ ៤ សង្ឆធ្វើកម្មដល់បុគ្គលណា សង្ឆមានបុគ្គលនោះជាគម្រប់ ៤ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថា កម្មផង សង្ឆក៏មិនត្រូវធ្វើផង ។

ចប់ កម្មសម្រាប់ធ្វើដោយសង្ឆចតុវគ្គ ។

[*៩៥*] *ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឆបញ្ចវគ្គ សង្ឆមានភិក្ខុនីជាគម្រប់ ៥ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថា កម្មផង សង្ឆក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឆបញ្ចវគ្គ សង្ឆមានសិក្ខមានាជាគម្រប់ ៥ ។ បេ ។ មានសាមណេរជាគម្រប់ ៥ មានសាមណេរីជាគម្រប់ ៥ មានភិក្ខុដែលពោលលាសិក្ខាជាគម្រប់ ៥ មានភិក្ខុត្រូវអន្តិមវត្ថុជាគម្រប់ ៥ មានភិក្ខុដែលសង្ឆលើកវត្ថុត ព្រោះមិនឃើញអាបត្តិជាគម្រប់ ៥ មានភិក្ខុដែលសង្ឆលើកវត្ត ព្រោះមិនសំដែងអាបត្តិជាគម្រប់ ៥ មានភិក្ខុដែលសង្ឆលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់ជាគម្រប់ ៥ មានមនុស្សខ្ជើយជាគម្រប់ ៥ មានបុគ្គលដែលលួចសំវាសជាគម្រប់ ៥ មានភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយជាគម្រប់ ៥ មានសត្វតិរច្ឆានជាគម្រប់ ៥ មានបុគ្គលដែលសម្ងាប់មាតាជាគម្រប់ ៥ មានបុគ្គលដែលសម្ងាប់បិតាជាគម្រប់ ៥ មានបុគ្គលដែលសម្ងាប់*

ចម្បេយ្យក្ខន្ធកេ បញ្ចសង្ឆកថាទសវគ្គករណកម្មំ

ឃាតកបញ្ចមោ ភិក្ខុនីខ្ជសកបញ្ចមោ សជ្ជៃភេជ-
កបញ្ចមោ លោហិតុប្បាទកបញ្ចមោ ឧភតោព្យញ្ជន-
កបញ្ចមោ ជាជាសំវាសកបញ្ចមោ ជាជាសីមាយ
ឋិតបញ្ចមោ ឥន្ទ្រិយ វេមាសេ ឋិតបញ្ចមោ យស្ស
សង្ឆ្លៃ កម្មំ ការេតិ តំបញ្ចមោ កម្មំ ការេយ្យ អកម្មំ
ន ច ការណីយំ ។

បញ្ចវគ្គករណំ ។

[៩៦] ឧសវត្តការណាញ្ចេ ភិក្ខវេ កម្មំ ភិក្ខុនីឧសមោ
កម្មំ ការេយ្យ អកម្មំ ន ច ការណីយំ ។ ឧសវត្តក-
រណាញ្ចេ ភិក្ខវេ កម្មំ សិក្ខមានឧសមោ ។ បេ ។
សាមណេរឧសមោ សាមណេរីឧសមោ សិក្ខំ បច្ចក្ខា-
តកឧសមោ អន្តិមវត្ថុំ អជ្ឈាបន្នកឧសមោ អាបត្តិយា
អឧស្ស ឧក្ខិត្តកឧសមោ អាបត្តិយា អប្ផដិកម្មេ
ឧក្ខិតកឧសមោ ចាបិ ការយ ឧិដ្ឋិយា អប្ផដិនិស្ស ក្ខ

ព្រះអរហន្តជាគម្រប់ ៥ មានបុគ្គលដែលទ្រុស្តភិក្ខុនីជាគម្រប់ ៥ មានភិក្ខុដែលបំបែកសង្ឆជាគម្រប់ ៥ មានបុគ្គលដែលធ្វើព្រះលោហិតុប្ផាទ (ព្រះសាស្តា) ឲ្យពុះពង ១ ១ ១

ឧក្ខិត្តកឧសមោ បណ្ណកឧសមោ ថេយ្យសំវាសកឧ-
សមោ តិត្ថិយឫក្ខ្ជកឧសមោ តិរច្ឆានគតឧសមោ
មាតុឃាតកឧសមោ បិតុឃាតកឧសមោ អរហន្តឃា-
តកឧសមោ ភិក្ខុនីទូសកឧសមោ សង្ឆ្លៃកេឧកឧ-
សមោ លោហិតុប្ប៉ាទកឧសមោ ឧភតោព្យ៉ញ្ជនកឧ-
សមោ ជាជាសំវាសកឧសមោ ជាជាសីមាយ ឋិតឧ-
សមោ ឥទ្ធិយា វេហាសេ ឋិតឧសមោ យស្ស សង្ឆោ
កម្មំ ការេតិ តំឧសមោ កម្មំ ការេយ្យ អកម្មំ ន ច
ការណីយំ ។

ទសវគ្គការណំ ។

[៩៧] រីសតិវត្តការណាញ្ចេ ភិក្ខវេ កម្មំ ភិក្ខុនីរីសោ
កម្មំ ការេយ្យ អកម្មំ ន ច ការណីយំ ។ រីសតិវត្ត-
ការណាញ្ចេ ភិក្ខវេ កម្មំ សិក្ខមានារីសោ ។ បេ ។

ទិដ្ឋិអាក្រក់ជាគម្រប់ ១០ មានមនុស្សខ្ជើយជាគម្រប់ ១០ មានបុគ្គលដែលលួចសំវាសជាគម្រប់ ១០ មានកិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយជាគម្រប់ ១០ មានសត្វតិរច្ឆានជាគម្រប់ ១០ មានបុគ្គលដែលសម្ងាប់មាតាជាគម្រប់ ១០ មានបុគ្គលដែលសម្ងាប់បិតាជាគម្រប់ ១០ មានបុគ្គលដែលសម្ងាប់ព្រះអរហន្ត ជាគម្រប់ ១០ មានបុគ្គលដែលទ្រុស្តកិក្ខុនីជាគម្រប់ ១០ មានកិក្ខុដែលបំបែកសង្ឆជាគម្រប់ ១០ មានបុគ្គលដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពង១ឡើងជាគម្រប់ ១០ មានឧកតោព្យញ្ជនកជាគម្រប់ ១០ មានកិក្ខុដែលមានសំវាសផ្សេង ។ គ្នាជាគម្រប់ ១០ មានកិក្ខុដែលស្ថិតនៅក្នុងសីមាផ្សេង ។ គ្នាជាគម្រប់ ១០ មានកិក្ខុដែលស្ថិតនៅលើអាកាសដោយឫទ្ធិជាគម្រប់ ១០ សង្ឆធ្វើកម្មដល់បុគ្គលណា សង្ឆមានបុគ្គលនោះជាគម្រប់ ១០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថា កម្មផង សង្ឆក៏មិនត្រូវធ្វើផង ។

ចប់កម្មសម្រាប់ធ្វើដោយសង្ឆទសវគ្គ ។

[៩៧] ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឆវីសតិ-វគ្គ សង្ឆមានកិក្ខុនីជាគម្រប់ ២០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថា កម្មផង សង្ឆមិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើកម្ម សម្រាប់ធ្វើដោយសង្ឆវីសតិវគ្គ សង្ឆមានសិក្ខមានាជាគម្រប់ ២០ ។ បេ ។

ចម្បេយ្យក្ខន្ធកេ បញ្ចសង្ឆកថាវីសតិវគ្គករណកម្មំ

សាមណេរវីសោ សាមណេរីវីសោ សិក្ខំ បច្ចក្ខាត-
ការីសោ អន្តិមវត្ថុំ អជ្ឈាបន្នការីសោ អាបត្តិយា
អទស្សនេ ឧក្ខិត្តការីសោ អាបត្តិយា អប្បដិកម្ម
ឧក្ខិត្តការីសោ ចាបិការយ ទិដ្ឋិយា អប្បដិនិស្សគ្គ
ឧក្ខិត្តការីសោ បណ្ឌការីសោ ថេយ្យសំវាសការីសោ
តិត្ថិយប្ឆក្ខន្ធការីសោ តិរច្ឆានកតវីសោ មាតុឃាតក-
រីសោ បិតុឃាតិការីសោ អរហន្តឃាតការីសោ ភិក្ខុនី-
ទូសការីសោ សង្ឆ្យភេទការីសោ លោហិតុប្បាទការីសោ
ឧភោតោព្យញ្ជនការីសោ ជាជាសំវាសការីសោ ជាជា-
សីមាយ ឋិតវីសោ យស្ស សង្ឆ្យោ ភិន្ទ ភេតិ
តំវីសោ ភិន្ទ ភេយ្យ អភិន្ទ ន ច ការណីយំ ។

វីសតិវគ្គករណំ ។

មានសាមណេរជាគម្រប់ ២០ មានសាមណេរីជាគម្រប់ ២០ មានកិក្ខុដែលពោលលាសិក្ខាជាគម្រប់ ២០ មានកិក្ខុដែលត្រូវអន្តិមវត្ថុជាគម្រប់ ២០ មានកិក្ខុដែលសង្ឆលើកវត្តព្រោះមិនឃើញអាបត្តិជាគម្រប់ ២០ មានកិក្ខុដែលសង្ឆលើកវត្តព្រោះមិនសំដែងអាបត្តិជាគម្រប់ ២០ មានកិក្ខុដែលសង្ឆលើកវត្តព្រោះមិនលះបង់ទិដ្ឋិអាក្រក់ជាគម្រប់ ២០ មានមនុស្សខ្ជើយជាគម្រប់ ២០ មានបុគ្គលដែលលួចសំវាសជាគម្រប់ ២០ មានកិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយជាគម្រប់ ២០ មានសត្វតិរច្ឆានជាគម្រប់ ២០ មានបុគ្គលដែលសម្ងាប់មាតាជាគម្រប់ ២០ មានបុគ្គលដែលសម្ងាប់បិតាជាគម្រប់ ២០ មានបុគ្គលដែលសម្ងាប់ព្រះអរហន្តជាគម្រប់ ២០ មានបុគ្គលដែលទ្រុស្តកិក្ខុនីជាគម្រប់ ២០ មានកិក្ខុដែលបំបែកសង្ឆជាគម្រប់ ២០ មានកិក្ខុដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពង់ឡើងជាគម្រប់ ២០ មានឧកតោព្យញ្ជនក: ជាគម្រប់ ២០ មានកិក្ខុដែលមានសំវាសផ្សេង ៗ គ្នាជាគម្រប់ ២០ មានកិក្ខុដែលស្ថិតនៅក្នុងសីមាផ្សេង ៗ គ្នាជាគម្រប់ ២០ សង្ឆធ្វើកម្មដល់បុគ្គលណា សង្ឆមានបុគ្គលនោះជាគម្រប់ ២០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឆក៏មិនត្រូវធ្វើផង ។

ចប់ កម្មសម្រាប់ធ្វើដោយសង្ឆវ៉ីសតិវគ្គ ។

[៩៨] ចារ្យាសិកចតុត្ថោ ចេ ភិក្ខវេ ឧ-
ដ្ឋេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ឧដ្ឋេយ្យ តំវ៉ីសោ
អព្ភេយ្យ អកម្មំ ន ច ការណ្ឌីយំ ។ មូលាយ ២-
 កស្ស្ជ្ជារ្ហចតុត្ថោ ចេ ភិក្ខវេ ២ ឧដ្ឋេយ្យ ២-
លាយ ២ មានត្តំ ឧដ្ឋេយ្យ ២ អព្ភេយ្យ
អកម្មំ ន ច ការណ្ឌីយំ ។ ២ ២ ២
២ ២ ២

[៩៨] ម្នាលភិក្ខុទាំងឡាយ បើសង្ឆមានភិក្ខុអ្នកនៅបរិវាសជាគម្រប់ ៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឆមានភិក្ខុអ្នកនៅបរិវាសនោះជាគម្រប់ ២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថា កម្មផង សង្ឆក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឆមានភិក្ខុដែលគួរដល់ការទាញ អន្តរាបត្តិមកដាក់ក្នុងមូលាបត្តិជាគម្រប់ ៤ ហើយឲ្យវបរិវាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឆមានភិក្ខុនោះជាគម្រប់ ២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថា កម្មផង សង្ឆក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឆមានភិក្ខុដែលគួរដល់មានត្តជាគម្រប់ ៤ ហើយឲ្យបរិ-វាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឆមានភិក្ខុដែលគួរដល់មានត្តនោះជាគម្រប់ ២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថា កម្មផង សង្ឆមិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឆមានភិក្ខុអ្នកប្រព្រឹត្តមានត្តជាគម្រប់ ៤ ហើយឲ្យបរិវាសទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត បើសង្ឆមានភិក្ខុអ្នកប្រព្រឹត្តមានត្តនោះជាគម្រប់ ២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថា កម្មផង សង្ឆក៏មិនត្រូវធ្វើផង ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឆមានភិក្ខុដែលគួរដល់អព្ភាន

បរិវាសំ ឧនេយ្យ មូលាយ បដិកស្សេយ្យ មានត្តំ ឧ-
នេយ្យ តំវីសោ អញ្ញេយ្យ អកមុ្ម ន ច ការណីយំ ។

[៩៩] ឯកចូ្ចសូ្ស ភិក្ខវេ សជ្ជុមជ្ជេ បដិក្ខោសនា
រូហតិ ឯកចូ្ចសូ្ស ន រូហតិ ។ ទសូ្ស ច ភិក្ខវេ សជ្ជុមជ្ជេ
បដិក្ខោសនា ន រូហតិ ។ ភិក្ខុនិយា ភិក្ខវេ សជ្ជុមជ្ជេ
បដិក្ខោសនា ន រូហតិ ។ សិក្ខមានាយ ភិក្ខវេ ។ បេ ។
សាមណេរសូ្ស ភិក្ខវេ សាមណេរិយា ភិក្ខវេ សិក្ខំ
បចូ្ចក្ខាតកសូ្ស ភិក្ខវេ អន្តិមវត្ថុំ អជ្ឈាបន្នកសូ្ស ភិក្ខវេ
ឧមុ្មត្តកសូ្ស ភិក្ខវេ ខិត្តចិត្តសូ្ស ភិក្ខវេ វេទនដ្ដសូ្ស ភិក្ខវេ
អាបត្តិយា អទស្សនេ ឧក្ខិត្តកសូ្ស ភិក្ខវេ អាបត្តិយា
អប្បដិកមេ្ម ឧក្ខិត្តកសូ្ស ភិក្ខវេ ទាបិកាយ ឧ្ដ្ឋិយា
អប្បដិនិស្សគ្គេ ឧក្ខិត្តកសូ្ស ភិក្ខវេ បណ្ឌកសូ្ស ភិក្ខវេ

ជាគម្រប់ ៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ ហើយឲ្យ
មានត្ត បើសង្ឆមានកិច្ចដែលគួរដល់អព្ភានៗ ជាគម្រប់ ២០ ហើយឲ្យ
អព្ភាន (យ៉ាងនេះ) មិនហៅថា កម្មផង សង្ឆក៏មិនត្រូវធ្វើផង ។

[៩៩] ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឆ
របស់បុគ្គលខ្លះឡើង របស់បុគ្គលខ្លះមិនឡើង ។ ម្នាលភិក្ខុទាំងឡាយ ឯ
ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឆ របស់នរណាដែលមិនឡើង ។ ម្នាល
ភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឆ របស់ភិក្ខុនីមិនឡើង
ទេ ។ ម្នាលភិក្ខុទាំងឡាយ របស់សិក្ខមានា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ
របស់សាមណេរ ម្នាលភិក្ខុទាំងឡាយ របស់សាមណេរី ម្នាលភិក្ខុទាំង-
ឡាយ របស់ភិក្ខុអ្នកពោលលាសិក្ខា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុអ្នក
ត្រូវអន្តិមវត្ថុ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលឆ្កួត ម្នាលភិក្ខុទាំង-
ឡាយ របស់ភិក្ខុដែលលមានចិត្តរវើរវាយ ម្នាលភិក្ខុទាំងឡាយ របស់
ភិក្ខុដែលមានវេទនាគ្របសង្កត់ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលសង្ឆ
លើកវត្តព្រោះមិនឃើញអាបត្តិ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលសង្ឆ
លើកវត្តព្រោះមិនសំដែងអាបត្តិ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលសង្ឆ
លើកវត្តព្រោះមិនលះបង់នូវទិដ្ឋិអាក្រក់ ម្នាលភិក្ខុទាំងឡាយ របស់បណ្ឌក:

ថេយ្យសំវាសកស្ស កិ ក្ខ្ យ តិ ត្ថ ិ យ ឬ ក្ក ន ្ ត ក ស ្ ស ក ិ ក ្ ខ ្ យ
ត ិ រ ច ្ ឆ ា ន ក ត ស ្ ស ក ិ ក ្ ខ ្ យ ម ា ត ុ ឃ ា ត ក ស ្ ស ក ិ ក ្ ខ ្ យ ប ិ ត ុ-
ឃ ា ត ក ស ្ ស ក ិ ក ្ ខ ្ យ អ រ ហ ា ន ្ ត ឃ ា ត ក ស ្ ស ក ិ ក ្ ខ ្ យ ក ិ ក ្ ខ ុ-
ន ី ទ ូ ស ក ស ្ ស ក ិ ក ្ ខ ្ យ ស ង ្ ឆ ៃ ភ េ ទ ក ស ្ ស ក ិ ក ្ ខ ្ យ ល ោ ហ ិ-
ត ុ ប ្ ប ា ទ ក ស ្ ស ក ិ ក ្ ខ ្ យ ឧ ភ ត ោ ព ្ យ ញ ្ ជ ន ក ស ្ ស ក ិ ក ្ ខ ្ យ ជ ា-
ជ ា ស ំ វ ា ស ក ស ្ ស ក ិ ក ្ ខ ្ យ ជ ា ជ ា ស ី ម ា យ ប ិ ត ស ្ ស ក ិ ក ្ ខ ្ យ
ឥ ទ ្ ធ ិ យ ា វ េ ហ ា ស េ ប ិ ត ស ្ ស ក ិ ក ្ ខ ្ យ យ ស ្ ស ស ង ្ ឆ ៃ ក ម ្ ម ং
ក ហ ោ ត ិ ត ស ្ ស ក ិ ក ្ ខ ្ យ ស ង ្ ឆ ្ យ ម ជ ្ ឈ ប ដ ិ ណ ្ ណ ោ ស ជ ា ជ
រ ូ ហ ត ិ ។ ឥ ម េ ស ំ ខ ោ ក ិ ក ្ ខ ្ យ ស ង ្ ឆ ្ យ ម ជ ្ ឈ ប ដ ិ ណ ្ ណ ោ-
ស ជ ា ជ រ ូ ហ ត ិ ។ ក ស ្ ស ច ក ិ ក ្ ខ ្ យ ស ង ្ ឆ ្ យ ម ជ ្ ឈ
ប ដ ិ ណ ្ ណ ោ ស ជ ា រ ូ ហ ត ិ ។ ក ិ ក ្ ខ ុ ស ្ ស ក ិ ក ្ ខ ្ យ ប ក ត ត ្ ត ស ្ ស
ស ម ា ជ ស ំ វ ា ស ក ស ្ ស ស ម ា ជ ស ី ម ា យ ប ិ ត ស ្ ស

ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលលួចសំវាស ម្នាលភិក្ខុទាំងឡាយ
របស់ភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយ ម្នាលភិក្ខុទាំងឡាយ របស់សត្ត
តិរច្ឆាន ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលសម្ងាប់មាតា ម្នាលភិក្ខុទាំង-
ឡាយ របស់បុគ្គលដែលសម្ងាប់បិតា ម្នាលភិក្ខុទាំងឡាយ របស់បុគ្គល
ដែលសម្ងាប់ព្រះអរហន្ត ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលទ្រុស្ត
ភិក្ខុនី ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលបំបែកសង្ឆ ម្នាលភិក្ខុទាំងឡាយ
របស់បុគ្គលដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុះពងឡើង ម្នាលភិក្ខុ
ទាំងឡាយ របស់ឧកតោព្យញ្ជនក: ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែល
មានសំវាសផ្សេង ៗ គ្នា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលស្ថិតនៅក្នុង
សីមាផ្សេង ៗ គ្នា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលស្ថិតនៅលើអាកាស
ដោយឫទ្ធិ ជំនុំសង្ឆធ្វើកម្មដល់បុគ្គលណា ម្នាលភិក្ខុទាំងឡាយ ការ
ហាមឃាត់ក្នុងកណ្តាលជំនុំសង្ឆ របស់បុគ្គលនោះមិនឡើងទេ ។ ម្នាលភិក្ខុ
ទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឆ របស់បុគ្គលទាំងអម្បាល
នេះឯងមិនឡើងទេ ។ ម្នាលភិក្ខុទាំងឡាយ ឯការហាមឃាត់ក្នុងកណ្តាល
ជំនុំសង្ឆ របស់នរណាទើបឡើង ។ ម្នាលភិក្ខុទាំងឡាយ ការហាម
ឃាត់ក្នុងកណ្តាលជំនុំសង្ឆ របស់ភិក្ខុជាបកតត្តមានសំវាសស្មើគ្នា ស្ថិត

អន្តមសោ អនន្តរិកស្ស្ចាបិ ភិក្ខុនោ វិញ្ញាបេន្តស្ស សង្ឆ្យមជ្ឈ្យ បដិក្ខ្លោសនា ១ហតិ ។ ឥមស្ស ខោ ភិក្ខវេ សង្ឆ្យមជ្ឈ្យ បដិក្ខ្លោសនា ១ហតិ ។

[១០០] ទ្វេមា ភិក្ខវេ និស្ស្ចារណា អត្ថិ ភិក្ខវេ បុ្ត- លោ អ្ប្ប្ចត្ត្ចោ និស្ស្ចារណ្ យ តំ ចេ ១ ១ ១

នៅក្នុងសីមាជាមួយគ្នា ដោយហោចទៅ សូម្បីភិក្ខុដែលអង្គុយនៅជាលំដាប់ ដែលញ៉ាំងសង្ឆឲ្យដឹង ក៏ឡើងដែរ ។ ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់កណ្តាលជំនុំសង្ឆ របស់ភិក្ខុនេះឯង ទើបឡើង ។

[១០០] *ម្នាលភិក្ខុទាំងឡាយ និស្សារណាកម្ម (ការបណ្តេញចេញ) នេះមានពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ មានបុគ្គលគឺភិក្ខុដែលមិនទាន់ដល់នូវនិស្សារណាកម្មនៅឡើយ បើសង្ឆបណ្តេញបុគ្គលនោះចេញ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឆបណ្តេញចេញដោយល្អ (ត្រូវ) បុគ្គលពួកខ្លះ ឈ្មោះថា សង្ឆបណ្តេញចេញដោយអាក្រក់ (ខុស) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលមិនទាន់ដល់នូវនិស្សារណាកម្ម បើសង្ឆបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឆបណ្តេញចេញដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្អាតបរិសុទ្ធគ្មានអាបត្តិ បើសង្ឆបណ្តេញភិក្ខុនោះចេញ ឈ្មោះថា សង្ឆបណ្តេញចេញដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ តថាគតហៅថា បុគ្គលដែលមិនទាន់ដល់នូវនិស្សារណាកម្ម បើសង្ឆបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឆបណ្តេញចេញដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេចដែលមិនទាន់ដល់នូវនិស្សារណាកម្ម បើសង្ឆបណ្តេញបុគ្គលនោះ ចេញ ឈ្មោះថា សង្ឆបណ្តេញចេញដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ*

ពាលោ ហោតិ អព្យត្តោ អាបត្តិពហុលោ អនបទានោ
កិហិសំសដ្ឋោ វិហរតិ អនជ្ឈុលោមិកេហិ កិហិសំ-
សត្ថេហិ តំ ចេ សង្ឆោ ជិស្ឆាបេតិ សុជិស្ឆាបិតោ ។
អយំ រុច្ចតិ ភិក្ខវេ បុត្តលោ អប្ឆត្តោ ជិស្ឆាបណំ តំ
ចេ សង្ឆោ ជិស្ឆាបេតិ សុជិស្ឆាបិតោ ។

[១០១] ទ្វេមា ភិក្ខវេ ឋិសារណា អត្ថិ ភិក្ខវេ
បុត្តលោ អប្ឆត្តោ ឋិសារណំ តំ ចេ សង្ឆោ ឋិសារេតិ
ឯកន្ចេ សោសារិតោ ឯកន្ចេ ធោសារិតោ ។ ឥត-
មោ ច ភិក្ខវេ បុត្តលោ អប្ឆត្តោ ឋិសារណំ តំ
ចេ សង្ឆោ ឋិសារេតិ ធោសារិតោ ។ បណ្ហាកោ
ភិក្ខវេ អប្ឆត្តោ ឋិសារណំ ឥញ្ចេ សង្ឆោ ឋិសារេតិ
ធោសារិតោ ។ ថេយ្យសំវាសកោ ភិក្ខវេ ។ បេ ។

ក្នុងសាសនានេះ លូងមិនធ្ងាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ បើសង្ឆបណ្ដេញភិក្ខុនោះចេញ ឈ្មោះថា សង្ឆបណ្ដេញចេញដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះតថាគតហៅថា បុគ្គលដែលមិនទាន់ដល់នូវនិស្សារណាកម្ម បើសង្ឆបណ្ដេញបុគ្គលនោះចេញ ឈ្មោះថា បណ្ដេញចេញដោយល្អ ។

[១០១] ម្នាលភិក្ខុទាំងឡាយ ឱិសារណាកម្ម[1] មាន ២ យ៉ាង ម្នាលភិក្ខុទាំងឡាយ មានបុគ្គលដែលមិនទាន់ដល់នូវឱិសារណាកម្ម នៅឡើយ បើសង្ឆហៅបុគ្គលនោះបញ្ជូល បុគ្គលពួកខ្លះ ឈ្មោះថា សង្ឆហៅបញ្ជូលដោយល្អ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឆហៅបញ្ជូលដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្ដេច ដែលមិនទាន់ដល់នូវឱិសារណាកម្ម បើសង្ឆហៅបុគ្គលនោះបញ្ជូល ឈ្មោះថា សង្ឆហៅបញ្ជូលដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បណ្ណកៈ មិនដល់នូវឱិសារណាកម្មទេ បើសង្ឆហៅបណ្ណកៈនោះបញ្ជូល ឈ្មោះថា សង្ឆហៅបញ្ជូលដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលលួចសំវាស ។ បេ ។

---

1 ការហៅបញ្ជូលពួក ដោយអំណាចនៃកម្ម មានឧបសម្ប្ទាឲ្យបានជាភិក្ខុការៈជាដើម ហៅថា ឱិសារណាកម្ម ។

ចម្បេយ្យក្ខន្ធកេ ទ្វេ ឱសារណា

តិត្ថិយឫក្ខ្ជ្ជនកោ ភិក្ខវេ តិរច្ឆានគតោ ភិក្ខវេ មាតុឃា-
តកោ ភិក្ខវេ បិតុឃាតកោ ភិក្ខវេ អរហន្តឃាតកោ
ភិក្ខវេ ភិក្ខុនីទូសកោ ភិក្ខវេ សង្ឆ្យភេទកោ ភិក្ខវេ
លោហិតុប្ប្ជាទកោ ភិក្ខវេ ឧភតោព្យ្ជ្ជនកោ ភិក្ខវេ
អ្ជ្ជត្តោ ឱសារណំ តំ ចេ សង្ឆ្យ ឱសារេតិ ទោសា-
រិតោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្ជ្ជលោ អ្ជ្ជត្តោ ឱសារណំ
តំ ចេ សង្ឆ្យ ឱសារេតិ ទោសារិតោ[(១)] ។ ឥតមោ
ច ភិក្ខវេ បុគ្ជ្ជលោ អ្ជ្ជត្តោ ឱសារណំ តំ ចេ សង្ឆ្យ
ឱសារេតិ សោសារិតោ ។ ហត្ថច្ឆ្ជ្ជោ ភិក្ខវេ អ្ជ្ជត្តោ
ឱសារណំ តំ ចេ សង្ឆ្យ ឱសារេតិ សោសារិតោ ។
ចាទច្ឆ្ជ្ជោ ភិក្ខវេ ។ បេ ។ ហត្ថចាទច្ឆ្ជ្ជោ ភិក្ខវេ

---

១ ឱ. ឥមេ វុច្ចន្តិ ភិក្ខវេ បុគ្ជ្ជលា អ្ជ្ជត្តា ឱសារណំ តំ ចេ សង្ឆ្យ ឱសារេតិ ទោសារិតា ។

ចម្បេយ្យក្ខន្ធក: ឱសារណាកម្ម (ការហៅបញ្ចូលពួក) មានពីរយ៉ាង

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយ ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្ងាប់មាតា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្ងាប់បិតា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្ងាប់ព្រះអរហន្ត ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលទ្រុស្តភិក្ខុនី ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបំបែកសង្ឆ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្វើលោហិតុប្បាទ ម្នាលភិក្ខុទាំងឡាយ ឧកតោព្យញ្ជនក: មិនដល់នូវឱសារណាកម្មទេ បើសង្ឆហៅបុគ្គលនោះបញ្ចូល ឈ្មោះថាសង្ឆហៅបញ្ចូលដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតហៅបុគ្គលនេះ ឯងថា មិនដល់នូវឱសារណាកម្ម បើសង្ឆហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឆហៅបញ្ចូលដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលមិនដល់នូវឱសារណាកម្ម បើសង្ឆហៅបុគ្គលនោះ បញ្ចូលឈ្មោះថា សង្ឆបញ្ចូលដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតដៃ មិនដល់នូវឱសារណាកម្មទេ បើសង្ឆហៅបុគ្គលនោះបញ្ចូលឈ្មោះថា សង្ឆហៅបញ្ចូលដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតជើង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតទាំងដៃទាំងជើង

កណ្ណាច្ឆិន្នោ ភិក្ខវេ ជាសច្ឆិន្នោ ភិក្ខវេ កណ្ណាជាសច្ឆិន្នោ

ភិក្ខវេ អង្ក្ខុលិច្ឆិន្នោ ភិក្ខវេ អឌ្ឍច្ឆិន្នោ ភិក្ខវេ កណ្ហា-

រច្ឆិន្នោ ភិក្ខវេ ផណាហាត្តកោ ភិក្ខវេ ខុជ្ជោ ភិក្ខវេ

វាមណោ ភិក្ខវេ ឥលតណ្ហី ភិក្ខវេ លក្ខណាហាតោ

ភិក្ខវេ ឥសាហាតោ ភិក្ខវេ លិខិតកោ ភិក្ខវេ ស៊ីបឌី

ភិក្ខវេ ចាបរោគី ភិក្ខវេ ឧរិសជ្ជសកោ ភិក្ខវេ ឥ-

ណោ ភិក្ខវេ ឥុណី ភិក្ខវេ ខញ្ជោ ភិក្ខវេ ឧក្ខហាតោ

ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតត្រចៀក ម្នាលភិក្ខុទាំងឡាយ មនុស្ស
កំបុតច្រមុះ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតទាំងត្រចៀកទាំងច្រមុះ ម្នាល
ភិក្ខុទាំងឡាយមនុស្សកំបុតម្រាមដៃ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុត
មេដៃមេជើង ម្នាលភិក្ខុទាំងឡាយ មនុស្សជាប់សរសៃធំ (សរសៃពួរជើង)
ម្នាលភិក្ខុទាំងឡាយ មនុស្សមានដៃព្រៃក (មានម្រាមដៃជាប់គ្នា ដូចស្ងាប
ប្រចៀវ) ម្នាលភិក្ខុទាំងឡាយ មនុស្សគម ម្នាលភិក្ខុទាំងឡាយ មនុស្ស
តឿ ម្នាលភិក្ខុទាំងឡាយ មនុស្សពកកឬពកត្រង់អវ:យវ:ឯណានីមួយ ម្នាល
ភិក្ខុទាំងឡាយ មនុស្សដែលគេបៀតបៀនឲ្យមានស្វាកស្នាម ម្នាលភិក្ខុ
ទាំងឡាយ មនុស្សដែលគេវាយឲ្យមានស្នាមដោយរំពាត់ ម្នាលភិក្ខុទាំង-
ឡាយ មនុស្សដែលគេកត់ឈ្មោះទុក (ញ្ជូរទោសទុក) ម្នាលភិក្ខុទាំង-
ឡាយ មនុស្សដែលមានជើងហើមស្ងួត ម្នាលភិក្ខុទាំងឡាយ មនុស្សដែល
មានរោគអាក្រក់ (មានឫសដូងបាតជាដើម) ម្នាលភិក្ខុទាំងឡាយ មនុស្ស
ដែលមានរូបទ្រុស្តបរិសទ្ស (គឺមានរូបអាក្រក់ខុសគេ មានខ្ពស់ពេកទាប
ពេកជាដើម) ម្នាលភិក្ខុទាំងឡាយ មនុស្សដែលទើបតែនឹងខ្វាក់ ឬខ្វាក់ម្ខាង
ម្នាលភិក្ខុទាំងឡាយ មនុស្សកែងកូងដៃជើងជាដើម ម្នាលភិក្ខុទាំងឡាយ
មនុស្សខ្ជកជើង ម្នាលភិក្ខុទាំងឡាយ មនុស្សដែលស្ងាប់ ១ ចំហៀងខ្លួន

ចម្បេយ្យក្ខន្ធកេ ឧក្ខេបនីយកម្មា អធម្មកម្មំ

ភិក្ខវេ ធិដ្ឋិវិយោបថោ ភិក្ខវេ ជ្ឈាឧ្ជ្ជ្ជ

ចម្បេយ្យក្ខន្ធក: ឧក្ខេបនីយកម្ម ដែលជាកម្មមិនប្រកបដោយធម៌

ម្នាលភិក្ខុទាំងឡាយ មនុស្សខ្វិន ម្នាលភិក្ខុទាំងឡាយ មនុស្សចាស់គ្រាំ-គ្រា ម្នាលភិក្ខុទាំងឡាយ មនុស្សដែលខ្វាក់ពីកំណើត ម្នាលភិក្ខុទាំង-ឡាយ មនុស្សគ ម្នាលភិក្ខុទាំងឡាយ មនុស្សថ្ងង់ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងខ្វាក់ទាំងគ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងខ្វាក់ទាំងថ្ងង់ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងគទាំងថ្ងង់ ម្នាលភិក្ខុទាំងឡាយ មនុស្ស ទាំងខ្វាក់ទាំងគទាំងថ្ងង់ មិនដល់នូវឱិសារណាកម្មទេ បើសង្ឆហៅបុគ្គល នោះបញ្ជូល ឈ្មោះថា សង្ឆហៅបញ្ជូលដោយល្អ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតហៅបុគ្គលនេះឯងថា មិនដល់នូវឱិសារណាកម្មទេ បើ សង្ឆហៅបុគ្គលនោះបញ្ជូល ឈ្មោះថា សង្ឆហៅបញ្ជូលដោយល្អ ។

ចប់ វាសភគាមភាណវារ:ទី ១ ។

[១០២] ម្នាលភិក្ខុទាំងឡាយ បើអាបត្តិដែលភិក្ខុត្រូវឃើញ មិនមាន ដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គល (គឺភិក្ខុ) ១ រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោក ឃើញអាបត្តិនុ៎ះទេ ។ ភិក្ខុនោះពោលតបវិញយ៉ាងនេះថា ម្នាលអាវុសោ

អាបត្តិ យមហំ បស្សេយ្យន្តិ ។ តំ សង្ឆោ អាបត្តិយា
អនុស្សរនេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ
ភិក្ខុស្ស ន ហោតិ អាបត្តិ បដិកាតព្ពា ។ តមេនំ ចោ-
ទេតិ សង្ឆោ វា សម្ពហុលា វា ឯកបុគ្គលោ វា អាបត្តឺ
ត្វំ អាវុសោ អាបន្នោ បដិកភេហិ តំ អាបត្តិន្តិ ។
សោ ឯវំ វទេតិ ជត្តិ មេ អាវុសោ អាបត្តិ យមហំ
បដិកភេយ្យន្តិ ។ តំ សង្ឆោ អាបត្តិយា អប្បដិ-
ការេ ឧក្ខិបតិ អធម្មកម្មំ ។ ឥធ បន ភិក្ខវេ
ភិក្ខុស្ស ន ហោតិ ទាបិការ ឧ្ជិ បដិនិស្សជ្ជនា ។
តមេនំ ចោទេតិ សង្ឆោ វា សម្ពហុលា វា ឯកបុគ្គលោ
វា ទាបិការ ត្ត អាវុសោ ឧ្ជិ បដិនិស្សជ្ជតំ ទាបិការ
ឧ្ជិន្តិ ។ សោ ឯវំ វទេតិ ជត្តិ មេ អាវុសោ
ទាបិការ ឧ្ជិ យមហំ បដិនិស្សជ្ជេយ្យន្តិ ។ តំ
សង្ឆោ ទាបិការយ ឧ្ជិយ អប្បដិនិស្សគ្ត ឧក្ខិបតិ
អធម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ន ហោតិ
អាបត្តិ ឧដ្ឋ ន ហោតិ អាបត្តិ បដិកាតព្ពា ។ តមេ-
នំ ចោទេតិ សង្ឆោ វា សម្ពហុលា វា ឯកបុគ្គលោ វា

អាបត្តិដែលខ្ញុំគួរឃើញនោះ មិនមានដល់ខ្ញុំទេ ។ សង្ឆ្ក ក៏លើកវត្តកិក្ខុនោះ ព្រោះមិនឃើញអាបត្តិ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលភិក្ខុត្រូវសំដែងមិនមានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឆ្ក ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ ។ ភិក្ខុនោះពោលតបវិញយ៉ាងនេះ ថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែងនោះ មិនមានដល់ខ្ញុំទេ ។ សង្ឆ្ក ក៏លើកវត្តកិក្ខុនោះ ព្រោះមិនសំដែងអាបត្តិចេញ (យ៉ាងនេះ) ឈ្មោះ ថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ទិដ្ឋិ អាក្រក់ដែលត្រូវលះបង់ មិនមានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឆ្ក ភិក្ខុ ច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកមាន ទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ ។ ភិក្ខុនោះ ពោលតបវិញយ៉ាងនេះថា ម្នាលអាវុសោ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ មិនមានដល់ខ្ញុំទេ ។ សង្ឆ្ក ក៏លើកវត្តកិក្ខុនោះ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ចេញ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវឃើញ ក៏មិនមាន អាបត្តិដែលត្រូវសំដែង ក៏មិន មានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឆ្ក ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី

ចម្បេយ្យក្ខន្ធកេ ឧក្ខេបនីយកម្មា ធម្មកម្មំ

អាបត្តឺ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តឺ
បដិកភេហិ តំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ ជត្តិ
មេ អាវុសោ អាបត្តិ យមហំ បស្សយ្យំ ជត្តិ មេ
អាវុសោ អាបត្តិ យមហំ បដិកភេយ្យន្តិ ។ តំ សង្ឆោ
អនុស្សវេ វ អប្ប្ដិកម្ម ១ ឧក្ខិបតិ អធម្ម្ធកម្ម ។
ឥធ បន ភិក្ខវេ ភិក្ខុ ១ ហោតិ អាបត្តិ ១ ១ ១
ហោតិ ចាបិ ១ ១ ១ ១ ១ ។ ១ ១
ចោទេតិ ១ ១ ១ ១ ១ ១
១ ១ ១ ១ ១

ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញមិនមានដល់ខ្ញុំទេ ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែងក៏មិនមានដល់ខ្ញុំដែរ ។ សង្ឆលើកវត្តភិក្ខុនោះ ព្រោះមិនឃើញ (អាបត្តិ) ក្តី ព្រោះមិនសំដែងក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលត្រូវឃើញ ក៏មិនមាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ ក៏មិនមានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញមិនមានដល់ខ្ញុំទេ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ ក៏មិនមានដល់ខ្ញុំដែរ ។ សង្ឆលើកវត្តភិក្ខុនោះ ព្រោះមិនឃើញ (អាបត្តិ) ក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវសំដែងក៏មិនមាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ ក៏មិនមានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ

អាបន្នោ បជិកកេហិ តំ អាបត្តឺ ចាបិកា តេ ជិដ្ឋិ
បជិនិស្សជ្ជេតំ ចាបិកំ ជិដ្ឋិន្តិ ។ សោ ឯវំ វទេតិ ជត្តិ
មេ អាវុសោ អាបត្តិ យមហំ បជិកយ្យំ ជត្តិ មេ
អាវុសោ ចាបិកា ជិដ្ឋិ យមហំ បជិនិស្សជ្ជេយ្យន្តិ ។
តំ សង្ឆោ អប្ជជិកម្ម វ អប្ជជិនិស្សគ្ត ១ ឧក្ខិបតិ
អធម្ម្ម ។ ឥធ ១ ១ ១ ១ ១ ១
អាបត្តិ ១ ១ ១ ១ ១ ១
ចាបិកា ១ ១ ១ ១ ១

លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់ន៏ុះចេញ ។ ភិក្ខុនោះពោលតបវិញយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែង មិនមានដល់ខ្ញុំទេ ម្នាលអាវុសោ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ ក៏មិនមានដល់ខ្ញុំដែរ ។ សង្ឆលើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវឃើញ ក៏មិនមាន អាបត្តិដែលត្រូវសំដែងក៏មិនមាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ ក៏មិនមានដល់ភិក្ខុក្នុងសាសនានេះទេ ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិន៏ុះទេ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញ មិនមានដល់ខ្ញុំទេ ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែង ក៏មិនមានដល់ខ្ញុំដែរ ម្នាលអាវុសោ ទាំងទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ ក៏មិនមានដល់ខ្ញុំដែរ ។ សង្ឆលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។

ចម្បេយ្យក្ខន្ធកេ ឧក្ខេបនីយកម្មា ធម្មកម្មំ

[១០៣] ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ ឧដ្ឋញ្ចា ។ តមេនំ ចោទេតិ សង្ឆោ វ សម្ពហុលា វ ឯកបុគ្គលោ វ អាបត្តឺ ត្វំ អាវុសោ អាបន្នោ បស្ស-សេតំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ អាមាវុសោ បស្ស-មីតិ ។ តំ សង្ឆោ អាបត្តិយា អឧស្សេ ឧក្ខិបតិ អឧម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ បដិកាតញ្ចា ។ តមេនំ ចោទេតិ សង្ឆោ វ សម្ពហុលា វ ឯកបុគ្គលោ វ អាបត្តឺ ត្វំ អាវុសោ អាបន្នោ បដិ-កភេហិ តំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ អាមាវុសោ បដិករិស្សាមីតិ ។ តំ សង្ឆោ អាបត្តិយា អប្បដិកម្មេ ឧក្ខិបតិ អឧម្មកម្មំ ។ ឥធ បន ភិក្ខវេ ភិក្ខុស្ស ហោតិ ចាបិកា ឧិដ្ឋិ បដិនិស្សជ្ជេតា ។ តមេនំ ចោទេតិ សង្ឆោ វ សម្ពហុលា វ ឯកបុគ្គលោ វ ចាបិកា តេ អាវុសោ ឧិដ្ឋិ បដិនិស្សជ្ជេតំ ចាបិកំ ឧិដ្ឋិន្តិ ។ សោ ឯវំ វទេតិ អាមាវុសោ បដិនិស្សជ្ជិស្សាមីតិ ។ តំ សង្ឆោ ចាបិកាយ ឧិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបតិ

ចម្បេយ្យក្ខន្ធកៈ ឧក្ខេបនីយកម្ម ដែលជាកម្មមិនប្រកបដោយធម៌

[១០៣] ម្នាលភិក្ខុទាំងឡាយ មួយទៀត អាបត្តិដែលត្រូវឃើញ មានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អើអាវុសោ ខ្ញុំឃើញដែរ ។ សង្ឆលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលត្រូវសំដែងមានដល់ភិក្ខុ ក្នុងសាសនានេះ ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អើអាវុសោ ចាំខ្ញុំសំដែង ។ សង្ឆលើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ មានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អើអាវុសោ ចាំខ្ញុំលះបង់ ។ សង្ឆលើកវត្តភិក្ខុនោះ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ

អ១ម្ម១កម្ម ។ ឥ១ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ ១ជ្ជ១ា ហោតិ អាបត្តិ បដិ១ាតព្ា ។ ហោតិ អាបត្តិ ១ជ្ជ១ា ហោតិ ១ាបិ១ា ១ិដ្ឋិ បដិ១ិស្ស្ជ្ជ១ា ។ ហោតិ អាបត្តិ បដិ១ាតព្ា ហោតិ ១ាបិ១ា ១ិដ្ឋិ បដិ១ិស្ស្ជ្ជ-១ា ។ ហោតិ អាបត្តិ ១ជ្ជ១ា ហោតិ អាបត្តិ បដិ១ាតព្ា ហោតិ ១ាបិ១ា ១ិដ្ឋិ បដិ១ិស្ស្ជ្ជ១ា ។ ១មេ១ំ ចោ-១េតិ សង្ឆោ វ សម្ពហុលា វ ឯ១បុ១្១លោ វ អ-បត្តឺ ១ំ អាវុសោ អាបន្នោ បស្ស្ជ១ំ អាបត្តឺ បដិ១ម្ម-ហិ ១ំ អាបត្តឺ ១ាបិ១ា ១េ ១ិដ្ឋិ បដិ១ិស្ស្ជ្ជ១ំ ១ាបិ១ំ ១ិដ្ឋិ១ិ ។ សោ ឯវំ វ១េតិ អាមាវុសោ បស្ស្ជ្ជ១ាមិ អាម បដិ១ាវិស្ស្ជ្ជ១ាមិ អាម បដិ១ិស្ស្ជ្ជ១ិ ។ ១ំ សង្ឆោ អ១ស្ស្ជ១េ វ អ្ជ្ជ១ិ១ាម្ម ១ អ្ជ្ជ១ិ១ិស្ស្ជ្ជ១ា ១ ឧ១្ខ១ិ១ិ អ១ម្ម១ាកម្ម ។

[១០៤] ឥ១ បន ភិក្ខវេ ភិក្ខុស្ស ហោតិ អាបត្តិ ១ជ្ជ១ា ។ ១មេ១ំ ចោ១េតិ សង្ឆោ ១ សម្ពហុលា ១ ឯ១បុ១្១លោ ១ អាបត្តឺ ១ំ អាវុសោ អាបន្នោ បស្ស្ជ១ំ អាបត្តិ១ិ ។ សោ ឯវំ វ១េតិ ១ត្ថិ មេ អាវុសោ អាបត្តិ

(យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន ដល់ភិក្ខុក្នុងសាសនានេះ ។ អាបត្តិដែលត្រូវឃើញក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ អាបត្តិដែលត្រូវសំដែងក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ អាបត្តិដែលត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន (ទាំង) ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះទិដ្ឋិអាក្រក់នោះចេញ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អើអាវុសោ ខ្ញុំឃើញដែរ អើចាំខ្ញុំសំដែងចេញ អើចាំខ្ញុំលះបង់ចេញ ។ សង្ឆលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌ ។

[១០៤] ម្នាលភិក្ខុទាំងឡាយ អាបត្តិដែលត្រូវឃើញ មានដល់ភិក្ខុក្នុងសាសនានេះ ។ សង្ឆក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែល

យមហំ បស្សេយ្យន្តិ ។ តំ សង្ឆោ អាបត្តិយា អទស្សនេ ឧក្ខិបតិ ធម្មកម្មំ ។ ឥទ បន កិក្ខេ កិក្ខុស្ស ហោតិ អាបត្តិ បដិកាតព្ពា ។ តមេនំ ចោទេតិ សង្ឆោ វ សម្ព-ហុលា វ ឯកបុគ្គលោ វ អាបត្តឺ ត្វំ អាវុសោ អាបន្នោ បដិកភេហិ តំ អាបត្តិន្តិ ។ សោ ឯវំ វទេតិ ជត្តិ មេ អាវុ-សោ អាបត្តិ យមហំ បដិកភេយ្យន្តិ ។ តំ សង្ឆោ អាបត្តិ-យា អប្បដិកម្មេ ឧក្ខិបតិ ធម្មកម្មំ ។ ឥទ បន កិក្ខេ កិក្ខុស្ស ហោតិ ចាបិកា ទិដ្ឋិ បដិនិស្សជ្ជេតា ។ តមេនំ ចោទេតិ សង្ឆោ វ សម្ពហុលា វ ឯកបុគ្គលោ វ ចាបិកា តេ អាវុសោ ទិដ្ឋិ បដិនិស្សជ្ជេតំ ចាបិកំ ទិដ្ឋិន្តិ ។ សោ ឯវំ វទេតិ ជត្តិ មេ អាវុសោ ចាបិកា ទិដ្ឋិ យមហំ បដិនិស្សជ្ជេយ្យន្តិ ។ តំ សង្ឆោ ចាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិបតិ ធម្មកម្មំ ។ ឥទ បន កិក្ខេ កិក្ខុស្ស ហោតិ អាបត្តិ ទដ្ឋព្ពា ហោតិ អាបត្តិ បដិ-កាតព្ពា ។ ហោតិ អាបត្តិ ទដ្ឋព្ពា ហោតិ ចាបិកា ទិដ្ឋិ បដិនិស្សជ្ជេតា ។ ហោតិ អាបត្តិ បដិកាតព្ពា ហោតិ ចាបិកា ទិដ្ឋិ បដិនិស្សជ្ជេតា ។ ហោតិ អាបត្តិ

ខ្ញុំ ត្រូ វ ឃើ ញ មិ ន មា ន ដ ល់ ខ្ញុ ំ ទ ។ ស ង្ ឆ ្ ម លើ ក ว ត្ ត ភិ ក្ ខ ុ នោ ះ ព្ រោ ះ មិ ន ឃើ ញ អា ប ត្ តិ (យ ៉ា ង នេ ះ) ហៅ ថ ា ក ម្ ម ប្ រ ក ប ដោ យ ធ ម៌ ។ ម្ ា ល ភិ ក្ ខ ុ ទ ាំ ង ឡ ាយ ម្ យ ៉ា ង ទ ៀ ត អា ប ត្ តិ ដែ ล ត្ រូ ว សំ ដែ ง ม ม ន ដ ล់ ภิ ก ขุ ใ น ศ า ส น า นี้ ។ ส ง ฆ์ ก ็ ี ภิ ก ขุ ห ล า ย รู ป ก ็ ี บ ุ ค ค ล ม ว ย รู ป ก ็ ี ช ว น ภ ิ ก ข ุ น ั ้ น ว า ม ิ ต ร อ า ว ุ ส ว ล ว ก ต ร ว จ อ า ป ต ิ แ ล ้ ว จ ง ล ว ก ส ม ั ด อ า ป ต ิ น ั ้ น ข ึ ้ น ม า ส ว น ภ ิ ก ข ุ น ั ้ น ก ล ่ า ว ต อ บ อ ย ่ า ง น ี ้ ว า ม ิ ต ร อ า ว ุ ส ว ล อ า ป ต ิ ท ี ่ ข ้ า พ เ จ ้ า ต ร ว จ ส อ บ ม ิ ม ี ม า ส ู ่ ข ้ า พ เ จ ้ า ห า ม ิ ม ี ม า ส ู ่ ข ้ า พ เ จ ้ า ส ง ฆ ์ ล ว ก ต ร ว จ อ า ป ต ิ น ั ้ น ม ิ ม ี ม า ส ู ่ ข ้ า พ เ จ ้ า ย ่ อ ม ก ล ่ า ว ว ่ า ก ร ร ม ป ร ก ป ด ว ย ธ ร ร ม ด ี ห ร อ ม ิ ด ี ม ี ข ึ ้ น แ ก ่ ภ ิ ก ข ุ ท ั ้ ง ห ล า ย ม ิ ม ี ข ึ ้ น ส ำ ห ร ั บ ข ้ า พ เ จ ้ า ด ว ย อ ป ม า ฉ ะ น ี ้ ฉ ะ น ั ้ น ข ้ า พ เ จ ้

ជដ្ឌញ្ញា ហោតិ អាបត្តិ បជិកាតញ្ញា ហោតិ ចាបិកា ជិដ្ឋិ បជិនិស្សជ្ជេតា ។ តមេនំ ចោទេតិ សង្ឆោ វ សម្ពហុ-លា វ ឯកបុគ្គលោ វ អាបត្តឺ ត្វំ អាវុសោ អាបន្នោ បស្សសេតំ អាបត្តឺ បជិកហេហិ តំ អាបត្តឺ ចាបិកា តេ អាវុសោ ជិដ្ឋិ បជិនិស្សជ្ជេតំ ចាបិកំ ជិដ្ឋិន្តិ ។ សោ ឯវំ វទេតិ ជត្តិ មេ អាវុសោ អាបត្តិ យមហំ បស្សេយ្យំ ជត្តិ មេ អាបត្តិ យមហំ បជិករេយ្យំ ជត្តិ មេ ចា-បិកា ជិដ្ឋិ យមហំ បជិនិស្សជ្ជេយ្យន្តិ ។ តំ សង្ឆោ អជ្ឌសេ វ អប្ជជិកម្ម វ អប្ជជិនិស្សគ្ត វ ឧក្ខិបតិ ជម្ម្ហកម្ម្ហន្តិ ។

[១០៥] អថ ខោ អាយស្ម ឧចាលិ យេន ភគ្ត ត្ត ឧបសង្ក្ត ឧបសង្ក្ត ភគ្ត ។ ឯកមន្ត ជិសីជិ ។ ឯកមន្ត ជិសិ ខោ អាយស្ម ឧចាលិ ភគ្ត ឯតជ្ជ យោ ជ ខោ ភន្ត សមគ្ត សង្ឆោ សម្ម្ហ ការ ណីយ ក ម្ម អ ម្ហ ក ហោ ជ ម្ម ក ម្ម ជ ខោ ត ភន្ត ១ ។ ជ ម្ម ក ម្ម ត ឧចាលិ

ត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន ទាំងទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន ។ សង្ឆ្ក ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញមិនមានដល់ខ្ញុំទេ អាបត្តិដែលខ្ញុំត្រូវសំដែងក៏មិនមានដល់ខ្ញុំ ទាំងទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ ក៏មិនមានដល់ខ្ញុំដែរ ។ សង្ឆ្យលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ហៅថា កម្ម ប្រកបដោយធម៌ ។

[១០៥] គ្រានោះឯង ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរពាក្យនេះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កម្មដែលត្រូវធ្វើ ក្នុងទីចំពោះមុខ សង្ឆ្យណាមួយព្រមព្រៀងគ្នាធ្វើក្នុងទីកំបាំងមុខទៅវិញ បពិត្រព្រះអង្គដ៏ចម្រើន កម្មនោះជាកម្មត្រូវតាមធម៌ ជាកម្មត្រូវតាមវិន័យដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ

អវិនយកម្មន្តិ ។ យោ ឧ ខោ ភន្តេ សមត្តោ សង្ឆោ
បដិបុច្ឆាការណីយំ កម្មំ អប្ឆដិបុច្ឆា កភេតិ បដិញ្ញាយ
ការណីយំ កម្មំ អប្ឆដិញ្ញាយ កភេតិ សតិវិនយារ-
ហស្ស អមូឍ្ហវិនយំ ឧេតិ អមូឍ្ហវិនយារហស្ស ឥស្ស
ចាបិយសិកាកម្មំ កភេតិ ឥស្ស ចាបិយសិកាកម្ម-
រហស្ស ឥជ្ជនីយកម្មំ កភេតិ ឥជ្ជនីយកម្មារហស្ស
និយស្សកម្មំ កភេតិ និយស្សកម្មារហស្ស បញ្ចាជនី-
យកម្មំ កភេតិ បញ្ចាជនីយកម្មារហស្ស បដិសារណី-
យកម្មំ កភេតិ បដិសារណីយកម្មារហស្ស ឧក្ខេប-
នីយកម្មំ កភេតិ ឧក្ខេបនីយកម្មារហស្ស បរិវាសំ ឧេតិ
បរិវាសារហំ មូលាយ បដិកស្ឆតិ មូលាយ បដិកស្ឆ-
ណារហស្ស មានត្តំ ឧេតិ មានត្តារហំ អព្ភេតិ អព្ភាណារហំ
ឧបសម្ប្បាឧេតិ ឩម្ម្ចកម្មំ ឧ ខោ តំ ភន្តេ វិនយកម្មន្តិ ។
អឩម្ម្ចកម្មំ តំ ឧចាលិ អវិនយកម្មំ យោ ខោ ឧចាលិ
សមត្តោ សង្ឆោ សម្ម្ចុខាការណីយំ កម្មំ អសម្ម្ចុខា

កម្មនោះ ជាកម្មមិនត្រូវតាមធម៌ ជាកម្មមិនត្រូវតាមវិន័យទេ ។ ព្រះឧបាលិដ៏មានអាយុ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឆណាមួយព្រមព្រៀងគ្នា ធ្វើដោយការមិនសាកសួរវិញ កម្មដែលត្រូវធ្វើដោយការប្តេជ្ញា សង្ឆធ្វើដោយមិនបានប្តេជ្ញាវិញ ឲ្យអមូទ្ធវិន័យ ដល់ភិក្ខុដែលគួរដល់សតិវិន័យវិញ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់អមូទ្ធវិន័យវិញ ធ្វើតជ្ជនីយកម្មដល់ភិក្ខុ ដែលគួរដល់តស្សបាបិយសិកាកម្មវិញ ធ្វើនិយស្សកម្មដល់ភិក្ខុ ដែលគួរដល់តជ្ជនីយកម្មវិញ ធ្វើបញ្ជាជនីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្មវិញ ធ្វើបដិសារ-ណីយកម្មដល់ភិក្ខុ ដែលគួរដល់បញ្ជាជនីយកម្មវិញ ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុ ដែលគួរដល់បដិសារណីយកម្មវិញ ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្មវិញ ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែលគួរដល់បរិវាសវិញ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈវិញ ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់មានត្តវិញ ឲ្យឧបសម្បទាដល់ភិក្ខុដែលគួរដល់អព្ភានវិញ បពិត្រព្រះអង្គដ៏ចម្រើន កម្មនោះជាកម្មត្រូវតាមធម៌ ជាកម្មត្រូវតាមវិន័យដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះ មិនមែនជាកម្មត្រូវតាមធម៌ មិនមែនជាកម្មត្រូវតាមវិន័យទេ ម្នាលឧបាលិ សង្ឆណាមួយព្រមព្រៀងគ្នា ធ្វើកម្មដែលត្រូវធ្វើក្នុងទីចំពោះមុខ (ត្រឡប់ជាធ្វើ) ក្នុងទីកំបាំងមុខវិញ

ភវតិ ឯវं ខោ ឧចាលិ អធម្មកម្មं ហោតិ អវិនយកម្មं ឯវញ្ច បន សង្ឆោ សាតិសារោ ហោតិ យោ ខោ ឧចាលិ សមត្តោ សង្ឆោ បដិបុច្ឆាការណីយំ កម្មं អប្បដិបុច្ឆា ភវតិ បដិញ្ញាយ ការណីយំ កម្មं អប្បដិញ្ញាយ ភវតិ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ អមូឡ្ហ-វិនយារហស្ស តស្ស ចាបិយសិការកម្មं ភវតិ តស្ស ចាបិយសិការកម្មារហស្ស តជ្ជនីយកម្មं ភវតិ តជ្ជ-នីយកម្មារហស្ស និយស្សកម្មं ភវតិ និយស្សកម្ម-រហស្ស បព្ជាជនីយកម្មं ភវតិ បព្ជាជនីយកម្មារហស្ស បដិសារណីយកម្មं ភវតិ បដិសារណីយកម្មារហស្ស ឧក្ខេបនីយកម្មं ភវតិ ឧក្ខេបនីយកម្មារហស្ស បរិវាសं ទេតិ បរិវាសារហं មូលាយ បដិកស្សតិ មូលាយ បដិកស្សនារហស្ស មានត្តं ទេតិ មានត្តារហं អព្ភេតិ អព្ភានារហं ឧបសម្ជាទេតិ ឯវं ខោ ឧចាលិ អធម្មកម្មं ហោតិ អវិនយកម្មं ឯវញ្ច បន សង្ឆោ សាតិសារោ ហោតីតិ ។

ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា អធម្មកម្ម (កម្មមិនត្រូវតាមធម៌) ឈ្មោះថា អវិនយកម្ម (កម្មមិនត្រូវតាមវិន័យ) ឯសង្ឆ្យសោតក៏ជាសង្ឆ្យប្រកបដោយទោស ដោយប្រការដូច្នេះ ម្នាលឧបាលិ កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឆ្យណាមួយព្រមព្រៀងគ្នាធ្វើ ដោយមិនបានសាកសួរ កម្មដែលត្រូវធ្វើដោយសេចក្ដីប្ដេជ្ញា សង្ឆ្យធ្វើដោយមិនបានប្ដេជ្ញាវិញ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើតស្សបាបិយ-សិកាកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យឧបសម្ប្ទា ដល់ភិក្ខុដែលគួរដល់អព្ភាន ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឆ្យសោត ក៏ជាសង្ឆ្យប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។

[១០៦] យោ ឧ ខោ ភន្តេ សមក្តោ សង្ឆោ សម្ម្ខាការណីយំ កម្មំ សម្ម្ខា ការោតិ ធម្ម្ការកម្មំ ឧ ខោ តំ ភន្តេ វិនយការកម្មន្តិ ។ ធម្ម្ការកម្មំ តំ ឧចាលិ វិនយការកម្មន្តិ ។ យោ ឧ ខោ ភន្តេ សមក្តោ សង្ឆោ បដិបុច្ឆាការណីយំ កម្មំ បដិបុច្ឆាការោតិ បដិញ្ញាយ ការណីយំ កម្មំ បដិញ្ញាយ ការោតិ សតិវិនយារហស្ស សតិវិនយំ ទេតិ អមូឍ្ហវិនយារហស្ស អមូឍ្ហវិនយំ ទេតិ ឥស្ស ចាបិយសិការកម្ការហស្ស ឥស្ស ចាបិយសិការ-កម្មំ ការោតិ ឥជ្ជនីយការកម្ការហស្ស ឥជ្ជនីយការកម្មំ ការោតិ និយស្ស្ការកម្ការហស្ស និយស្ស្ការកម្មំ ការោតិ បញ្ចាជនីយការកម្ការហស្ស បញ្ចាជនីយការកម្មំ ការោតិ បដិសារណីយការកម្ការហស្ស បដិសារណីយការកម្មំ ការោតិ ឧក្ខេ្ខបនីយការកម្ការហស្ស ឧក្ខេ្ខបនីយការកម្មំ ការោតិ បរិវាសារហស្ស បរិវាសំ ទេតិ មូលាយ បដិការ្ស្ស្ជារហំ មូលាយ បដិការ្ស្ស្ជតិ មានត្តារហស្ស មានត្តំ ទេតិ អព្ភានារហំ អព្ភេតិ ឧបសម្ជ្ជារហំ ឧបសម្ជ្ជាទេតិ

ចម្បេយ្ជ្ជនក: ពាក្យសួររបស់ឧបាលិត្ថេរអំពីបញ្ជាជនីយកម្មជាដើម

[១០៦] ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន កម្មដែលត្រូវធ្វើ ក្នុងទីចំពោះមុខ សង្ឆណាមួយព្រមព្រៀងគ្នាធ្វើ ក្នុងទីចំពោះមុខ បពិត្រព្រះអង្គដ៏ចម្រើន កម្មរបស់សង្ឆនោះ តើហៅថា ធម្មកម្ម (កម្មត្រូវតាមធម៌) ថា វិនយកម្ម (កម្មត្រូវតាមវិន័យ) ដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះហៅថា ជាធម្មកម្ម ជាវិនយកម្ម ។ ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឆណាមួយព្រមព្រៀងគ្នាធ្វើ ដោយការសាកសួរ កម្មដែលត្រូវធ្វើដោយសេចក្តីប្តេជ្ញា សង្ឆធ្វើដោយសេចក្តីប្តេជ្ញា ឲ្យសតិ-វិន័យ ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយ-សិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្ស-កម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបញ្ជាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បញ្ជាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារ-ណីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សន: ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សន: ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទា ដល់កុលបុត្តដែលគួរដល់ឧបសម្បទា

ធម្មកម្មំ ន ខោ តំ ភន្តេ វិនយកម្មន្តិ ។ ធម្មកម្មំ
តំ ឧចាលិ វិនយកម្មំ យោ ខោ ឧចាលិ សមក្ខោ
សង្ឆោ សម្មុខាការណីយំ កម្មំ សម្មុខា កភោតិ
ឯវំ ខោ ឧចាលិ ធម្មកម្មំ ហោតិ វិនយកម្មំ ឯវញ្ចេ
បន សង្ឆោ អនតិសារេ ហោតិ យោ ខោ ឧចាលិ
សមក្ខោ សង្ឆោ បដិបុច្ឆាការណីយំ កម្មំ បដិបុច្ឆា
កភោតិ បដិញ្ញាយ ការណីយំ កម្មំ បដិញ្ញាយ ក-
ភោតិ សតិវិនយារហស្ស សតិវិនយំ ទេតិ អមូឡ្ហវិនយា-
រហស្ស អមូឡ្ហវិនយំ ទេតិ តស្ស ចាបិយសិកាកម្ម-
រហស្ស តស្ស ចាបិយសិកាកម្មំ ភោតិ តជ្ជនីយ-
កម្មារហស្ស តជ្ជនីយកម្មំ ភោតិ និយស្សកម្ម-
រហស្ស និយស្សកម្មំ ភោតិ បព្ជាជនីយកម្មារហស្ស
បព្ជាជនីយកម្មំ ភោតិ បដិសារណីយកម្មារហស្ស
បដិសារណីយកម្មំ ភោតិ ឧក្ខេបនីយកម្មារហស្ស
ឧក្ខេបនីយកម្មំ ភោតិ បរិវាសារហស្ស បរិវាសំ
ទេតិ មូលាយ បដិកស្សនារហំ មូលាយ បដិកស្សតិ

បពិត្រព្រះអង្គដ៏ចម្រើន កម្មរបស់សង្ឆនោះ ជាធម្មកម្ម ជាវិនយកម្ម ដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះ ជាធម្មកម្ម ជាវិនយកម្ម ម្នាលឧបាលិ កម្មដែលសង្ឆត្រូវធ្វើក្នុងទីចំពោះមុខ សង្ឆណា មួយព្រមព្រៀងគ្នាធ្វើក្នុងទីចំពោះមុខ ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាធម្មកម្ម ជាវិនយកម្ម ឯសង្ឆសោតក៏ឈ្មោះថា ជាសង្ឆមិន ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ម្នាលឧបាលិ កម្មដែល ត្រូវធ្វើដោយការសាកសួរ សង្ឆណាមួយព្រមព្រៀងគ្នាធ្វើ ដោយការ សាកសួរ កម្មដែលត្រូវធ្វើដោយសេចក្តីប្តេជ្ញា សង្ឆធ្វើដោយសេចក្តី ប្តេជ្ញា ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអមូឡ្ហវិន័យដល់ ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរ ដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយ-កម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែល គួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយ-កម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈ

មានត្តារហាសួ មានត្តំ ឧេតិ អញ្ញាណារហាំ អញ្ញេតិ ឧបសម្ជារហាំ ឧបសម្ជាឧេតិ ឯវំ ខោ ឧចាលិ ឆម្មកម្មំ ហោតិ ទិនយកម្មំ ។ ឯវញ្ហ បន សង្ឆោ អនតិសារោ ហោតីតិ ។

[១០៧] យោ ឧ ខោ ភន្តេ សមក្ខោ សង្ឆោ សតិវិនយារហាសួ អមូឍ្ហវិនយំ ឧេតិ អមូឍ្ហវិនយារហាសួ សតិវិនយំ ឧេតិ ឆម្មកម្មំ ឧ ខោ តំ ភន្តេ ទិនយកម្មន្តិ ។ អឆម្មកម្មំ តំ ឧចាលិ អទិនយកម្មន្តិ ។ យោ ឧ ខោ ភន្តេ សមក្ខោ សង្ឆោ អមូឍ្ហវិនយារហាសួ តស្ស ចាបិយសិកាកម្មំ ឧកោតិ តស្ស ចាបិយសិកាកម្មារហាសួ អមូឍ្ហវិនយំ ឧេតិ តស្ស ចាបិយសិកាកម្មារហាសួ ឧជ្ជនីយកម្មំ ឧកោតិ ឧជ្ជនីយកម្មារហាសួ តស្ស ចាបិយសិកាកម្មំ ឧកោតិ ឧជ្ជនីយកម្មារហាសួ ឧិយស្ជកម្មំ ឧកោតិ ឧិយស្ជកម្មារហាសួ ឧជ្ជនីយកម្មំ ឧកោតិ ឧិយស្ជកម្មារហាសួ បញ្ចាជនីយកម្មំ ឧកោតិ បញ្ចាជនីយកម្មារហាសួ ឧិយស្ជកម្មំ ឧកោតិ

ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្តដល់ភិក្ខុ ដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទាដល់កុលបុត្តដែលគួរដល់ឧបសម្បទា ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាធម្មកម្ម ជាវិនយកម្ម ។ ឯសង្ឆសោតក៏ហៅថា ជាសង្ឆមិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។

[១០៧] ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន សង្ឆណាមួយព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យដល់ភិក្ខុ ដែលគួរដល់សតិវិ-ន័យ ឲ្យសតិវិន័យដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ បពិត្រព្រះអង្គដ៏ចម្រើន កម្មនោះ ជាធម្មកម្ម ជាវិន័យកម្មដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះ ជាអធម្មកម្ម ជាអវិនយកម្ម ។ ព្រះបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន សង្ឆណាមួយព្រមព្រៀងគ្នាធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើតជ្ជ-នីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្ជាជនីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់បព្ជាជនីយកម្ម

បញ្ចាជនីយកម្មារហស្ស បដិសារណីយកម្មំ ឥកោតិ ប-
ដិសារណីយកម្មារហស្ស បញ្ចាជនីយកម្មំ ឥកោតិ បដិ-
សារណីយកម្មារហស្ស ឧក្ខេបនីយកម្មំ ឥកោតិ ឧក្ខេ-
បនីយកម្មារហស្ស បដិសារណីយកម្មំ ឥកោតិ ឧក្ខេប-
នីយកម្មារហស្ស បរិវាសំ ទេតិ បរិវាសារហស្ស ឧក្ខេ-
បនីយកម្មំ ឥកោតិ បរិវាសារហំ មូលាយ បដិកស្សតិ
មូលាយ បដិកស្សនារហស្ស បរិវាសំ ទេតិ មូលាយ
បដិកស្សនារហស្ស មានត្តំ ទេតិ មានត្តារហំ មូលាយ
បដិកស្សតិ មានត្តារហំ អព្ភេតិ អព្ភានារហស្ស មានត្តំ
ទេតិ អព្ភានារហំ ឧបសម្ផាទេតិ ឧបសម្ផនារហំ អព្ភេតិ
ឆម្មកម្មំ ឧ ខោ តំ ភន្តេ វិនយកម្មន្តិ ។ អឆម្មកម្មំ
តំ ឧចាលិ អវិនយកម្មំ ។ យោ ខោ ឧចាលិ សមក្ខោ
សង្ឆោ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ អមូឡ្ហ-
វិនយារហស្ស សតិវិនយំ ទេតិ ឯវំ ខោ ឧចាលិ អឆម្ម-
កម្មំ ហោតិ អវិនយកម្មំ ឯវញ្ចេ បន សង្ឆោ សាតិ-
សាវេ ហោតិ ។ យោ ខោ ឧចាលិ សមក្ខោ
សង្ឆោ អមូឡ្ហវិនយារហស្ស ឥស្ស ចាបិយសិកាកម្មំ

ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បញ្ជាជនីយកម្ម ធ្វើបញ្ជាជនីយ-
កម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីកម្មដល់ភិក្ខុ
ដែលគួរដល់បដិសារណីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរ
ដល់ឧក្ខេបនីយកម្ម ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ធ្វើ
ឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈដល់
ភិក្ខុដែលគួរដល់បរិវាស ឲ្យបរិវាសដល់ភិក្ខុ ដែលគួរដល់មូលាយបដិ-
កស្សនៈ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមូលាយ-
បដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់
មានត្ត ឲ្យមានត្តដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទាដល់ភិក្ខុដែល
គួរដល់អព្ភាន ឲ្យអព្ភានដល់ភិក្ខុដែលគួរដល់ឧបសម្បទា បពិត្រ
ព្រះអង្គដ៏ចម្រើន កម្មនោះ ជាធម្មកម្ម ជាវិនយកម្មដែរឬ ។ ព្រះអង្គទ្រង់
ត្រាស់ថា ម្នាលឧបាលិ កម្មនោះមិនមែនជាធម្មកម្ម ជាវិនយកម្មទេ ។
ម្នាលឧបាលិ សង្ឆណាមួយព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យដល់ភិក្ខុ
ដែលគួរដល់សតិវិន័យ ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ
ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាអធម្មកម្ម ជាអវិនយ-
កម្ម ឯសង្ឆសោតក៏ជាសង្ឆប្រកបដោយទោស ដោយប្រការដូច្នេះ ។
ម្នាលឧបាលិ សង្ឆណាមួយព្រមព្រៀងគ្នា ធ្វើតស្សបាបិយសិកាកម្ម

កភេតិ តស្ស ចាបិយសិកាកម្មារហស្ស អមូឧ្ជ្ជាវិនយំ ឧេតិ តស្ស ចាបិយសិកាកម្មារហស្ស តជ្ជនីយកម្មំ កភេតិ តជ្ជនីយកម្មារហស្ស តស្ស ចាបិយសិកាកម្មំ កភេតិ តជ្ជនីយកម្មារហស្ស និយស្សកម្មំ កភេតិ និយស្សកម្មារហស្ស តជ្ជនីយកម្មំ កភេតិ និយស្ស-កម្មារហស្ស បព្ជាជនីយកម្មំ កភេតិ បព្ជាជនីយ-កម្មារហស្ស និយស្សកម្មំ កភេតិ បព្ជាជនីយកម្ម-រហស្ស បដិសារណីយកម្មំ កភេតិ បដិសារណីយ-កម្មារហស្ស បព្ជាជនីយកម្មំ កភេតិ បដិសារណីយ-កម្មារហស្ស ឧក្ខេបនីយកម្មំ កភេតិ ឧក្ខេបនីយ-កម្មារហស្ស បដិសារណីយកម្មំ កភេតិ ឧក្ខេបនី-យកម្មារហស្ស បរិវាសំ ឧេតិ បរិវាសារហស្ស ឧក្ខ-បនីយកម្មំ កភេតិ បរិវាសារហំ មូលាយ បដិកស្សតិ មូលាយ បដិកស្សនារហស្ស បរិវាសំ ឧេតិ មូលាយ បដិកស្សនារហស្ស មានត្តំ ឧេតិ មានត្តារហំ មូលាយ បដិកស្សតិ មានត្តារហំ អព្ភេតិ អព្ភានារហស្ស មានត្តំ ឧេតិ អព្ភានារហំ ឧបសម្ជាឧេតិ ឧបសម្ជនារហំ អព្ភេតិ

ដល់ភិក្ខុ ដែលគួរដល់អមូឡ្ហវិន័យ ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយ-សិកាកម្ម ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុ ដែលគួរដល់និយស្សកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយ-កម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សន: ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សន: ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សន: ឲ្យមូលាយបដិកស្សន: ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្ប្ទា ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យអព្ភានដល់ភិក្ខុដែលគួរ

ឯវํ ខោ ឧចាលិ អធម្មកម្មํ ហោតិ អវិនយកម្មํ ។ ឯវញ្ហេ បន សង្ឆោ សាតិសាហេ ហោតីតិ ។

[១០៨] យោ ឧ ខោ ភិក្ខេ សមក្ខោ សង្ឆោ សតិវិនយារហស្ស សតិវិនយํ ទេតិ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយํ ទេតិ ធម្មកម្មํ ឧ ខោ តํ ភិក្ខេ វិនយ-កម្មន្តិ ។ ធម្មកម្មํ តํ ឧចាលិ វិនយកម្មន្តិ ។ យោ ឧ ខោ ភិក្ខេ សមក្ខោ សង្ឆោ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយํ ទេតិ តស្ស ចាបិយសិកាកម្មារហស្ស តស្ស ចាបិយសិកាកម្មํ ករោតិ តជ្ជនីយកម្មារហស្ស តជ្ជនីយកម្មํ ករោតិ និយស្សកម្មារហស្ស និយស្ស-កម្មํ ករោតិ បព្ជាជនីយកម្មារហស្ស បព្ជាជនីយកម្មํ ករោតិ បដិសារណីយកម្មារហស្ស បដិសារណីយ-កម្មํ ករោតិ ឧក្ខេបនីយកម្មារហស្ស ឧក្ខេបនីយកម្មํ ករោតិ បរិវាសារហស្ស បរិវាសํ ទេតិ មូលាយ បដិ-កស្សនារហํ មូលាយ បដិកស្សតិ មានត្តារហស្ស មានត្តํ ទេតិ អព្ភានារហํ អព្ភេតិ ឧបសម្ជនារហํ ឧបសម្ជាទេតិ ធម្មកម្មํ ឧ ខោ តํ ភិក្ខេ វិនយកម្មន្តិ ។

ដល់ឧបសម្បទា ម្នាលឧបាលិ កម្មយ៉ាងនេះឯង ជាអធម្មកម្ម ជាអវិនយ-
កម្ម ។ ឯសង្ឆសោត ក៏ជាសង្ឆប្រកបដោយទោសដោយប្រការដូច្នេះ ។

[១០៨] ព្រះបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន
សង្ឆណាមួយព្រមព្រៀងគ្នា ឲ្យសតិវិនយ ដល់ភិក្ខុ ដែលគួរដល់សតិវិន័យ
ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ បពិត្រព្រះអង្គដ៏ចម្រើន កម្ម
នោះ ជាធម្មកម្ម ជាវិនយកម្មដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ
កម្មនោះ ជាធម្មកម្ម ជាវិន័យកម្មហើយ ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា
បពិត្រព្រះអង្គដ៏ចម្រើន សង្ឆណាមួយព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យ
ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុដែលគួរដល់
តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម
ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុ
ដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីកម្ម ដល់ភិក្ខុដែលគួរដល់
បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម
ឲ្យបរិវាសដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈដល់ភិក្ខុដែល
គួរដល់មូលាយបដិកស្សនៈ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភាន
ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទាដល់កុលបុត្តដែលគួរដល់ឧប-
សម្បទា បពិត្រព្រះអង្គដ៏ចម្រើន កម្មនោះ ជាធម្មកម្មជាវិនយកម្មដែរឬ ។

ធម្មកម្មំ តំ ឧចាលិ វិនយកម្មំ ។ យោ ខោ ឧចាលិ សមត្តោ សង្ឆោ សតិវិនយារហស្ស សតិវិនយំ ទេតិ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយំ ទេតិ ឯវំ ខោ ឧចាលិ ធម្មកម្មំ ហោតិ វិនយកម្មំ ។ ឯវញ្ចេ បន សង្ឆោ អនតិសារេ ហោតិ ។ យោ ខោ ឧចាលិ សមត្តោ សង្ឆោ អមូឡ្ហវិនយារហស្ស អមូឡ្ហវិនយំ ទេតិ តស្ស ចាបិយសិកាកម្មារហស្ស តស្ស ចាបិយសិកាកម្មំ ករោតិ តជ្ជនីយកម្មារហស្ស តជ្ជនីយកម្មំ ករោតិ និយស្សកម្មារហស្ស និយស្សកម្មំ ករោតិ បព្ជាជនីយកម្មារហស្ស បព្ជាជនីយកម្មំ ករោតិ បដិសារណីយកម្មារហស្ស បដិសារណីយកម្មំ ករោតិ ឧក្ខេបនីយកម្មារហស្ស ឧក្ខេបនីយកម្មំ ករោតិ បរិវាសារហស្ស បរិវាសំ ទេតិ មូលាយ បដិកស្សនារហំ មូលាយ បដិកស្សតិ មានត្តារហស្ស មានត្តំ ទេតិ អព្ភានារហំ អព្ភេតិ ឧបសម្ជនារហំ ឧបសម្ជាទេតិ ឯវំ ខោ ឧចាលិ ធម្មកម្មំ ហោតិ វិនយកម្មំ ។ ឯវញ្ចេ បន សង្ឆោ អនតិសារេ ហោតីតិ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះជាធម្មកម្ម ជាវិនយកម្ម ហើយ ។ ម្នាលឧបាលិ សង្ឆណាមួយ ព្រមព្រៀងគ្នាឲ្យសតិវិន័យដល់ភិក្ខុ ដែលគួរដល់សតិវិន័យ ឲ្យអមូឬ្ហវិន័យ ដល់ភិក្ខុដែលគួរដល់អមូឬ្ហវិន័យ ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាធម្មកម្ម ជាវិនយកម្ម ។ ឯសង្ឆ សោតក៏ជាសង្ឆមិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាល ឧបាលិ សង្ឆណាមួយ ព្រមព្រៀងគ្នា ឲ្យអមូឬ្ហវិន័យ ដល់ភិក្ខុដែលគួរដល់ អមូឬ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយ-សិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់ បព្វាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយ-កម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាសដល់ ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សន: ដល់ភិក្ខុដែលគួរដល់មូលា-យបដិកស្សន: ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភានដល់ភិក្ខុដែល គួរដល់អព្ភាន ឲ្យឧបសម្ប្ទា ដល់កុលបុត្តដែលគួរដល់ឧបសម្ប្ទា ម្នាល ឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាធម្មកម្ម ជាវិនយកម្ម ។ ឯសង្ឆ សោតក៏ជាសង្ឆមិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។

[១០៩] អថខោ ភគវា ភិក្ខូ អាមន្តេសិ យោ ខោ ភិក្ខវេ សមត្តោ សជ្ជោ សតិវិនយារហស្ស អមូឡ្ហវិនយំ ទេតិ ឯវំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សជ្ជោ សាតិសាវោ ហោតិ ។ យោ ខោ ភិក្ខវេ សមត្តោ សជ្ជោ សតិវិនយារហស្ស តស្ស ចាបិយសិកាកម្មំ ករោតិ សតិវិនយារហស្ស តជ្ជនីយកម្មំ ករោតិ សតិវិនយារ-ហស្ស និយស្សកម្មំ ករោតិ សតិវិនយារហស្ស បព្ជាជនីយកម្មំ ករោតិ សតិវិនយារហស្ស បដិសា-រណីយកម្មំ ករោតិ សតិវិនយារហស្ស ឧក្ខេបនី-យកម្មំ ករោតិ សតិវិនយារហស្ស បរិវាសំ ទេតិ សតិវិនយារហំ មូលាយ បដិកស្សតិ សតិវិនយារ-ហស្ស មានត្តំ ទេតិ សតិវិនយារហំ អព្ភេតិ សតិវិន-យារហំ ឧបសម្ជាទេតិ ឯវំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សជ្ជោ សាតិសាវោ ហោតិ ។ យោ ខោ ភិក្ខវេ សមត្តោ សជ្ជោ អមូឡ្ហវិនយារហស្ស តស្ស ចាបិយសិកាកម្មំ ករោតិ

[១០៩] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ហៅភិក្ខុទាំងឡាយ មកថា ម្នាលភិក្ខុទាំងឡាយ សង្ឆណាមួយ ព្រមព្រៀងគ្នាឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់សតិវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឆសោតក៏ជាសង្ឆប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឆណាមួយ ព្រមព្រៀងគ្នា ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើតជ្ជ-នីយកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យឧបសម្ប-ទា ដល់ភិក្ខុដែលគួរដល់សតិវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះ ឯង ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឆសោតក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឆឯណាមួយ ព្រមព្រៀងគ្នា ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ

ឯវំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឆោ សាតិសារោ ហោតិ ។ យោ ខោ ភិក្ខវេ សមក្ខោ សង្ឆោ អមូឡ្ហវិនយារហស្ស ឆន្ទនីយកម្មំ ករោតិ អមូឡ្ហវិនយារហស្ស និយ្យសកម្មំ ករោតិ អមូឡ្ហវិនយារហស្ស បញ្ចាជនីយកម្មំ ករោតិ អមូឡ្ហវិន-យារហស្ស បដិសារណីយកម្មំ ករោតិ អមូឡ្ហវិនយារ-ហស្ស ឧក្ខេបនីយកម្មំ ករោតិ អមូឡ្ហវិនយារហស្ស បរិវាសំ ទេតិ អមូឡ្ហវិនយារហំ មូលាយ បដិកស្សតិ អមូឡ្ហវិនយារហស្ស មានត្តំ ទេតិ អមូឡ្ហវិនយារហំ អព្ភេតិ អមូឡ្ហវិនយារហំ ឧបសម្ផាទេតិ អមូឡ្ហវិនយា-រហស្ស សតិវិនយំ ទេតិ ឯវំ ខោ ភិក្ខវេ អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឆោ សាតិសារោ ហោតិ ។ យោ ខោ ភិក្ខវេ សមក្ខោ សង្ឆោ តស្ស ចា-បិយសិកាកម្មារហស្ស ឆន្ទនីយកម្មំ ករោតិ តស្ស ចា-បិយសិកាកម្មារហស្ស និយ្យសកម្មំ ករោតិ តស្ស ចា-បិយសិកាកម្មារហស្ស បញ្ចាជនីយកម្មំ ករោតិ តស្ស ចាបិយសិកាកម្មារហស្ស បដិសារណីយកម្មំ ករោតិ

ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឆ សោតក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំង-ឡាយ សង្ឆណាមួយ ព្រមព្រៀងគ្នាធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើបព្វាជ-នីយកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើបដិសារណីយកម្មដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហ-វិន័យ ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យមូលាយបដិកស្សន: ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យមានត្តដល់ភិក្ខុ ដែលគួរដល់អមូឡ្ហ-វិន័យ ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យឧបសម្បទាដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឆ សោតក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំង-ឡាយ សង្ឆណាមួយ ព្រមព្រៀងគ្នា ធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើនិយស្សកម្មដល់ភិក្ខុ ដែលគួរដល់តស្សបា-បិយសិកាកម្ម ធ្វើបព្វាជនីយកម្មដល់ភិក្ខុ ដែលគួរដល់តស្សបាបិយសិកា-កម្ម ធ្វើបដិសារណីយកម្មដល់ភិក្ខុ ដែលគួរដល់តស្សបាបិយសិកាកម្ម

តស្ស ចាបិយសិ្ការ្ការ្ម្ការ្ហ ឧ្ការ្ម្ការ្ហ ឧ្ការ្ម្ការ្ហ
ការ្ហ ។ ។ ។

ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុ ដែលគួរដល់តស្សបាបិយសិកាកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ។ បេ ។ ឲ្យសតិវិន័យដល់ភិក្ខុ ដែលគួរដល់តស្សបាបិយសិកាកម្ម ឲ្យអមូឡ្ហវិន័យដល់ភិក្ខុ ដែលគួរដល់ តស្សបាបិយសិកាកម្ម ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឆសោតក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឆណាមួយព្រមព្រៀងគ្នា ឲ្យសតិវិន័យដល់ភិក្ខុ ដែលគួរដល់តជ្ជនីយកម្ម ។ បេ ។ ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ដល់ភិក្ខុ ដែលគួរដល់បព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ដល់ ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បរិវាស ដល់ភិក្ខុដែល គួរដល់មូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មានត្ត ដល់ភិក្ខុដែលគួរ ដល់អព្ភាន ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ឲ្យអមូឡ្ហវិន័យដល់កុល-បុត្តដែលគួរដល់ឧបសម្បទា ធ្វើតស្សបាបិយសិកាកម្ម ដល់កុលបុត្តដែលគួរ ដល់ឧបសម្បទា ធ្វើតជ្ជនីយកម្ម ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ធ្វើ និយស្សកម្ម ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ធ្វើបព្វាជនីយកម្មដល់ កុលបុត្តដែលគួរដល់ឧបសម្បទា ធ្វើបដិសារណីយកម្ម ដល់កុលបុត្តដែល គួរដល់ឧបសម្បទា ធ្វើឧក្ខេបនីយកម្ម ដល់កុលបុត្តដែលគួរដល់ឧបសម្បទា

ចម្បេយ្យក្ខន្ធកេ តជ្ជនីយកម្មាធម្មវគ្គាទយោ

ឧបសម្ផជ្ជារហស្ស បរិវាសំ ឧតិ ឧបសម្ផជ្ជារហំ
មូលាយ បដិកស្សតិ ឧបសម្ផជ្ជារហស្ស មានត្តំ
ឧតិ ឧបសម្ផជ្ជារហំ អព្ភេតិ ឯវំ ខោ ភិក្ខវេ
អធម្មកម្មំ ហោតិ អវិនយកម្មំ ឯវញ្ច បន សង្ឆោ
សាតិសារោ ហោតីតិ ។

ឧបាលិបុច្ឆាភាណវារំ ទុតិយំ ។

[១១០] ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ
ហោតិ កលហការកោ វិវាទការកោ ភស្សការកោ
សង្ឆេ អធិការណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ
អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហកា-
រកោ វិវាទការកោ ភស្សការកោ សង្ឆេ អធិការណ-
ការកោ ហន្ទ ១ មយំ តជ្ជនីយកម្មំ ករោមាតិ ។
ឧ តស្ស តជ្ជនីយកម្មំ ករោន្តិ អធម្មេន វក្ត ។
ឧ តម្ហា អាវាសា អញ្ញេ ១ អាវាសំ ១ ១ ១

ឲ្យបរិវាស ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ឲ្យមូលាយបដិកស្សនៈ ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ឲ្យមានត្ត ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ឲ្យអព្ភាន ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឆសោតក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ ។

ចប់ ឧបាលិបុច្ឆាភាណវារ: ទី ២ ។

[១១០] ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុជាអ្នកធ្វើនូវការបង្ក្រហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ (ទាស់ទែងគ្នា) ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្ក្រហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ បើដូច្នោះ មានតែយើងរាល់គ្នាធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះ ជាពួកមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ ។ ឯភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃទៀត ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ ក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឆ

តជ្ជនីយកម្មកតោ អជ្ឌម្នេ ១ តេ ១ ហន្ទ ១ ១ ១

បានធ្វើតជ្ជនីយកម្មហើយដោយភិក្ខុទាំងឡាយ ដែលជាពួកមិនប្រកបដោយ ធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុ ទាំងឡាយនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ក៏ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះ ចេញពីអាវាសនោះ ទៅកាន់អាវាស ដទៃ ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុ-សោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុ ទាំងឡាយដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះ មានតែ យើងរាល់គ្នាធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះជាពួក តែ ប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាស នោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះគិតគ្នា យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឆបានធ្វើតជ្ជ-នីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួក តែប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះ ជាពួកទាំងប្រកបដោយធម៌ឬម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃទៀត ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាស នោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឆ បានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួក ទាំងប្រកបដោយធម៌

ហន្ទ្ធ ស្ស មយំ តជ្ជនីយកម្មំ ការេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ការេន្តិ ធម្មេ ្ជ ្ជ ្ជ

ឫម បើដូច្នោះ មានតែយើងរាល់គ្នាធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំង-ឡាយនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ឫម ក៏ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ (ទៀត) ។

[១១១] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្ក្រហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងជាអ្នកធ្វើនូវការបង្ក្រហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ ក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជ-នីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាស

អញ្ញេ បិ អាវាសំ តច្ឆតិ ។ តត្ថ បិ ភិក្ខូ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆេន តជ្ជនីយកម្មកតោ ឆន្ទេន វត្តេហិ ហន្ទ ស្ស មយំ តជ្ជនីយកម្មំ ការេមា-តិ ។ តេ តស្ស តជ្ជនីយកម្មំ ការេន្តិ ធម្មេ ជ្ជ ិ ្ យ ូ ប ្ ត ្ (។ សោ តម្ហា អាវាសា អញ្ញេ បិ អាវាសំ តច្ឆតិ ។ តត្ថ បិ ភិក្ខូ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆេន តជ្ជនីយកម្មកតោ ធម្ម ្ ជ ្ (្ (((

ដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ ក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆាបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលជាពួក តែប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះ ជាពួកទាំងប្រកបដោយធម៌ឫម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆាបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួកទាំងប្រកបដោយធម៌ឫម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែប្រកបដោយធម៌ឫម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆាបានធ្វើតជ្ជ-នីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែប្រកបដោយធម៌ឫម បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះ ជាពួកទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ (ទៀត) ។

ចម្បេយ្យក្ខន្ធកេ តជ្ជនីយកម្មធម្មវគ្គាទយោ

[១១២] ឥធ បន ភិក្ខវេ ភិក្ខុ ភណ្ឌនការកោ ហោតិ កលហការកោ វិវាទការកោ ភស្សការកោ សង្ឆេ អធិការណការកោ ។ តត្រ ចេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការកោ កលហការកោ វិវាទការកោ ភស្សការកោ សង្ឆេ អធិការណការកោ ហន្ទ្ធ មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោន្តិ ធម្មេន វត្តា ។ សោ តម្ហា អាវាសា អញ្ញេ អាវាសំ គច្ឆតិ ។ តត្ថ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆេ តជ្ជនីយកម្មការតោ ធម្មេន វត្តេហិ ហន្ទ្ធ មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ករោតិ ធម្មប្បដិរូបកេន វត្តា ។ សោ តម្ហា អាវាសា អញ្ញេ អាវាសំ គច្ឆតិ ។ តត្ថ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆេ តជ្ជនីយកម្មការតោ ធម្មប្បដិរូបកេន វត្តេហិ ហន្ទ្ធ មយំ តជ្ជនីយកម្មំ

ចម្បេយ្យក្ខន្ធក: ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មប្រកបដោយធម៌ជាដើម

[១១២] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួក តែប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះ ជាពួកទាំងប្រកបដោយធម៌ឫម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួកទាំងប្រកបដោយធម៌ឫម បើដូច្នោះ មានតែយើងទាំងឡាយ

ការោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ការេន្តិ ធម្ម-ប្បដិរូបកេន សមត្តា ។ សោ តម្ហា អាវាសា អញ្ញំ បិ អាវាសំ គច្ឆតិ ។ តត្ថ បិ ភិក្ខូ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆេន តជ្ជនីយកម្មការោ ធម្ម-ប្បដិរូបកេន សមត្តេហិ ហន្ទ្ធ ម យំ តជ្ជនីយកម្មំ ការោមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ការេន្តិ អធម្មេន វត្តា ។ សោ តម្ហា អាវាសា អញ្ញំ បិ អាវាសំ គច្ឆតិ ។ តត្ថ បិ ភិក្ខូ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆេន តជ្ជនីយកម្មការោ អធម្មេន វត្តេហិ ហន្ទ្ធ ម យំ តជ្ជនីយកម្មំ ការោមាតិ ។ តេ តស្ស តជ្ជនីយ-កម្មំ ការេន្តិ អធម្មេន សមត្តា ។

[១១៣] ឥធ ឧបាលិ ភិក្ខវេ ភិក្ខុ ភណ្ឌនការោ ហោតិ កលហការោ វិវាទការោ ភស្ស្ការោ សង្ឆេ អធិការណការោ ។ តត្រ ចេ ភិក្ខូ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ ភណ្ឌនការោ

ធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែប្រកបដោយ ធម៌ឫម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាស នោះ ទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាង នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆបានធ្វើតជ្ជនី-យកម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែប្រកបដោយ ធម៌ឫម បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះ ជាពួកទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ ។ ឯភិក្ខុ ទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ជាពួកទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជ-នីយកម្ម ដល់ភិក្ខុនេះ (ទៀត) ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកប ដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ(ទៀត) ។

[១១៣] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងវិញទៀត ភិក្ខុក្នុងសាសនា នេះ ជាអ្នកធ្វើនូវការបង្ក្គហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នក ធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ ។ ក្នុងរឿងនោះ បើភិក្ខុ ទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងជាអ្នក

ចម្បេយ្យក្ខន្ធកេ តជ្ជនីយកម្មធម្មប្បដិរូបការគ្គាទយោ

កលហការកោ ភិណ្ឌការកោ ភស្ឃការកោ សង្ឆៃ អធិការណការកោ ហន្ទ្ធ មយំ តជ្ជនីយកម្មំ ការេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ការេន្តិ ធម្មប្បដិរូបកេន វត្តា ។ សោ តម្ហា អាវាសា អញ្ញេ អាវាសំ គច្ឆតិ ។ តត្ថ ភិក្ខូ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆៃ តជ្ជនីយកម្មការោ ធម្មប្បដិរូបកេន វត្តេហិ ហន្ទ្ធ មយំ តជ្ជនីយកម្មំ ការេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ការេន្តិ ធម្ម-ប្បដិរូបកេន សមត្តា ។ សោ តម្ហា អាវាសា អញ្ញេ អាវាសំ គច្ឆតិ ។ តត្ថ ភិក្ខូ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆៃ តជ្ជនីយកម្មការោ ធម្ម-ប្បដិរូបកេន សមត្តេហិ ហន្ទ្ធ មយំ តជ្ជនីយកម្មំ ការេមាតិ ។ តេ តស្ស តជ្ជនីយកម្មំ ការេន្តិ អធម្មេន វត្តា ។ សោ តម្ហា អាវាសា អញ្ញេ អាវាសំ គច្ឆតិ ។ តត្ថ ភិក្ខូ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ

ធ្វើនូវការបង្ក្រហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងឡាយនោះ ជាពួកទាំងប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆបានធ្វើតជ្ជនីយកម្ម ដោយភិក្ខុទាំងឡាយជាពួកទាំងប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនី-យកម្មដល់ភិក្ខុនេះ (ទៀត) ។ ភិក្ខុទាំងនោះជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឆបានធ្វើ

សជ្ជេន តជ្ជនីយកម្មកតោ អនុម្មេន វត្តេហិ ហន្ទ្ធ ១ មយំ តជ្ជនីយកម្មំ ករោមាតិ ។ តេ ១ តស្ស ១ តជ្ជនី-
យកម្មំ ករន្តិ អនុម្មេន ១ សមត្តា ។ ១ សោ ១ តម្ហា
អាវាសា អញ្ញេ ១ អាវាសំ ១ គច្ឆតិ ។ ១ ១ ១

តជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ (ទៀត) ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្ក្រហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្ក្រហេតុ ជាអ្នកធ្វើនូវជម្លោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឆ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ ឬម ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅ

អញ្ញិបិ អាវាសំ តច្ឆតិ ។ តត្ថបិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សង្ឆេន តជ្ជនីយកម្មកតោ ធម្មិកប្បដិរូបកេន សមក្ខេហិ ហន្ទ ១ មយំ តជ្ជនីយ-កម្មំ ការេមាតិ ។ តេ ១ តស្ស ១ តជ្ជនីយកម្មំ ការេន្តិ អធម្មេន ១ ១ ។ សោ ១ ១ ១

កាន់អាវាសដទៃទៀត ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះ ថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឆបានធ្វើតជ្ជនីយ-កម្មហើយ ដោយភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា តែប្រកបដោយ ធម៌ឫម បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុ នោះ (ទៀត) ។ ភិក្ខុនោះក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនេះឯង ដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុ ទាំងឡាយជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំង-ឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះព្រមព្រៀងគ្នា តែមិន ប្រកបដោយធម៌ ធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ ភិក្ខុនោះក៏ ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយក្នុងអាវាស នោះគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែល សង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះទៅកាន់អាវាសដទៃ ។

តត្ថបិ ភិក្ខូនំ ឝ្ចរ ហោតិ អយំ ខោ អាវុសោ ភិក្ខុ
ឝ្ចជ្ជេន ឝ្ចជ្ជនីយកម្មកតោ ឧម្មេន ឝ្ចត្តេហិ ហន្ទ្ធ ឝ្ច
មយំ ឝ្ចជ្ជនីយកម្មំ ការោមាតិ ។ តេ ឝ្ច ឝ្ចជ្ជនីយ-
កម្មំ ការេន្តិ ឧម្មប្ជដ្ជិ្ជ្ជ ការេន ឝ្ចត្តា ។

[១១៥] ឝ្ចឧ ឝ្ចន ភិក្ខ្ជ ភិក្ខ្ជ ពាលោ ហោតិ
អ្ជ្ជ្ជ្ជ អ្ជ្ជ្ជ ពហ្ជ្ជ្ជ អ្ជ្ជ្ជ ឝ្ចជ្ជ ឝ្ចជ្ជ ឝ្ចជ្ជ
ឝ្ចជ្ជ ឝ្ចជ្ជ ឝ្ចជ្ជ ។ ឝ្ច

ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនេះឯងដែលសង្ឆបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំង-ឡាយជាពួក តែប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយធ្វើតជ្ជនីយកម្មដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក ទាំងប្រកបដោយធម៌ឫមធ្វើតជ្ជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។

[១១៥] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ លូង់ មិនធ្ងាស មានអាបត្តិច្រើន មិនមានកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំ មិនសមគួរ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះ ឯង លូង់ មិនធ្ងាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំ មិនសមគួរ បើដូច្នោះ មានតែយើងទាំងឡាយធ្វើនិយស្សកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងអម្បាលនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើនិយស្សកម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯងដែលសង្ឆបានធ្វើនិយស្សកម្មហើយ ដោយភិក្ខុទាំងឡាយជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះមានតែយើងទាំងឡាយធ្វើនិយស្សកម្មដល់ភិក្ខុនេះ (ទៀត) ។

តេ តស្ស ជិយស្សកម្មំ ការេន្តិ អជម្ហេ សមត្ថា ។ បេ ។ ជម្ហេ វត្តា ។ ជម្ម្ប្ជិ្ជ្ជ្ជ

ភិក្ខុទាំងអម្បាលនោះព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើនិយស្ស-
កម្មដល់ភិក្ខុនោះ ។ បេ ។ ជាពួក តែមិនប្រកបដោយធម៌ ។ ជាពួក ទាំង
ប្រកបដោយធម៌ឫម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ឫម ។ បណ្ឌិត
គប្បីធ្វើចក្ក[1] ឲ្យដូចសេចក្តីដែលបានពោលមកហើយឲ្ងដ៏ខាងក្រោយ ។

[១១៦] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុជាអ្នកទ្រុស្ត
ត្រកូល មានមារយាទអាក្រក់ ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយគិតគ្នា
យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកទ្រុស្តត្រកូល
មានមារយាទអាក្រក់ បើដូច្នោះ មានតែយើងទាំងឡាយធ្វើបព្វាជនីយកម្ម
ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើបព្វាជនីយ-
កម្មដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ ។ ឯ
ភិក្ខុទាំងឡាយក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ
ភិក្ខុនេះឯង ដែលសង្ឆបានធ្វើបព្វាជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ
ដែលជាពួកទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ

---

១ រឿងដែលត្រូវសំដែងវិលទៅរកសេចក្តីដើមវិញ ហៅថា ចក្ក គឺត្រូវបន្ថែមសេចក្តីខាងដើម
និងខាងចុងដូចរឿងរ៉ាវដែលនិយាយមកហើយ ។

បញ្ចាជនីយកម្មំ ករោមាតិ ។ តេ តស្ស បញ្ចាជនីយ-
កម្មំ ករោន្តិ អជ្ជេន សមត្តា ។ បេ ។ ជម្មេន វត្តា ។
ធម្មប្បដិរូបកេន វត្តា ។ ធម្មប្បដិរូបកេន សមត្តា ។
ចត្តុ ការតុ ។

[១១៧] ឥធ បន ភិក្ខវេ ភិក្ខុ ឥហ អត្ថោ សតិ
បរិកាសតិ ។ ត្រ ចេ ភិក្ខុនំ ឯវ ហោតិ អយំ ខោ
អាវុសោ ភិក្ខុ ឥហ អត្ថោ សតិ បរិកាសតិ ហន្ទ ស្ស
មយ បដិសារណីយកម្មំ ករោមាតិ ។ តេ តស្ស
បដិសារណីយកម្មំ ករោន្តិ អជ្ជេន វត្តា ។ បេ ។
អជ្ជេន សមត្តា ។ ជម្មេន វត្តា ។ ធម្មប្បដិរូបកេន
វត្តា ។ ធម្មប្បដិរូបកេន សមត្តា ។ ចត្តុ ការតុ ។

[១១៨] ឥធ បន ភិក្ខវេ ភិក្ខុ អាបត្តឺ អាបជ្ជិត្វា
ន ឥច្ឆតិ អាបត្តឺ បស្សិតុ ។ ត្រ ចេ ភិក្ខុនំ ឯវ
ហោតិ អយំ ខោ អាវុសោ ភិក្ខុ អាបត្តឺ អាបជ្ជិត្វា
ន ឥច្ឆតិ អាបត្តឺ បស្សិតុ ហន្ទ ស្ស មយ អាបត្តិយា

ធ្វើបញ្ជាជនីយកម្ម ដល់ភិក្ខុនេះ ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើបញ្ជាជនីយកម្មដល់ភិក្ខុនោះ (ទៀត) ។ បេ ។ ជាពួកតែប្រកបដោយធម៌ ។ ជាពួកទាំងប្រកបដោយធម៌ឬម ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ឬម ។ បណ្ឌិតគប្បីធ្វើចក្ក (បំពេញសេចក្ដីដូចខាងដើម) ។

ឯអាត្មាអញសោតក៏ជាស្តេចកំសត់មានទ្រព្យតិច មានសម្បត្តិតិច មានពលតិច មានពាហន:តិច មានដែនតិច មានឃ្លាំងនិងជង្រុកមិនបរិបូណ៌ អាត្មាអញ នឹងអាចដើម្បីតទល់នឹងស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្ត សូម្បីតែម្តងក៏មិនបាន បើដូច្នោះ គួរតែអាត្មាអញលបរត់ចេញទៅពីក្រុងជាមុនឲ្យហើយ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ ក៏នាំមហេសីលបរត់ចេញទៅពីក្រុងជាមុន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ដណ្តើមយកពួកពល ពាហន: ជនបទ ឃ្លាំង ជង្រុក របស់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ ហើយក៏គ្រប់គ្រងរក្សា ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចក្នុងដែលកោសលព្រះនាមទីឃីតិ ព្រមទាំងមហេសីយាងចេញទៅឯក្រុងពារាណសី ក៏បានទៅដល់ក្រុងពារាណសីដោយលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ បានឮមកថាស្តេចក្នុងដែនកោសលព្រះមានទីឃីតិ ព្រមទាំងមហេសីក្ងែងកេទរបស់ខ្លួនមិនឲ្យបុគ្គលដទៃស្គាល់បាន ទ្រង់ស្ងៀកដណ្តប់ជាបរិព្វាជកហើយក៏នៅអាស្រ័យក្នុងផ្ទះស្ងួនធ្នាំង ក្នុងឱកាសមួយជាទីបំផុតក្រុងពារាណសីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសីរបស់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិមិនយូរប៉ុន្មានក៏ទ្រង់គភ៌ ។ ឯព្រះមហេសីនោះក៏កើតមានចំណង់មានសភាពយ៉ាងនេះ

កោសម្ពិក្ខន្ធកេ ទីឃាវុកុមារវត្ថុ

ឥច្ឆតិ សុរិយស្ស ឧក្តមនការេ ចតុរង្ខិនី សេនំ សន្ធេ្ទ
រម្ម្ហិកំ សុភូមិយំ ឋិតំ បស្ស្ហិតុំ ខត្តានញ្ច ជោវនំ ចាតុំ ។
អថខោ ភិក្ខវេ ឌីឃីតិស្ស កោសលរញ្ញោ មហេសី
ឌីឃីតី កោសលរាជានំ ឯតទវោច ក្ពិនិម្ហិ ខេ តស្ស
មេ ឯវ្ហេ ជោហេ ឧប្ប្ជោ ឥច្ឆាមិ សុរិយស្ស
ឧក្តមនការេ ចតុរង្ខិនី សេនំ សន្ធេ្ទ រម្ម្ហិកំ សុភូមិយំ
ឋិតំ បស្ស្ហិតុំ ខត្តានញ្ច ជោវនំ ចាតុន្តិ ។ ក្ពុតោ ខេ
អម្ហាកំ ឧក្តតានំ ចតុរង្ខិនី សេនា សន្ធេ្ទ រម្ម្ហិកា
សុភូមិយំ ឋិតា ខត្តានញ្ច ជោវនន្តិ ។ សចាហំ ខេ
ន លភិស្ស្ហាមិ មរិស្ស្ហាមីតិ ។ ខេន ខោ បន ភិក្ខវេ
សមយេន ព្រហ្មទត្តស្ស ការីរញ្ញោ បុរោហិតោ
ព្រាហ្មណោ ឌីឃីតិស្ស កោសលរញ្ញោ សហាយោ
ហោតិ ។ អថខោ ភិក្ខវេ ឌីឃីតិ កោសលរាជា យេន

គឺព្រះនាងចង់ឃើញពួកសេនាប្រកបដោយអង្គ ៤ ស្ថិតស្ថាងគ្រឿងប្រដាប់ពាក់អាវក្រោះហើយឈរនៅក្នុងទីមានផែនដីរាបស្អាត ក្នុងវេលាដែលព្រះអាទិត្យរះឡើង ១ ចង់សោយទឹកដែលគេលាងព្រះខ័ន ១ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មហេសីរបស់ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិក៏បានក្រាបទូលស្តេចក្នុងដែនកោសលព្រះនាម ទីឃីតិយ៉ាងនេះ ថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មានគក់ហើយ ឯខ្ញុំម្ចាស់កើតមានចំណង់មានសភាពយ៉ាងនេះ គឺខ្ញុំម្ចាស់ចង់ឃើញសេនាប្រកបដោយអង្គ ៤ ស្ថិតស្ថាងគ្រឿងប្រដាប់ពាក់អាវក្រោះហើយឈរនៅក្នុងទីមានផែនដីរាបស្អាតក្នុងវេលាដែលព្រះអាទិត្យរះឡើង ១ ចង់ផឹកទឹកដែលគេលាងព្រះខ័ន ១ ។ ស្តេចនោះទ្រង់ត្រាស់តបទៅវិញថា នែនាងទេវី បើយើងជាអ្នកកំសត់ម្ល៉ះ តើនឹងទៅរកសេនាប្រកបដោយអង្គ ៤ ស្ថិតស្ថាងគ្រឿងប្រដាប់ពាក់អាវក្រោះ ហើយឈរនៅក្នុងទីមានផែនដីរាបស្អាត និងទឹកដែលគេលាងព្រះខ័នបានមកពីទីណា ។ ព្រះនាងទេវីទូលតបថា បពិត្រព្រះសម្មតិទេព បើខ្ញុំម្ចាស់មិនបានគ្រឿងទាំងនោះទេ ខ្ញុំម្ចាស់មុខជានឹងស្ងាប់មិនខាន ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង មានព្រាហ្មណ៍ជាបុរោ-ហិតរបស់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ជាសំឡាញ់នឹងស្តេចក្នុងដែនកោសលឈ្មោះទីឃីតិ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុង

ព្រហ្មទត្តស្ស ការ៉ារញ្ញោ បុរោហិតោ ព្រាហ្មណោ
តេនុបសង្កមិ ឧបសង្កមិត្វា ព្រហ្មទត្តស្ស ការ៉ារញ្ញោ
បុរោហិតំ ព្រាហ្មណំ ឯតទវោច សចេ តេ សម្ម តញ្ជិនី
តស្សា ឯវ្ហ្យ ចោ ឧោហ្ណ ឧប្ជ្ជ ឥច្ឆតិ សុរ៉ាយ ស្ស
ឧត្តមនការ ចតុ ជ្ជ ន ០ ០ ០

ដែនកោសលព្រះនាមទីឃីតិយាងចូលទៅរកព្រាហ្មណ៍ ជាបុរោហិតរបស់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត លុះចូលទៅដល់ហើយទ្រង់ត្រាស់ទៅនឹងព្រាហ្មណ៍ជាបុរោហិត របស់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត យ៉ាងនេះថា នែសំឡាញ់ ឥឡូវស្ត្រីជាសំឡាញ់របស់អ្នកមានគភ៌ហើយ ឯចំណង់របស់នាងនោះកើតឡើងបែបនេះ គឺនាងនោះចង់តែឃើញពួកសេនាប្រកបដោយអង្គ ៤ ស្ថិតស្ថាងគ្រឿងប្រដាប់ពាក់អាវក្រោះហើយឈរនៅក្នុងទីមានផែនដីរាបស្អាត ក្នុងវេលាព្រះអាទិត្យរះឡើង និងចង់ផឹកទឹកដែលគេលាងព្រះខ័ន ។ ឯព្រាហ្មណ៍បុរោហិតទូលតបវិញថា សូមទ្រង់ព្រះមេត្តាប្រោស បើដូច្នោះ យើងខ្ញុំចង់ឃើញព្រះនាងទេវីផង ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសីរបស់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ ក៏បានចូលទៅរកព្រាហ្មណ៍ជាបុរោហិតរបស់ស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ។ ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍ជាបុរោហិតរបស់ស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្ត បានឃើញមហេសីរបស់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ យាងមកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រោកចាកអាសន: ហើយធ្វើសំពត់សម្រាប់បង់កលើស្មាម្ខាងរួចប្រណម្យអញ្ជលីឡើង ចំពោះមហេសីរបស់ស្តេចក្នុងដែនកោ-សលព្រះនាមទីឃីតិហើយ បន្ទឹឡើងនូវឧទាន ៣ ដងថា អើហ្ន

កោសម្ពិក្ខន្ធកេ ទីឃាវុកុមារវត្ថុ

គោសលរាជា វត កោ ភុកុច្ឆិតគោ គោសលរាជា វត
ភោ ភុកុច្ឆិតគោតិ អវិមជ ដេវ ហោហិ លច្ឆសិ សុរិយស្ស
ឧត្តមនការេ ចតុរង្ខិនី សេនំ សន្ធ្ងំ រម្ម្ហិកំ សុភូមិយំ
ឋិតំ បស្ស្ហិតុំ ខត្តានញ្ច ជោវនំ ចាតុន្តិ ។ អថខោ ភិក្ខវ
ព្រហ្មទត្តស្ស ការីរញ្ញោ បុរោហិតោ ព្រាហ្មណោ យេន
ព្រហ្មទត្តោ ការីរាជា តេនុបសង្ខ្លមិ ឧបសង្ខ្លមិត្វា
ព្រហ្មទត្តំ ការីរាជានំ ឯតទវោច តថា ដេវ ជិមិត្តានិ
ជិស្ស្ហន្តិ ស្ងេ សុរិយស្ស ឧត្តមនការេ ចតុរង្ខិនី សេនា
សន្ធ្ងា រម្ម្ហិការ សុភូមិយំ ឋិដ្ឋតុ ខត្តា ច ជោរិយន្ត្ងតិ ។
អថខោ ភិក្ខវ ព្រហ្មទត្តោ ការីរាជា មនុស្ស
អាណាបេសិ យថា ភណ្ណ បុរោហិតោ ព្រាហ្មណោ
អាហ តថា ការោថាតិ ។ អលភិ ខោ ភិក្ខវ ឌីឃីតិស្ស
គោសលរញ្ញោ មហេសី សុរិយស្ស ឧត្តមនការេ

ស្តេចក្នុងដែនសោសលបានមកឋិតនៅក្នុងផ្ទៃហើយ អើហ្ន៎ ស្តេចក្នុងដែនកោសលបានមកឋិតនៅក្នុងផ្ទៃហើយ បពិត្រព្រះនាងទេវី ព្រះនាងកុំព្រួយព្រះទ័យឡើយ លុះវេលាព្រះអាទិត្យរះឡើងហើយ ព្រះនាងមុខជានឹងបានឃើញពួកសេនាប្រកបដោយអង្គ ៤ ស្ងិតស្អាងគ្រឿងប្រដាប់ពាក់អាវក្រោះហើយ ឈរនៅក្នុងទីមានផែនដីរាបស្អាតផង បានសោយទឹកដែលគេលាងព្រះខ័នផងមិនខានឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ វេលានោះ ព្រាហ្មណ៍ជាបុរោហិតរបស់ស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្តបានចូលទៅគាល់ស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្តលុះចូលទៅដល់ហើយ ក៏ក្រាបទូលស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស និមិត្តទាំងឡាយក៏ប្រាកដដូច្នោះ កាលបើព្រះអាទិត្យរះឡើងក្នុងវេលាថ្ងៃស្អែកហើយ សូមឲ្យពួកសេនាប្រ-កបដោយអង្គ ៤ ស្ងិតស្អាងគ្រឿងប្រដាប់ពាក់អាវក្រោះហើយឈរនៅលើទីមានផែនដីរាបល្អផង សូមឲ្យជនទាំងឡាយលាងនូវព្រះខ័នផង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ក៏បានត្រាស់បង្គាប់ទៅពួកមនុស្សថា នែនាយទាំងឡាយ ព្រាហ្មណ៍ជាបុរោហិតបានបង្គាប់យ៉ាងណា ក៏អស់អ្នកវាល់គ្នាចូរធ្វើយ៉ាងនោះកុំខាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើព្រះអាទិត្យរះឡើងហើយ ឯមហេសីរបស់ស្តេច

ចតុវណ្ណានំ សេនំ សន្ធេត្វ វម្មិកំ សុភូមិយំ ឋិតំ ឧស្សាបេត្វ ខត្តានញ្ច ដោវនំ ចាតុំ ។ អថខោ ភិក្ខវេ ឧយ្យានិសេ្ស្ន គោសលរញ្ញោ មហេសី ឥសេ្ស ឥត្ថីសេ្ស ឧរិចាកមន្ទាយ ឧត្ត ១ ជាយិ ។ ឥសេ្ស ឧយ្យានិ ជាមំ អកំសុ ។ អថខោ ភិក្ខវេ ឧយ្យានិ ការុមាវេ ឧចិរសេ្ស្ន ១ ញ្ញុតំ ចាបុណិ ។ អថខោ ភិក្ខវេ ឧយ្យានិ គោសលរញ្ញោ ឯតមត្ថមារោចិ អយំ ខោ ព្រហ្មទត្តោ ការីរាជា ពហុ-ដោ អម្ហាកំ អនត្ថេ ១ ការការោ ១ ១ អម្ហាកំ ពលញ្ច ១ ១ ១

ក្នុងដែនកោសលព្រះនាមទីឃីតិ ក៏បានឃើញពួកសេនាប្រកបដោយអង្គ ៤ ស្ថិតស្ពាងគ្រឿងប្រដាប់ពាក់អាវក្រោះ ហើយឈរនៅលើទីមានផែនដីរាបល្អផង បានសោយទឹកដែលគេលាងព្រះខ័នផង ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសីរបស់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ លុះមានគភ៌ចាស់ហើយក៏ទ្រង់ប្រសូតព្រះរាជបុត្រមក ។ ព្រះមាតាបិតាទ្រង់ប្រទាននាមកុមារនោះថា ទីឃាវុ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុ-មារមិនយូរប៉ុន្មានក៏បានដល់នូវការដឹងក្តី ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិទ្រង់រិះគិតយ៉ាងនេះថា ស្តេចក្នុងដែនកាសីឈ្មោះព្រហ្មទត្តនេះ បានធ្វើសេចក្តីវិនាសដល់យើងជាច្រើន ទាំងពួកពលផង ពាហន:ផង ជនបទផង ឃ្លាំងផង ជង្រុកផង របស់យើង ស្តេចនេះក៏រឹបជាន់យកអស់ ប្រសិនបើស្តេចនេះជ្រាបដំណឹងយើងហើយ មុខជានឹងឲ្យមនុស្សសម្ងាប់យើងទាំងបីនាក់មិនខានឡើយ បើដូច្នោះហើយ គួរអាត្មាអញឲ្យទីឃាវុកុមារចេញទៅនៅក្រៅក្រុងវិញ ។ ម្នាលភិក្ខុទាំង-ឡាយ លំដាប់នោះ ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ ក៏បានឲ្យទីឃាវុកុមារចេញទៅនៅខាងក្រៅក្រុង ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារកាលនៅខាងក្រៅក្រុង មិនយូរប៉ុន្មានក៏បានសិក្សាចេះដឹងនូវសិល្បសាស្ត្រសព្វគ្រប់ ។

កោសម្ពិក្ខន្ធកៈ ទីឃាវុកុមារវត្ថុ

[១៥០] តេន ខោ បន ភិក្ខវេ សមយេន ឌីឃី-
តិស្ស កោសលរញ្ញោ ភាគិនេយ្យោ ព្រហ្មទត្តេ ការាសីរញ្ញេ
បដិវសតិ ។ អទ្ធសា ខោ ភិក្ខវេ ឌីឃីតិស្ស កោសល-
រញ្ញោ ភាគិនេយ្យោ ឌីឃីតឺ កោសលរាជានំ សបជាប-
តិកំ ពារាណសិយំ អញ្ញតរស្មឺ បច្ចន្តិមេ ឋិការេ
ការុម្ភការនិវេសនេ អញ្ញតការវេសេន បរិញ្ញាតការ ច្ឆន្នេន
បដិវសន្តំ ឌិស្វាន យេន ព្រហ្មទត្តោ ការាសីរាជា តេ-
ឧបសង្ក្រមិ ឧបសង្ក្រមិត្វា ព្រហ្មទត្តំ ការាសីរាជានំ ឯត-
ទវោច ឌីឃីតិ ទេវ កោសលរាជា សបជាបតិកោ
ពារាណសិយំ អញ្ញតរស្មឺ បច្ចន្តិមេ ឋិការេ ការុម្ភការ-
និវេសនេ អញ្ញតការវេសេន បរិញ្ញាតការ ច្ឆន្នេន បដិវស-
តីតិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ ការាសីរាជា មនុស្ស
អាណាបេសិ តេនហិ ភណេ ឌីឃីតឺ កោសលរាជានំ
សបជាបតិកំ អានេថាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ តេ
មនុស្សា ព្រហ្មទត្តស្ស ការាសីរញ្ញោ បដិស្សុណិត្វា

កោសម្ពិក្ខន្ធក: រឿងទីឃាវុកុមារ

[១៥០] ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង នាយខ្នាន់ព្រះកេសរបស់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ នៅអាស្រ័យក្នុងសំណាក់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ។ ម្នាលភិក្ខុទាំងឡាយ នាយខ្នាន់ព្រះកេសរបស់ស្តេច ក្នុងដែនកោសលព្រះនាមទីឃីតិបានឃើញស្តេចក្នុងដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសី ធ្វើកេទរបស់ខ្លួនមិនឲ្យបុគ្គលដទៃស្គាល់បាន ទ្រង់ស្ងៀកដណ្តប់ជាបរិព្វាជកហើយនៅអាស្រ័យក្នុងផ្ទះស្ងួនធ្នាំងក្នុងទីឱ្យកាសមួយ ជាទីបំផុតក្រុងពារាណសី លុះបានឃើញហើយ ក៏បានចូលទៅគាល់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត លុះចូលទៅដល់ហើយ ក៏ក្រាបទូលស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវស្តេចក្នុងដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសី ធ្វើកេទរបស់ខ្លួនមិនឲ្យបុគ្គលដទៃស្គាល់បាន ទ្រង់ស្ងៀកដណ្តប់ជាបរិព្វាជកហើយនៅអាស្រ័យក្នុងផ្ទះស្ងួនធ្នាំង ក្នុងទីឱ្យកាសមួយជាទីបំផុតក្រុងពារាណសី ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ក៏ទ្រង់បង្គាប់ពួកមនុស្សទាំងឡាយថា នែនាយទាំងឡាយ បើដូច្នោះ អ្នកវាល់គ្នាចូរទៅនាំយកស្តេចក្នុងដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីមក ។ ម្នាលភិក្ខុទាំងឡាយ ឯមនុស្សទាំងនោះបានទទួលព្រះឱ្ការៈរបស់ស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្ត

ឌីឃីតឺ គោសលរាជានំ សបជាបតិកំ អានេសុំ ។
អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសីរាជា មនុស្ស
អាណាបេសិ តេនហិ ភណេ ឌីឃីតឺ គោសលរាជានំ
សបជាបតិកំ ឧជ្ជាយ រជ្ជយា បច្ឆាពាហំ គាឡ្ហពន្ធនំ
ពន្ធិត្វា ខុរមុណ្ហំ ការិត្វា ខរស្សរេន បណាវេន រថិយាយ
រថិយំ សិង្ឆាដកេន សិង្ឆាដកំ បរិនេត្វា ឧក្ខិណេន
ទ្វារេន និក្ខាមេត្វា ឧក្ខិណាតោ ឆតរស្ស ចតុជា ធិន្ធិត្វា
ចតុទ្ធិសា ពិណានិ និក្ខិបថាតិ ។ ឯវំ ទេវតិ ទោ
ភិក្ខវេ តេ មនុស្ស ព្រហ្មទត្តស្ស កាសីរញ្ញោ ប-
ដិស្សុណិត្វា ឌីឃីតឺ គោសលរាជានំ សបជាបតិកំ
ឧជ្ជាយ រជ្ជយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរ-
មុណ្ហំ ការិត្វា ខរស្សរេន បណាវេន រថិយាយ រថិយំ
សិង្ឆាដកេន សិង្ឆាដកំ បរិនេន្តិ ។ អថខោ ភិក្ខវេ
ឌីឃាវុស្ស កុមារស្ស ឯតទហោសិ ចិរំ ជិដ្ឋ[1] ទោ
មេ មាតាបិតរោ យន្ទូនាហំ មាតាបិតរោ បស្សេយ្យន្តិ ។

---

១ ឱ. ចិរទិដ្ឋា ។

ដោយពាក្យថា ព្រះករុណាវិសេសព្រះអង្គ ហើយក៏ទៅនាំយកស្តេចក្នុងដែនកោសលព្រះនាមទីឃីតិព្រមទាំងមហេសីមក ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ទ្រង់បង្គាប់ទៅពួកមនុស្សទាំងឡាយថា នែនាយទាំងឡាយ បើដូច្នោះ អ្នកវាល់គ្នាចូរនាំគ្នាចាប់ស្តេចក្នុងដែនកោសលឈ្មោះទីឃីតិ ព្រមទាំងមហេសីចងឲ្យមានដើមដៃទៅខាងក្រោយ[១] ឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងចេញ រួច (ត្រូវទូង) ស្គរ ដែលមានសំឡេងឮខ្លាំងហើយនាំបណ្តើរជុំវិញសព្វច្រកសព្វផ្លូវត្រឡែងកែង រួចនាំចេញតាមទ្វារខាងត្បូង ហើយកាប់ជា ៤ កំណាត់កប់ទៅក្នុងរណ្ដាគ្រប់ទិសទាំង ៤ ជាខាងត្បូងនៃក្រុង ។ ម្នាលភិក្ខុទាំងឡាយ ឯមនុស្សទាំងនោះបានទទួលព្រះឱ្យការស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏នាំគ្នាចាប់ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ ព្រមទាំងមហេសីឲ្យមានដើមដៃទៅខាងក្រោយឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងចេញ ហើយ (ទូង) ស្គរដែលមានសំឡេងឮខ្លាំង រួចនាំបណ្តើរជុំវិញសព្វច្រកសព្វផ្លូវត្រឡែងកែង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញខានឃើញមាតាបិតាយូរណាស់ហើយ បើដូច្នោះ គួរតែអាត្មាអញទៅមើលមាតាបិតាបានម្តងសិន ។

---

១ គឺចងស្លាបសេក បណ្តើរអាក្រាស ។

កោសម្ពិក្ខន្ធកេ ទីឃាវុកុមារវត្ថុ

អថខោ ភិក្ខវេ ឌីឃាវុ កុមារោ ពាវាណសឹ បវិសិត្វា អទ្ធស មាតាបិតរោ ឧជ្ជាយ រជ្ជយា បច្ឆាពាហំ តាជ្ជ-ពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ការិត្វា ខរស្សរេន បណាវេន រថិយាយ រថិយំ សិង្ឆាដកេន សិង្ឆាដកំ បរិនេន្តេ ឌិស្វាន យេន មាតាបិតរោ តេនុបសង្ក្រមិ ។ អទ្ធសា ខោ ភិក្ខវេ ឌីឃីតិ កោសលរាជា ឌីឃាវុំ កុមារំ ជ្ជរតោ រ អាតច្ចន្តំ ឌិស្វាន ឌីឃាវុំ កុមារំ ឯតទវោច មា ខោ តំ តាត ឌីឃាវុ ឌីឃំ បស្ស មា រស្សំ ន ហិ តាត ឌីឃាវុ រេរេ រេ សម្ផ្ជ្ជ អរេរេ ហិ តាត ឌីឃាវុ រេ សម្ផ្ជ្ជតិ ។ ឯវំ វុត្តេ ភិក្ខវេ តេ មនុស្ស ឌីឃីតឺ កោសលរាជានំ ឯតទវោចុំ ឧម្ម្ជ្ជតោ អយំ ឌីឃីតិ កោសលរាជា រិប្ជ្ជលបតិ កោ ឥមស្ស ឌី-ឃាវុ កំ អយំ ឯវមាហ មា ខោ តំ តាត ឌីឃាវុ ឌីឃំ បស្ស មា រស្សំ ន ហិ តាត ឌីឃាវុ រេរេ រេ សម្ផ្ជ្ជ អរេរេ ហិ តាត ឌីឃាវុ រេ សម្ផ្ជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារចូលទៅក្រុងពារាណសីហើយ ក៏បានឃើញមាតាបិតា ដែលគេកំពុងតែចងស្ទាបសេកជាប់ដោយខ្សែដ៏មាំ ការក្បាលឲ្យរលីងចេញ (ទូង) ស្ករដែលមានសំឡេងឮខ្ទាំង ហើយនាំ បណ្តើរជុំវិញសព្វច្រក សព្វផ្លូវត្រឡែងកែង លុះឃើញហើយក៏ចូល ទៅរកមាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចក្នុងដែនកោសលព្រះនាម ទីឃីតិទ្រង់ទតទៅឃើញទីឃាវុកុមារមកអំពីចម្ងាយ លុះឃើញហើយក៏ មានព្រះឱ្ការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំ ឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចង ពៀរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើស្តេចនោះ មានព្រះឱ្ការយ៉ាងនេះ ហើយ ពួកមនុស្សទាំងនោះ ក៏ពោលពាក្យនេះនឹងស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិថា ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិនេះធ្ងួតនិយាយ ផ្ដេសផ្ដាសទេតើ នរណាឈ្មោះទីឃាវុ (ជាកូន) របស់ស្តេចនេះ ស្តេចនេះ និយាយទៅនឹងនរណាយ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចង ពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។

ជាហំ ភណេ ឧម្មត្តកោ វិប្ផលចាមិ អបិច យោ
ញ្ញ សោ វិភាវេស្សតីតិ ។ ទុតិយម្ប ិ ខោ ភិក្ខវ ។ បេ ។
តតិយម្ប ិ ខោ ភិក្ខវ ឌីឃីតិ កោសលរាជា ឌីឃារុ
ការ ១ តនភ្ជ ១ ១ ១

ស្តេចទីឃីតិនោះតបទៅវិញថា នែនាយ យើងមិនមែនឆ្ពួតនិយាយផ្តេស-ផ្តាសទេ បើនរណាជាអ្នកប្រាជ្ញ អ្នកនោះទើបថ្វែងសេចក្តីបាន ។ ម្នាលភិក្ខុទាំងឡាយ ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ មានព្រះឱង្ការទៅនឹងទីឃាវុកុមារជាគម្រប់ពីរដងផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិ មានព្រះឱង្ការទៅនឹងទីឃាវុកុមារជាគម្រប់បីដងផង យ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងនោះ ក៏បាននិយាយពាក្យនេះនឹងស្តេច ក្នុងដែនកោសលព្រះនាមទីឃីតិជាគម្រប់បីដងទៀតថា ស្តេចក្នុងដែនកោសលព្រះនាមទីឃីតិនេះឆ្ពួតនិយាយផ្តេសផ្តាសទេតើ នរណាឈ្មោះទីឃាវុ (ជាកូន) របស់ស្តេចនេះ ស្តេចនេះនិយាយទៅនឹងនរណា យ៉ាងនេះថា នែទីឃាវុកូន អ្នកកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។ ស្តេចនោះទ្រង់តបទៅវិញថា នែនាយ យើងមិនមែនជាមនុស្សឆ្ពួតនិយាយផ្តេសផ្តាសទេ ប៉ុន្តែបើនរណាជាអ្នកប្រាជ្ញ អ្នកនោះ

រិកាវេស្ស្ជតីតិ ។ អថខោ ភិក្ខវេ តេ មនុស្ស្ជ ឌីឃីតឺ
កោសលរាជានំ សបជាបតិកំ រថិយាយ រថិយំ សិង្ឆ្ជ-
ដកេ សិង្ឆ្ជដកំ ឧបរិនេត្ជ ឧក្ខិណេន ទ្ជារេន និក្ខ្ជ-
មេត្ជ ឧក្ខិណាតោ ឧតរស្ស្ជ ចតុជ ធិង្ខ្ជិត្ជ ចតុទ្ជិសា
ពិលានិ និក្ខ្ជិបិត្ជ តុម្ពំ ឧបេត្ជ ឧក្ខ្ជមឺសុ ។ អថខោ
ភិក្ខ្ជវេ ឌីឃាវុ កុមារោ ពារាណសឺ ឧបសិត្ជ សុរ
ឌីហរិត្ជ តុម្ពិយេ ចាយេសិ ។ យជ តេ មត្ជ អ្ជ-
ស្ជ ឧតិតា អថ ការ្ជានិ សង្ខ្ជ្ជ្ជ្ជ្ជ ម្ជ្ជ្ជ ម្ជ្ជ្ជ ម្ជ្ជ ម្ជ ម្ជ ម

ទើបថ្វៃងសេចក្ដីបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មនុស្សទាំងនោះក៏នាំបណ្ដើរស្ដេច ក្នុងដែនកោសលព្រះនាមទីឃីតិ ព្រមទាំងមហេសីទៅសព្វច្រកសព្វផ្លូវត្រឡែងកែង ហើយចេញទៅតាមទ្វារខាងត្បូង ហើយកាត់ខ្ជួនជា ៤ កំណាត់ រួចកប់ក្នុងរណ្ដៅគ្រប់ទិសទាំង ៤ ជាខាងត្បូងនៃព្រះនគរហើយទុកពួកពល (ឲ្យនៅថែទាំ) រួចចយចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារចូលទៅកាន់ក្រុងពារាណ-សី ហើយក៏នាំយកសុវាមកបំផឹកពួកពល (ទាំងនោះ) ។ ពួកពលទាំងនោះស្រវឹងដួលដេកទៅកាលណា ទីឃាវុកុមារក៏ប្រមូលកំណាត់ឈើ ហើយលើកសរីរៈមាតាបិតាដាក់លើជើងថ្ករួចបូជាភ្លើង ហើយផ្គងអញ្ជលីធ្វើប្រទក្សិណជើងថ្ក ៣ ជុំ ។ ម្នាលភិក្ខុទាំងឡាយ ចួនជាពេលនោះ ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ទ្រង់គង់នៅលើប្រាសាទដ៏ប្រសើរឲ្ជដ៏ខាងលើ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត បានទតទៅឃើញទីឃាវុកុមារកំពុងតែផ្គងអញ្ជលីធ្វើប្រទក្សិណជើងថ្ក ៣ ជុំ លុះឃើញហើយក៏ទ្រង់ត្រិះរិះយ៉ាងនេះថា មនុស្សនោះច្បាស់ជាញាតិ ឬជាសាលោហិតរបស់ស្ដេចក្នុងដែនកោសលឈ្មោះទីឃីតិហើយ ឱហ្ន៎សេចក្ដីវិនាស (ព្រោះបុរសនេះគង់នឹងមាន) ដល់អាត្មាអញ មិនសមបើ

អាហ្ការេ ចេស្ស តីតិ ។ អថ ខោ ភិក្ខវេ ឌីឃាវុ ការ្យ្ហ អ្ជ្ជ
ឯ យ្ជ ឧ ត ្ត ្ត ្

គ្មាននរណាមួយប្រាប់អាត្មាអញសោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារទៅឯព្រៃហើយខ្សឹកខ្សួលទួញយំអស់ចិត្តរួចជូតទឹកភ្នែកហើយត្រឡប់ចូលទៅក្នុងក្រុងពារាណសីវិញ ក៏ទៅឯរោងដំរីទៀបព្រះរាជវាំងហើយនិយាយពាក្យនេះនឹងហ្មដំរីថា នែអ្នកហ្មដំរី ខ្ញុំចង់រៀនសិល្ប: (អំពីអ្នកតើបានឬទេ) ។ ឯហ្មដំរីនោះនិយាយតបថា នែនាយមាណព បើដូច្នោះ ចូរអ្នករៀនចុះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ក៏ស្រែកច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចក្នុងដែនកាសីព្រះនាមព្រះព្រហ្មទត្ត បានទ្រង់ព្រះសណ្តាប់ចម្រៀងនិងពិណដែលទីឃាវុកុមារក្រោកឡើង ក្នុងបច្ចូសសម័យនៃរាត្រីហើយច្រៀងប្រកបដោយសំឡេងយ៉ាងពីរោះក្នុងរោងដំរី លុះទ្រង់ព្រះសណ្តាប់រួចហើយ ក៏ទ្រង់ត្រាស់សួរមនុស្សទាំងឡាយថា នែនាយ នរណាក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ក៏ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី ។ មនុស្សទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មាណពជាកូនសិស្សរបស់ហ្មដំរីឯណោះ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ក៏ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី ។ ស្តេចនោះទ្រង់ត្រាស់ថា នែនាយ បើដូច្នោះ

តំ មាណវកំ អានេថាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ តេ
មនុស្សា ព្រហ្មទត្តស្ស កាសីរញ្ញោ បដិស្សុណិត្វា ឌីឃាវុ
កុមារំ អានេសុំ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កា-
សីរាជា ឌីឃាវុ កុមារំ ឯតទវោច ត្វំ ភណេ មាណវក
រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ហត្ថិសាលាយំ មញ្ជុ
សរេន តាយ រីណាញ្ចូ ភាទេសីតិ ។ ឯវំ ទេវាតិ ។
តេនហិ ភណេ មាណវក តាយស្ស រីណាញ្ចូ ភាទេហីតិ ។
ឯវំ ទេវាតិ ខោ ភិក្ខវេ ឌីឃាវុ កុមារោ ព្រហ្មទត្តស្ស
កាសីរញ្ញោ បដិស្សុណិត្វា អាវាដាបេត្វោ មញ្ជុ
សរេន តាយ រីណាញ្ចូ ភាទេសិ ។ អថខោ ភិក្ខវេ
ព្រហ្មទត្តោ កាសីរាជា ឌីឃាវុ កុមារំ ឯតទវោច ត្វំ
ភណេ មាណវក មំ ឧបដ្ឋហាតិ ។ ឯវំ ទេវាតិ ខោ
ភិក្ខវេ ឌីឃាវុ កុមារោ ព្រហ្មទត្តស្ស កាសីរញ្ញោ
បច្ចុស្សោសិ ។ អថខោ ភិក្ខវេ ឌីឃាវុ កុមារោ ព្រហ្ម-
ទត្តស្ស កាសីរញ្ញោ បុព្ពុដ្ឋាយី អហោសិ បច្ឆានិចាតី

អ្នកទាំងឡាយចូរនាំមាណពនោះមក ។ ម្នាលភិក្ខុទាំងឡាយ មនុស្ស
ទាំងនោះទទួលស្តាប់ព្រះឱ្ការស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្តដោយ
ពាក្យថា ព្រះករុណាវិសេស ហើយក៏ទៅនាំទីឃាវុកុមារមក ។ ម្នាលភិក្ខុ
ទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់មានព្រះ
ឱ្ការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែនាយមាណព អ្នកឯងក្រោកឡើង
ក្នុងបច្ចូសសម័យនៃរាត្រី ក៏ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញ
ពិណផង ក្នុងរោងដំរី មែនឬ ។ ទីឃាវុកុមារក្រាបទូលថា ព្រះករុណាវិ-
សេស ។ ស្តេចនោះទ្រង់ត្រាស់ថា នែនាយមាណព បើដូច្នោះ ចូរអ្នកឯង
ច្រៀងហើយដេញពិណឲ្យយើងស្តាប់មើល ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃា-
វុកុមារទទួលស្តាប់ព្រះឱ្ការស្តេច ក្នុងដែនកាសីព្រះនាមព្រហ្មទត្តដោយ
ពាក្យថា ព្រះករុណាវិសេស ហើយចង់ឲ្យស្តេចជ្រាបជ្រាណ ទើបស្រែក
ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ។ ម្នាលភិក្ខុទាំងឡាយ
ខណៈនោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត មានព្រះឱ្ការទៅនឹងទី-
ឃាវុកុមារយ៉ាងនេះថា នែនាយមាណព ចូរអ្នកឯងនៅបម្រើយើងចុះ ។
ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារក៏ទទួលស្តាប់ព្រះឱ្ការស្តេចក្នុងដែនកា-
សីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ។ ម្នាលភិក្ខុទាំង-
ឡាយ វេលានោះទីឃាវុកុមារក៏បានក្រោកមុនដេកក្រោយ និងទទួលស្តាប់

ភ្លឹការបដិស្សាវី មជ្ឌបចារី ឧិយ្យាតិ ។ អថខោ
ភិក្ខវេ ព្រហ្មទត្តោ ការ្ការ្ជា ឧ្ជិយ្ជារុ ការ្ជារ ជ្ជ្ជ្ជ
ជ្ជ្ជ ជ្ជ ។ ជ្ជ ។ ជ្ជ ។

បង្ហាប់ការអ្វី ។ ប្រព្រឹត្តគួរជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ដល់ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តមិនយូរប៉ុន្មាន ក៏បានតាំងទីឃាវុកុមារក្នុងទីជាអ្នកស្និទ្ធស្នាលខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ទ្រង់មានព្រះឱ្ការៈទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែនាយមាណព បើដូច្នោះ ចូរអ្នកទឹមរាជរថមក យើងនឹងទៅកាន់ទីប្រពាតម្រឹគ ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារទទួលស្តាប់ព្រះឱ្ការៈស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏រៀបទឹមរាជរថ រួចក្រាបទូលស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឯរាជរថរបស់ព្រះអង្គ ខ្ញុំព្រះអង្គទឹមរួចស្រេចហើយ សូមព្រះអង្គទ្រង់ជ្រាបកាលគួរឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់ឡើងគង់លើរាជរថ ទីឃាវុកុមារ ក៏បររាជរថទៅ ។ ពួកសេនាដើរទៅតាមផ្លូវឯទៀត ទីឃាវុកុមារជាអ្នកបររាជរថ ក៏បរទៅតាមផ្លូវឯទៀតបែកផ្សេងពីគ្នា ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តយាងទៅដល់ទីធ្វាយ ហើយទ្រង់មានព្រះឱ្ការៈទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែនាយមាណព បើដូច្នោះ

មាណវកេ រថំ មុញ្ចិត្វា កិលញ្ជេ ឆិន្ទិត្វា ។ ឯវំ ខោ ភិក្ខវេ ទីឃាវុ កុមារោ ព្រហ្មទត្តស្ស ការាបេ

ចូរអ្នកឯងដាក់រាជរថសិន ដ្បិតយើងនឿយព្រួយលំបាក យើងនឹងដេកសម្រាកបន្តិចសិន ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារបានទទួលស្តាប់ព្រះឱ្ការស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ដាក់រាជរថចេញអង្គុយពែនភ្ជែនលើផែនដី ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ក៏ទ្រង់ផ្ទំកើយព្រះសីស:លើភ្លៅទីឃាវុកុមារ ។ ស្តេចនោះនឿយព្រួយលំបាកទ្រង់ផ្ទំលក់មួយរំពេច ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ទីឃាវុកុមារក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តនេះបានធ្វើសេចក្តីវិនាសជាច្រើនដល់អាត្មាអញ ទាំងពល ពាហន: ជនបទ ឃ្លាំងនិងជង្រុក របស់អាត្មាអញ ស្តេចនេះរឹបជាន់យកអស់ មិនតែប៉ុណ្ណោះ ទាំងមាតាបិតារបស់អាត្មាអញ ស្តេចនេះក៏សម្ងាប់ចោលអស់ វេលានេះ គួរអាត្មាអញសងពៀរដល់ស្តេចនេះវិញ ហើយក៏ហួតព្រះខ័នចេញពីស្រោម ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារមានសេចក្តីត្រិះរិះយ៉ាងនេះថា បិតាបានផ្តាំអាត្មាអញក្នុងពេលដែលទៀបធ្វើមរណ-ភាពថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ បើអាត្មាអញកន្ទងពាក្យបិតាហើយ

គោសិយា ១ក្តំ បវេសេសិ ។ ១ុតិយម្ជិ ១ោ ១ិ១ក្ខវ
។ ១ប ។ ១តិយម្ជិ ១ោ ១ិ១ក្ខវ ១ីយ១ុ១ស្ស ១ុ១ារ១ស្ស
ឯ១ត១ហោ១ិ ១យំ ១ោ ១្រ១ហ្ម១ត្តោ ១ាសី១ាជ ១ហុ១ោ
១ម្ហ១ាកំ ១ន១ត្ត១ស្ស ១ារ១ោ ១មិ១ា ១ម្ហ១ាកំ ១ល១ា
១ាហ១ា១ា ១ន១ប១ោ ១ ១ោ១ស ១ ១ោ១ដ្ឋ១ារ១ា ១ច្ចិ១ុ
១មិ១ា ១ ១ម ១ា១ាបិ១ារ ហ១ា ១យំ ១ូ១ស្ស ១ាលោ
យ១ាហ ១ រ ១ម្ប្ប១ាយ១ន្តី១ិ ១ោ១ិ១ យ ១ក្ត ១ិ១ាហ ។
១ិ១ិ១ម្ជិ ១ោ ១ិ១ក្ខវ ១ីយ១ុ១ស្ស ១ុ១ារ១ស្ស ឯ១ត១-
ហោ១ិ ១ិ១ា ១ោ ១ ១ ១ារ១ណ១ាលេ ១ារ១ ១ា ១ោ ១ ១ ១ាត
១ីយ១ុ ១ីយ ១ ១ស្ស ១ា ១ស្ស ១ ១ ១ិ ១ាត
១ីយ១ុ ១ារ១ណ ១ារ ១ម្ម១ន្ត ១ារ១ណ ១ិ ១ាត ១ីយ១ុ ១ារ
១ម្ម១ន្ត១ិ ១ ១ោ ១ ១ ១ ១ ១ារ ១ារ១ ១ យ ១ារ ១ិ១ុ ១ច១ ១
១ិ១ិ១ក្ត១ម្ម១ន្ត១ិ ១ុ១ន១ោ ១ោ១ិ១ យ ១ក្ត ១ ១ារ១ណ ។
១ ១ោ១ោ ១ិ១ក្ខវ ១្រ១ហ្ម១ត្តោ ១ាសី១ាជ ១ី១ោ ១ ១ ១ ១ ១

អំពើនេះឈ្មោះថា មិនសមគួរដល់អាត្មាអញឡើយ ហើយក៏សៀតព្រះខ័ន
ទៅក្នុងស្រោមវិញ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារមានសេចក្តីត្រិះរិះ
ជាគម្រប់ពីរដងទៀត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារមានសេចក្តី
ត្រិះរិះជាគម្រប់បីដងទៀតយ៉ាងនេះថា ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត
នេះបានធ្វើសេចក្តីវិនាសជាច្រើនដល់អាត្មាអញ ទាំងពល ពាហនៈ
ជនបទ ឃ្លាំង និងជង្រុករបស់អាត្មាអញ ស្តេចនេះរឹបជាន់យកអស់ មិន
តែប៉ុណ្ណោះ ទាំងមាតាបិតារបស់អាត្មាអញ ស្តេចនេះក៏សម្ងាប់ចោលអស់
រលោនេះ គួរអាត្មាអញសងពៀរដល់ស្តេចនេះវិញ ហើយក៏ហូតព្រះ
ខ័នចេញពីស្រោម (ម្តងទៀត) ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារ
មានសេចក្តីត្រិះរិះជាគម្រប់បីដងទៀតយ៉ាងនេះថា បិតាបានផ្តាំអាត្មាអញ
ក្នុងពេលដែលទៀបធ្វើមរណភាពថា នែទីឃាវុកូន អ្នកឯងកុំឃើញ
កាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយ
ការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ
បើអាត្មាអញកន្ទងពាក្យបិតាហើយ អំពើនេះឈ្មោះថា មិនសមគួរដល់អា-
ត្មាអញឡើយ ហើយក៏សៀតព្រះខ័នទៅក្នុងស្រោមវិញ ។ ម្នាលភិក្ខុ
ទាំងឡាយ លោនោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់ភិតភ័យ
ភ្ញាក់ផ្អើលស្ងើតស្ងក់តក់ស្ងុតហើយក៏តើនឡើងភ្លាម ។ ម្នាលភិក្ខុទាំងឡាយ

កោសម្ពិក្ខន្ធកេ ទីឃាវុកុមារវត្ថុ

ឌីឃាវុ កុមារោ ព្រហ្មទត្តំ កាសីរាជានំ ឯតទវោច កិស្ស ត្វំ ទេវ ភីតោ ឧព្វិក្ខោ ឧស្សុក្ខ្យោ ឧត្រាសោ សហសា វុដ្ឋាសីតិ ។ ឥធ មំ ភណ្ណ មាណវក ឌីឃីតិស្ស កោ-សលរញ្ញោ បុត្តោ ឌីឃាវុ កុមារោ សុបិនន្តេន ១ក្ខេន បរិចាតេសិ តេនាហំ ភីតោ ឧព្វិក្ខោ ឧស្សុក្ខ្យោ ឧត្រាសោ សហសា វុដ្ឋាសិន្តិ ។ អថខោ ភិក្ខវេ ឌីឃាវុ កុមារោ ភាមេន ហត្ថេន ព្រហ្មទត្តស្ស កាសីរញ្ញោ សីសំ បរាមសិត្វា ១ក្ខិណេន ហត្ថេន ១ក្ខំ ឌិញ្ជាហោត្វា ព្រហ្មទត្តំ កាសីរាជានំ ឯតទវោច អហំ ១ោ សោ ទេវ ឌីឃីតិស្ស កោសលរញ្ញោ បុត្តោ ឌីឃាវុ កុមារោ ពហុនោ ត្វំ អម្ហាកំ អនត្តស្ស ការកោ តយា អម្ហាកំ ពលញ្ច ភាហនញ្ច ជនបទោ ច កោសោ ច កោដ្ឋ-ការញ្ច អច្ចិន្ទ្ធំ តយា ច មេ មាតាបិតរោ ហតា អយំ ១ូស្ស ការណ យោហំ ១ៅ អប្ប១ាយ្យន្តិ ។ អថខោ ភិក្ខវេ ព្រហ្មទត្តោ កាសីរាជា ឌីឃាវុស្ស កុមារស្ស ១ាតេ១ សុ សិរសា ឯ១ិតត្វា ឌីឃាវុំ កុមារំ ឯតទវោច ជីវិតំ មេ

ខណ:នោះ ទីឃាវុកុមារទូលសួរស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ហេតុអ្វី បានជាព្រះអង្គទ្រង់ កិតក័យភ្ញាក់ផ្អើលស្ងើតស្ងក់តក់ស្ងុតហើយតើនឡើងភ្លាម ។ ស្តេចនោះតបវិញថា នែនាយមាណព ព្រោះយើងយល់សប្តិ (ថាដូចជា) ទីឃាវុកុមារជាកូនស្តេចក្នុងដែនកោសលឈ្មោះទីឃីតិ លើកព្រះខ័នឡើងគម្រាមយើងក្នុងទីនេះ ព្រោះហេតុនោះ បានជាយើងកិតក័យភ្ញាក់ផ្អើលស្ងើតស្ងក់តក់ស្ងុតហើយក្រោកឡើងភ្លាម ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ទីឃាវុកុមារយកដៃខាងធ្វេងចាប់សង្កត់ព្រះសីស:ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ហើយយកដៃខាងស្តាំ ហូតព្រះខ័នរួចនិយាយពាក្យនេះនឹងស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តថា នែព្រះអង្គខ្លួនខ្ញុំឯងហើយដែលឈ្មោះទីឃាវុកុមារជាកូនស្តេច ក្នុងដែនកោសលព្រះនាមទីឃីតិ ព្រះអង្គបានធ្វើសេចក្តីវិនាសជាច្រើនដល់ខ្ញុំ ទាំងពលពាហន: ជនបទ ឃ្លាំង និងជង្រុករបស់ខ្ញុំ ព្រះអង្គក៏រឹបជាន់យកអស់ ម្យ៉ាងទៀត ទាំងមាតាបិតារបស់ខ្ញុំ ព្រះអង្គក៏សម្ងាប់ចោលអស់ រលាងនេះ គួរខ្ញុំសងពៀរដល់ព្រះអង្គវិញ ។ ម្នាលភិក្ខុទាំងឡាយ លានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ក៏ឱនព្រះសីរ្ស ក្រាបទៀបជើងទីឃាវុកុមារ ហើយមានព្រះឱង្ការទៅនឹងទីឃាវុកុមារ

តាត ឌីឃាវុ ឧេហិ ជីវិតំ មេ តាត ឌីឃាវុ ឧេហីតិ ។ ក្យាហំ ឧស្សហាមិ ឧេវស្ស ជីវិតំ ឌាតុំ ឧេវ ខោ មេ ជីវិតំ ឧឧេយ្យាតិ ។ ឧេនហិ តាត ឌីឃាវុ ត្វញ្ចេវ មេ ជីវិតំ ឧេហិ អហញ្ច ឧេ ជីវិតំ ឧម្ជីតិ ។ អថខោ ភិក្ខវេ ព្រហ្មឌត្តោ ច ការីរាជា ឌីឃាវុ ច ការ្ជមាវ អញ្ញ-មញ្ញស្ស ជីវិតំ អឌំសុ ចាណិញ្ច អត្តហេសុំ សបថញ្ច អកំសុ អឌ្ឍហាយ[1] ។ អថខោ ភិក្ខវេ ព្រហ្មឌត្តោ ការីរាជា ឌីឃាវុំ ការ្ជមារ ឯតឌវេច ឧេនហិ តាត ឌីឃាវុ រជ្ជ យោជេហិ ឧមិស្ជាមាតិ ។ ឯវ ឧេវាតិ ខោ ភិក្ខវេ ឌីឃាវុ ការ្ជមាវ ព្រហ្មឌត្តស្ស ការីរញ្ញោ ប-ជិស្ជុណិត្វា រជ្ជ យោជេត្វា ព្រហ្មឌត្តំ ការីរាជានំ ឯតឌ-វេច យុត្តោ ខោ ឧេ ឧេវ រជ្ជ យស្ជានិ ការ្ជ-មញ្ញសីតិ ។ អថខោ ភិក្ខវេ ព្រហ្មឌត្តោ ការីរាជា រជ្ជ អកិរ្ជហិ ឌីឃាវុ ការ្ជមាវ រជ្ជ ឧេសេសិ ។ ឧថា ឧថា រជ្ជ ឧេសេសិ យថា យថា ឌចិរស្ជេ ឧេជាយ

1 ឌ. អ្ជ្ជ្ជ្ជ ។

យ៉ាងនេះថា នែទីឃាវុកូន សូមអ្នកអាណិតឲ្យជីវិតដល់យើងផង នែទីឃាវុ
កូន សូមអ្នកអាណិតឲ្យជីវិតដល់យើងផង ។ ទីឃាវុកុមារតបវិញថា ខ្ញុំនឹង
អាចថ្វាយជីវិតព្រះអង្គដូចម្តេចបាន គួរតែព្រះអង្គប្រទានជីវិតមកខ្ញុំវិញ ។
ស្តេចនោះទ្រង់ត្រាស់ថា នែទីឃាវុកូន បើដូច្នោះ អ្នកឯងចូរឲ្យជីវិតដល់យើង
ចុះ យើងក៏ឲ្យជីវិតដល់អ្នកឯងវិញ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុង
ដែនកាសីព្រះនាមព្រហ្មទត្តនិងទីឃាវុកុមារ បានឲ្យជីវិតគ្នាទៅវិញទៅមក
ហើយបានទាំងចាប់ដៃគ្នាផងធ្វើសម្បថផង ដើម្បីមិនឲ្យមានរឿងប្រទូស្ត
គ្នាតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសី
ព្រះនាមព្រហ្មទត្តទ្រង់មានព្រះឱ្យការទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែ
ទីឃាវុកូន បើដូច្នោះ ចូរអ្នកទឹមរាជរថចុះ យើងនឹងត្រឡប់ទៅវិញ ។
ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារបានទទួលស្តាប់ព្រះឱ្យការស្តេចក្នុងដែន
កាសីព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ទឹម
រាជរថរួចក្រាបទូលស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តយ៉ាងនេះថា សូម
ទ្រង់ព្រះមេត្តាប្រោស ឯរាជរថរបស់ព្រះអង្គខ្ញុំព្រះអង្គទឹមរួចស្រេចហើយ
សូមព្រះអង្គទ្រង់ជ្រាបកាលគួរឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ខណៈ
នោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់យាងឡើងគង់លើរាជរថ
ឯទីឃាវុកុមារក៏បររាជរថទៅ ។ មិនយូរប៉ុន្មានទីឃាវុកុមារក៏បររាជរថទៅ

សមាគច្ឆិ ។ អថខោ ភិក្ខូ ព្រហ្មទត្តោ កាសីរាជា ពារាណសឿ បវិសិត្វា អមច្ចេ ចារិសង្ខ្យ សន្ធិចាតាបេត្វា ឯតទវោច សចេ ភណេ ឌីឃីតិស្ស កោសលរញ្ញោ បុត្តំ ឌីឃាវុំ កុមារំ បស្សេយ្យាថ កិន្តិ តំ ការេយ្យា-ថាតិ ។ ឯកច្ចេ អមច្ចា ឯវមាហំសុ មយំ ខេ ហត្ថេ ឆិន្ទេយ្យាម មយំ ខេ ចាខេ ឆិន្ទេយ្យាម មយំ ខេ ហត្ថចាខេ ឆិន្ទេយ្យាម មយំ ខេ ការ្ណេ ឆិន្ទេយ្យាម មយំ ខេ ជាសំ ឆិន្ទេយ្យាម មយំ ខេ ការ្ណេជាសំ ឆិន្ទេយ្យាម មយំ ខេ សីសំ ឆិន្ទេយ្យាមាតិ ។ អយំ ខោ សោ ភណេ ឌីឃីតិស្ស កោសលរញ្ញោ បុត្តោ ឌីឃាវុ កុមារោ ជាយំ លញ្ជ កិញ្ចិ ការ្ម ឥមិជ ច មេ ជីវិតំ ជិន្ទ មយ ច ឥមស្ស ជីវិតំ ជិន្ទ ។ អថខោ ភិក្ខូ

ជួបនឹងពួកសេនាដែលទៅតាមផ្លូវផ្សេងពីគ្នានោះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ទ្រង់យាងចូលទៅក្រុងពារាណសីហើយ ទ្រង់ប្រជុំពួកអាមាត្យជាបរិសទ្យរួចហើយទ្រង់មានព្រះឱ្ការយ៉ាងនេះថា នែនាយ ប្រសិនបើអ្នកទាំងឡាយបានឃើញទីឃាវុកុ-មារជាកូនស្តេចក្នុងដែនកោសលឈ្មោះទីឃីតិហើយ តើគួរធ្វើទីឃាវុកុមារនោះដូចម្តេច ។ អាមាត្យទាំងឡាយក៏ក្រាបទូលដោយពួក ។ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ដៃចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ជើងចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ទាំងដៃទាំងជើងចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ត្រចៀកចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ច្រមុះចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ទាំងត្រចៀកទាំងច្រមុះចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ក្បាលចេញ ។ ស្តេចនោះទ្រង់ប្រាប់ថា នែនាយទាំងឡាយ បុរសនេះឯងហើយដែលឈ្មោះទីឃាវុកុមារជាកូនស្តេចក្នុងដែនកោសលឈ្មោះទីឃីតិនោះ អ្នកទាំងឡាយមិនត្រូវធ្វើទោសកុមារនេះតិចតួចទេ ព្រោះកុមារនេះ បានឲ្យជីវិតយើង យើងក៏បានឲ្យជីវិតដល់កុមារនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ

ព្រហ្មទត្តោ កាសីរាជា ឧីយារុំ ឧុមារំ ឯតទវោច យំ ខោ
តេ តាត ឧីយារុ បិតា មរណកាលេ អវច មា ខោ ត្វំ
តាត ឧីយារុ ឧីយំ បស្ស មា រស្សុំ ន ហិ តាត ឧីយារុ
វេរេន វេរ សម្មន្តិ អវេរេន ហិ តាត ឧីយារុ វេរ សម្មន្តីតិ
កិន្តេ បិតា សន្ធាយ អវចាតិ ។ យំ ខោ មេ ឧេវ បិតា
មរណកាលេ អវច មា ឧីយន្តិ មា ចិរំ វេរំ អកាសីតិ
ឥមំ ខោ មេ ឧេវ បិតា មរណកាលេ អវច មា ឧីយន្តិ
យំ ខោ មេ ឧេវ បិតា មរណកាលេ អវច មា រស្សន្តិ
មា ទិប្ប៎ំ មិត្តេហិ ភិជ្ជិត្ថាតិ ឥមំ ខោ មេ ឧេវ បិតា
មរណកាលេ អវច មា រស្សន្តិ យំ ខោ មេ ឧេវ បិតា
មរណកាលេ អវច ន ហិ តាត ឧីយារុ វេរេន វេរ

ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ទ្រង់មានព្រះឱ្យ្ការទៅនឹងទីឃាវុកុ-
មារយ៉ាងនេះថា នែទីឃាវុកូន កាលដែលបិតារបស់អ្នកជិតនឹងធ្វើមរណ-
ភាពបានផ្តាំបណ្តាំណាចំពោះអ្នកឯងថា នែទីឃាវុកូន អ្នកឯងកុំឃើញ
កាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយ
ការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ តើ
បិតារបស់អ្នកសំដៅយកហេតុត្រង់ណា បានជាផ្តាំ (ដូច្នេះ) ។ ទីឃាវុកុមារ
ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គ
ជិតនឹងធ្វើមរណភាពបានផ្តាំបណ្តាំណាចំពោះខ្ញុំព្រះអង្គថា អ្នកកុំឃើញ
កាលវែង គឺថាអ្នកឯងកុំធ្វើពៀរឲ្យយូរអង្វែងឡើយ សូមទ្រង់ព្រះមេត្តា
ប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណភាព បានផ្តាំបណ្តាំ
នេះឯង (នេះហៅថា) កុំឃើញកាលវែង សូមទ្រង់ព្រះមេត្តាប្រោស កាល
ដែលបិតារបស់ខ្ញុំព្រះអង្គទៀបនឹងធ្វើមរណភាព បានផ្តាំបណ្តាំណាចំពោះ
ខ្ញុំព្រះអង្គថា អ្នកឯងកុំឃើញកាលខ្លី គឺថាអ្នកឯងកុំប្រញាប់បែកចាកពួកមិត្ត
សំឡាញ់ឡើយ សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គ
ជិតនឹងធ្វើមរណភាព បានផ្តាំបណ្តាំនេះឯង (នេះហៅថា) កុំឃើញកាល
ខ្លី សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើ
មរណភាពបានផ្តាំបណ្តាំណាចំពោះខ្ញុំព្រះអង្គថា នែទីឃាវុកូន ធម្មតាពៀរ

កោសម្ពិក្ខន្ធកេ ទីឃាវុកុមារវត្ថុ

សម្ផុ្ដ អវេរេ ហិ តាត ឌីឃាវុ វេរ សម្ផុ្ដ្ដតិ ឧេវេ
មេ មាតាបិតរេ ហាតាតិ សចាហំ ឧេ ជីវិតា ភេរេ-
ឧេយ្យ យ ឧេ្ដ អត្ដកាមា ឧ ម ជីវិតា ភេរេ-
ឧេយ្យ យ ម អត្ដកាមា ឧ ឧ ជីវិតា ភេរេឧេយ្យ
ឍ្ដ ឧ ឧ ន ្ដ្ដ ឧ ន ្ដ ជ ឧ ម ឧ
ជីវិ ជ ម ជ ឧ ជ ជ ជ ជ ជ ជ
ជ ជ ជ ជ ជ

មិនដែលរម្ងាប់ដោយការចងពៀរទេ នៃទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ (នោះសំដៅត្រង់) មាតាបិតារបស់ខ្ញុំព្រះអង្គដែលព្រះ-អង្គសម្ងាប់ចោលអស់ ព្រោះហេតុនោះ បើខ្ញុំព្រះអង្គនឹងបំផ្ងាញព្រះអង្គឲ្យដាច់ចាកជីវិតហើយ គង់មានពួកជនដែលប្រាថ្នាប្រយោជន៍ ចំពោះព្រះអង្គនឹងបំផ្ងាញខ្ញុំព្រះអង្គឲ្យដាច់ចាកជីវិតវិញ ពួកជនដែលប្រាថ្នាប្រយោជន៍ដល់ខ្ញុំព្រះអង្គ មុខជានឹងបំផ្ងាញជនទាំងនោះ ឲ្យដាច់ចាកជីវិតមិនខានឡើយ ពៀរនោះមិនបានរម្ងាប់ដោយការចងពៀរយ៉ាងនេះឯង ឥឡូវព្រះអង្គទ្រង់ប្រទានជីវិតដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គក៏ថ្វាយជីវិតដល់ព្រះអង្គវិញ ពៀរនោះនឹងរម្ងាប់ដោយការមិនចងពៀរយ៉ាងនេះឯង សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណ-ភាពបានផ្តាំបណ្តាំនេះឯងថា នៃទីឃាវុកូន ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នៃទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តទ្រង់ស្ងើចថា អើហ្ន៎ (ហេតុនេះ) ហៅពេញជាអស្ចារ្យណាស់ អើហ្ន៎ (ហេតុនេះ) ហៅពេញជាចម្លែកណាស់ ទីឃាវុកុមារនេះពេញជាអ្នកប្រាជ្ញមែន ព្រោះដឹងសេចក្តីដែលបិតាពោលដោយសង្ខេប ដោយពិស្តារបាន ហើយក៏ទ្រង់ត្រឡប់ប្រគល់ពល ពាហន: ជនបទ ឃ្លាំង

ពោជ្ឌាការញ្ច បជិចាទេសិ ជីតរញ្ច អជាសិ ។ តេសំ ហិ ជាម ភិក្ខវេ ភាជ្ជនំ អាជិន្ទជណ្ហានំ អាជិន្ទសត្ថានំ ឯវរូបំ ១ន្ត្ថិសោរចំ ភវិស្ស្ជតីតិ ។ ឥជ ១ោ បជ តំ ភិក្ខវេ ១ោ១ភេ យ ១ ១ ១

និងជង្រុក ជាដំណែលបិតាទៅទីឃារុកុមារវិញ បានទាំងប្រទានធីតា ១ ថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ គួរកោតដែរ យ៉ាងពួកក្សត្រទាំងនោះ (ធ្លាប់តែ) កាន់ដំបង (ធ្លាប់តែ) កាន់គ្រឿងសស្ត្រាហើយ ចេះមានអំណាត់និងសេចក្តីប្រព្រឹត្តល្អបែបនេះបាន ។ ព្រោះហេតុដូច្នោះ ម្នាលភិក្ខុទាំងឡាយ អ្នកវាល់គ្នាបានមកបួសក្នុងធម្មវិន័យនេះ ដែលតថាគតបានសំដែងដោយល្អយ៉ាងនេះហើយ គួរតែខំអត់ធន់ គួរតែខំប្រព្រឹត្តល្អឲ្យល្អឡើង ។

[១៥១] ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាទៅនឹងភិក្ខុទាំងនោះជាគម្រប់បីដងយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំង-ឡាយ កុំធ្វើសេចក្តីបង្ក្រហេតុ កុំធ្វើសេចក្តីឈ្លោះគ្នា កុំធ្វើសេចក្តីប្រកាន់ផ្សេង ។ គ្នា កុំធ្វើសេចក្តីវិវាទគ្នាឡើយ ។ ឯអធម្មវាទីភិក្ខុនោះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគជាគម្រប់បីដងយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគជាធម្មស្សាមីទ្រង់ឈប់បង្ហ័ងចុះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគមានសេចក្តីខ្ជាប់ខ្ជួនតិច សូមទ្រង់ប្រកបតែនឹងធម៌ដែលជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នរឿយ ។ ចុះ

មយមេតេន ភណ្ឌនេន ភាសលហេន វិត្តហេន រាជេន
បញ្ញាយិស្សាមាតិ ។ អថខោ ភគវា បរិយាធិន្នរូចា
ខោ ឥមេ មោឃបុរិសា ឧយិមេ សុភាវ សញ្ញាបេតុន្តិ
ឧដ្ឋាយាសនា បក្ការមិ ។

ទីឃាវុកាណវារំ បឋមំ ។

[១៥២] អថខោ ភគវា បុព្ពណ្ហសមយំ និវាសេត្វា
បត្តចីវរមាទាយ កោសម្ពឺ បិណ្ឌាយ ចារិសិ កោសម្ពិយំ
បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌចាតប្បដិក្ការ្ជោ
សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ សង្ឆ្យមជ្ឌ
ឬ្ជ្ជ ឥមា គាថាយោ អភាសិ ។

ឯយើងខ្ញុំទាំងឡាយមុខជានឹងប្រាកដដោយសេចក្តីបង្ក្ហេតុ ដោយសេចក្តីឈ្លោះគ្នា ដោយសេចក្តីប្រកាន់ផ្សេង ៗ គ្នា ដោយសេចក្តីវិវាទគ្នាមិនខាន ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់រិះគិតថា ពួកមោឃបុរសទាំងនេះ មានសភាពគឺកិលេសគ្របសង្កត់ហើយ តថាគតមិនងាយនឹងពន្យល់មោឃបុរសទាំងនេះបានឡើយ ហើយក៏ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

ចប់ ភាវៈពោលអំពីទីឃាវុកុមារទី ១ ។

[១៥២] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ហើយទ្រង់បាត្រនិងចីវរយាងចូលទៅក្រុងកោសម្ពី ដើម្បីបិណ្ឌបាតក្នុងពេលព្រឹកព្រហាម លុះយាងទៅបិណ្ឌបាតក្នុងក្រុងកោសម្ពីហើយទ្រង់ត្រឡប់មកពីបិណ្ឌបាតវិញ ក៏ទ្រង់រៀបទុកដាក់គ្រឿងសេនាសនៈ ហើយកាន់យកបាត្រនិងចីវរ ទ្រង់ឋិតកណ្តាលជំនុំសង្ឆ ក្នុងវេលាក្រោយភត្ត ហើយទ្រង់ពោលព្រះគាថាទាំងនេះថា

[១៥៣] បុថុសង្ខោ សមជនោ
ន ពាលោ ឧកោចិ មញ្ញថ
សជ្ជ្ស្ម ភិជ្ជមានស្ម
ជាញ្ញ ភិយ្យោ អមញ្ញារុ ។
បរិមុដ្ឋា បណ្ហិតាកាសា
ឋចាតោចរកាណិនោ
យាវិច្ឆន្តិ មុខាយាមំ
យេន នីតា ន តំ ១ិ
អក្ខោ្ជ មំ អវធ មំ
អជ្ជ មំ អហាសិ មេ
យេ ច តំ ១ុបនយ្ហន្តិ
ឯ ១ តេ ន សម្ម ។
អក្ខោ្ជ មំ អវធ មំ
អជ្ជ មំ អហាសិ មេ
យេ ច តំ ១ុបនយ្ហន្តិ
ឯ ១ តេ ១ ។
ន ហិ ១ ១ ១ ១

[១៥៣] ជននេះមានសំឡេងខ្ទាំងផង ជាជនប្រហែលគ្នាផង សូម្បីជនណាមួយដឹងខ្លួនថា ជាបុគ្គលពាលក៏គ្មាន កាលបើសង្ឆ្ស កំពុងតែបែកគ្នា ជនទាំងឡាយក៏មិនបានដឹងហេតុដទៃឲ្យក្រៃលែង ។ ពួកជនដែលភ្ងេចស្មារតី ហើយធ្វើឫកពាខ្លួនដូចជាអ្នកប្រាជ្ញ មានសំដីជាអារម្មណ៍ ចង់ហារមាត់និយាយប៉ុន្មាន ក៏និយាយប៉ុណ្ណោះទៅ ទុកជាមានគេនាំទៅប្រជល់ឲ្យឈ្លោះគ្នា ក៏មិនដឹងសេចក្ដីនោះថាជាសេចក្ដីឈ្លោះឡើយ ។ ពួកជនណាចង់សេចក្ដីក្រោធនោះទុក ដោយគិតថា ជនឯណោះបានជេរអាត្មាអញ ជនឯណោះបានវាយអាត្មាអញ ជនឯណោះបានផ្ចាញ់ផ្ចាលអាត្មាអញ ជនឯណោះបានលួចទ្រព្យអាត្មាអញ ពៀររបស់ជនទាំងនោះមិនបានរម្ងាប់ទេ ។ ម្យ៉ាងទៀត ពួកជនណាមិនបានចង់សេចក្ដីក្រោធនោះទុកដោយគិតថា ជនឯណោះបានជេរអាត្មាអញ ជនឯណោះបានវាយអាត្មាអញ ជនឯណោះបានផ្ចាញ់ផ្ចាលអាត្មាអញ ជនឯណោះបានលួចទ្រព្យអាត្មាអញ ពៀររបស់ជនទាំងនោះទើបរម្ងាប់ទៅបាន ។ ក្នុងលោកនេះ ធម្មតាពៀរ

សម្ធន្ធីធ ភុជាចនំ
អវេរេន ច សម្ធន្ធិ
ឯស ធម្មោ សនន្ធនោ ។
បរេ ច ន វិជានន្ធិ
មយមេត្ត យមាម្ហសេ
យេ ច តត្ត វិជានន្ធិ
ត្ត សម្ធន្ធិ មេធគា ។
អដ្ឋិច្ឆិ ម្ហ[1] ចាណាហ
ភវាសួធនហារិនោ
ផ្ទ វិលុម្ប ម ជានំ
ត សំ ហោតិ   សន្ធ ។
ភស្ម ភុម្ហ ភ ។
ស ។ ស ។ ជ ។
ស ។ ។ ។ ។

១ ឱ. អដ្ឋិច្ឆិ ន្ធ ។

មិនដែលរម្ងាប់ទៅដោយការចងពៀរបានម្តងឡើយ រម្ងាប់បានតែដោយការមិនចងពៀរ នេះជាធម្មតាតែងមានពីដើមរៀងមក ។ ពួកជនដទៃមិនដែលដឹងច្បាស់ថា យើងដល់នូវសេចក្តីវិនាសក្នុងកណ្តាលជំនុំសង្ឆនេះទេ បណ្តាជនទាំងនោះ បើពួកជនណាមួយដឹងច្បាស់ សេចក្តីឈ្លោះទើបរម្ងាប់អំពីសំណាក់ជនទាំងនោះបាន ។ អម្បាលឆ្នឹងមាតាបិតារបស់ទីឃាវុកុមារគេកាត់ចោល ទាំងជីវិតគេក៏សម្ងាប់ចោល ទាំងគោ សេះ និងធនធានគេក៏នាំយកទៅ ទាំងដែនគេក៏រឹបជាន់ដណ្តើមយកអស់ ម្តេចស្តេចទាំងនោះ គង់នៅមានសេចក្តីព្រមព្រៀងគ្នាបាន ។ ចុះអ្នកទាំងឡាយហេតុអ្វីក៏គ្មានសេចក្តីព្រមព្រៀងគ្នា ។

បើបុគ្គលបានសំឡាញ់ មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន[1] ជាអ្នកប្រាជ្ញមានធម៌ជាគ្រឿងនៅសប្បាយ ត្រាប់ទៅជាមួយគ្នា

---

១ ក្នុងអដ្ឋកថា មេត្តសូត្តថា បុគ្គលមានប្រាជ្ញា ចេះរក្សាសីលឲ្យបរិសុទ្ធនិងពិចារណាបច្ច័យមានចីវរជាដើម និងកំណត់ដឹងនូវសេចក្តីសប្បាយ ៧ យ៉ាង មានសប្បាយដោយអាវាសជាដើម ហៅថា មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ។

អភិកុយ្យ សញ្ញានិ បរិស្សយានិ

ចរេយ្យ តេនត្តមនោ សតីមា ។

នោ ចេ លភេថ និបកំ សហាយំ

សទ្ធិញ្ចរំ សាធុវិហារីធីរំ

ភជាវ រដ្ឋំ រាជិតំ បហាយ

ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

ឯកស្ស ចរិតំ សេយ្យោ

នត្ថិ ពាលេ សហាយតា ។

ឯកោ ចរេ ន ច ផាបានិ កយិរ

អប្ប្ាស្ស្ាុក្ណោ មាតង្គរញ្ញេវ នាគោតិ ។

បុគ្គលនោះ អាចគ្របសង្កត់នូវសេចក្តីអន្តរាយទាំងពួងបាន ហើយជាអ្នកមានសេចក្តីត្រេកអរមានស្មារតី គប្បីត្រាច់ទៅជាមួយនឹងសំឡាញ់នោះចុះ ។ បើបុគ្គលមិនបានសំឡាញ់ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះគួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាស្តេចលះបង់ដែន ដែលខ្លួនឈ្នះហើយត្រាច់ទៅម្នាក់ឯង (ពុំនោះសោត) ប្រៀបដូចជាដំរីដ៏ប្រសើរត្រាច់ទៅម្នាក់ឯងក្នុងព្រៃ ។ ការដែលបុគ្គលត្រាច់ទៅតែម្នាក់ឯង ហៅពេញជាប្រសើរ ព្រោះបុគ្គលពាលគ្មានសហាយតាគុណ[1] ទេ ។ ម្យ៉ាងទៀត បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង មិនគួរធ្វើអំពើលាមកឡើយ ប្រៀបដូចជាដំរីដ៏ប្រសើរ មានសេចក្តីខ្ជាប់ខ្ជួយតិច ត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

---

១ អដ្ឋកថាធម្មបទថា ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន ហៅថា សហាយ-តាគុណ ។

កោសម្ពិក្ខន្ធកេ ភគវតោ ពាលកលោណការកគាមគមនំ

[១៥៤] អថខោ ភគវា សង្ខ្យមជ្ឈ្យ ឋិតកោវ ឥមា គាថាយោ ភាសិត្វា យេន ពាលកលោណការកគាមោ[1] តេនុបសង្កមិ ។ តេន ខោ បន សមយេន អាយស្មា ភគុ ពាលកលោណការកគាមេ វិហរតិ ។ អទ្ទសា ខោ អាយស្មា ភគុ ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ជិស្វាន អាសនំ បញ្ញាបេសិ ចាតោទកំ ចាឧបនីយំ ចាឧកាថលិកំ ឧបនិក្ខិបិ បចុក្ខ្ជ្ជ បត្តចីវរំ បដិក្ខ្ជ្ជ ។ ជិសីជិ ភគវា បញ្ញត្តេ អាសនេ ជិសជ្ជ ចាតេ បក្ខ្ជ្ជាលេសិ ។ អាយស្មាបិ ខោ ភគុ ភគវន្តំ អភិវាទេត្វា ឯកមន្តំ ជិសីជិ ។ ឯកមន្តំ ជិសិន្នំ ខោ អាយស្មន្តំ ភគុំ ភគវា ឯតឧវោច កច្ចិ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិ បិណ្ឌោកេន ន កិលមសីតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា ន ចាហំ ភន្តេ បិណ្ឌោកេន កិលមាមីតិ ។ អថខោ ភគវា អាយស្មន្តំ

---

1 ឱ. ពាលកលោណការគាមោ ។

[១៥៤] *កាលបើព្រះមានព្រះភាគទ្រង់បិតកណ្ដាលជំនុំសង្ឆ ពោលព្រះគាថាអម្បាលនេះហើយ ក៏ទ្រង់យាងទៅឯពាលកលោណការក-គ្រាម ។ សម័យនោះឯង ក៏ចួនជាព្រះភគុដ៏មានអាយុគង់នៅក្នុងពាលក-លោណការកគ្រាមដែរ ។ ឯព្រះភគុដ៏មានអាយុបានឃើញព្រះមានព្រះភាគទ្រង់យាងមកអំពីចម្ងាយ លុះឃើញហើយ ក៏រៀបក្រាលអាសន: រួចតម្កល់ទឹកសម្រាប់លាងព្រះបាទ តាំងសម្រាប់ទ្រព្រះបាទដែលលាងរួចហើយនិងគ្រឿងសម្រាប់ទ្រព្រះបាទ ដែលមិនទាន់លាងស្រេចហើយ ទើបក្រោកឡើងទៅទទួលបាត្រនិងចីវរ ។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសន:ដែលភិក្ខុក្រាលថ្វាយ លុះគង់ហើយទើបលាងព្រះបាទា ។ ចំណែកឯព្រះភគុដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះភគុដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុ អ្នកល្មមអត់ធន់បានទេឬ អ្នកល្មមប្រព្រឹត្តទៅបានស្រួលទេឬ អ្នកមិនលំបាកដោយបិណ្ឌបាតទេឬ ។ ព្រះភគុដ៏មានអាយុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមអត់ធន់បាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត ខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាតទេ ។ លោនោះ ព្រះមានព្រះភាគ*

ភកុំ ជម្ម៏យា ភ្ជាយ សន្ធ្ជសេ្ជ្ជ្ជ

ទ្រង់ពន្យល់ព្រះកគុដ៏មានអាយុឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ យាងទៅឯប្រទេសនៃព្រៃឈ្មោះបាចីនវង្ស ។ សម័យនោះឯង ចួនជាព្រះអនុរុទ្ធដ៏មានអាយុ ១ ព្រះនន្ទិយៈដ៏មានអាយុ ១ ព្រះកិម្ពិលៈដ៏មានអាយុ ១ គង់នៅក្នុងប្រទេសនៃព្រៃឈ្មោះបាចីនវង្សដែរ ។ មានបុរសម្នាក់ជាអ្នករក្សាព្រៃ បានឃើញព្រះមានព្រះភាគទ្រង់យាងមកអំពីចម្ងាយ លុះឃើញហើយក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះសមណៈ ព្រះអង្គកុំយាងចូលទៅក្នុងព្រៃនេះឡើយ ដ្បិតមានពួកកុលបុត្ត ៣ រូប មានសភាពជាអ្នកស្រឡាញ់ខ្លួននៅក្នុងព្រៃនេះ ព្រះអង្គកុំធ្វើសេចក្តីអផ្សុកដល់កុលបុត្តទាំងនោះឡើយ ។ ព្រះអនុរុទ្ធដ៏មានអាយុក៏បានឮពាក្យបុរសជាអ្នករក្សាព្រៃ កំពុងប្រឹក្សាជាមួយនឹងព្រះមានព្រះភាគដែរ លុះឮហើយក៏និយាយទៅនឹងបុរសជាអ្នករក្សាព្រៃយ៉ាងនេះថា ម្នាលអ្នករក្សាព្រៃដ៏មានអាយុ អ្នកឯងកុំឃាត់ព្រះមានព្រះភាគឡើយ ដ្បិតព្រះមានព្រះភាគជាគ្រូរបស់យើង ព្រះអង្គទ្រង់យាងមកដល់ហើយ ។ ខណៈនោះ ព្រះអនុរុទ្ធដ៏មានអាយុចូលទៅរកព្រះនន្ទិយៈដ៏មានអាយុ និងព្រះកិម្ពិលៈដ៏មានអាយុ លុះចូលទៅដល់ហើយក៏និយាយនឹងព្រះនន្ទិយៈដ៏មានអាយុ និងព្រះកិម្ពិលៈ

អកិញ្ចមថាយស្មន្តោ អកិញ្ចមថាយស្មន្តោ សត្ថា ឣ-
ភតវា អនុប្ឋត្តោតិ ។ អថខោ អាយស្មា ច អនុរុទ្ធោ
អាយស្មា ច ឣនិ្ជយោ អាយស្មា ច កិមិ្ពលោ ភគវន្តំ
បច្ចុគ្គន្ត្វា ឯកោ ភគវតោ បត្តចីវរំ បដិគ្គហេសិ ឯកោ
អាសនំ បញ្ញាបេសិ ឯកោ ចាឣោឣកំ ចាឣបីបំ ចាឣ-
ភជលិកំ ឧបនិក្ខិបិ ។ និសីឣិ ភគវា បញ្ញត្តេ
អាសនេ និសជ្ជ ចាឣេ បក្ខាលេសិ ។ តេ បិ ខោ
អាយស្មន្តោ[1] ភគវន្តំ អភិវាឣេត្វា ឯកមន្តំ និសីឣិសុ ។
ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អនុរុទ្ធំ ភគវា ឯត-
ឣវោច កចិ្ចំ ភោ អនុរុទ្ធា ១មនីយំ កចិ្ចំ យាបនីយំ

---

1 ឱ. អាយស្មន្តា ។

ដ៏មានអាយុយ៉ាងនេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំង-ឡាយនិមន្តទៅទទួល ម្នាលលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំង-ឡាយនិមន្តទៅទទួល ដ្បិតព្រះមានព្រះភាគជាគ្រូរបស់យើង ព្រះអង្គ ទ្រង់យាងមកដល់ហើយ ។ វេលានោះ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះនន្ទិយ: ដ៏មានអាយុ និងព្រះកិម្ពិល:ដ៏មានអាយុ ក៏ក្រោកទៅទទួលព្រះមានព្រះ ភាគ មួយអង្គទទួលបាត្រនិងចីវរព្រះមានព្រះភាគ មួយអង្គរៀបចំក្រាល អាសន: មួយអង្គតម្កល់ទឹកសម្រាប់លាងព្រះបាទ តាំងសម្រាប់តម្កល់ព្រះ បាទដែលលាងហើយ និងគ្រឿងសម្រាប់តម្កល់ព្រះបាទដែលមិនទាន់បាន លាង ។ ព្រះមានព្រះភាគទ្រង់គង់លើអាសន:ដែលកិក្ខុនោះក្រាលហើយ លុះគង់ហើយទ្រង់លាងព្រះបាទា ។ ចំណែកលោកដ៏មានអាយុទាំងនោះ ក៏នាំគ្នាក្រាបថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់រួចហើយ អង្គុយនៅក្នុងទី សមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះ អង្គទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលអនុរុទ្ធទាំងឡាយ[១] អ្នកទាំង-ឡាយល្មមអត់ធន់បានឬទេ អ្នកទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួលឬទេ

---

១ ព្រះអង្គទ្រង់ត្រាស់ហៅមិនសំដៅយកព្រះអនុរុទ្ធតែមួយអង្គទេ ទ្រង់ត្រាស់ហៅចំពោះព្រះ នាមព្រះថេរ:ទាំងបីព្រះអង្គ ។

កច្ចិ បិណ្ឌោកោ ន កិលមថាតិ ។ ១មនីយំ ភត-
ក យាបនីយំ ភតក ន ច មយំ ភន្តេ បិណ្ឌោកោ
កិលមាមាតិ ។ កច្ចិ បន ភោ អនុរុទ្ធា សមត្តា សម្ម-
ឧមានា អវិវ ឧមានា ១ីភេ ឧ ១ីភូតា អញ្ញមញ្ញ ២ិយ-
ចក្ខូហិ សម្ម ១ស្ស ន្តា ១ិ ១ារ ១ាតិ ។ ១ត ១ស ១ តេ[1] ២ យ ១ ២ ១ ១ ១

អ្នកទាំងឡាយមិនលំបាកដោយបិណ្ឌបាតឬទេ ។ ព្រះថេរៈទាំង ៣ អង្គក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត យើងខ្ញុំមិនបានលំបាកដោយបិណ្ឌបាតទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៀតថា ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយបានព្រមព្រៀងស្មោះសរមិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ដែរឬ ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា ព្រះករុណា យើងខ្ញុំទាំងនោះព្រមព្រៀងស្មោះសរនឹងគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៀតថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយបានជាព្រមព្រៀងស្មោះ-សរនឹងគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ ដូចម្តេចទៅ ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះថា អាត្មាអញបាននៅជាមួយនឹងពួកបុគ្គល ដែលប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នាបែបនេះ ហៅពេញជាលាភរបស់អាត្មាអញ អាត្មាអញហៅពេញជា

សន្ធឺ វិហារមីតិ តស្ស មយ្ហំ ភន្តេ ឥមេសុ អាយស្មន្តេ-
សុ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច
មេត្តំ វចីកម្មំ មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ
រហោ ច តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ យន្នូនាហំ
សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស
វសេន វត្តេយ្យន្តិ សោ ខោ អហំ ភន្តេ សកំ ចិត្តំ
និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន
វត្តামិ ជាជ ហិ ខោ ជោ ភន្តេ កាយោ ឯកញ្ច បន
មញ្ញេ ចិត្តន្តិ ។ អាយស្មាបិ ខោ ជន្ធិយោ អា-
យស្មាបិ ខោ កិម្ពិលោ ភគវន្តំ ឯតទវោច មយ្ហំបិ ខោ
ភន្តេ ឯវំ ហោតិ លាភា វត មេ សុលទ្ធំ វត មេ
យោហំ ឯវ្ហេបេហិ សព្រហ្មចារីហិ សន្ធឺ វិហារមីតិ តស្ស
មយ្ហំ ភន្តេ ឥមេសុ អាយស្មន្តេសុ មេត្តំ កាយកម្មំ
បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច មេត្តំ វចីកម្មំ មេត្តំ
មនោកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច តស្ស

បានស្រួលពេកហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គតែងតម្កល់ កាយកម្មប្រកបដោយមេត្តា ចំពោះលោកដ៏មានអាយុអម្បាលនេះ ទាំងទី ចំពោះមុខនិងទីកំបាំង ខ្ញុំព្រះអង្គ តែងតម្កល់វចីកម្មនិងមនោកម្មប្រកប ដោយមេត្តា ទាំងទីចំពោះមុខនិងទីកំបាំង សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ អាត្មាអញគួរដាក់ចិត្ត របស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះ វិញ សូមទ្រង់ព្រះមេត្តាប្រោស (លុះគិតដូច្នេះហើយ) ខ្ញុំព្រះអង្គក៏បាន ដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុ ទាំងនេះទៅ សូមទ្រង់ព្រះមេត្តាប្រោស ឯកាយរបស់យើងខ្ញុំផ្សេងគ្នាក៏ ពិតមែន ប៉ុន្តែចិត្តដូចគ្នាតែម្យ៉ាង ។ ឯព្រះនន្ទិយ:ដ៏មានអាយុ និងព្រះ កិម្ពិល:ដ៏មានអាយុក៏បានក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ទៀតថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះយ៉ាងនេះ ថា អាត្មាអញនៅជាមួយនឹងពួកបុគ្គល ដែលប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នា បែបនេះ ហៅពេញជាលាភរបស់អាត្មាអញ អាត្មាអញហៅពេញជាបាន ស្រួលពេកហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គតែងតម្កល់កាយ-កម្មប្រកបដោយមេត្តា ចំពោះលោកដ៏មានអាយុអម្បាលនេះ ទាំងទីចំពោះ មុខនិងទីកំបាំង ខ្ញុំព្រះអង្គតែងតម្កល់វចីកម្មនិងមនោកម្មប្រកបដោយមេត្តា

មយ្ហំ ភន្តេ ឯវំ ហោតិ យន្នូនាហំ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តេយ្យន្តិ សោ ខោ អហំ ភន្តេ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំ-យេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តামি ជានា ហិ ខោ ០ ភន្តេ ការយា ឯកញ្ច បន មញ្ញេ ចិត្តន្តិ ឯវំ ខោ មយំ ភន្តេ សមត្តា សម្ភោគមានា អវិរោធមានា ទីឃរត្តំ ភិក្ខូ អញ្ញមញ្ញ បិយចក្ខូហិ សម្ម្ សន្តា វិហរាមាតិ ។ ១ ០ ០ ០

ទាំងទីចំពោះមុខនិងទីកំបាំង សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ អាត្មាអញគួរដាក់ចិត្តរបស់ខ្ជួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញចុះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនោះបានដាក់ចិត្តរបស់ខ្ជួនចេញហើយប្រព្រឹត្ត តាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញ សូមទ្រង់ព្រះមេត្តាប្រោស ឯកាយរបស់យើងខ្ញុំផ្សេងគ្នាពិតមែន ប៉ុន្តែចិត្តដូចគ្នាតែម្យ៉ាង សូមទ្រង់ព្រះមេត្តាប្រោស ដោយហេតុយ៉ាងនេះហើយ បានជាយើងខ្ញុំព្រមព្រៀងស្មោះសរ មិនវ៉ាទគ្នាដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយមិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅត្រង់ខ្ជះដែរឬ ។ ព្រះអនុរុទ្ធ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំមិនបានប្រហែសធ្វេសទេ ហើយមានព្យាយាមដុតកិលេស និងមានចិត្តបញ្ជូនទៅត្រង់ ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំង-ឡាយដែលឥតមានប្រហែសធ្វេស មានតែព្យាយាមដុតកិលេស មានចិត្ត បញ្ជូនទៅត្រង់ តើយ៉ាងដូចម្តេច ។ ព្រះថេរៈទាំង ៣ អង្គក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស បណ្តាយើងខ្ញុំដែលនៅក្នុងទីនេះ បើលោកណា

តាមតោ បិណ្ឌាយ បដិក្ក្រមតិ សោ អាសនំ បញ្ញាបេតិ ចាដោឧកំ ចាឧបីឋំ ចាឧកថលិកំ ឧបនិក្ខិបតិ អវក្ការចាតឺ ដោវិត្វា ឧបដ្ឋាបេតិ ចានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ យោ បច្ឆា តាមតោ បិណ្ឌាយ បដិក្ក្រមតិ សចេ ហោតិ ភុត្តាវសេសោ សចេ អាកង្ខ្ជតិ ភុញ្ជតិ ដោ ចេ អាកង្ខ្ជតិ អបហរិតេ វ ឆឌ្ឌេតិ អប្ប-ណ- កេ វ ឧឧកេ ឋិបិលាបេតិ សោ អាសនំ ឧទ្ធរតិ ចាដោឧកំ ចាឧបីឋំ ចាឧកថលិកំ បដិសាមេតិ អវក្ការចាតឺ ដោវិត្វា បដិសាមេតិ ចានីយំ បរិភោ-ជនីយំ បដិសាមេតិ ភត្តក្ខ្ជំ សម្ម្ជ្ជតិ យោ បស្ស្ជតិ ចានីយឃដំ វ បរិភោជនីយឃដំ វ រ្ជ្ជ្ជ

ត្រឡប់មកពីបិណ្ឌបាតអំពីស្រុកមុនគេ លោកនោះរៀបចំក្រាលអាសន: តម្កល់ទឹកសម្រាប់លាងជើង តម្កល់តាំងសម្រាប់ទ្រជើង ដែលលាងរួច និងតម្កល់គ្រឿងសម្រាប់ទ្រជើងដែលមិនទាន់លាង ហើយលាងកាជន៍ សម្រាប់ផ្ទេរបាយតម្កល់ទុកឲ្យស្រួល រួចតម្កល់ទឹកធាន់និងទឹកប្រើប្រាស់ លោកណាមកពីបិណ្ឌបាតអំពីស្រុកក្រោយគេ បើមានរបស់ដែលសល់ពីធាន់ បើភិក្ខុនោះចង់ធាន់ក៏ធាន់ទៅ បើមិនចង់ធាន់ទេ ចាក់ចោលទៅក្នុងទីគ្មានស្មៅស្រស់ក៏បាន បាចសាចទៅក្នុងទឹកដែលគ្មានសត្វតូចក៏បាន រួចលោកនោះរើអាសន:ចេញ ហើយរៀបចំទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើងដែលលាងរួចហើយ និងគ្រឿងសម្រាប់ទ្រជើងដែលមិនទាន់លាង ហើយលាងកាជន៍សម្រាប់ផ្ទេរបាយ រៀបចំទុកដាក់ រួចរៀបទុកដាក់ទឹកធាន់និងទឹកប្រើប្រាស់ ហើយបោសរោងកត្ត បើលោកណាឃើញក្អមសម្រាប់ដាក់ទឹកធាន់ក្តី ក្អមសម្រាប់ដាក់ទឹកប្រើប្រាស់ក្តី ក្អមសម្រាប់ដាក់ទឹកលាងវច្ច:ក្តី រលីងសោះទទេ លោកនោះក៏តម្កល់ទុកឲ្យមានឡើង បើលោកនោះមិនអាចលើកដោយកម្លាំងដៃបានទេ ក៏យើងខ្ញុំហៅភិក្ខុ (ឯទៀត) មកជាពីរូបជួយលើកឬសែងដោយដៃយកទៅតម្កល់ទុក សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំមិនបាច់បញ្ជូញវាចាព្រោះហេតុប៉ុណ្ណោះឡើយ សូមទ្រង់ព្រះមេត្តាប្រោស

បញ្ចាហិកំ ខោ បន មយំ ភន្តេ សព្ជវត្ថិយា ឆម្ជិយា
ភ្ជាយ សន្ធិសីជាម ឝ ខោ មយំ ភន្តេ អប្ជមត្ត
អាតាបិនោ បហិតត្ត ១ ១ អជ ខោ ភ្ជ
អាយ ស្ជ ន ញ ១ ១ ១

ម្យ៉ាងទៀត តែគ្រប់ ៥ ថ្ងៃហើយ យើងខ្ញុំតែងអង្គុយប្រជុំគ្នាដោយធម្មីកថា អស់រាត្រីទាំងមូល[1] សូមទ្រង់ព្រះមេត្តាប្រោស ដោយហេតុយ៉ាងនេះ ហើយ បានជាយើងខ្ញុំព្រះអង្គ ឥតមានសេចក្តីប្រហែសធ្វេស ខំព្យាយាម ដុតកិលេស មានចិត្តបញ្ជូនទៅត្រង់ ឥតមាននឹកនា (ដល់កាយនិងជីវិត ឡើយ) ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ពន្យល់ព្រះអនុរុទ្ធដ៏មានអាយុ ផង ព្រះនន្ទិយ:ដ៏មានអាយុផង ព្រះកិម្ពិល:ដ៏មានអាយុផង ឲ្យយល់ ប្រយោជន៍ក្នុងបច្ចុប្បន្ននិងបរលោក ឲ្យប្រតិបត្តិតាម ឲ្យខ្ចីឃ្នាតក្នុងការ កុសល ឲ្យរីករាយ ដោយធម្មីកថា រួចទ្រង់ក្រោកចាកអាសន:ហើយ យាងទៅកាន់ចារិកប្រទេសបារិលេយ្យក: កាលទ្រង់យាងទៅកាន់ចារិក ដោយលំដាប់ ក៏បានដល់ទៅប្រទេសបារិលេយ្យក: ។ ឮថា ព្រះមាន ព្រះភាគទ្រង់គង់នៅក្រោមម្ទប់ភទ្ទសាលព្រឹក្ស ក្នុងដងព្រៃឈ្មោះ រក្ខិត: នាប្រទេសបារិលេយ្យក:នោះ ។

[១៥ថ] វេលានោះ កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ងាត់ សមំ្ងនៅក្នុងព្រះកម្មដ្ឋាន ទ្រង់កើតមានព្រះហឫទ័យត្រិះរិះឡើងយ៉ាងនេះ ថា ក្នុងពេលមុន តថាគតនៅច្រឡូកច្រឡំដោយពួកភិក្ខុទាំងនោះ ដែលនៅ ក្នុងក្រុងកោសម្ពីជាអ្នកធ្វើសេចក្តីបង្ក្ហេតុ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តី វិវាទ ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឆ មិនបានសេចក្តីសប្បាយ

---

1 គ្រប់ប្រាំថ្ងៃ តែងប្រជុំគ្នានិយាយធម៌អាចិអស់មួយយប់ ។

កោសម្ពិក្ខន្ធកេ បារិលេយ្យកហត្ថិនាគវត្ថុ

ឯតរហិ ឯកោ អនុតិយោ សុទ្ធំ ជាសុ វិហរាមិ អញ្ញត្រៃ
តេហិ កោសម្ពិកេហិ ភិក្ខូហិ ភណ្ឌនការកេហិ
កលហការកេហិ វិវាទការកេហិ ភស្សការកេហិ
សង្ឆៃ អធិការណការកេហីតិ ។ អញ្ញតរោបិ ខោ
ហត្ថិនាគោ អាកិណ្ណោ វិហរតិ ហត្ថីហិ ហត្ថិនីហិ
ហត្ថិកលភេហិ[1] ហត្ថិច្ឆាបេហិ[2] ឆិន្នក្ការានិ ចេវ តិណានិ
ខាទតិ ឱភគ្គោភគ្គញ្ចស្ស សាខាភង្គំ ខាទន្តិ អាវិលានិ
ច ចានីយានិ បិវតិ ឱគ្គាហញ្ចស្ស[3] ឱតិណ្ណាស្ស ហត្ថិ-
និយោ ការយំ ឧបនិយ៉ំសន្តិយោ តច្ឆន្តិ ។ អថខោ
តស្ស ហត្ថិនាគស្ស ឯតទហោសិ អហំ ខោ អាកិណ្ណោ
វិហរាមិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ ហត្ថិច្ឆា-
បេហិ ឆិន្នក្ការានិ ចេវ តិណានិ ខាទামិ ឱភគ្គោភគ្គញ្ច
មេ សាខាភង្គំ ខាទន្តិ អាវិលានិ ច ចានីយានិ បិវាមិ

---

១ ឱ. ហត្ថិកឡភេហិ ។ ២ ហត្ថិច្ឆាបកេហិ ។ ៣ ឱគាហន្តស្ស ។

ក្នុងពេលនេះ តថាគតតែម្នាក់ឯង គ្មាននរណាជាគម្រប់ពីរ ហើយបាននៅជាសប្បាយ ព្រោះរៀរផុតអំពីពួកភិក្ខុទាំងនោះ ដែលនៅក្នុងក្រុងកោសម្ពីជាអ្នកធ្វើសេចក្តីបង្ក្រហេតុ ធ្វើសេចក្តីឈ្លោះគ្នា ធ្វើសេចក្តីវិវាទគ្នា ធ្វើតិរច្ឆាន-កថា ធ្វើអធិករណ៍ក្នុងសង្ឆ ។ មានដំរីដ៏ប្រសើរ ១ នៅច្រឡូកច្រឡំនឹងពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ និងពួកកូនដំរីតូច ៗ ហើយស៊ីស្មៅដែលពួកដំរី (មានដំរីឈ្មោលជាដើមនោះ) បោចផ្តាច់ចុងចេញ ចំ-ណែកខាងពួកដំរីទាំងនោះក៏ស៊ីមែកឈើបាក់ ៗ ដែលដំរីដ៏ប្រសើរនោះកាច់បំបាក់ខ្ទេចខ្ទីវិញ ឯដំរីដ៏ប្រសើរក៏ផឹកតែទឹកល្អក់ កាលបើដំរីដ៏ប្រសើរដើរចុះឡើងកំពង់ទឹក អស់ពួកមេដំរីក៏ដើរត្រដុសកាយ ។ ឯដំរីដ៏ប្រសើរនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនៅច្រឡូកច្រឡំដោយពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ និងពួកកូនដំរីតូច ៗ ហើយស៊ីស្មៅដែលដំរីទាំងនោះបោចផ្តាច់ចុងចេញ ចំណែកពួកដំរីទាំងនោះ ក៏ស៊ីមែកឈើបាក់ ៗ ដែលអាត្មាអញកាច់បំបាក់ខ្ទេចខ្ទីវិញ អាត្មាអញផឹកទឹកក៏ល្អក់

ឱ្ការាហ្ការ[1] មេ ឱ្ការ ណ្ហាសុ ហត្ថិនិយោ ការាយ ឧបនិ-
ឃ្ការ្ការ ការ្ការ ការ្ការ ការ ការ

កាលបើអាត្មាអញដើរចុះឡើងកំពង់ទឹក អស់ពួកមេដំរីក៏ដើរត្រដុសកាយ បើដូច្នោះ គួរអាត្មាអញថយចេញពីហ្វូងទៅនៅម្នាក់ឯងវិញចុះ ។ គ្រានោះ ដំរីដ៏ប្រសើរនោះ ដើរបែកចេញពីហ្វូង ចូលទៅកាន់សំណាក់ព្រះដ៏មានព្រះ ភាគ ដែលទ្រង់គង់ក្រោមម្ជុ:ភ:ទ្ធសាលព្រឹក្សក្នុងដងព្រៃឈ្មោះរក្ខិត: នាបា-រិលេយ្យក:ប្រទេស លុះចូលទៅដល់ហើយក៏តម្កល់ទឹកធាន់និងទឹកប្រើ-ប្រាស់ដោយប្រមោយចំពោះព្រះដ៏មានព្រះភាគ ហើយធ្វើទីកន្ទែងនោះ មិនឲ្យមានស្មៅស្រស់ផង ។ លំដាប់ពីនោះមក ដំរីដ៏ប្រសើរនោះ ក៏មាន សេចក្ដីត្រិះរិះយ៉ាងនេះថា កាលពីដើមអាត្មាអញនៅច្រឡូកច្រឡំនឹងពួក ដំរីឈ្មោល ពួកមេដំរី ពួកដំរីស្នាវ និងពួកកូនដំរីតូច ។ ហើយអាត្មាអញ បានស៊ីស្មៅ ដែលពួកដំរីទាំងនោះ ជោចផ្ដាច់ចុងចេញ ចំណែកខាងពួកដំរី ទាំងនោះក៏បានស៊ីមែកឈើបាក់ ។ ដែលអាត្មាអញកាច់បំបាក់ខ្ទេចខ្ទីវិញ មិនតែប៉ុណ្ណោះសោត អាត្មាអញបានទាំងផឹកទឹកល្អក់ កាលបើអាត្មាអញ ដើរចុះឡើងកំពង់ទឹក ពួកមេដំរីវាក៏ដើរត្រដុសកាយ ក្នុងពេលនេះ អាត្ម អញតែម្នាក់ឯងឥតមាននរណាជាគម្រប់ពីរ ហើយបាននៅជាសុខស្រួល-បួល ព្រោះបានវៀរចាកពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្នាវ

ហត្ថិច្ឆាបេហីតិ ។ អថខោ ភគវា អត្តនោ ច បរិវេកំ
វិនិត្វា តស្ស ច ហត្ថិនាគស្ស ចេតសា ចេតោបរិ-
តក្កមញ្ញាយ តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឯតំ នាគស្ស នាគេន
ឆ្ឌ្ឌ្ៀសានន្ទស្ស ហត្ថិនោ
សមេតិ ចិត្តំ ចិត្តេន
យនេកោ រមតី រិនេតិ ។

[១៥៦] អថខោ ភគវា ចារិលេយ្យកេ យថាភិរន្តំ
វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្ពេន ចា-
រិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា
សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

[១៥៧] អថខោ កោសម្ពិកានំ[1] ឧបាសកានំ
ឯតទហោសិ ឥមេ ខោ អយ្យា កោសម្ពិកា ភិក្ខូ
ពហុនោ អម្ហាកំ អនត្ថស្ស ការកា ឥមេហិ ឧញ្ញាតេ
ភគវា បក្កន្តោ ហន្ទ មយំ អយ្យេ កោសម្ពិកេ ភិក្ខូ
នេវ អភិវាទេយ្យាម ន បច្ចុដ្ឋេយ្យាម ន អញ្ជលិកម្មំ

១ ឌ. អថខោ កោសម្ពិកា ឧបាសកា ឥមេ ខោតិ ទិស្សតិ ។

និងពួកកូនដំរីតូច ។ ។ លោនោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបសេចក្ដីវិវេករបស់ព្រះអង្គផង ហើយទ្រង់ជ្រាបសេចក្ដីត្រិះរិះនៃចិត្តរបស់ដំរីដ៏ប្រសើរនោះ ដោយព្រះហឫទ័យរបស់ព្រះអង្គផង ហើយក៏ទ្រង់បន្ទឺព្រះឧទាននេះ ក្នុងពេលនោះ ថា

ហត្ថិនាគ (ដំរីប្រសើរ) រមែងត្រេកអរក្នុងព្រៃ តែម្នាក់ឯង ហេតុណា ហេតុនុ៎ះ ចិត្តរបស់ហត្ថិនាគមានភ្ជុកង់ទន្ទាំនេះ ស្ទើគ្នានឹងចិត្តរបស់ព្រះពុទ្ធនាគដែរ[1] ។

[១៥៦] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងបារិលេយ្យ-ក:ប្រទេស គួរដល់ពុទ្ធអធ្យាស្ស័យហើយ ទ្រង់យាងទៅកាន់ចារិកនៃក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ ។ បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តជេត-ពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ ។

[១៥៧] លោនោះ ពួកឧបាសកដែលនៅក្នុងក្រុងកោសម្ពី មានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកលោកជាម្ចាស់ទាំងនេះ ជាភិក្ខុនៅក្នុងក្រុងកោសម្ពីបានធ្វើអំពើឥតប្រយោជន៍ជាច្រើនដល់យើង ព្រះដ៏មានព្រះភាគ សោត ក៏ពួកភិក្ខុទាំងនេះ ប្ដៀតប្ដៀនទាល់តែទ្រង់យាងចេញបាត់ទៅ បើដូច្នោះ យើងមិនគួរសំពះ មិនគួរក្រោកទទួល មិនគួរធ្វើអញ្ជលិកម្ម

1 ពាក្យថា ពុទ្ធនាគ គឺព្រះពុទ្ធជាម្ចាស់ ។

សាមីចិកម្មំ ករយ្យាម ន សក្ករយ្យាម ន ករុករយ្យា-
ម ន មានេយ្យាម ន ឫជេយ្យាម ឧបតតាំបិ បិណ្ឌាកំ[1]
ន ឧជ្ជេយ្យាម ឯវំ ឥមេ អម្ហេហិ អសក្ករិយមានា អ-
ករុករិយមានា អមានិយមានា អឫជិយមានា អសក្ការ-
បកតា បក្ខមិស្សន្តិ វា វិព្ភមិស្សន្តិ វា ភតវត្តំ វា បសា-
ទេស្សន្តីតិ ។ អថខោ ភោសម្ពិកា ឧចាសកា ភោសម្ពិ-
ភេ ភិក្ខូ ឌេវ អភិវាទេសុំ ន បច្ចុដ្ឋេសុំ ន អញ្ជលិកម្មំ
សាមីចិកម្មំ អកំសុ ន សក្ករីសុ ន ករុករីសុ ន មានេសុំ
ន ឫជេសុំ ឧបតតាំបិ បិណ្ឌាកំ ន អទំសុ ។ អថខោ
ភោសម្ពិកា ភិក្ខូ ភោសម្ពិភេហិ ឧចាសភេហិ អ-
សក្ករិយមានា អករុករិយមានា អមានិយមានា អឫ-
ជិយមានា អសក្ការបកតា ឯវមាហំសុ ហន្ទ មយំ
អាវុសោ សាវត្ថឺ គន្ត្វា ភតវតោ សន្តិភេ ឥមំ អធិការណំ
រូបសមេយ្យាមាតិ ។ អថខោ ភោសម្ពិកា ភិក្ខូ សេ-
ជាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន សាវត្ថី
ភេនុបសង្ក្រមឹសុ ។

---

[1] ឱ. បិណ្ឌបាតំ ។

មិនគួរធ្វើសាមីចិកម្ម មិនគួរធ្វើសក្ការ: មិនគួរធ្វើសេចក្ដីគោរព មិនគួរ
រាប់អាន មិនគួរបូជា ពួកលោកម្ចាស់ជាកិក្ខុនៅក្នុងក្រុងកោសម្ពីទេ ទុក
ជាកិក្ខុទាំងនោះចូលមកជិត យើងក៏មិនគួរឲ្យបិណ្ឌបាតឡើយ កិក្ខុទាំង
នេះ តែពួកយើងលែងធ្វើសក្ការ: លែងធ្វើសេចក្ដីគោរព លែងរាប់អាន
លែងបូជា យ៉ាងនេះហើយ ក៏ទៅជាអ្នកគ្មានគ្រឿងសក្ការ:ហើយមុខជា
នឹងរត់ចេញទៅខ្លះ សឹកចេញទៅខ្លះ ញ៉ាំងព្រះមានព្រះភាគឲ្យប្រោស
ប្រាណខ្លះមិនខាន ។ គ្រានោះ ពួកឧបាសកក្រុងកោសម្ពីលែង
សំពះ លែងក្រោកទទួល លែងធ្វើអញ្ជលិកម្ម និងសាមីចិកម្ម លែង
ធ្វើសក្ការ: គោរព រាប់អាន បូជាពួកកិក្ខុក្រុងកោសម្ពី ទុកជាកិក្ខុ
ទាំងនោះ ចូលទៅបិណ្ឌបាត ក៏លែងឲ្យបិណ្ឌបាត ។ វេលានោះ
ពួកកិក្ខុក្រុងកោសម្ពី កាលបើពួកឧបាសកក្រុងកោសម្ពី លែងធ្វើសក្ការ:
គោរព រាប់អាន បូជា ក៏ទៅជាអ្នកគ្មានគ្រឿងសក្ការ: ហើយក៏
និយាយនឹងគ្នាយ៉ាងនេះថា នែអាវុសោ បើដូច្នោះ មានតែយើង ទៅ
ក្រុងសាវត្ថីរម្ងាប់អធិករណ៍នេះ ក្នុងសំណាក់ព្រះមានព្រះភាគចេញ ។
លំដាប់នោះ ពួកកិក្ខុក្រុងកោសម្ពី ក៏រៀបចំទុកដាក់គ្រឿងសេនាសន:រួច
នាំយកបាត្រនិងចីវរចូលទៅក្រុងសាវត្ថី ។

កោសម្ពិក្ខន្ធកេ អដ្ឋារសវត្ថុអធម្មវាទី

[១៩៨] អស្សោសិ ខោ អាយស្មា សារីបុត្តោ តេ ភិក្ខូ កោសម្ពិកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឆ្យ អធិការណការកា សាវត្ថឺ អាគច្ឆន្តីតិ ។ អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច តេ ភិក្ខូ ភន្តេ កោសម្ពិ-ការា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការ-ការកា ភស្សការកា សង្ឆ្យ អធិការណការកា សាវត្ថឺ អាគច្ឆន្តិ ។ តេ ភន្តេ ភិក្ខូ ។ ។ ។

កោសម្ពិក្ខន្ធក: បុគ្គលពោលខុសធម៌ដោយវត្ថុ ១៨ យ៉ាង

[១៥៨] ព្រះសារីបុត្តដ៏មានអាយុ បានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើការបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឆ បានមកដល់ក្រុងសាវត្ថី ។ ទើបព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះសារី-បុត្តដ៏មានអាយុអង្គុយនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថាពួកភិក្ខុក្រុងកោសម្ពីនោះជាអ្នកធ្វើសេចក្ដីបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថានិងធ្វើអធិករណ៍ក្នុងសង្ឆបានមកដល់ក្រុងសាវត្ថី សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះដូចម្តេចខ្លះ ។ ព្រះដ៏មានព្រះភាគទ្រង់តបថា នែសារីបុត្ត បើដូច្នោះ អ្នកចូរតាំងនៅឲ្យសមគួរតាមធម៌ចុះ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ធ្វើដូចម្តេចខ្ញុំព្រះអង្គអាចស្គាល់ថា ជាធម៌ឬមិនមែនជាធម៌បាន ។ ព្រះដ៏មានព្រះភាគទ្រង់តបថា នែសារីបុត្ត អ្នកត្រូវស្គាល់អធម្មវាទីបុគ្គល (បុគ្គលពោលខុសធម៌) ដោយវត្ថុ ១៨ យ៉ាង នែសារីបុត្ត ក្នុងសាសនានេះ មានភិក្ខុសំដែងសភាវ:ដែលមិនមែនធម៌ថាជាធម៌វិញ សំដែងធម៌ថា មិនមែនជាធម៌វិញ សំដែងសភាវ:មិនមែនវិន័យថាជាវិន័យវិញ សំដែងវិន័យថាមិនមែនវិន័យ

ឧីបេតិ អកាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ
តថាគតេនាតិ ឧីបេតិ ភាសិតំ លបិតំ តថាគតេន
អកាសិតំ អលបិតំ តថាគតេនាតិ ឧីបេតិ អនាចិណ្ណា
តថាគតេន អាចិណ្ណា តថាគតេនាតិ ឧីបេតិ អាចិណ្ណា
តថាគតេន អនាចិណ្ណា តថាគតេនាតិ ឧីបេតិ អប្ឋញ្ញត្តំ
តថាគតេន បញ្ញត្តំ តថាគតេនាតិ ឧីបេតិ បញ្ញត្តំ
តថាគតេន អប្ឋញ្ញត្តំ តថាគតេនាតិ ឧីបេតិ អនាបត្តឺ
អាបត្តីតិ ឧីបេតិ អាបត្តឺ អនាបត្តីតិ ឧីបេតិ លហុកំ
អាបត្តឺ ករុកា អាបត្តីតិ ឧីបេតិ ករុកំ អាបត្តឺ លហុកា
អាបត្តីតិ ឧីបេតិ សាវសេសំ អាបត្តឺ អនវសេសា
អាបត្តីតិ ឧីបេតិ អនវសេសំ អាបត្តឺ សាវសេសា
អាបត្តីតិ ឧីបេតិ ឧុដ្ឋុល្លំ អាបត្តឺ អឧុដ្ឋុល្លា អាបត្តីតិ
ឧីបេតិ អឧុដ្ឋុល្លំ អាបត្តឺ ឧុដ្ឋុល្លា អាបត្តីតិ ឧីបេតិ
ឥមេហិ ខោ សារីបុត្ត អដ្ឋារសហិ វត្ថូហិ អឆម្ភាឧី
ជានិតព្ពោ អដ្ឋារសហិ ច ខោ សារីបុត្ត វត្ថូហិ ឆម្ភាឧី
ជានិតព្ពោ ឥធ សារីបុត្ត ភិក្ខុ អឆម្ភំ អឆម្ភោតិ ឧីបេតិ
ឆម្ភំ ឆម្ភោតិ ឧីបេតិ អវិនយំ អវិនយោតិ ឧីបេតិ វិនយំ

វិញ សំដែងពាក្យដែលតថាគត មិនបានពោលមិនបានចរចាថា តថាគត បានពោលបានចរចាវិញ សំដែងពាក្យដែលតថាគតបានពោលបានចរចា ថា តថាគតមិនបានពោល មិនបានចរចាវិញ សំដែងកិច្ចដែលតថាគត មិន បានសន្សំថាតថាគតបានសន្សំវិញ សំដែងកិច្ចដែលតថាគតបានសន្សំថា តថាគតមិនបានសន្សំវិញ សំដែងសិក្ខាបទដែលតថាគត មិនបានបញ្ញត្តថា តថាគតបានបញ្ញត្តវិញ សំដែងសិក្ខាបទដែលតថាគតបានបញ្ញត្តថា តថា-គតមិនបានបញ្ញត្តវិញ សំដែងអនាបត្តិថា ជាអាបត្តិវិញ សំដែងអាបត្តិថា ជាអនាបត្តិវិញ សំដែងអាបត្តិស្រាលថា ជាអាបត្តិធ្ងន់វិញ សំដែងអាបត្តិ ធ្ងន់ថា ជាអាបត្តិស្រាលវិញ សំដែងអាបត្តិដែលជាសាវសេស[1]ថា អាបត្តិ ជាអនវសេស[2]វិញ សំដែងអាបត្តិដែលជាអនវសេសថា អាបត្តិជាសាវ-សេសវិញ សំដែងទុដ្ឋុល្លាបត្តិថា ជាអទុដ្ឋុល្លាបត្តិវិញ សំដែងអទុដ្ឋុល្លាបត្តិ ថា ទុដ្ឋុល្លាបត្តិវិញ នែសារីបុត្ត អ្នកត្រូវស្គាល់អធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាងនេះឯងចុះ នែសារីបុត្ត ចំណែកខាងធម្មវាទីបុគ្គល អ្នកត្រូវ ស្គាល់ដោយវត្ថុ ១៨ យ៉ាងដែរ នែសារីបុត្ត ក្នុងសាសនានេះ មានភិក្ខុ សំដែងសភាវ:មិនមែនធម៌ ថា មិនមែនធម៌ សំដែងធម៌ថាធម៌ សំដែង សភាវ:មិនមែនជាវិន័យ ថា មិនមែនវិន័យ សំដែងវិន័យ ថា វិន័យ

---

១ លើកតែអាបត្តិបារាជិកចេញ អាបត្តិទាំងអស់ហៅថាសាវសេស ។ ២ គឺអាបត្តិបារាជិក ។

រិនយោតិ ឧីបេតិ អកាសិតំ អលបិតំ តថាកតេន អកា-
សិតំ អលបិតំ តថាកតេនាតិ ឧីបេតិ ភាសិតំ លបិតំ
តថាកតេន ភាសិតំ លបិតំ តថាកតេនាតិ ឧីបេតិ អនា-
ចិណ្ណា តថាកតេន អនាចិណ្ណា តថាកតេនាតិ ឧីបេតិ
អាចិណ្ណា តថាកតេន អាចិណ្ណា តថាកតេនាតិ ឧីបេតិ
អប្ប ញ្ញត្តំ តថាកតេន អប្ប ញ្ញត្តំ តថាកតេនាតិ ឧីបេតិ
បញ្ញត្តំ តថាកតេន បញ្ញត្តំ តថាកតេនាតិ ឧីបេតិ អនា-
បត្តឺ អនាបត្តីតិ ឧីបេតិ អាបត្តឺ អាបត្តីតិ ឧីបេតិ លហុកំ
អាបត្តឺ លហុកា អាបត្តីតិ ឧីបេតិ ករុកំ អាបត្តឺ ករុកា
អាបត្តីតិ ឧីបេតិ សាវសេសំ អាបត្តឺ សាវសេសា អា-
បត្តីតិ ឧីបេតិ អនវសេសំ អាបត្តឺ អនវសេសា អាបត្តីតិ
ឧីបេតិ ឧុដ្ឋុលំ អាបត្តឺ ឧុដ្ឋុល្យា អាបត្តីតិ ឧីបេតិ អ-
ឧុដ្ឋុលំ អាបត្តឺ អឧុដ្ឋុល្យា អាបត្តីតិ ឧីបេតិ ឥមេហិ ខោ
សារីបុត្ត អដ្ឋារសហិ រត្ថូហិ ធម្មាឧី ជានិតព្ពោតិ ។

[១៥៩] អស្ស្ជិ ខោ អាយស្មា មហាមោគ្គ ល្យា-
ណោ ។ បេ ។ អស្ស្ជិ ខោ អាយស្មា មហាកស្ស្ជ ចោ
អស្ស្ជិ ខោ អាយស្មា មហាកច្ចាណោ អស្ស្ជិ ខោ

សំដែងពាក្យដែលតថាគតមិនបានពោលមិនបានចរចាថា តថាគតមិនបានពោលមិនបានចរចា សំដែងពាក្យដែលតថាគតបានពោលបានចរចាថា តថាគតបានពោលបានចរចា សំដែងកិច្ចដែលតថាគតមិនបានសន្សំថា តថាគតមិនបានសន្សំ សំដែងកិច្ចដែលតថាគតបានសន្សំថា តថាគតបានសន្សំ សំដែងសិក្ខាបទដែលតថាគតមិនបានបញ្ញត្តថា តថាគតមិនបានបញ្ញត្ត សំដែងសិក្ខាបទដែលតថាគតបានបញ្ញត្តថា តថាគតបានបញ្ញត្ត សំដែងអនាបត្តិថា អនាបត្តិ សំដែងអាបត្តិថា អាបត្តិ សំដែងអាបត្តិស្រាលថា អាបត្តិស្រាល សំដែងអាបត្តិធ្ងន់ថា អាបត្តិធ្ងន់ សំដែងអាបត្តិដែលជាសាវសេស: ថា អាបត្តិជាសាវសេស: សំដែង អាបត្តិដែលជាអនវសេស: ថា អាបត្តិជាអនវសេស: សំដែងទុដ្ឋុល្លាបត្តិថា ទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុលាបត្តិ ថា អទុដ្ឋុល្លាបត្តិដដែល នៃសារីបុត្ត អ្នកត្រូវស្គាល់ធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាងនេះឯង ។

[១៥៩] ព្រះមហាមោគ្គល្លានដ៏មានអាយុបានឮ ។ បេ ។ ព្រះមហាកស្សបដ៏មានអាយុ ព្រះមហាកច្ចាន:ដ៏មានអាយុ ព្រះមហាកោដ្ឋិត

អាយស្មា មហាកោដ្ឋិតោ អស្សោសិ ។ អាយស្មា ម-
ហាកប្ប៊ិនោ អស្សោសិ ។ អាយស្មា មហាចុន្ទោ
អស្សោសិ ។ អាយស្មា អនុរុទ្ធោ អស្សោសិ ។ អា-
យស្មា រេវតោ អស្សោសិ ។ អាយស្មា ឧបាលិ អស្សោ-
សិ ។ អាយស្មា អានន្ទោ អស្សោសិ ។ អាយស្មា
ភាវុលោ តេ ការ ការោសម្ហិការ ភិក្ខូ ភណ្ឌនការការ
ការលហការការ ១ វិវាទការការ ១ ១ ១

ដ៏មានអាយុ ព្រះមហាកប្ប៊ិនដ៏មានអាយុ ព្រះមហាចុន្ទដ៏មានអាយុ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះរេវត:ដ៏មានអាយុ ព្រះឧបាលិដ៏មានអាយុ ព្រះអានន្ទដ៏មានអាយុ ព្រះរាហុលដ៏មានអាយុបានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆាន-កថា ធ្វើអធិករណ៍ក្នុងសង្ឆបានមកដល់ក្រុងសាវត្ថីហើយ ។ គ្រានោះ ព្រះរាហុលដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលដ៏មានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថាពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឆបានមកដល់ក្រុងសាវត្ថី សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុនោះដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា នែរាហុល បើដូច្នោះ ចូរអ្នកតាំងនៅឲ្យសមគួរតាមធម៌ចុះ ។ ព្រះរាហុលដ៏មានអាយុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ធ្វើដូចម្តេច ខ្ញុំព្រះអង្គអាចស្គាល់ថា ធម៌ឬថាមិនមែនជាធម៌បាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែរាហុល អ្នកត្រូវ

វត្ថូហិ អជ្ឌ្ឍាឍី ជានិតព្ពោ ។ បេ ។ ឥមេហិ ខោ ភហុល អដ្ឌារសហិ វត្ថូហិ អជ្ឌ្ឍាឍី ជានិតព្ពោ អដ្ឌារ-សហិ ច ខោ ភហុល វត្ថូហិ ឌ្ឍ្ឍាឍី ជានិតព្ពោ ។ បេ ។ ឥមេហិ ខោ ភហុល អដ្ឌារសហិ វត្ថូហិ ឌ្ឍ្ឍាឍី ជានិតព្ពោតិ ។

[១៦០] អស្សោសិ ខោ មហាបជាបតី គោតមី តេ ភិក្ខូ ភគ្គានការកា ភិក្ខូ ភណ្ឌនការកា ភលហការកា វិវាទការកា ភស្សការកា សង្ឆ្យ អធិការណការកា សាវត្ថឺ អាគច្ឆន្តីតិ ។ អថ ខោ មហាបជាបតី គោតមី យេន ភគ្ឍ តេនុបសង្ក្ឍមិ ឧបសង្ក្ឍមិត្វា ភគ្ឍ្ឍ អភិវា-ទេត្វា ឯ្ឍ្ឍមន្ត អដ្ឌាសិ ។ ឯ្ឍ្ឍមន្ត ឋិតា ខោ មហា-បជាបតី គោតមី ភគ្ឍ្ឍ ឯ្ឍ្ឍ ឧ្ឍ្ឍ ច តេ ភិក្ខូ ភន្ត គោ-សម្ពិការ ភិក្ខូ ភណ្ឌនការការ ភលហការការ វិវាទ-ការការ ភស្សការការ សង្ឆ្យ អធិការណការការ សាវត្ថឺ អាគច្ឆន្តិ ភថាហ ភន្ត តេសុ ភិក្ខូសុ បដិ-បជ្ជ្ឍ្ឍ្ឍ ។ តេ ឍ ហ ភ ភ ឧ ភ ឧ ឍ ឍ ។ ។ ។

ស្គាល់អធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាង ។ បេ ។ នៃរាហុល អ្នកត្រូវ
ស្គាល់អធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាងនេះឯង នៃរាហុល ចំណែកខាង
ធម្មវាទីបុគ្គល អ្នកក៏ត្រូវស្គាល់ដោយវត្ថុ ១៨ យ៉ាងដែរ ។ បេ ។ នៃរាហុល
អ្នកត្រូវស្គាល់ធម្មវាទីបុគ្គលដោយវត្ថុ ១៨ យ៉ាងនេះឯង ។

[១៦០] ព្រះនាងមហាបជាបតីគោតមីបានឮដំណឹងថា ពួកភិក្ខុក្រុង
កោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបង្ករហេតុឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា
ធ្វើអធិករណ៍ ក្នុងសង្ឆបានមកដល់ក្រុងសាវត្ថីហើយ ។ គ្រានោះ
ព្រះនាងមហាបជាបតីគោតមី បានចូលទៅគាល់ព្រះមានព្រះភាគ លុះ
ចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅ
ក្នុងទីដ៏សមគួរ ។ លុះព្រះនាងមហាបជាបតីគោតមី បានឋិតនៅក្នុងទីដ៏
សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រ
ព្រះអង្គដ៏ចម្រើន ឮថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបង្ករហេតុ
ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ ក្នុងសង្ឆបាន
មកដល់ក្រុងសាវត្ថីហើយ បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គនឹង
ប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះដូចម្ដេច ។ ព្រះមានព្រះភាគទ្រង់តបថា
នៃគោតមី បើដូច្នោះ ព្រះនាងចូរស្តាប់ធម៌ក្នុងសំណាក់សង្ឆទាំងពីរពួកចុះ

ឧភយត្ត ធម្មំ សុត្វា យេ តត្ត ភិក្ខូ ធម្មវាទិនោ តេសំ ទិដ្ឋិញ្ច ខន្តិញ្ច រុចិញ្ច អាទាយញ្ច[1] ហោតេហិ យំ ច ភិញ្ជ ភិក្ខុនីសង្ឆេន ភិក្ខុសង្ឆតោ បច្ចាសីសិតព្ពំ សព្ពន្តំ ធម្មវាទិតោ វ បច្ចាសីសិតព្ពន្តិ ។

[១៦១] អស្សោសិ ខោ អនាថបិណ្ឌិកោ គហបតិ តេ គិរ គោសម្ពិកា ភិក្ខូ ភណ្ឌនការកា កលហ-ការកា វិវាទការកា ភស្សការកា សង្ឆេ អធិការណ-ការកា សាវត្តឺ អាគច្ឆន្តីតិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្ក្រមិ ឧបង្ក្រមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អនាថបិណ្ឌិកោ គហបតិ ភគវន្តំ ឯត-ទវោច តេ គិរ ភន្តេ គោសម្ពិកា ភិក្ខូ ភណ្ឌនការ-ការកា កលហការកា វិវាទការកា ភស្សការកា សង្ឆេ អធិការណការកា សាវត្តឺ អាគច្ឆន្តិ ពហាមំ ភន្តេ តេសុ ភិក្ខូសុ បដិបជ្ជាមីតិ ។ តេនហិ ត្វំ គហបតិ ឧភយត្ត ជានំ ទេហិ ឧភយត្ត ជានំ ទត្វា

---

១ អាទាយាតិបិ បាឬ ទិស្សតិ ។

បើនាងស្តាប់ធម៌ក្នុងសំណាក់សង្ឆទាំងពីរពួកហើយ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណាដែលជាធម្មវាទី ចូរព្រះនាងកាន់យកតាមទិដ្ឋិ សេចក្តីគាប់ចិត្ត សេចក្តីពេញចិត្ត និងលទ្ធិរបស់ពួកភិក្ខុនោះ ម្យ៉ាងទៀត របស់ឯណា នីមួយដែលភិក្ខុនីសង្ឆ គប្បីប្រាជ្ញាអំពីសំណាក់ភិក្ខុសង្ឆ របស់ទាំងអស់ នោះភិក្ខុនីត្រូវប្រាជ្ញាអំពីធម្មវាទីបុគ្គលចុះ ។

[១៦១] *អនាថបិណ្ឌិកគហបតិបានឮដំណឹងថា ពួកភិក្ខុក្រុងកោ-សម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ ក្នុងសង្ឆបានមកដល់ក្រុងសាវត្ថី ។ លោនោះ អនាថ-បិណ្ឌិកគហបតិ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ហើយទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតិអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូល ព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថា ពួក ភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ ក្នុងសង្ឆបានមកដល់ក្រុងសាវត្ថីហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះ ដូច ម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់តបថា នែគហបតី បើដូច្នោះ អ្នកត្រូវឲ្យ ទានក្នុងសង្ឆទាំងពីរពួកចុះ លុះអ្នកឲ្យទានក្នុងសង្ឆទាំងពីរពួករួចហើយ*

ឧភយត្ត ឆ្ងំ សុណ ឧភយត្ត ឆ្ងំ សុត្វា យេ
តត្ត ភិក្ខូ ឆម្ភាជិនោ តេសំ ជិដ្ឋិញ្ច ខន្តិញ្ច រុចិញ្ច
អាជាយញ្ច ហោតេហីតិ ។

[១៦២] អស្សោសិ ខោ វិសាខា មិគារមាតា តេ
ភិក្ខូ គោសម្ពិកា ភិក្ខូ ភណ្ឌនការកា កលហការ-
កា វិវាទការកា ភស្សការកា សង្ឆ្យ អធិការណ-
ការកា សាវត្ថឺ អាគច្ឆន្តីតិ ។ អថខោ វិសាខា មិគា-
រមាតា យេន ភគវា តេនុបសង្ក្រមិ ឧបសង្ក្រមិត្វា ភគវន្តំ
អភិវាទេត្វា ឯកមន្តំ ឋិសីទិ ។ ឯកមន្តំ ឋិសិន្នា ខោ
វិសាខា មិគារមាតា ភគវន្តំ ឯតទវោច តេ ភិក្ខូ ភន្តេ
គោសម្ពិកា ភិក្ខូ ភណ្ឌនការកា កលហការកា
វិវាទការកា ភស្សការកា សង្ឆ្យ អធិការណការកា
សាវត្ថឺ អាគច្ឆន្តិ ភាយាមំ ភន្តេ តេសុ ភិក្ខូសុ
បដិបជ្ជាមីតិ ។ តេនហិ ត្វំ វិសាខេ ឧភយត្ត ជានំ
ហេហិ ឧភយត្ត ជានំ ឆត្វា ឧភយត្ត ឆ្ងំ សុណ

អ្នកចូរស្តាប់ធម៌ក្នុងសំណាក់សង្ឆទាំងពីរពួកទៀត លុះអ្នកស្តាប់ធម៌ក្នុងសំ-ណាក់សង្ឆទាំងពីរពួករួចហើយ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណាដែលជាធម្មវាទី ចូរអ្នកកាន់យកតាមទិដ្ឋិ សេចក្តីគាប់ចិត្ត សេចក្តីពេញចិត្តនិងលទ្ធិរបស់ពួកភិក្ខុនោះចុះ ។

[១៦២] *នាងវិសាខាជាមិគារមាតាបានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានក-ថា ធ្វើអធិករណ៍ ក្នុងសង្ឆបានមកដល់ក្រុងសាវត្ថីហើយ ។ លំដាប់នោះ នាងវិសាខាជាមិគារមាតាបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាជាមិគារមាតាអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឮថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឆ បានមកដល់ក្រុងសា-វត្ថីហើយ បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះ ដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់តបថា នែនាងវិសាខា បើដូច្នោះ ចូរនាងឲ្យទានក្នុងសង្ឆទាំងពីរពួកចុះ លុះនាងឲ្យទានដល់សង្ឆទាំងពីរពួករួចហើយ ចូរនាងស្តាប់ធម៌ក្នុងសំណាក់សង្ឆទាំងពីរពួកទៀត*

ឧភយត្ត ធម្មំ សុត្វា យេ តត្ត ភិក្ខូ ធម្មវាទិនោ តេសំ ទិដ្ឋិញ្ច ខន្តិញ្ច រុចិញ្ច អាទាយញ្ច ហេ្វចេហីតិ ។

[១៦៣] អថខោ ពោ្រសម្ពិកា ភិក្ខូ អនុបុព្ពេន យេន សាវត្ថី តទវសរឹសុ[១] ។ អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច តេ ភិរ ភន្តេ ពោ្រសម្ពិកា ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឆ្យ អធិការណការកា សាវត្ថឹ អនុប្បត្តា ពកំ ឧ ខោ ភន្តេ តេសុ ភិក្ខូសុ សេនាសនំ[២] បដិបជ្ជិតព្ពន្តិ ។ តេនហិ តយា[៣] សារីបុត្ត ១ីតំ សេនាសនំ ជានិតព្ពន្តិ ។ សចេ បន ភន្តេ ១ីតំ ន ហោតិ ពកំ បដិបជ្ជិតព្ពន្តិ ។ តេនហិ សារីបុត្ត ១ីតំ ពកត្វាបិ ជានិតព្ពំ ន ត្ហេ្ហ

---

១ ឱ. តទវសរុ ។ ២ សេនាសនេតិបិ ១ាហោ ទិស្សតិ ។ ៣ ឱ. ម. ១ោត្តកេសុ តយាសទ្ធោ ន ទិស្សតិ ។

លុះនាងស្តាប់ធម៌ក្នុងសំណាក់សង្ឆទាំងពីរពួកហើយ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណាដែលជាធម្មវាទី ចូរនាងកាន់យកតាមទិដ្ឋិ សេចក្តីគាប់ចិត្ត សេចក្តីពេញចិត្ត និងលទ្ធិរបស់ពួកភិក្ខុនោះចុះ ។

[១៦៣] គ្រានោះ ពួកភិក្ខុក្រុងកោសម្ពី បានដល់ទៅក្រុងសាវត្ថី ដោយលំដាប់ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឦថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្ក្រហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ ក្នុងសង្ឆបានមកដល់ក្រុងសាវត្ថីហើយ សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះ ដោយសេនាសនៈដូចម្តេច ។ ព្រះមានព្រះភាគទ្រង់តបថា នែសារីបុត្ត បើដូច្នោះ អ្នកចូរឲ្យទីសេនាសនៈដ៏ស្ងាត់ទៅភិក្ខុទាំងនោះចុះ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស បើគ្មានទីសេសនាសនៈស្ងាត់ទេ តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែសារីបុត្ត បើដូច្នោះ អ្នកត្រូវធ្វើទីសេនាសនៈដ៏ស្ងាត់ឲ្យតែខាងបាន ហើយប្រគល់ឲ្យភិក្ខុទាំងនោះទៅ

សារីបុត្ត កោនចិ បរិយាយេន រុឌ្ឍតរស្ស ភិក្ខុនោ សេនាសនំ បដិពាហិតព្ពន្តិ រាជាមិ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្សាតិ ។ អាមិសេ បន ភន្តេ ១ កថំ បដិបជ្ជិតព្ពន្តិ ។ អាមិសំ ១ ១ សារីបុត្ត សព្ពេ សមកំ ភាជេតព្ពន្តិ ។

[១៦៤] អថ ១ ១ ១

នៃសារីបុត្ត តថាគតមិនបានពោលថា ភិក្ខុត្រូវហាមទីសេនាសន:ដល់ភិក្ខុដែលចាស់ជាងដោយបរិយាយនីមួយទេ ភិក្ខុណាហាម ត្រូវអាបត្តិទុក្កដ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ចំណែកខាងគ្រឿងអាមិស:វិញ តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នៃសារីបុត្ត ចំណែកខាងគ្រឿងអាមិស:នោះ អ្នកត្រូវចែកទៅភិក្ខុទាំងអស់ឲ្យស្មើគ្នា ។

[១៦២] គ្រានោះ ឧក្ខិត្តកភិក្ខុនោះ កាលពិចារណាធម៌និងវិន័យហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ អាត្មាអញជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ អាត្មាអញជាភិក្ខុដែលសង្ឆ (គួរ) លើកវត្តហើយ មិនមែនជាភិក្ខុដែលសង្ឆលើកវត្តមិនបានទេ អាត្មាអញជាភិក្ខុដែលសង្ឆលើកវត្តហើយដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ។ លុះនោះ ឧក្ខិត្តកភិក្ខុនោះបានចូលទៅរកពួកឧក្ខិត្តានុវត្តកភិក្ខុ លុះចូលទៅដល់ហើយទើបនិយាយពាក្យនេះនឹងពួកឧក្ខិត្តានុវត្តកភិក្ខុថា នៃអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ខ្ញុំជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ ខ្ញុំជាភិក្ខុដែលសង្ឆ (គួរ) លើកវត្តហើយ មិនមែនជាភិក្ខុដែលសង្ឆលើកវត្តមិនបានទេ ខ្ញុំជាភិក្ខុដែលសង្ឆលើកវត្តហើយដោយកម្មប្រកប

ហានារហេន ឯវ មំ អាយស្មន្តោ ឱសារេថាតិ ។ អថ ខោ
តេ ឧក្ខិត្តានុវត្តកា ភិក្ខូ តំ ឧក្ខិត្តកំ ភិក្ខុំ អានាយ
យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ
អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ
តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អយំ ភន្តេ ឧក្ខិត្តកោ
ភិក្ខុ ឯវមាហ អាបត្តិ ឯសា អាវុសោ នេសា អនាបត្តិ
អាបន្នោម្ហិ នម្ហិ អនាបន្នោ ឧក្ខិត្តោម្ហិ នម្ហិ អនុក្ខិត្តោ
ឧម្មុកោនម្ហិ ការេន ឧក្ខិត្តោ អការេន ហានារហេន ឯវ
មំ អាយស្មន្តោ ឱសារេថាតិ ការេ ន ខោ ភន្តេ បដិបជ្ជិ-
តព្ពន្តិ ។ អាបត្តិ ឯសា ភិក្ខវេ នេសា អនាបត្តិ អាបន្នោ
ឯសោ ភិក្ខុ នេសោ ភិក្ខុ អនាបន្នោ ឧក្ខិត្តោ ឯសោ
ភិក្ខុ នេសោ ភិក្ខុ អនុក្ខិត្តោ ឧម្មុកោន ការេន ឧក្ខិត្តោ

ដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមអស់លោកមកធ្វើឱ្យសារណាកម្មចំពោះខ្ញុំចុះ ។ លំដាប់នោះ ឧក្ខិត្តានុវត្តកភិក្ខុទាំងនោះ បាននាំឧក្ខិត្តកភិក្ខុនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឧក្ខិត្តកភិក្ខុនេះបាននិយាយយ៉ាងនេះថា នែអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ខ្ញុំជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ ខ្ញុំជាភិក្ខុដែលសង្ឆ (គួរ) លើកវត្តហើយ មិនមែនជាភិក្ខុដែលសង្ឆលើកវត្តមិនបានទេ ខ្ញុំជាភិក្ខុដែលសង្ឆលើកវត្តហើយដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមអស់លោកមកធ្វើឱ្យសារណាកម្មចំពោះខ្ញុំចុះ សូមទ្រង់ព្រះមេត្តាប្រោស តើយើងខ្ញុំព្រះអង្គគួរប្រតិបត្តិ ដូចម្តេចទៅ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ភិក្ខុនេះជាអ្នកត្រូវអាបត្តិហើយ ភិក្ខុនេះមិនមែនជាមិនត្រូវអាបត្តិទេ ភិក្ខុនេះជាភិក្ខុដែលសង្ឆ (គួរ) លើកវត្តហើយ ភិក្ខុនេះមិនមែនជាភិក្ខុដែលសង្ឆលើកវត្តមិនបានទេ ភិក្ខុនេះសង្ឆបានលើកវត្តហើយ

អកុប្ផេន ហានារហេន យតោ ច ខោ សោ ភិក្ខវេ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សតិ ច តេនហិ ភិក្ខវេ តំ ភិក្ខុំ ឱសារេថាតិ ។ អថខោ តេ ឧក្ខិត្តានុវត្តិកា ភិក្ខូ តំ ឧក្ខិត្តកំ ភិក្ខុំ ឱសារេត្វា យេន ឧក្ខេបកា ភិក្ខូ តេនុបសង្ក្រមិំសុ ឧបសង្ក្រមិត្វា ឧក្ខេបកេ ភិក្ខូ ឯតទ-វោចុំ យស្មឹ អាវុសោ វត្ថុស្មឹ អហោសិ សង្ឆ្យសេ្ស ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឆ្យភេទោ សង្ឆ្យរាជិ សង្ឆ្ស-ាវត្ថានំ សង្ឆ្យនានាការណំ សោ ឯសោ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្ឆិ ច ឱសារិតោ ច ហន្ទ មយំ អាវុសោ តស្ស វត្ថុស្ស រូបសមាយ សង្ឆ្យសាមគ្គឺ ករោមាតិ ។ អថខោ តេ ឧក្ខេបកា ភិក្ខូ យេន ភគវា តេនុបសង្ក្រ-មិំសុ ឧបសង្ក្រមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹ-សុ ។ ឯកមន្តំ និសិន្នា ខោ តេ ឧក្ខេបកា ភិក្ខូ ភគវន្តំ ឯតទវោចុំ តេ ភន្តេ ឧក្ខិត្តានុវត្តិកា ភិក្ខូ ឯវមាហំសុ

ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ម្នាលភិក្ខុទាំងឡាយ វេលាណាបើភិក្ខុនោះត្រូវអាបត្តិផង សង្ឆលើកវត្តហើយផង ឃើញអាបត្តិផង ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកវាល់គ្នាចូរធ្វើឱ្យសារណាកម្មភិក្ខុនោះវេលានោះចុះ ។ វេលានោះ ឧក្ខិត្តានុវត្តកភិក្ខុទាំងនោះ ក៏បានធ្វើឱ្យសារណាកម្ម ចំពោះឧក្ខិត្តកភិក្ខុនោះរួចហើយ ក៏ចូលទៅរកពួកឧក្ខេបកភិក្ខុវិញ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងពួកឧក្ខេបកភិក្ខុថា នែអាវុសោ សេចក្តីបង្ក្រហេតុ សេចក្តីឈ្លោះ សេចក្តីកាន់យកផ្សេង ។ ការវិវាទ ការបំបែកសង្ឆ សេចក្តីប្រេះឆារបស់សង្ឆ សេចក្តីកំណត់របស់សង្ឆ និងអំពើផ្សេង ។ របស់សង្ឆ ប្រាកដដល់សង្ឆព្រោះរឿងវ៉ាវណា ភិក្ខុនោះឯងត្រូវអាបត្តិផង សង្ឆបានលើកវត្តផង ឃើញអាបត្តិផង សង្ឆបានធ្វើឱ្យសារណាកម្មស្រេចហើយ នែអាវុសោ ណ្ហើយចុះ យើងធ្វើសង្ឆសាមគ្គីដើម្បីនឹងរម្ងាប់រឿងវ៉ាវនោះចេញ ។ វេលានោះ ឧក្ខេបកភិក្ខុទាំងនោះ ក៏បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះពួកឧក្ខេបកភិក្ខុនោះ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ពួកឧក្ខិត្តានុវត្តកភិក្ខុនោះបាននិយាយយ៉ាងនេះថា នែអាវុសោ

យស្មឹ អាវុសោ វត្ថុស្មឹ អហោសិ សង្ខ្យាសង្ខ្យ ភណ្ឌានំ
ភាសហោ វិត្ថហោ វិវាទោ សង្ខ្យាភេទោ សង្ខ្យាជ សង្ខ្យ-
វត្ថានំ សង្ខ្យាជាការណំ សោ ឯសោ ភិក្ខុ អាបន្នោ
ច ឧក្ខិត្តោ ច បស្សិ ច ឧិសារិតោ ច ហន្ទ មយំ អាវុសោ
ឥស្ស វត្ថុស្ស រូបសមាយ សង្ខ្យាសមក្ខឺ ភាវេមាតិ ភាវ
ន្ទ ខោ ភន្តេ បដិបជ្ជិតព្ពន្តិ ។ យតោ ច ខោ សោ ភិក្ខវេ
ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សិ ច ឧិសារិតោ
ច ឥតេនហិ ភិក្ខវេ សង្ឆោ ឥស្ស វត្ថុស្ស រូបសមាយ
សង្ខ្យាសមក្ខឺ ភាវេតុ ។ ឯវញ្ច បន ភិក្ខវេ
ការេតព្ពា ។ សព្ពេហេវ ឯកជ្ឈំ សន្និបតិតព្ពំ ឥលា-
ឥនហិ ច អតិលាឥនហិ ច ន ភេហិចិ ធម្ម
ជានតោ ។ សន្និបតិត្វា ញត្តិ ភិក្ខុជ បដិពលេ
សង្ឆោ ញាបេតព្ពោ សុណាតុ មេ ភន្តេ សង្ឆោ យស្មឹ វត្ថុ-
ស្មឹ អហោសិ សង្ខ្យាសង្ខ្យ ភណ្ឌានំ ភាសហោ វិត្ថហោ វិវាទោ
សង្ខ្យាភេទោ សង្ខ្យាជ សង្ខ្យវត្ថានំ សង្ខ្យាជាការណំ

សេចក្ដីបង្ករហេតុ សេចក្ដីឈ្លោះ សេចក្ដីកាន់យកផ្សេង ៗ ការវិវាទ ការបំបែកសង្ឆ សេចក្ដីប្រេះធាររបស់សង្ឆ សេចក្ដីកំណត់របស់សង្ឆនិង អំពើផ្សេង ៗ របស់សង្ឆប្រាកដដល់សង្ឆព្រោះរឿងវ៉ាវណា ភិក្ខុនោះឯង ដែលត្រូវអាបត្តិផង សង្ឆបានលើកវត្ថុផង បានឃើញអាបត្តិផង សង្ឆ បានធ្វើឱ្យសារណាកម្មស្រេចហើយផង នែអាវុសោ ណ្ហើយចុះ យើងធ្វើ សង្ឆសាមគ្គីដើម្បីរម្ងាប់រឿងវ៉ាវនោះចេញ សូមទ្រង់ព្រះមេត្តាប្រោស តើ ពួកខ្ញុំព្រះអង្គត្រូវប្រតិបត្តិ ដូចម្ដេចទៅ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វេលាណាបើភិក្ខុនោះ ត្រូវអាបត្តិផង សង្ឆបាន លើកវត្ថុផង ឃើញអាបត្តិផង សង្ឆបានធ្វើឱ្យសារណាកម្មផង ម្នាល ភិក្ខុទាំងឡាយ បើដូច្នោះ សង្ឆចូរធ្វើសង្ឆសាមគ្គីដើម្បីរម្ងាប់រឿងវ៉ាវនោះ ចេញ ។ ម្នាលភិក្ខុទាំងឡាយ សង្ឆត្រូវធ្វើបែបយ៉ាងនេះ ។ ភិក្ខុទាំងអស់ ត្រូវប្រជុំគ្នាក្នុងទីតែមួយ ពួកភិក្ខុឯណានីមួយទោះឈឺក្ដី មិនឈឺក្ដី មិន បាច់ឲ្យឆន្ទៈទេ ។ លុះប្រជុំគ្នារួចហើយត្រូវភិក្ខុ ដែលធ្លាសប្រតិពលផ្ដៀង សង្ឆថា បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្ដាប់ពាក្យខ្ញុំ ដ្ឋិត សេចក្ដីបង្ករហេតុ សេចក្ដីឈ្លោះគ្នា សេចក្ដីប្រកាន់ផ្សេង ៗ គ្នា ការវិវាទ គ្នា ការបំបែកសង្ឆ សេចក្ដីប្រេះធាររបស់សង្ឆ សេចក្ដីកំណត់របស់ សង្ឆ និងអំពើផ្សេង ៗ របស់សង្ឆ ប្រាកដមានដល់សង្ឆហើយ

កោសម្ពិក្ខន្ធកេ សង្ឆសាមគ្គីករណំ

សោ ឯសោ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សិ ច ឱសារិតោ ច ។ យទិ សង្ឆស្ស បត្តកល្ល សង្ឆោ តស្ស វត្ថុស្ស រូបសមាយ សង្ឆសាមក្ខឺ ការេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឆោ យស្ស ឯ វត្ថុស្ស ឯ អហោសិ សង្ឆស្ស ភណ្ឌនំ ការលហោ វិវាទោ ១ វិ១ តោ សង្ឆភេទោ សង្ឆរាជি សង្ឆវវត្ថានំ សង្ឆនានា-ការណំ សោ ឯសោ ភិក្ខុ អាបន្នោ ច ឧក្ខិត្តោ ច បស្សិ ច ឱសារិតោ ច ។ សង្ឆោ តស្ស វត្ថុស្ស រូបសមាយ សង្ឆសាមក្ខឺ ការេតិ ។ យស្ស្ចាយស្ស្ចតោ ១ មតិ តស្ស វត្ថុស្ស រូបសមាយ សង្ឆសាមក្ខិយ ការណំ សោ តុណ្ហាស្ស យស្ស ១ ១ ១

ព្រោះរឿងណា ភិក្ខុនោះហើយដែលត្រូវអាបត្តិផង សង្ឆបានលើកវត្ត ផង ឃើញអាបត្តិផង សង្ឆបានធ្វើឱ្យសារណាកម្មស្រេចហើយផង ។ បើកម្មមានកាលសមគួរដល់សង្ឆហើយ សង្ឆត្រូវធ្វើសង្ឆសាមគ្គី ដើម្បី រម្ងាប់រឿងនោះចេញ ។ នេះជាពាក្យផ្ទៀងសង្ឆ ។ បពិត្រព្រះសង្ឆដ៏ច-ម្រើន សូមព្រះសង្ឆស្តាប់ពាក្យខ្ញុំ ដ្បិតសេចក្តីបង្ក្គហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេង ៗ គ្នា ការវិវាទគ្នា ការបំបែកសង្ឆ សេចក្តីប្រេះធ្លា របស់សង្ឆ សេចក្តីកំណត់របស់សង្ឆ និងអំពើផ្សេង ៗ របស់សង្ឆ ប្រាកដដល់សង្ឆហើយ ព្រោះរឿងណា ភិក្ខុនោះហើយដែលត្រូវ អាបត្តិផង សង្ឆបានលើកវត្តផង ឃើញអាបត្តិផង សង្ឆបានធ្វើឱ្យសារ-ណាកម្មផង ។ ឥឡូវសង្ឆបានធ្វើសង្ឆសាមគ្គី ដើម្បីរម្ងាប់រឿងនោះ ហើយ ។ ការធ្វើសង្ឆសាមគ្គីដើម្បីរម្ងាប់រឿងនោះ គាប់ចិត្តដល់លោក ដ៏មានអាយុអង្ក្គណា លោកដ៏មានអាយុអង្ក្គនោះត្រូវស្ងៀម បើមិនគាប់ ចិត្តដល់លោកដ៏មានអាយុអង្ក្គណា លោកដ៏មានអាយុអង្ក្គនោះត្រូវនិយាយ ឡើង ។ ឯសង្ឆសាមគ្គី សង្ឆបានធ្វើហើយ ការបំបែកសង្ឆ សង្ឆ ក៏បានផ្សះផ្សាហើយ សេចក្តីកំណត់របស់សង្ឆ សង្ឆក៏បានផ្សះផ្សាហើយ ទាំងអំពើផ្សេង ៗ របស់សង្ឆ សង្ឆក៏បានផ្សះផ្សាហើយ ដើម្បីរម្ងាប់នូវ រឿងនោះ ។ ការធ្វើសង្ឆសាមគ្គីប្រហែលជាគាប់ចិត្តដល់សង្ឆហើយ

សជ្ជ្ជ្ជ ឥស្ម   តុណ្ហី ។ ឯវមេតំ ជ្ជ្ជ្ជ្ជ្ជ ។ តាវ ។ ។ ។

ព្រោះហេតុនោះ បានជាសង្ឆស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីព្រម-ព្រៀងនេះដោយការស្ងៀមនៅយ៉ាងនេះ ។ សង្ឆត្រូវធ្វើឧបោសថ ត្រូវសំដែងបាតិមោក្ខក្នុងខណៈនោះឯង ។

[១៦៥] គ្រានោះ ព្រះឧបាលិដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីបង្ក្រហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេង ។ គ្នា ការវិវាទគ្នា ការបំបែកសង្ឆ សេចក្តីប្រេះធារបស់សង្ឆ សេចក្តីកំណត់របស់សង្ឆ និងអំពើផ្សេង ។ របស់សង្ឆប្រាកដហើយ ព្រោះរឿងណា សង្ឆមិនទាន់បានជម្រះរឿងនោះ មិនទាន់ដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយស្រាប់តែធ្វើសង្ឆសាមគ្គីតែម្តង សូមទ្រង់ព្រះមេត្តាប្រោស សង្ឆសាមគ្គីនោះប្រកបដោយធម៌ដែរឬ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែឧបាលិ សេចក្តីបង្ក្រហេតុ សេចក្តីឈ្លោះ សេចក្តីប្រកាន់ផ្សេង ។ គ្នា ការវិវាទគ្នា ការបំបែកសង្ឆ សេចក្តីប្រេះធារបស់សង្ឆ សេចក្តីកំណត់របស់សង្ឆ និងអំពើផ្សេង ។ របស់សង្ឆប្រា-កដដល់សង្ឆហើយ ព្រោះរឿងណា សង្ឆមិនទាន់បានជម្រះរឿងនោះ

មូលំ កត្វា សជ្ឈសាមក្តឺ ភវតិ អជ្ឈត្តិកា សា ឧចាលិ
សជ្ឈសាមក្តីតិ ។ យស្មឺ បន ភន្តេ វត្ថុស្មឺ ហោតិ សជ្ឈស្ស
ភណ្ឌានំ ភាលហោ រិត្តហោ រិវាគោ សជ្ឈភេគោ សជ្ឈរាជិ
សជ្ឈវវត្ថានំ សជ្ឈជាជាការណំ សជ្ជោ តំ វត្ថុំ រិនិច្ឆិ-
ជិត្វា មូលា មូលំ កត្វា សជ្ឈសាមក្តឺ ភវតិ ជ្ឈត្តិកា
ជ្ជ ទ្ធោ សា ភន្តេ សជ្ឈសាមក្តីតិ ។ យស្មឺ ឧចាលិ
វត្ថុស្មឺ ហោតិ សជ្ឈស្ស ភណ្ឌានំ ភាលហោ រិត្តហោ រិវាគោ
សជ្ឈភេគោ សជ្ឈរាជិ សជ្ឈវវត្ថានំ សជ្ឈជាជាការណំ
សជ្ជោ តំ វត្ថុំ រិនិច្ឆិជិត្វា មូលា មូលំ កត្វា សជ្ឈសា-
មក្តឺ ភវតិ ជ្ឈត្តិកា សា ឧចាលិ សជ្ឈសាមក្តីតិ ។
ភតិ ជ្ជ ទ្ធោ ភន្តេ សជ្ឈសាមក្ខិយោតិ ។ ទ្ធ ឧចាលិ

មិនទាន់ដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយស្រាប់តែធ្វើសង្ឆ-សាមគ្គីតែម្តង នៃឧបាលិ សង្ឆសាមគ្គីនោះ មិនប្រកបដោយធម៌ទេ ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត ចុះបើសេចក្តីបង្ករហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេង ៗ គ្នា ការវិវាទគ្នា ការបំបែកសង្ឆ សេចក្តីប្រេះធារបស់សង្ឆ សេចក្តីកំណត់របស់សង្ឆ និងអំពើផ្សេង ៗ របស់សង្ឆប្រាកដដល់សង្ឆហើយ ព្រោះរឿងណា សង្ឆបានជម្រះរឿងនោះ បានដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឆសាមគ្គីទៅ សូមទ្រង់ព្រះមេត្តាប្រោស សង្ឆសាមគ្គីនោះ ប្រកបដោយធម៌ដែរឬ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែឧបាលិ សេចក្តីបង្ករហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេង ៗ គ្នា ការវិវាទគ្នា ការបំបែកសង្ឆ សេចក្តីប្រេះធារបស់សង្ឆ សេចក្តីកំណត់របស់សង្ឆ និងអំពើផ្សេង ៗ របស់សង្ឆប្រាកដដល់សង្ឆហើយ ព្រោះរឿងណា សង្ឆក៏បានជម្រះរឿងនោះចេញ បានដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឆសាមគ្គីទៅ នែឧបាលិ សង្ឆសាមគ្គីនោះហៅថា ប្រកបដោយធម៌ ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស សង្ឆសាមគ្គីតើមានប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់ថា

សជ្ជ្ សាមក្ខិយោ អត្ថ ឧចាលិ សជ្ជ្ សាមក្ខ ី អត្ថ្ លាបេ
ព្ យ ញ្ ជ ុ ប េ ត ា អ ត ្ ថ ិ ឧ ច ា ល ិ ស ជ ្ ជ ្ ស ា ម ក ្ ខ ី អ ត ្ ថ ុ ប េ ត ា ច
ព្ យ ញ្ ជ ុ ប េ ត ា ច ។ ក ត ម ា ច ឧ ច ា ល ិ ស ជ ្ ជ ្ ស ា ម ក ្ ខ ី
អ ត ្ ថ ្ ប េ ត ា ព ្ យ ញ ្ ជ ុ ប េ ត ា ។ យ ស ្ ម ឹ ឧ ច ា ល ិ វ ត ្ ត ុ ស ្ ម ឹ ហ ោ ត ិ
ស ជ ្ ជ ្ ស ្ ស ក ណ ្ ដ ំ ក ល ហ ោ វ ិ ក ្ ខ េ ប ោ (?) (?) (?)

នៃឧបាលិ សង្ឆសាមគ្គីមានពីរយ៉ាង នៃឧបាលិ សង្ឆសាមគ្គីប្រាសចាកអត្ត តែប្រកបដោយព្យញ្ជន: ១ នៃឧបាលិ សង្ឆសាមគ្គីប្រកបទាំងអត្ត ទាំងព្យញ្ជន: ១ ។ នៃឧបាលិ ឯសង្ឆសាមគ្គីដែលប្រាសចាកអត្ត តែប្រកបដោយព្យញ្ជន: តើដូចម្តេច ។ នៃឧបាលិ សេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា ដោយប្រកាន់ផ្សេង ។ គ្នា ការវិវាទ ការបំបែកសង្ឆ សេចក្តីប្រេះធារបស់សង្ឆ សេចក្តីកំណត់របស់សង្ឆ និងអំពើផ្សេង ។ របស់សង្ឆ ប្រ-ាកដដល់សង្ឆហើយ ព្រោះរឿងណា សង្ឆមិនទាន់បានជម្រះរឿងនោះ មិនទាន់ដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយស្រាប់តែធ្វើសង្ឆសាមគ្គីទៅ នៃឧបាលិ សង្ឆសាមគ្គីនេះ តថាគតហៅថា ប្រាសចាកអត្ត តែប្រកបដោយព្យញ្ជន: ។ នៃឧបាលិ ចំណែកខាងសង្ឆសាមគ្គីដែលប្រ-ាកបទាំងអត្តទាំងព្យញ្ជន: តើដូចម្តេច ។ នៃឧបាលិ សេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេង ។ គ្នា ការវិវាទគ្នា ការបំបែសង្ឆ សេចក្តីប្រេះធារបស់សង្ឆ សេចក្តីកំណត់របស់សង្ឆ និងអំពើផ្សេង ។ របស់សង្ឆ ប្រាកដដល់សង្ឆហើយ ព្រោះរឿងណា សង្ឆក៏បានជម្រះរឿងនោះបានដឹងដើមហេតុតាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឆសាមគ្គីទៅ នៃឧបាលិសង្ឆសាមគ្គីនេះ តថាគតហៅថា ប្រកបទាំងអត្តទាំងព្យញ្ជន: ។ នៃឧបាលិ សង្ឆសាមគ្គីមានពីរយ៉ាងនេះឯង ។ វេលានោះ ព្រះឧបាលិ

ទ្វេ សជ្ជ្សាមត្ថិយោតិ ។ អថខោ អាយស្មា ឧបាលិ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ការិត្វា យេន ភគវា តេនញ្ជលិម្បណ្ណាមេត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

[១៦៦] សជ្ជ្សុ ភិក្ខូសុ ច មន្តនាសុ ច
អត្ថេសុ ជាតេសុ វិនិច្ឆយេសុ ច
ភគ្គមត្ថ្ការ ជនេ មហាត្ថិកោ
ភិក្ខុ ភគ្គ ហោតិ ឧ បត្ថ្ការ ។
អ្ជានុ ជ្ជ ជ្ជ ១ ១ ១ ១ ១ ១
ជ្ជ ១ ១ ១ ១ ១

ដ៏មានអាយុក្រោកចាកអាសន: ធ្វើឧត្តរាសង្គ: (ចីពរ) ឆៀងស្មាម្ខាង រួចប្រណាម្យអញ្ជលី ចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយព្រះគាថា ថា

[១៦៦] កាលបើកិច្ចក្តី ការប្រឹក្សាវិន័យក្តី សេចក្តីអធិប្បាយវិន័យក្តី សេចក្តីវិនិច្ឆ័យវិន័យក្តី កើតចំពោះសង្ឆហើយ តើជនគឺកិក្ខុមានប្រការដូចម្តេច ទើបហៅថា មានឧបការ:ច្រើនក្នុងសាសនានេះ និងដូចម្តេចដែលគួរលើកតម្កើងក្នុងសាសនានេះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កិក្ខុនោះដែលគេមិនគួរតិះដៀលដោយសីលជាបឋម បានពិចារណាមើលមារយាទខ្លួន បានសង្រ្ចមឥន្ទ្រិយដោយល្អហើយ ពួកសត្រូវក៏មិនបានតិះដៀលដោយធម៌ឡើយ អ្នកដទៃគួរនិយាយ (បន្ទោស) កិក្ខុដោយហេតុណា ហេតុនោះ មិនមានដល់កិក្ខុនោះឡើយ ។ កិក្ខុបែបនោះឯងតាំងនៅក្នុងសីលវិសុទ្ធិក្ងៀវក្ងាអង់អាចនិយាយគ្របសង្កត់គេបាន ទៅក្នុងកណ្តាលប-រិសទ្យក៏គ្មានតក់ស្ទុតគ្មានរន្ធត់ឡើយ កិក្ខុនោះមិនបាននិយាយពាក្យមិនគួរ ដែលញ៉ាំងប្រយោជន៍ឲ្យសាបសូន្យឡើយ

តថេវ បញ្ហ បរិសាសុ បុច្ឆិតោ
ន ចាបិ បជ្ជាយតិ ន មង្ក ហោតិ ។
សោ កាលាតតំ ព្យាការណារហំ វចោ
រញ្ជេតិ វិញ្ញូបរិសំ វិចក្ខណោ
សការហ រុឌ្ឍតរេសុ ភិក្ខុសុ
អាចេរកម្ហិ ច សកេ វិសារទោ
អលំ បមេតុំ បតុណោ ឥកេតរេ
បចូត្តិកានញ្ច ១ វិជ្ជិកោវិទោ
បចូត្តិកា យេន ១ ១ ១ ១ ១ ១
មហាជនោ បញ្ញាបនញ្ច ១ ១ ១
សកញ្ច ១ ១ ១ ១ ១ ១
ទ្ធយ្យាការ ១ ១ ១ ១ ១ ១
ទ្ធតេយ្យ ១ ១ ១ ១ ១ ១
សជ្ជ ១ ១ ១ ១ ១ ១
ការ ១ ១ ១ ១ ១ ១
អ ១ ១ ១ ១ ១ ១

(បើមាន) គេសួរប្រស្នាក្នុងពួកបរិសទ្យយ៉ាងនោះ ក៏ឥតជ្រប់ស្រពោន ឥតអៀនអន់ឡើយ ។ ភិក្ខុនោះមានប្រាជ្ញាញ៉ាំងបរិសទ្យជាអ្នកប្រាជ្ញឲ្យត្រេកអរ នឹងពាក្យដែលមានមកក្នុងកាលគួរ និងគួរជាទីដោះស្រាយប្រស្នាបាន ទាំងមានសេចក្តីគោរពពួកភិក្ខុចាស់ជាង និងក្ងៀវក្ងាក្នុងពាក្យអាចារ្យរបស់ខ្លួន ហើយអាចពិចារណានូវហេតុនោះ ។ និងស្ទាត់ក្នុងពាក្យដែលគួរនិយាយ ធ្វាសក្នុងហេតុដែលភ្ជាត់ខុសរបស់ពួកសត្រូវ ពួកសត្រូវសង្កត់សង្កិនក្តី មហាជនតែងពន្យល់ក្តី ដោយពាក្យណា ភិក្ខុនេះមិនលះបង់នូវពាក្យអាចារ្យរបស់ខ្លួន ដោយពាក្យនោះឡើយ កាលនឹងដោះស្រាយប្រស្នាជាប្រស្នាមិនបានបៀតបៀនឡើយ ហើយអាចក្នុងទូតេយ្យ-កម្មមផង ទទួលរងខាងកិច្ចការ របស់សង្ឆផង ដូចជាជនអ្នកទទួលយកនូវគ្រឿងបូជា ភិក្ខុនោះ កាលពួកភិក្ខុបញ្ជូនទៅ (ដើម្បី) ធ្វើនូវពាក្យជាកិច្ចការរបស់សង្ឆ ក៏មិនបានមើលងាយ ដោយអំពើនោះថា អាត្មាអញធ្វើឡើយ

កោសម្ពិក្ខន្ធកេ ឧបាលិគាថា

អាបជ្ជតិ យាវតកេសុ វត្ថុសុ
អាបត្តិយា ហោតិ យថា ច វុដ្ឋិតិ
ឯតេ រិកជ្ជា ឧភយស្ស សាតតា
អាបត្តិវុដ្ឋានបទស្ស កោវិទោ
និស្សារណំ កច្ចតិ យានិ ចាចរំ
និស្សារិតោ ហោតិ យថា ច វត្ថុជ
ឱសារណំ តំវុសិតស្ស ជន្តុនោ
ឯតំបិ ជានាតិ រិកជ្ជកោវិទោ
សការហេ រុឌ្ឍតរេសុ ភិក្ខុសុ
ឆវេសុ ថេរេសុ ច មជ្ឈិមេសុ ច
មហាជនស្ស្ចតុចរេ ច បណ្ឌិតោ
សោ តាទិសោ ភិក្ខុ ឥធ បត្តហារហោតិ ។

កោសម្ពិក្ខន្ធកំ ទសមំ ។

បើត្រូវអាបត្តិ ក្នុងវត្ថុមានប្រមាណណា ក៏ចេញចាកអាបត្តិ ដោយសមគួរតាម (វត្ថុមានប្រមាណប៉ុណ្ណោះ) ភិក្ខុនោះចេះចាំ ស្ទាត់នូវវិភង្គទាំងពីរនេះ ហើយវាងវៃក្នុងហេតុដែលចេញ ចាកអាបត្តិ ប្រសិនបើភិក្ខុដទៃប្រព្រឹត្តនូវអំពើទាំងឡាយ ណា មានសេចក្ដីបង្ក្គហេតុជាដើម ហើយគួរនឹងធ្វើនិស្សារ-ណាកម្ម (កម្មដែលរលាស់ខ្លួនចេញ) ភិក្ខុនោះបានជួយធ្វើ និស្សារណាកម្មដោយសមគួរតាមរឿង (នៃអំពើនោះ) ឱសារ-ណាកម្ម (កម្មដែលសង្ឆឲ្យចូលពួកវិញ) ណាដែលសង្ឆ ត្រូវធ្វើចំពោះជនគឺភិក្ខុដែលប្រព្រឹត្តតាមវត្តនោះ ភិក្ខុនោះក៏ ធ្វាសក្នុងវិភង្គ អាចស្គាល់ឱសារណាកម្មនុ៎ះឯង ភិក្ខុនោះប្រ-បកដោយសេចក្ដីគោរពក្នុងពួកភិក្ខុដែលចាស់ជាងខ្លួន ម្យ៉ាង ទៀត ប្រកបដោយសេចក្ដីគោរពក្នុងភិក្ខុខ្ចីផង ភិក្ខុចាស់ផង ភិក្ខុជាកណ្ដាលផង ជាបណ្ឌិតប្រព្រឹត្តនូវប្រយោជន៍ដល់ មហាជនក្នុងលោកនេះ ភិក្ខុបែបនោះឯង គួរគេនឹងតម្កល់ តម្កើងក្នុងសាសនានេះ ។

ចប់ កោសម្ពិក្ខន្ធក:ទី ១០ ។

តស្សុទ្ទានំ

[១៦៧] កោសម្ពិយំ ជិនវរោ
រាជាបត្តិនិស្សរេ
ឧក្ខិបេយ្យ យស្មឹ តស្មឹ
តស្ស យាបត្តិ ទេសយេ ។
អន្ធោ សីមាយ តត្ថេវ
ពាលកញ្ចេវ រំសិនា
ចារិលេយ្យា ច សាវត្ថី
សារិបុត្តោ ច សាវត្ថី
សារិបុត្តោ ច កោលិតោ
មហាកស្សបកច្ចានោ
កោដ្ឋិតោ ភប្ប៊ីនេន ច
មហាចុន្ទោ ច អនុរុទ្ធោ
រេវតោ ឧចាលិ្ហយោ
អានន្ទោ ភហុ្ទលោ ចេវ
គោតមីជាថបិណ្ឌ្ហិកោ
វិសាខា មិការមាតា ច

ឧទ្ទានៃកោសម្ពិក្ខន្ធក: នោះ គឺ

[១៦៧] រឿងព្រះជិនស្រីដ៏ប្រសើរ គង់ក្នុងក្រុងកោសម្ពី ១ រឿងវិវាទព្រោះឃើញអាបត្តិ ១ រឿងភិក្ខុលើកវត្តព្រោះមិនឃើញអាបត្តិនោះ ១ រឿងព្រះអង្គទ្រង់ត្រាស់ថា អាបត្តិណាមានដល់ភិក្ខុនោះ ភិក្ខុនោះត្រូវសំដែងអាបត្តិនោះចេញ ១ រឿងឧក្ខិត្តានុវត្តកភិក្ខុធ្វើឧបោសថសង្ឆកម្មខាងក្នុងសីមា ១ រឿងព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ពាលកលោណកា-រកគ្រាម ១ រឿងព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ព្រៃបាចីនវង្ស ១ រឿងព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ប្រ-ទេសឈ្មោះបារិលេយ្យក: ១ រឿងព្រះមានព្រះភាគទ្រង់យាងទៅកាន់ក្រុងសាវត្ថី ១ រឿងព្រះសារីបុត្ត ព្រះកោលិត: (មោគ្គល្លាន) ព្រះមហាកស្សប: ព្រះមហាកច្ចាន: ព្រះកោ-ដ្ឋិត: ព្រះកប្ពិន ព្រះមហាចុន្ទ ព្រះអនុរុទ្ធ ព្រះរេវត: ព្រះឧបាលិ ព្រះអានន្ទ និងព្រះរាហុល ១ រឿងព្រះនាងគោតមី ១ រឿងអនាថបិណ្ឌិកសេដ្ឋី ១ រឿងនាងវិសាខាជាមិគារមាតា ១

កោសម្ពិក្ខន្ធកេ ឧទ្ទានគាថា

សេនាសនំ ១ រិត្តញ្ច
អាមិសំ សមកំបិ ច
ន ១ កោហិ ១ ធម្ម ១ ១ ១ ១
ឧចាលិ ១ ១ ១ ១ ១ ១
អនុ ១ ១ ១ ១ ១ ១
១ ១ ១ ១ ១

កោសម្ពិក្ខន្ធក: ឧទ្ទានគាថា

រឿងព្រះសារីបុត្តក្រាបបង្គំទូលព្រះអង្គថា យើងខ្ញុំត្រូវប្រតិបត្តិកិក្ខុទាំងនោះដោយសេនាសន:ដូចម្តេច ១ រឿងសេនាសន:ស្ងាត់ ១ រឿងចែកគ្រឿងអាមិស:ស្មើគ្នា ១ រឿងកិក្ខុណាមួយមិនត្រូវឲ្យធន្ទ: ១ រឿងព្រះឧបាលិក្រាបបង្គំទូលសួរ ១ រឿងបុគ្គលដែលគេមិនគួរតិះដៀលដោយសីល ១ រឿងសង្ឆ-សាមគ្គីក្នុងសាសនាព្រះជិនស្រី ១ ។

ចប់ មហាវគ្គ ។

សន្ធឹកចង្អុលច្រាប់មាតិកា

លេខទំព័រ

កបិនក្ខន្ធក:

រឿងភិក្ខុ ៣០ រូបនៅក្នុងដែនបាវេយ្យ	១
ពោលអំពីអានិសង្ស (កបិន) មាន ៥ យ៉ាង	៣
ពោលអំពីកបិនដែលភិក្ខុក្រាលមិនឡើង	៥
ពោលអំពីកបិនដែលភិក្ខុក្រាលឡើង	៧
ពោលអំពីកបិនដែលនឹងដោះ (និយាយអំពីមាតិកា) ៨ យ៉ាង	៩
និយាយពីកបិនដោះ អាទាយសត្តកវារ	១១
និយាយពីកបិនដោះ អាទាយឆក្កវារ	១៣
និយាយពីកបិនដោះ សមាទាយឆក្កវារ	១៥
និយាយពីកបិនដោះការដោះកបិនត្រង់ចីវរវិនាសជាកំណត់ជាដើម	១៧
និយាយពីកបិនដោះ ការដោះកបិនត្រង់សេចក្តីសន្និដ្ឋានជាកំណត់ជាដើម	២១
និយាយពីកបិនដោះ ការដោះកបិនត្រង់ចីវរសម្រេចជាកំណត់ជាដើម	២៣
និយាយពីកបិនដោះ ការដោះកបិនត្រង់បានឮដំណឹងជាកំណត់ជាដើម	២៥
និយាយពីកបិនដោះ ការដោះកបិនត្រង់ចីវរវិនាសជាកំណត់ជាដើម	២៧
និយាយពីកបិនដោះ ការដោះកបិនត្រង់ចីវរសម្រេចជាកំណត់ជាដើម	២៩
និយាយពីកបិនដោះ ការដោះកបិនត្រង់សេចក្តីសន្និដ្ឋានជាកំណត់ជាដើម	៣៣
និយាយពីកបិនដោះ ការដោះកបិនត្រង់អស់សេចក្តីសង្ឃឹមជាកំណត់ជាដើម	៣៥
និយាយពីកបិនដោះ ការដោះកបិនត្រង់ចីវរវិនាសជាកំណត់ជាដើម	៣៧
និយាយពីកបិនដោះ ការដោះកបិនត្រង់អស់សេចក្តីសង្ឃឹមជាកំណត់ជាដើម	៣៩
និយាយពីកបិនដោះ ការដោះកបិនត្រង់ចីវរវិនាសជាកំណត់ជាដើម	៤១
និយាយពីកបិនដោះ ការដោះកបិនត្រង់សេចក្តីសន្និដ្ឋានជាកំណត់ជាដើម	៤៥
និយាយពីកបិនដោះ ការដោះកបិនត្រង់ចីវរសម្រេចជាកំណត់ជាដើម	៤៧
និយាយពីកបិនដោះ ការដោះកបិនត្រង់សេចក្តីសន្និដ្ឋានជាកំណត់ជាដើម	៤៩
និយាយពីបលិពោធ និងអបលិពោធ	៥១
ឧទ្ទានគាថា	៥៣

សន្ធឹកចន្ទ្រាលច្រាប់មាតិកា

	លេខទំព័រ
ចីវរក្ខន្ធក:	៦១
រឿងពួកកុដុម្ពិកនៅក្រុងរាជគ្រឹះ	៦៣
រឿងជីវកកោមារភត្យ	៦៥
រឿងជីវកោមារភត្យ និងរឿងភរិយាសេដ្ឋី	៦៩
និយាយពីរឿងព្រះបាទពិម្ពិសារកើតរោគឫសដូងបាត	៧៥
និយាយពីសេដ្ឋីក្រុងរាជគ្រឹះកើតរោគឈឺក្បាល	៧៧
និយាយពីរឿងកូនសេដ្ឋីកើតរោគដុំពោះវៀន	៨៣
និយាយពីរឿងព្រះបាទចណ្ឌាបជ្ជោតកើតរោគស្គមលឿង	៨៥
រឿងព្រះបាទចណ្ឌាបជ្ជោត និយាយពីការថ្វាយសប្បិ	៨៧
រឿងព្រះបាទចណ្ឌាបជ្ជោត និយាយពីការឲ្យផ្លែកន្ធ្ងតព្រៃដល់ខ្ទុំឈ្មោះកាក	៨៩
និយាយពីព្រះដ៏មានព្រះភាគ (ទ្រង់ហ៊ាត) ថ្នាំបញ្ចុះ	៩១
ការទ្រង់អនុញ្ញាតគហបតីចីវរ	៩៧
សំពត់កម្ពលមានតម្លៃកន្លះពាន់របស់ស្តេចកាសី	៩៩
និយាយពី (ការទ្រង់អនុញ្ញាត) ចីវរ ៦ យ៉ាងនិងគហបតីចីវរ	១០១
និយាយពីភិក្ខុចូលទៅកាន់ព្រៃស្មសាន	១០៣
ការសន្មតភិក្ខុឲ្យជាអ្នកទទួលចីវរ	១០៥
ការសន្មតឃ្លាំង	១០៧
ការសន្មតភិក្ខុឲ្យជាអ្នករក្សាឃ្លាំង	១០៩
ការសន្មតភិក្ខុឲ្យជាអ្នកចែកចីវរ	១១១
ការទ្រង់អនុញ្ញាតទឹកជ្រលក់ (៦ យ៉ាង)	១១៣
ការទ្រង់អនុញ្ញាតខ្សែសម្រាប់ចងជាយចីវរជាដើម	១១៥
រឿងព្រះអានន្ទត្ថេរ	១១៧
និយាយពីរាត្រីជាចន្លោះនៃខែមាឃនិងខែផល្គុន	១១៩
សេចក្ដីបញ្ញត្តអតិរេកចីវរ	១២១
រឿងភិក្ខុ ១ រូប (មានស្បង់ធ្លុះ)	១២៣

សន្ទីកចង្អុលច្រាប់មាតិកា

	លេខទំព័រ
រឿងនាងវិសាខាមិគារមាតា	១២៥
រឿងនាងវិសាខាមិគារមាតា និយាយអំពីពរ ៨ ប្រការ	១២៩
និយាយពីភិក្ខុភ្លេចស្មារតីសិងលក់	១៣៧
ការទ្រង់អនុញ្ញាតនិសីទន: (សំពត់ទ្រាប់អង្គុយ)	១៣៩
ការទ្រង់អនុញ្ញាតសំពត់សម្រាប់ជូតមុខ	១៤១
ការទ្រង់អនុញ្ញាតនូវការអធិដ្ឋានត្រៃចីវរជាដើម	១៤៣
ភិក្ខុមិនត្រូវទ្រទ្រង់ចីវរដែលមិនកាត់ទាំងអស់	១៤៥
ហេតុដែលគួរទុកដាក់ត្រៃចីវរ	១៤៧
និយាយពីចីវរជារបស់សង្ឆ	១៤៩
រឿងឧបនន្ទ និយាយអំពីចំណែកចីវរ	១៥៣
រឿងភិក្ខុមានរោគឈឺពោះ	១៥៧
និយាយអំពីភិក្ខុអ្នកបម្រើជំងឺ	១៥៩
និយាយអំពីការឲ្យបាត្រនិងចីវររបស់ភិក្ខុស្លាប់ដល់អ្នកបម្រើជំងឺ	១៦១
និយាយអំពីតិត្ថិយសមាទានមានអាការអាក្រាតជាដើម	១៦៥
រឿងឆព្វគ្គិយភិក្ខុ និយាយអំពីការទ្រទ្រង់ចីវរមានពណ៌ខៀវសុទ្ធជាដើម	១៦៩
និយាយអំពីចីវរដែលមិនទាន់កើតឡើងដល់ភិក្ខុដែលនៅចាំវស្សារួចហើយ	១៧១
រឿងព្រះរេវតត្ថេរ និយាយអំពីការកាន់យកចីវរដោយសេចក្តីស្និទ្ធស្នាល	១៧៥
មាតិកា ៨ យ៉ាងដែលជាហេតុឲ្យកើតចីវរ	១៧៩
ឧទ្ទានគាថា	១៨១
ចម្បាយ្យក្ខន្ធក:	*១៨៨*
រឿងកស្សបគោត្តភិក្ខុ	១៨៩
រឿងអាគន្តុកភិក្ខុ	១៩៥
ឧក្ខេបនីយកម្ម និយាយអំពីកម្មនិងមិនមែនកម្ម	១៩៩
និយាយអំពីកម្ម ៤ យ៉ាង	២០១

សន្ទីកចង្ហ្គុលច្រាប់មាតិកា

	លេខទំព័រ
រឿងឆព្វគ្គិយភិក្ខុ និយាយអំពីធម្មជាតមិនមែនជាកម្ម	២០៣
និយាយអំពីកម្ម ៦ យ៉ាង	២០៥
និយាយអំពីជំនុំសង្ឆមាន ៥ ពួកនិងកម្មសម្រាប់ធ្វើដោយសង្ឆចតុវគ្គ	២១៣
និយាយអំពីជំនុំសង្ឆមាន ៥ ពួកនិងកម្មសម្រាប់ធ្វើដោយសង្ឆទសវគ្គ	២១៥
និយាយអំពីជំនុំសង្ឆមាន ៥ ពួកនិងកម្មសម្រាប់ធ្វើដោយសង្ឆវីសតិវគ្គ	២១៧
ការហាមឃាត់ (កណ្តាលជំនុំសង្ឆ) របស់បុគ្គល ខ្លះឡើង ខ្លះមិនឡើង	២១៩
និស្សារណាកម្ម (ការបណ្តេញចេញ) មានពីរយ៉ាង	២២១
ឱសារណាកម្ម (ការហៅបញ្ចូលពួក) មានពីរយ៉ាង	២២៣
ឧក្ខេបនីយកម្មដែលជាកម្មមិនប្រកបដោយធម៌	២២៥
ឧក្ខេបនីយកម្មដែលជាកម្មប្រកបដោយធម៌	២៣១
ពាក្យសួររបស់ឧបាលិត្ថេរអំពីបញ្ចជនីយកម្មជាដើម	២៣៣
ពាក្យសួររបស់ឧបាលិត្ថេរអំពីកម្មដែលមិនមែនជាធម្មវិនិ័យ	២៣៧
ពាក្យសួររបស់ឧបាលិត្ថេរអំពីកម្មដែលជាធម៌ជាវិនិ័យ	២៤១
កម្មដែលមិនមែនជាធម៌ជាវិនិ័យ	២៤៣
ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម	២៤៥
ពួកភិក្ខុព្រមព្រៀងគ្នា (ធ្វើ) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម	២៤៧
ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មប្រកបដោយធម៌ជាដើម	២៤៩
ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មប្រកបដោយធម៌ប្លមជាដើម	២៥១
ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម	២៥៣
ភិក្ខុទាំងឡាយជាពួក (ធ្វើ) បញ្ចាជីយកម្មមិនប្រកបដោយធម៌ជាដើម	២៥៥
ភិក្ខុទាំងឡាយជាពួក (ធ្វើ) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម	២៥៧
ពួកភិក្ខុព្រមព្រៀងគ្នា (រំងាប់) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម	២៥៩
ភិក្ខុទាំងឡាយជាពួក (រំងាប់) តជ្ជនីយកម្មដោយការប្លមធម៌ជាដើម	២៦១
ភិក្ខុទាំងឡាយជាពួក (រំងាប់) បដិសារណីយកម្មមិនប្រកបដោយធម៌ជាដើម	២៦៣
ភិក្ខុទាំងឡាយជាពួក (រំងាប់) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម	២៦៥

សន្ធឹកចង្អុលច្រាប់មាតិកា

	លេខទំព័រ
ពួកភិក្ខុព្រមព្រៀងគ្នា (ធ្វើ) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម.....	២៦៧
ភិក្ខុទាំងឡាយជាពួក (ធ្វើ) តជ្ជនីយកម្មដោយការលួមធម៌ជាដើម.....	២៦៩
ភិក្ខុទាំងឡាយជាពួក (ធ្វើ) និយស្សកម្មមិនប្រកបដោយធម៌ជាដើម.....	២៧១
ភិក្ខុទាំងឡាយជាពួក (ធ្វើ) បព្វាជនីយកម្មមិនប្រកបដោយធម៌ជាដើម.....	២៧៣
ភិក្ខុទាំងឡាយជាពួក (ធ្វើ) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម.....	២៧៥
ពួកភិក្ខុព្រមព្រៀងគ្នា (ធ្វើ) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម.....	២៧៧
ភិក្ខុទាំងឡាយជាពួក (រំងាប់) តជ្ជនីយកម្មមិនប្រកបដោយធម៌ជាដើម.....	២៧៩
ភិក្ខុទាំងឡាយជាពួក (រំងាប់) តជ្ជនីយកម្មប្រកបដោយធម៌ជាដើម.....	២៨១
ពួកភិក្ខុព្រមព្រៀងគ្នា (រំងាប់) តជ្ជនីយកម្មដោយការលួមធម៌ជាដើម.....	២៨៣
ភិក្ខុទាំងឡាយជាពួក (រំងាប់) និយស្សកម្មមិនប្រកបដោយធម៌ជាដើម.....	២៨៥
ភិក្ខុទាំងឡាយជាពួក (រំងាប់) បដិសារណីយកម្មមិនប្រកបដោយធម៌ជាដើម.....	២៨៧
ភិក្ខុទាំងឡាយជាពួក (រំងាប់) ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ជាដើម.....	២៨៩
ឧទ្ទានគាថា.....	២៩៣

កោសម្ពិក្ខន្ធក:

និទានភិក្ខុ ១ រូបត្រូវអាបត្តិ.....	៣០៤
ការយល់ឃើញអាបត្តិថាជាអាបត្តិមែន.....	៣០៥
ពួកភិក្ខុប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត.....	៣០៩
ការយល់ឃើញអាបត្តិថាជាអនាបត្តិ.....	៣១១
ការធ្វើឧបោសថកម្មជាដើមក្នុងទីព្ធដ៏ខាងក្នុងនៃសីមាជាដើម.....	៣១៥
និយាយអំពីការបង្ករហេតុនិងជម្លោះជាដើម.....	៣១៧
រឿងទីឃាវុកុមារ.....	៣២៩
អំណាត់និងការប្រព្រឹត្តល្អនិងគាថាសំដែងអំពីការរំងាប់នូវពៀរ.....	៣៤៣
គាថាសំដែងអំពីការរំងាប់នូវពៀរ.....	៣៤៥
ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ពាលកលោណការកគ្រាម.....	៣៤៧

សន្ធឹកចង្អុលច្រាប់មាតិកា

	លេខទំព័រ
សាមគ្គីធម្មកថា	៣៤៩
រឿងដំរីដ៏ប្រសើរឈ្មោះបារិលេយ្យក:	៣៥៥
ពួកឧបាសកក្នុងក្រុងកោសម្ពីមិនធ្វើកម្មមានអភិវាទនកម្មជាដើម	៣៥៧
បុគ្គលពោលខុសធម៌ដោយវត្ថុ ១៨ យ៉ាង	៣៥៩
បុគ្គលពោលត្រូវធម៌ដោយវត្ថុ ១៨ យ៉ាង	៣៦១
ពាក្យសួររបស់មហាបជាបតីគោតមី	៣៦៣
ពាក្យសួររបស់វិសាខាមិគារមាតា	៣៦៥
(ការធ្វើ) ឱសារណាកម្មចំពោះឧក្ខិត្តកភិក្ខុ	៣៦៧
ការធ្វើសង្ឆសាមគ្គី	៣៦៩
សង្ឆសាមគ្គី មានពីរយ៉ាង	៣៧៣
ឧបាលិគាថា	៣៧៥
ឧទ្ទានគាថា	៣៧៨